ក

# អារម្ភកថា

សៀវភៅជីវប្រវត្តិព្រះអសីតិមហាសាវ័ក ៨០ រូប ភាគ ៨ នេះ ជាភាគបញ្ចប់មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវសាវ័ក នាសម័យពុទ្ធកាល ដែលលោកបានទទួលតំណែងជាឯតទគ្គៈ ហើយមានឈ្មោះល្បីល្បាញ នាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរីកចម្រើនរុងរឿង ដល់ពុទ្ធបរិស័ទនៅក្នុងសម័យនោះផងដែរ ។

ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែង ឬភាពអស្ចារ្យ នៃព្រះថេរៈទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្តាប់ព្រះធម៌របស់លោក អ្នកខ្លះ បានធ្វើធម្មសាកច្ឆា អ្នកខ្លះ ក៏បានប្រគេនចង្ហាន់បិណ្ឌបាតដល់លោកជាដើម ។ ប៉ុន្តែ ឥឡូវនេះ ព្រះនាមរបស់ព្រះថេរៈខ្លះៗ ពុទ្ធបរិស័ទនាសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយ ឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវព្រះនាម តួនាទី ចរិយា អជ្ឈាស្រ័យ វត្តបដិបត្តិ និងការសម្តែងព្រះធម៌ផ្សេងៗ របស់ព្រះថេរៈទាំងអស់នោះ ដែលមានសម្តែងទុកនៅក្នុងគម្ពីរថេរគាថា និងក្នុង គម្ពីរអបទាន ជាដើម

ព្រោះថា ព្រះពុទ្ធសាសនា ដែលរុងរឿងចម្រើន ក៏អាស្រ័យមានអ្នកចងចាំ បដិបត្តិតាម និងចេះសម្តែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្តាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ព្រះថេរៈទាំងអស់នោះជាសក្ខីភាពបញ្ជាក់ថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារលោកផងដែរ ទើបខ្ញុំព្រះករុណា អាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចងក្រង ទុកជាពន្លឺដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចដាក់ភាសាបាលីផងបានទេ ព្រោះថាមានសេចក្តីពិស្តារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើជាងអត់ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់

គ

នៅមានខុសមិនខាន ជួនដោយចេះមិនដល់ ជួនដោយការភ្លេចភ្លាំង ជាពិសេសនោះ គឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិត ជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាកេរ្តិ៍មត៌កផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់អចលនបទ ឬសន្តិបទ គឺព្រះនិព្វាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើននៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌នូវកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌នូវកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស **២៥៥០ ប្រាក់ខ្មែរបាន ១៨.៩៩៥០០០ រៀល** និង **ប្រាក់ដុល្លារ ៦៨៥ ដុល្លារសហរដ្ឋអាមេរិក ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅ

ឃ

ក្នុង ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៥ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ១០ ព្រះអង្គផងដែរ ដែលមានលោកគ្រូ អគ្គបណ្ឌិត ធម្មាចារ្យ ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ ថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សូខុម និងឧបាសិកា ឌិម លក្ខណា នៅក្នុង ព.ស ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស ២៥៥១ ផ្នែកខាងសម្ដែង ព្រះធម៌ ដូចគ្នានឹង ព.ស ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល និង ប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំ នៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស ជាប្រធានក្នុងការ ដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំ បាន ១៩ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សូខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ិម ចណ្ណា នៅក្នុង ព.ស ២៥៥១ ។

**ង**

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិស មហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស **យ៉ង់ ស៊ុខ** (ស្លាប់) និងញោមស្រី **ឈឹម ហយ** (ស្លាប់) ម្យ៉ាងទៀត ញាតិកានៅក្នុង សង្សារវដ្ដ ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូន ចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូធម្មាចារ្យ **រស់ ស៊ុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីច** ជាដើម សូមឲ្យបាននូវ ចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសល នៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសល នេះឲ្យបាន ស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូម ឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជា អនាគតកុំបីខានឡើយ សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ១៥ កើត ខែអស្សុជ ព.ស ២៥៥២

eday´ RBHkruNaGatμaPaB **យ៉ង់ ស៊ុផាត**

## ឈ្មោះអ្នកជួយកែសម្រួល និងពិនិត្យអក្ខរាវិរុទ្ធ

សាមណេរ អ៊ឹម សុជាន នៅអាស្រមព្រះគន្ធកុដិ

លោកគ្រូធម្មាចារ្យ គាំ អ៊ីវ នៅបាត់ដំបង

ឧបាសក ជិម ជំនិត នៅបាត់ដំបង

ឧបាសក អ៊ឹម វ៉ៃយ៉ា នៅបាត់ដំបង

ឧបាសក រឹម សុមេធ នៅបាត់ដំបង

ឧបាសក សន ម៉ារឌី នៅបាត់ដំបង

ឆ

# មាតិការឿង


| ល.រ | | ទំព័រ |
| --- | --- | --- |
| ១ | ព្រះនាមអសីតិមហាសាវ័ក ៨០ | ជ |
| ២ | ជីវប្រវត្តិរបស់ព្រះយសោជត្ថេរ | ១ |
| ៣ | ជីវប្រវត្តិរបស់ព្រះសភិយត្ថេរ | ២៣ |
| ៤ | ជីវប្រវត្តិរបស់ព្រះសេលត្ថេរ | ៥៥ |
| ៥ | ជីវប្រវត្តិរបស់ព្រះឧទាយិត្ថេរ | ៨៩ |
| ៦ | ជីវប្រវត្តិរបស់ព្រះឧបវាណត្ថេរ | ១៣៥ |
| ៧ | ជីវប្រវត្តិរបស់ព្រះអង្គុលិមាលត្ថេរ | ១៦៤ |

ជ

# ប្រវត្តិព្រះអសីតិមហាសាវ័ក ៨០ រូប

ព្រះថេរៈទាំង ៨០ រូប មានព្រះអញ្ញាកោណ្ឌញ្ញៈ ព្រះសារីបុត្រ ព្រះមហាមោគ្គល្លានជាដើម សុទ្ធសឹងតែជាមហាសាវ័កដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រដូចបាន បាលីហៅថា **ឯតទគ្គៈ** គឺបានដល់ ភាពជាកំពូលរបស់ភិក្ខុមួយរូបៗ ដូចជាព្រះអញ្ញាកោណ្ឌញ្ញៈ ជាកំពូលផ្នែកខាងជាអ្នកបានបួសមុនគេ និងបានត្រាស់ដឹងព្រះធម៌មុនគេ ព្រះសារីបុត្រ ជាកំពូលផ្នែកខាង ជាអ្នកមានបញ្ញាគ្មានសាវ័កណាផ្ទឹមបាន ព្រះមហាមោគ្គល្លានជាកំពូលផ្នែកខាងឫទ្ធិ គ្មានសាវ័កណាស្មើផ្ទឹមបានដែរ យ៉ាងនេះជាដើម ។

ដូច្នេះ មហាសាវ័ករបស់ព្រះបរមគ្រូនៃយើងមាន ៨០ រូប ដូចមានព្រះនាមរបស់លោកខាងក្រោមនេះ គឺ ៖

១- ព្រះអញ្ញាកោណ្ឌញ្ញៈ ២- ព្រះសារីបុត្រ

៣- ព្រះមោគ្គល្លាន ៤- ព្រះកស្សបៈ

៥- ព្រះអនុរុទ្ធ ៦-ព្រះភទ្ទិយកាឡិគោធាយបុត្រ

ឈ

៧- ព្រះលកុណ្ឌកភទ្ទិយៈ
៨- ព្រះបិណ្ឌោលភារទ្វាជៈ
៩- ព្រះបុណ្ណមន្តានីបុត្រ
១០- ព្រះមហាកច្ចាយនៈ
១១- ព្រះចូឡបន្ថកៈ
១២- ព្រះមហាបន្ថកៈ
១៣- ព្រះសុភូតិ
១៤- ព្រះរេវតខទិរវនិយៈ
១៥- ព្រះកង្ខារេវតៈ
១៦- ព្រះសោណកោឡិវិសៈ
១៧- ព្រះសោណកុដិកណ្ណៈ
១៨- ព្រះសីវលី
១៩- ព្រះវក្កលិ
២០- ព្រះរាហុល
២១- ព្រះរដ្ឋបាល
២២- ព្រះកុណ្ឌធាន
២៣- ព្រះវង្គីសៈ
២៤- ព្រះឧបសេនវង្គន្តបុត្រ
២៥- ព្រះទព្វមល្លបុត្រ
២៦- ព្រះបិលិន្ទវច្ឆៈ
២៧- ព្រះពាហិយទារុចីរិយៈ
២៨- ព្រះកុមារកស្សបៈ
២៩- ព្រះមហាកោដ្ឋិតៈ
៣០- ព្រះអានន្ទ
៣១- ព្រះឧរុវេលកស្សបៈ
៣២- ព្រះកាឡុទាយី
៣៣- ព្រះពាកុលៈ
៣៤- ព្រះសោភិតៈ
៣៥- ព្រះឧបាលិ
៣៦- ព្រះនន្ទកៈ

ញ

| | |
|---|---|
| ៣៧- ព្រះនន្ទសក្យៈ | ៣៨- ព្រះមហាកប្បិន |
| ៣៩- ព្រះសាគតៈ | ៤០- ព្រះរាធៈ |
| ៤១- ព្រះមោឃរាជ | ៤២- ព្រះមហានាម |
| ៤៣- ព្រះអស្សជិ | ៤៤- ព្រះយស |
| ៤៥- ព្រះវិមល | ៤៦- ព្រះសុពាហុ |
| ៤៧- ព្រះបុណ្ណជិ | ៤៨- ព្រះគវម្បតិ |
| ៤៩- ព្រះនទីកស្សបៈ | ៥០- ព្រះគយាកស្សបៈ |
| ៥១- ព្រះភគ្គុ | ៥២- ព្រះកិម្ពិលៈ |
| ៥៣- ព្រះមហាចុន្ទ | ៥៤- ព្រះអជិតៈ |
| ៥៥- ព្រះតិស្សមេត្តេយ្យ | ៥៦- ព្រះបុណ្ណកៈ |
| ៥៧- ព្រះមេត្តគូ | ៥៨- ព្រះធោតកៈ |
| ៥៩- ព្រះឧបសីវៈ | ៦០- ព្រះនន្ទកត្ថេរ |
| ៦១- ព្រះហេមកៈ | ៦២- ព្រះតោទេយ្យ |
| ៦៣- ព្រះកប្បៈ | ៦៤- ព្រះជតុកណ្ណី |
| ៦៥- ព្រះភទ្រាវុធ | ៦៦- ព្រះឧទយត្ថេរ |

ត

៦៧- ព្រះបោសាលៈ ៦៨- ព្រះបិង្គិយៈ

៦៩- ព្រះនាគិតៈ ៧០- ព្រះនាលកៈ

៧១- ព្រះបុណ្ណៈ ៧២- ព្រះមេឃិយៈ

៧៣- ព្រះយសោជៈ ៧៤- ព្រះសភិយៈ

៧៥- ព្រះសេលៈ ៧៦- ព្រះឧទាយី

៧៧- ព្រះឧបវាណៈ ៧៨- ព្រះអង្គុលិមាល

៧៩- ព្រះវប្បៈ ៨០- ព្រះភទ្ទិយៈ ។

## ✍ ជីវប្រវត្តិរបស់ព្រះយសោជត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

*ព្រះយសោជត្ថេរ លោកបានសម្រេចសន្តិធម៌ ជាធម៌ដ៏ប្រសើរបំផុតនៅក្នុងព្រះសាសនានេះ ក៏ជាអ្នកបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ពីព្រះលោកនាយក ដោយសង្គ្រោះលោកចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំរបស់ព្រះពុទ្ធអង្គ ៨០ រូប និងជាអ្នកបរិបូណ៌ទៅដោយគុណធម៌ ជាអ្នកសមគួរដល់ការធ្វើសក្ការគោរពបូជា ថែមទាំងជាអ្នកមានជីវប្រវត្តិគួរឲ្យចាប់អារម្មណ៍ទៀតផង ។*

*ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះយសោជត្ថេរ មានសម្ដែងទុកនៅក្នុង* ***អដ្ឋកថាបរមត្ថទីបនី*** *ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៃ* ***គម្ពីរខុទ្ទកនិកាយ ថេរគាថា*** និងក្នុង ***គម្ពីរខុទ្ទកនិកាយ អបទាន*** *ដូចមានន័យថា ៖-*

*ព្រះយសោជត្ថេរ លោកបានធ្វើបុណ្យកុសលទុកក្នុងសម្នាក់ព្រះពុទ្ធគ្រប់អង្គ ដែលបានត្រាស់រួចមកហើយ ក្នុងអតីតកាលមកម៉្លោះ ប៉ុន្តែកាលដែលលោកកើតស្លាប់ៗ នៅក្នុងភពផ្សេងៗ នោះ លោកក៏តែងតែបំពេញកុសលវត្ត ដើម្បីកសាងសន្សំបុណ្យបារមីឲ្យគ្រប់គ្រាន់*

ក្នុងការបាក់ធ្លុះនូវអរិយសច្ចធម៌ ។ ក្នុងជាតិមួយ លោកបានកើតនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ នៅក្នុងក្រុងពន្ធុមតី ត្រូវនឹងពុទ្ធកាលនៃព្រះវិបស្សីសម្ពុទ្ធ ។ ថ្ងៃមួយ លោកបានឃើញព្រះពុទ្ធ ស្តេចយាងទៅតាមផ្លូវអាកាស ក៏កើតសេចក្តីជ្រះថ្លាឡើងចំពោះព្រះវិបស្សី ទើបបានថ្វាយផ្លែខ្នុរសម្ល ក្នុងខណៈដែលព្រះអង្គស្តេចកំពុងតែយាងចារិកបិណ្ឌបាត ។ ផលដែលបានថ្វាយផ្លែខ្នុរសម្លនោះ ក៏ធ្វើឲ្យលោកបានសោយសម្បត្តិនៅក្នុងមនុស្សលោក និងទេវលោក អស់កាលដ៏យូរអង្វែង ទាំងបានជាបច្ច័យធ្វើឲ្យលោកអស់នូវទុក្ខទៀតផង ។

ចំណែកប្រវត្តិក្នុងអតីតជាតិ របស់ព្រះយសោជត្ថេរ ដូចមានសម្តែងនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **តណ្ហាវគ្គ** ក្នុងរឿងត្រីកបិល ដែលពោលទាក់ទងដល់រឿងអតីតជាតិរបស់លោកថា ៖-

ក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈ មានបុរស ៥០០ នាក់បានរួមគ្នាធ្វើចោរកម្ម មានការប្លន់នូវពួកអ្នកស្រុកជាដើម ដើម្បីយកមាសប្រាក់មកចិញ្ចឹមជីវិត ហើយតមក ថ្ងៃមួយ ពួកគេត្រូវពួកអ្នកស្រុក ក្នុងជនបទដេញចាប់ ក៏នាំគ្នារត់ចូលទៅក្នុងព្រៃ កាលចូលទៅដល់ក្នុងព្រៃហើយ ក៏មើលមិនឃើញមានអ្វី ដែលល្មមនឹងជាទីពឹង

បាន តែចៃជន្យ បានទៅជួបភិក្ខុមួយរូប ដែលមានប្រក្រតីនៅក្នុងព្រៃជាវត្ត ទើបចូលទៅរកព្រះថេរៈ ថ្វាយបង្គំរួចហើយ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជាទីពឹង របស់ពួកខ្ញុំផងចុះ ។ ព្រះថេរៈមានថេរវាចាពន្យល់ថា ទីពឹងយ៉ាងដទៃ ដែលស្មើនឹងទីពឹងក្នុងសីលរមែងមិនមានដល់អ្នកទាំងឡាយ ដូច្នេះអ្នកទាំងឡាយ ចូរសមាទានសីល ៥ ចុះ លំដាប់តពីនោះមក ព្រះថេរៈ ក៏បានសម្តែងព្រះធម៌ទូន្មានដល់ពួកចោរទាំងនោះថា ឥឡូវនេះ ពួកអ្នកទាំងអស់គ្នាជាអ្នកមានសីលហើយ កុំនាំគ្នាប្រព្រឹត្តកន្លងសិក្ខាបទ សូម្បីមានហេតុដល់ជីវិតក៏ដោយ មិនគួរនឹងប្រព្រឹត្តកន្លងសិក្ខាបទទាំងនេះឡើយ ។ ពួកចោរទាំងនោះ បាននាំគ្នាព្រមទទួលឱវាទព្រះថេរៈថា ព្រះករុណាលោកម្ចាស់ ។ គ្រានោះ ពួកអ្នកស្រុកបាននាំគ្នាទៅដល់ទីលំនៅនោះដើររកខាងណេះ ខាងណោះ ក៏បានជួបនឹងពួកចោរទាំងនោះ ហើយក៏បាននាំគ្នាសម្លាប់ពួកចោរទាំងអស់នោះចោល ។ កាលពួកចោរទាំងនោះស្លាប់អស់ហើយ បានទៅកើតក្នុងទេវលោក រីឯមេចោរ បានជាប្រធាននៃទេវបុត្រ បាននាំគ្នាត្រាច់រង្គាត់ក្នុងទេវលោកអស់មួយពុទ្ធន្តរដោយអំណាចបុណ្យកុសល ដែលកើតមកអំពីការសមាទាននូវសីល

លុះមកដល់ពុទ្ធុប្បាទនេះ បានមកកើតនៅក្នុងត្រកូលអ្នកប្រមង់ ៥០០ ត្រកូល នៅជិតខ្លោងទ្វារក្រុងសាវត្ថី ប្រធានទេវបុត្ត ក៏បានមកចាប់បដិសន្ធិនៅក្នុងត្រកូលអ្នកប្រមង់ ដែលជាប្រធានគេ ចំណែកទេវបុត្តអន្លដទៃក្រៅពីនោះ បានមកចាប់បដិសន្ធិនៅក្នុងត្រកូលអ្នកប្រមង់ដែរ ដែលរងៗ បន្ទាប់ចុះមក ។ លុះជនទាំងអស់នោះ បានប្រសូតចេញអំពីគភ៌មាតារួចហើយ ប៉ុន្តែការប្រសូតនោះ បានប្រសូតព្រមគ្នាទាំងអស់ក្នុងថ្ងៃតែមួយ ក្នុងថ្ងៃដែលភរិយាអ្នកប្រមង់ ដែលជាប្រធានគេប្រសូតបុត្រមកនោះ ប្រធានអ្នកប្រមង់បានប្រើឲ្យមនុស្សទៅដើរស្វែងរកមើលថា តើមានត្រកូលណា ដែលមានទារកកើតក្នុងថ្ងៃនេះដែរឬទេ កាលបានដឹងថា មានដែរ ទើបបាននាំយកដំណឹងទាំងនោះ មកប្រាប់អ្នកប្រមង់ ដែលជាប្រធានគេ ឲ្យបានជ្រាប កាលបើបានជ្រាបដូច្នោះហើយ ក៏បានប្រាប់ឲ្យយកទ្រព្យសម្បត្តិទៅចិញ្ចឹមថែរក្សា ក្នុងត្រកូលទារកទាំងនោះ ដោយសង្ឃឹមក្នុងចិត្តថា ទារកទាំងនោះ បានជាមិត្តសម្លាញ់នឹងកូនរបស់យើង ។ រីឯទារកទាំងនោះ គ្រប់គ្នាបានជាមិត្តសម្លាញ់នឹងគ្នាតាំងពីនៅលេងដីមកម្ល៉េះ កាលទារកទាំងនោះ មាន

វ័យចម្រើនឡើងជាលំដាប់មក ។ ចំណែកបុត្ររបស់ប្រធានអ្នកប្រមង់ជាអ្នកមានភាពប្រសើរ ដោយយសជាដើមជាងទារកទាំងអស់នោះ ។

ក្នុងពេលនេះ នឹងសូមតំណាលពីរឿងត្រីឈ្មោះកបិល ដែលធ្វើឲ្យសោជកុលបុត្រ ពិចារណាឃើញហេតុផលប្រវត្តិ ដែលមកកើតជាត្រីកបិល ហើយកើតសេចក្ដីសង្វេគ គឺកើតការតក់ស្លុតចិត្តឡើង ទើបព្រមគ្នានឹងសម្លាញ់ទាំងអស់ នាំគ្នាចេញបួសក្នុងព្រះពុទ្ធសាសនានេះ ដូចមានសេចក្ដីពណ៌នាតទៅនេះថា ៖-

ក្នុងពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ ត្រីកបិលនេះ បានមកកើតជាកុលបុត្រម្នាក់ឈ្មោះថា **កបិល** មាតាឈ្មោះថា **នាងសាធនី** មានបងប្រុសឈ្មោះថា **សោធនៈ** និងប្អូនស្រីឈ្មោះថា **តាបនា** ។ អ្នកនៅក្នុងត្រកូលទាំងអស់នោះ បាននាំគ្នាចេញមកបួសក្នុងព្រះសាសនានោះទាំងអស់គ្នា ដោយនាងសាធនី និងនាងតាបនា ពីរនាក់ម៉ែកូនទៅបួសក្នុងសម្នាក់ភិក្ខុនី ចំណែកសោធនៈ និងកបិល ទៅបួសជាភិក្ខុ ។ រីឯព្រះសោធនត្ថេរ បួសហើយ បានតាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន ហើយមិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត ។ ឯព្រះកបិលត្ថេរ គិតតែខំរៀនក្នុងផ្លូវគន្ថធុរៈ តមកក៏ជាអ្នកមានចំណេះចេះ

ជីងច្រើន រហូតដល់មានបរិវារជាច្រើនទៀតផង ទាំងលាភសក្ការៈ ក៏បានកើតឡើងដល់លោកយ៉ាងច្រើនសន្ធឹកសន្ធាប់ ទើបធ្វើឲ្យលោក មានការស្រវឹងក្នុងចំណោះជីងរបស់ខ្លួន និងត្រូវសេចក្តីល្មោភនៅក្នុង លាភគ្របសង្កត់ ជាអ្នកសម្គាល់ខ្លួនខុសដោយគិតថា ខ្លួននេះឯង ជា អ្នកឆ្លាតជាងគេ វត្ថុដែលអ្នកដទៃពោលថា ជាអកប្បិយៈ គឺវត្ថុដែល មិនគួរ លោកត្រឡប់ជាពោលថា ជាកប្បិយៈទៅវិញ គឺជាវត្ថុគួរ និង ពោលដល់វត្ថុជាកប្បិយៈ ថាជាអកប្បិយៈ ទាំងបានពោលថា វត្ថុ ដែលមិនមានទោស ថាមានទោស សូម្បីពោលជាមួយនឹងភិក្ខុ ដែល ជាអ្នកមានសីលជាស្រឡាញ់ ក៏ដូច្នេះដែរ ។

ចំណែកព្រះសោធនត្ថេរ កាលបើបានជ្រាបដំណឹងនោះហើយ ទើបចូលទៅរកព្រះកបិលត្ថេរ ហើយបានពោលដាស់តឿន ដល់ព្រះ កបិលត្ថេរ ឲ្យឈប់ពោលយ៉ាងនោះទៀត រហូត ២-៣ លើក តែ ព្រះកបិលត្ថេរ មិនស្តាប់ពាក្យពោលដាស់តឿនរបស់ព្រះសោធនត្ថេរ ឡើយ ទោះជាលោកពោលដាស់តឿនជាចុងក្រោយថា អំពើដែល លោកម្ចាស់បានធ្វើនេះ ជាអំពើដែលព្រះមានព្រះភាគ ទ្រង់តិះតៀល ទាំងមិនមែនជាបដិបទានាំសត្វលោកចេញពីវដ្តៈនេះដែរ ដូច្នេះ លោក

ម្ចាស់ នឹងដឹងកម្មអាក្រក់នេះដោយខ្លួនឯងចុះ ។ ចាប់ពីពេលនោះមក ភិក្ខុដែលជាអ្នកមានសីលជាទីស្រឡាញ់ ម្នាក់ៗ បាននាំគ្នាគេចចេញពីព្រះកបិល ។ ព្រះកបិល ជាអ្នកមានការប្រព្រឹត្តអាក្រក់ ហើយតែងតែមានភិក្ខុ ដែលជាអ្នកប្រព្រឹត្តអាក្រក់មកនៅរួមជាមួយ ថ្ងៃមួយលោកបានគិតថា យើងនឹងសូត្របាតិមោក្ខ ទើបកាន់ផ្លិត ឡើងទៅអង្គុយលើធម្មាសនៈ ក្នុងរោងឧបោសថ ហើយសួរភិក្ខុទាំងឡាយថា លោកអ្នកដ៏មានអាយុទាំងឡាយ បាតិមោក្ខរមែងប្រព្រឹត្តទៅ ដើម្បីភិក្ខុទាំងឡាយ ដែលមកប្រជុំគ្នាហើយនៅក្នុងទីនេះឬ ? ភិក្ខុទាំងនោះម្នាក់ៗ ក៏នៅស្ងៀម ដោយគិតក្នុងចិត្តថា មិនមានប្រយោជន៍អ្វី ក្នុងការពោលតបនឹងព្រះកបិលនេះទេ ។

ព្រះកបិល កាលបើមិនបានស្តាប់ឮ ពាក្យតបពីភិក្ខុទាំងអស់នោះ ទើបពោលថា នែលោកអ្នកដ៏មានអាយុទាំងឡាយ ធម៌ និងវិន័យមិនមានប្រយោជន៍ បាតិមោក្ខដែលលោកស្តាប់ ឬមិនបានស្តាប់ក៏ដូចគ្នាដែរ កាលបើព្រះកបិលពោលរួចដូច្នេះហើយ ក៏បានក្រោកចាកអាសនៈចៀសចេញទៅ លោកបានធ្វើឲ្យព្រះបរិយត្តិធម៌ របស់ព្រះកស្សបសម្ពុទ្ធវិនាសទៅ ដោយឧបាយយ៉ាងនេះឯង ។ ក្នុងកាល

ជាខាងក្រោយមកព្រះសោធនត្ថេរ ដែលជាបងប្រុសរបស់លោក ក៏បានរំលត់ខន្ធបរិនិព្វាន ។ ពេលដែលព្រះកបិលអស់ជីវិតទៅ បានទៅកើតក្នុងអវិចីមហានរក ។ ចំពោះនាងសាធនី ដែលជាមាតា និងនាងតាបនា ដែលជាប្អូនស្រីរបស់លោក ដោយទោសដែលអ្នកទាំងពីរនាក់នោះ បានជេរភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលបរិសុទ្ធ ក៏បានធ្លាក់ទៅក្នុងអវិចីមហានរកដូចគ្នាដែរ ។ ព្រះកបិលបានទៅឆេះនៅក្នុងនរកអស់មួយពុទ្ធន្តរ ហើយដល់មកក្នុងពុទ្ធកាលនេះ លោកបានត្រឡប់មកកើតជាត្រីធំមួយ ដែលមានពណ៌សម្បុរដូចមាស តែមានមាត់ស្អុយ ទាំងនេះក៏ដោយវិបាកនៃកម្មដែលសល់អំពីមុន ទើបធ្វើឲ្យលោកកើតជាត្រី នៅក្នុងស្ទឹងអចិរវតី នេះជារឿងអតីតជាតិ ។ កាលតមក នៅក្នុងថ្ងៃមួយ អ្នកប្រមង់ទាំងនោះបានប្រឹក្សាគ្នាថា យើងនឹងទៅរកចាប់ត្រី ទើបនាំគ្នាកាន់យកគ្រឿងឧបករណ៍ជាច្រើន របស់អ្នកនេសាទ មានសំណាញ់ជាដើម ទៅកាន់ស្ទឹងអចិរវតី ក្នុងពេលដែលពួកគេបង់សំណាញ់ទៅ ត្រីឈ្មោះកបិល ក៏បានជាប់នៅក្នុងសំណាញ់អ្នកនេសាទនោះ ។ កាលពួកប្រមង់ទាំងនោះ បានក្រឡេកឃើញត្រីធំ មានសម្បុរដូចមាសដូច្នេះហើយ ក៏បាននិយាយសំឡេង

យ៉ាងទ្រហឹងថា ពួកយើងចូរទៅចុះចាប់ត្រីធំនេះយកទៅថ្វាយព្រះរាជា ពួកយើងប្រាកដជាបានរង្វាន់ ពីព្រះរាជាយ៉ាងច្រើនពិតប្រាកដមិនខាន ក៏នាំគ្នាចាប់ត្រីនោះឡើងមកដាក់លើទូក ហើយនាំគ្នាសែងត្រីនោះទៅកាន់ព្រះរាជដំណាក់ ។ ព្រះរាជា កាលបើបានទតឃើញខ្លួនត្រីនោះហើយ ក៏បានត្រាស់សួរថា នេះជាអ្វី ? ពួកគេបានក្រាបទូលថា ត្រីព្រះករុណាថ្លៃវិសេស ។

កាលព្រះរាជា ទ្រង់ទតឃើញត្រីមានពណ៌សម្បុរដូចជាមាសដូច្នេះហើយ ទ្រង់ត្រិះរិះថា ព្រះបរមសាស្តាទ្រង់ប្រាកដជាជ្រាបក្នុងហេតុ ដែលត្រីនេះមានពណ៌សម្បុរដូចមាសមិនខាន កាលទ្រង់ត្រិះរិះដូច្នេះ ទើបត្រាស់បញ្ជាឲ្យមនុស្សនាំយកត្រីនេះ ទៅកាន់សម្នាក់នៃព្រះលោកនាថ តែក្នុងខណៈដែលត្រីនោះហាមាត់ឡើង មានក្លិនស្អុយសាយទៅពេញវត្តជេតពន ។ ព្រះរាជា ទ្រង់ជ្រាប ទើបក្រាបទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដែលត្រីនេះ មានពណ៌សម្បុរដូចជាមាស និងមានក្លិនស្អុយចេញអំពីមាត់នេះ តើដោយអំពើកម្មយ៉ាងណា ព្រះអង្គ ? គ្រានោះ ព្រះទសពលត្រាស់តបថា បពិត្រមហារាជ ត្រីនេះ ក្នុងអតីតជាតិ ធ្លាប់បានបួសជាភិក្ខុ ឈ្មោះ

កបិល ប៉ុន្តែជាអ្នកចេះដឹងច្រើន ថែមទាំងជាអ្នកមានបរិវារជាច្រើនទៀតផង បួសនៅក្នុងព្រះសាសនានៃព្រះសម្ពុទ្ធកស្សបៈ ត្រូវសេចក្តីល្មោភ ក្នុងលាភសក្ការៈគ្របសង្កត់ចិត្ត ជេរភិក្ខុដែលមិនជាអ្នកស្តាប់តាមពាក្យរបស់ខ្លួន ទាំងធ្វើព្រះសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធឲ្យវិនាសដូច្នេះហើយ គេកាលបើអស់ជីវិតទៅ បានធ្លាក់ទៅសោយទុក្ខក្នុងអវិចីនរកដោយអំពើកម្មនោះ ឥឡូវនេះ ដែលគេបានមកកើតជាត្រី ដោយទាក់ទងអំពីផលកម្មដែលនៅសេសសល់ ព្រោះហេតុដែលលោកបានពោលប្រាប់នូវព្រះពុទ្ធវចនៈ និងបានពោលសរសើរគុណរបស់ព្រះពុទ្ធអស់កាលដ៏យូរ ទើបបានអត្តភាពមានពណ៌សម្បុរដូចជាមាសនេះ ដោយផលកម្មនោះឯង ហេតុដែលត្រីនេះ មានក្លិនស្អុយចេញពីមាត់ ពីព្រោះមកពីមួលបង្កាច់ព្រះពុទ្ធដីកា របស់ព្រះមុនីព្រះនាមកស្សបៈ បពិត្រមហារាជ តថាគតនឹងឲ្យត្រីនេះនិយាយ ព្រះរាជាក្រាបទូលថា ករុណាព្រះអង្គ ។

ព្រះបរមសាស្តា ទើបត្រាស់សួរត្រីនោះថា អ្នកឈ្មោះកបិលមែនឬ ? ត្រីកបិលក្រាបទូលតបថា ព្រះករុណាព្រះអង្គ ខ្ញុំឈ្មោះកបិលមែន ព្រះភគវាត្រាស់សួរទៀតថា អ្នកមកពីទីណាកបិល ?

ត្រីកបិលឆ្លើយថា ខ្ញុំព្រះអង្គមកអំពីអវិចីមហានរក ព្រះអង្គ ។ ព្រះអង្គបានត្រាស់សួរទៀតថា ព្រះសោធនត្ថេរ ដែលជាបងប្រុសរបស់លោកទៅកើតនៅក្នុងទីណា ? ត្រីកបិលឆ្លើយថា បងប្រុសរបស់ខ្ញុំលោកបរិនិព្វានទៅហើយ ព្រះអង្គ ។ ចុះនាងសាធនីមាតារបស់អ្នកតើទៅកើតក្នុងទីណា ? ត្រីកបិលឆ្លើយថា ទៅកើតក្នុងនរកដែរ ព្រះអង្គ ។ ចុះនាងតាបនា ដែលជាប្អូនស្រីរបស់អ្នក ទៅកើតក្នុងទីណាដែរ ? ត្រីកបិលឆ្លើយថា ទៅកើតក្នុងមហានរកដូចគ្នាដែរ ព្រះអង្គ ។ ចុះអ្នកឥឡូវនេះនឹងទៅទីណា ? ត្រីកបិលឆ្លើយថា ខ្ញុំព្រះអង្គ កាលអស់ជីវិតអំពីត្រីនេះទៅ នឹងទៅកាន់អវិចីមហានរកដូចដើមទៀត ព្រះអង្គ ។ ក្នុងពេលនោះ ត្រីកបិលនោះក៏បានកើតការក្តៅក្រហាយចិត្តកើតឡើង ទើបបោកក្បាលឲ្យស្លាប់ក្នុងពេលនោះមួយរំពេចទៅ ហើយក៏បានទៅកើតក្នុងនរកសោយទុក្ខលំបាកតទៅ ។ គ្រានោះ មហាជនបានឃើញហេតុដ៏អស្ចារ្យ ដូច្នេះហើយ ក៏មានសេចក្តីសង្វេគក្នុងចិត្តកើតឡើង ។

គ្រានោះ ព្រះសាស្តា ទ្រង់ប្រមើលមើលចិត្តបរិស័ទដែលមកប្រជុំគ្នាក្នុងពេលនោះ ទើបទ្រង់ត្រាស់សម្តែងកបិលសូត្រ ដូចមាន

សម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ថា ៈ-

អ្នកប្រាជ្ញទាំងឡាយ បានពោលដល់ការប្រព្រឹត្តធម៌ ១ ការប្រព្រឹត្តព្រហ្មចរិយធម៌ ១ ថាជាកែវដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីនឹងទ្រង់សម្តែងធម៌ឲ្យសមរម្យ ដល់ហេតុការណ៍នៅក្នុងខណៈនោះ ទើបទ្រង់ត្រាស់ព្រះគាថាទាំងនោះថា

តណ្ហាដូចជាវល្លិ រមែងចម្រើនលូតលាស់ដល់បុគ្គល ដែលជាអ្នកមានសេចក្តីប្រមាទ គេរមែងទៅកាន់ភពតូច ភពធំ ហាក់បីដូចជាពានរ ដែលប្រាថ្នាផ្លែឈើ លោតកញ្ឆេងតោងចាប់មែកនេះ លែងមែកនោះ ក្នុងព្រៃដូច្នោះ ។ តណ្ហានេះ ជាធម្មជាតលាមក រមែងជាប់ជំពាក់នៅក្នុងអារម្មណ៍ផ្សេងៗ ក្នុងលោកនេះ តែងតែចូលទៅគ្របសង្កត់បុគ្គលអ្នកមានសេចក្តីសោក ដូចជាតិណជាតិ ដែលត្រូវភ្លៀងស្រោចស្រពហើយ ដុះលូតលាស់ចម្រើនឡើងដូច្នោះដែរ ។ តែបុគ្គលណាញាំញី ( គ្របសង្កត់ ) តណ្ហាដែលជាធម្មជាតដ៏លាមកលំបាកដល់បុគ្គលក្នុងលោកនេះ នឹងកន្លងផុតទៅបាន សេចក្តីសោកទាំងឡាយ រមែងធ្លាក់ទៅលើបុគ្គលនោះ ដូចដំណក់ទឹកភ្លៀងធ្លាក់មកលើដូច្នោះ ។ ព្រោះដូច្នោះ តថាគតប្រាប់ដល់អ្នកទាំងឡាយថា ការ

ចម្រើនចូរមានដល់អ្នកទាំងឡាយ គ្រប់ពេលវេលា ដែលពួកអ្នកប្រជុំគ្នាហើយ ។ អ្នកទាំងឡាយចូរជីកឫសគល់នៃតណ្ហា គឺការកន្លល់លោភចង់បានចេញ ហាក់បីដូចអ្នកត្រូវការស្មៅជើរ ចូរជីកស្មៅនោះចោល ដូច្នោះ មារមិនរុកកួនអ្នកទាំងឡាយជារឿយៗ ឡើយ ដូចក្រសែទឹកបន្សាត់នាំយកគុម្ពនៃដើមបបុសដូច្នោះ ។ ( ពាក្យថា មារសំដៅដល់ កិលេសមារ មច្ចុមារ និងទេវបុត្តមារ ) ។

ក្នុងពេលចប់ព្រះធម៌ទេសនា កូនរបស់អ្នកនេសាទទាំង ៥០០ នាក់ មានយសោជៈជាប្រធាន ក៏មានសេចក្តីសង្វេគតក់ស្លុតក្នុងចិត្ត និងព្រមគ្នាមានសេចក្តីជ្រះថ្លា និងមានបំណងដើម្បីឲ្យអស់នូវសេចក្តីទុក្ខ ទើបក្រាបទូលព្រះមានព្រះភាគ សូមបព្វជ្ជាឧបសម្បទា នៅក្នុងសម្នាក់ព្រះបរមសាស្តា ។ កាលអ្នកទាំងនោះ បានទទួលពុទ្ធានុញ្ញាតឲ្យបួសជាភិក្ខុ កាលអ្នកទាំងអស់គ្នានោះបានបួសជាភិក្ខុហើយ ទើបនាំគ្នាគេចទៅនៅក្នុងស្ថានទីស្ងប់ស្ងាត់ ដើម្បីធ្វើសមណធម៌តទៅ ។

ជីវប្រវត្តិរបស់ព្រះយសោជត្ថេរ ព្រមទាំងភិក្ខុដែលជាបរិវាររបស់លោកទាំង ៥០០ រូបនោះ មានតំណាលរឿងទុកនៅក្នុងការធ្វើសមណធម៌ រហូតដល់ប្រសព្វផលសម្រេចបានដ៏ខ្ពង់ខ្ពស់បំផុត និង

ទទួលការលើកតម្កើងពីព្រះលោកនាថ មានជាលក្ខដ្ឋានទៅក្នុង **គម្ពីរខុទ្ទកនិកាយ ឧទាន** ក្នុង **ឧទានននុវគ្គ** នៃ **យសោជសូត្រ** ថា ៈ-

សម័យមួយ ព្រះមានជោគទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ក៏នៅក្នុងសម័យនោះឯង មានភិក្ខុប្រមាណ ៥០០ រូប មានព្រះយសោជត្ថេរជាដើម បាននាំគ្នានិមន្តទៅកាន់ក្រុងសាវត្ថី ដើម្បីចូលទៅគាល់ព្រះ-សម្ពុទ្ធ ។ ខណៈដែលភិក្ខុអាគន្តុកៈទាំង ៥០០ នោះ បានប្រាស្រ័យនឹងភិក្ខុដែលជាម្ចាស់ទីកន្លែង ពេលដែលកំពុងតែចាត់ចែងទីអាសនៈ និងយកបាត្រទៅទុកដាក់នោះ ក៏មានសំឡេងអ៊ូអរខ្លាំង រហូតឮទៅដល់ទីគង់ប្រថាប់នៃព្រះបរមសាស្ដា ។ គ្រានោះ ព្រះភគវា ត្រាស់សួរព្រះអានន្ទត្ថេរថា ម្នាលអានន្ទ តើសំឡេងអ្នកណាអ៊ូអរខ្លាំង ដូចគ្នានឹងអ្នកប្រមង់ចែកត្រីគ្នា ។ លំដាប់នោះ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុប្រមាណ ៥០០ រូប ដែលមានព្រះយសោជត្ថេរជាប្រធាន បាននាំគ្នានិមន្តមកកាន់ក្រុងសាវត្ថី ដើម្បីមកចូលគាល់ព្រះអង្គ តែភិក្ខុអាគន្តុកៈទាំងនោះ បានប្រាស្រ័យសន្ទនាគ្នាជាមួយនឹងភិក្ខុដែលជាម្ចាស់អាវាស និងចាត់ចែងអាសនៈ ប្រមូល

បាត្រ និងចីវរទៅទុកដាក់ ដូច្នេះហើយ ទើបធ្វើឲ្យមានសំឡេងអ៊ូអរឡើង ព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរទៅហៅភិក្ខុទាំងនោះ មកតាមពាក្យរបស់តថាគតថា ព្រះសាស្ដាទ្រង់ត្រាស់ឲ្យហៅអ្នកទាំងឡាយ ។ ពេលនោះ ព្រះអានន្ទ ទទួលព្រះពុទ្ធដីកាហើយ ក៏បានចូលទៅរកភិក្ខុទាំងនោះដល់ទីកន្លែង ហើយនិយាយប្រាប់ភិក្ខុទាំងនោះ ឲ្យជ្រាបតាមព្រះពុទ្ធបំណង ។ ភិក្ខុទាំងនោះ កាលបើបានជ្រាបហើយ ទើបនាំគ្នាចូលទៅគាល់ព្រះភគវា ដល់ទីគន់ប្រថាប់ ថ្វាយបង្គំរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

គ្រានោះ ព្រះទសពល ត្រាស់សួរភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វី ទើបបានជាអ្នកទាំងឡាយបញ្ចេញសំឡេងអ៊ូអរប្រហែលគ្នានឹងអ្នកប្រមង់ចែកត្រីគ្នាដូច្នេះ ។ ព្រះយសោជៈបានស្ដាប់ព្រះពុទ្ធតម្រាស់ត្រាស់សួរដូច្នោះហើយ បានក្រាបទូលឡើងថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ភិក្ខុប្រមាណ ៥០០ រូបនេះ បានធ្វើដំណើរមកដល់ក្រុងសាវត្ថី ដោយលំដាប់ ប្រាថ្នាដើម្បីនឹងចូលមកគាល់ព្រះមានបុណ្យ ពេលដែលភិក្ខុជាអាគន្តុកៈ ជួបប្រាស្រ័យជាមួយនឹងភិក្ខុ ដែលជាម្ចាស់អាវាស ព្រមទាំងការចាត់ចែងទីសេនាសនៈ និង

ប្រមូលបាត្រ និងចីវរ ទើបធ្វើឲ្យមានសំឡេងអ៊ូអរឡើងដូច្នោះឯង ។ ព្រះលោកនាថ ទ្រង់ត្រាស់បណ្តេញថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយចៀសចេញទៅ តថាគតផ្តន្ទាទោសអ្នកទាំងឡាយ អ្នកទាំងឡាយ មិនគួរនៅក្នុងសម្នាក់របស់តថាគតនេះទៀតឡើយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះមហាមុនីហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះភគវា ធ្វើប្រទក្សិណចៀសចេញទៅ ក៏បានរៀបចំទុកដាក់ទីសេនាសនៈ រួចហើយក៏បានកាន់យកបាត្រ និងចីវរ នាំគ្នានិមន្តដើរចេញទៅកាន់វជ្ជីជនបទ កាលទៅដល់វជ្ជីជនបទដោយលំដាប់ រហូតទៅដល់ស្ទឹងវគ្គុមុទា បាននាំគ្នាធ្វើកុដិប្រក់ស្លឹកហើយនាំគ្នាចាំវស្សានៅទៀបឆ្នេរនៃស្ទឹងវគ្គុមុទានោះ ។ ក្នុងគ្រានោះព្រះយសោជៈចូលចាំវស្សាហើយ បានហៅភិក្ខុទាំងឡាយមកប្រាប់ថា នៃលោកអ្នកដ៏មានអាយុទាំងឡាយ ព្រះបរមគ្រូ ទ្រង់ជាអ្នកប្រាថ្នានូវប្រយោជន៍ ជាអ្នកស្វែងរកនូវប្រយោជន៍ និងជាអ្នកអនុគ្រោះ ទ្រង់អាស្រ័យការអនុគ្រោះផ្តន្ទាទោសអ្វីៗ ណា យើងទាំងអស់គ្នា ព្រមទទួលដោយប្រការនោះចុះ ។

ភិក្ខុទាំងនោះយល់ព្រមតាមពាក្យណែនាំ របស់ព្រះយសោជៈ

ហើយ ម្នាក់ៗ ក៏មានបំណងនៅតែម្នាក់ៗឯង ជាអ្នកមិនមានសេចក្តីប្រមាទ មានសេចក្តីព្យាយាម មានចិត្តក្លាហានគ្រប់ៗ រូប ដូច្នេះហើយ ទើបធ្វើឲ្យពួកលោកបានត្រាស់ដឹងនូវសច្ចធម៌ បានធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ ក្នុងវស្សានោះឯង ។ ចំណែកព្រះសយម្ភូ ទ្រង់គង់ប្រថាប់នៅក្នុងក្រុងសាវត្ថី តាមព្រះអធ្យាស្រ័យហើយ ស្តេចបានចារិកទៅកាន់ក្រុងវេសាលី ស្តេចចារិកទៅដោយលំដាប់ រហូតទៅដល់ក្រុងវេសាលី ហើយព្រះអង្គចូលទៅគង់ប្រថាប់ នៅក្នុងកូដាគារ-សាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ក្នុងពេលនោះ ព្រះភគវាទ្រង់មនសិការៈ គឺការកំណត់ចិត្តរបស់ភិក្ខុទាំងឡាយ ដែលគង់នៅទៀបឆ្នេរនៃស្ទឹងវគ្គុមុទាដោយព្រះទ័យព្រះអង្គហើយ ទើបទ្រង់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ ភិក្ខុទាំងឡាយដែលនៅទៀបឆ្នេរនៃស្ទឹងវគ្គុមុទា នៅក្នុងទិសណា ទិសនោះ ដូចជាមានពន្លឺ ដូចមានឱភាសដល់តថាគត ពួកអ្នកទាំងអស់នោះ ជាអ្នកមិនខ្ជិលច្រអូសដូច្នេះ ម្នាលអានន្ទ អ្នកគប្បីបញ្ជូនភិក្ខុ ជាទូតទៅកាន់សម្នាក់នៃភិក្ខុទាំងឡាយ ដែលគង់នៅទៀបឆ្នេរនៃស្ទឹងវគ្គុមុទានោះ ដោយប្រាប់ថាព្រះសាស្តាឲ្យហៅអ្នកទាំងឡាយ ព្រះអង្គមានបំណងនឹងចង់ជួបអ្នក

ទាំងឡាយ ។ ដូច្នេះ ព្រះអានន្ទបានប្រាប់ដល់ភិក្ខុមួយរូប តាមដែលព្រះទសពលទ្រង់ប្រាប់ ភិក្ខុនោះទទួលពាក្យរបស់ព្រះអានន្ទរួចហើយក៏បានបាត់ពីកូដាគារសាលា នាព្រៃមហាវ័ន បានទៅប្រាកដនៅខាងមុខភិក្ខុទាំងឡាយ ត្រង់ប្រាំងច្នេរនៃស្ទឹងវគ្គមុទា ប្រៀបបីដូចជាបុរសដែលមានកម្លាំងលាតដៃបត់ចេញ បត់ដៃចូល ដូច្នោះ ភិក្ខុនោះ បានពោលនឹងភិក្ខុទាំងឡាយ ដែលគង់នៅទៀបច្នេរនៃស្ទឹងវគ្គមុទា តាមពាក្យដែលព្រះអានន្ទប្រាប់សព្វគ្រប់ហើយ ។ កាលភិក្ខុទាំងនោះ បានដឹងដូច្នោះ ក៏បាននាំគ្នាប្រញាប់ប្រញាល់ទុកដាក់នូវទីសេនាសនៈ និងកាន់យកបាត្រ និងចីវរបាត់អំពីប្រាំងច្នេរនៃស្ទឹងវគ្គមុទា ទៅប្រាកដចំពោះព្រះភក្ត្រនៃព្រះមុនី នៅឯកូដាគារសាលានាព្រៃមហាវ័នឯណោះប្រៀបដូចជាបុរសដែលលាតដៃចេញ បត់ដៃចូល ដូច្នោះឯង ។

ក្នុងគ្រានោះ ព្រះមុនីទ្រង់គង់ប្រថាប់នៅដោយអនេញ្ជាសមាធិ ចំណែកភិក្ខុទាំងនោះ កាលចូលទៅដល់ទីគាល់ព្រះមុនីហើយ ក៏មានសេចក្តីត្រិះរិះថា ឥឡូវនេះ ព្រះមានបុណ្យ ទ្រង់គង់ប្រថាប់នៅដោយវិហារធម៌អ្វីហ្ន៎ ក៏បានដឹងថា ព្រះពុទ្ធអង្គទ្រង់នៅដោយអនេញ្ជាសមាធិ ភិក្ខុទាំងនោះ ព្រមគ្នាចូលអនេញ្ជាសមាធិ បានដល់ **សមាធិ** ដែល

មិនញាប់ញ័រ គឺមិនមានកិលេសមកធ្វើឲ្យញាប់ញ័រ ។ ក្នុងគ្រានោះ លុះរាត្រីបឋមយាមកន្លងទៅហើយ ព្រះអានន្ទក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យដៃបែរមុខទៅរកព្រះសម្ពុទ្ធ ត្រង់ទីគង់ប្រថាប់ ហើយក្រាបទូលព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន រាត្រីកន្លងផុតអំពីបឋមយាមទៅហើយ ភិក្ខុជាអាគន្តុកៈទាំងឡាយមកអង្គុយរង់ចាំយូរហើយ ព្រះអង្គ សូមព្រះសុគត ទ្រង់បានប្រាស្រ័យជាមួយនឹងភិក្ខុជាអាគន្តុកៈនេះផង ។ កាលព្រះអានន្ទបានក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏ទ្រង់នៅស្ងៀម រហូតដល់កន្លងមជ្ឈិមយាម ព្រះអានន្ទត្ថេរ បានក្រាបទូលព្រះភគវា ដូចលើកទីមួយដែរ ព្រះអង្គក៏ទ្រង់នៅស្ងៀមទៀត ។ សូម្បីក្នុងវារៈទី ៣ ដែលបានកន្លងមកដល់បច្ឆិមយាម រហូតទៅដល់អរុណរះឡើង ព្រះអានន្ទត្ថេរ បានក្រាបទូលដូចលើកទីពីរដែរ ដោយបានក្រាបទូលថា បពិត្រព្រះអង្គជាសក្កៈ រាត្រីបានកន្លងបច្ឆិមយាមទៅហើយ រហូតដល់អរុណរះឡើងទៀតផង ភិក្ខុដែលជាអាគន្តុកៈទាំងឡាយ មកអង្គុយរង់ចាំព្រះអង្គយូរណាស់ហើយ ដូច្នេះ សូមព្រះលោកនាយក បានប្រាស្រ័យជាមួយនឹងភិក្ខុ ដែលជាអាគន្តុកៈទាំងនេះផង ព្រះអង្គ ។

គ្រានោះ ព្រះមានបុណ្យទ្រង់ក៏បានចេញចាកសមាធិនោះហើយ បានត្រាស់ប្រាប់ដល់ព្រះអានន្ទត្ថេរថា ម្នាលអានន្ទ តថាគត និងភិក្ខុទាំង ៥០០ រូបនេះ បាននាំគ្នាអង្គុយចូល **អានេញ្ជសមាធិ** ។

ការសម្រេចមគ្គផល របស់ព្រះយសោជត្ថេរ ព្រមទាំងភិក្ខុដែលជាសម្លាញ់ទាំងនោះ បានទទួលការសរសើរអំពីព្រះបរមសាស្តាដូចមានរឿងសម្តែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៖-

កាលព្រះជិនស្រី ទ្រង់បានឮសំឡេងអ៊ូអរ របស់ភិក្ខុទាំងនោះ ដោយមានព្រះយសោជត្ថេរ ជាប្រធាន ទើបទ្រង់ត្រាស់ឲ្យបណ្តេញព្រះយសោជត្ថេរ ព្រមទាំងបរិវារចេញទៅ ។ ចំណែកព្រះយសោជៈក៏មានសេចក្តីសង្វេគតក់ស្លុតចិត្ត ក៏ដូចគ្នានឹងសេះអាជានេយ្យដ៏ល្អដែលត្រូវគេវាយដោយខ្សែតី ក៏ភ្ញាក់រឭកបាន យ៉ាងណាមិញ ភិក្ខុទាំងនោះ កាលបើកើតការតក់ស្លុតយ៉ាងនេះហើយ ទើបនាំគ្នាខំប្រឹងប្រែងព្យាយាមចម្រើនវិបស្សនាកម្មដ្ឋាន នៅទៀបឆ្នេរនៃស្ទឹងវគ្គុមុទា ដោយការប្រឹងប្រែងយ៉ាងនេះ មិនយូរប៉ុន្មានក៏បានសម្រេចអភិញ្ញា ៦ ក្នុងវស្សានោះឯង ។ កាលព្រះភគវាទ្រង់ជ្រាបថា ព្រះយសោជត្ថេរ

ព្រមទាំងភិក្ខុដែលជាបរិវារបានសម្រេចអភិញ្ញា ៦ ហើយ ទើបទ្រង់មានបំណងឲ្យភិក្ខុទាំងនោះ ចូលមកគាល់ ដោយទ្រង់បានប្រាស្រ័យដោយអនេញ្ជាសមាបត្តិ ។ ម្យ៉ាងទៀត ព្រះយសោជៈ ជាអ្នកដល់ព្រមដោយការសមាទានធុតង្គគុណគ្រប់ទាំងអស់ ព្រោះដូច្នោះហើយទើបធ្វើឲ្យរាងកាយរបស់លោកស្គាំងស្គម ។

កាលព្រះលោកនាយក ទ្រង់បានលើកតម្កើងសរសើរ ព្រះយសោជត្ថេរ ក្នុងភាពជាអ្នកប្រាថ្នាតិច ទើបទ្រង់ត្រាស់គាថា ៣ គាថា ដូចដែលមានសម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៈ-

ព្រះទសពលត្រាស់សរសើរថា នរៈ គឺយសោជត្ថេរនេះ មានអវយវៈប្រាកដស្មើដោយថ្នាំងនៃវល្លិ៍ មានខ្លួនស្គមរវីមរវាម ដោយសារសៃ ដឹងប្រមាណក្នុងបាយ និងទឹក ជាអ្នកមានចិត្តមិនរួញរា ។ យសោជត្ថេរពោលថា ភិក្ខុ ( នៅ ) ក្នុងព្រៃតូច ឬព្រៃធំ បើទុកជាសត្វរបោម និងមូសខាំហើយ ក៏គប្បីជាអ្នកមានស្មារតី អត់ទ្រាំចំពោះអន្តរាយ មានរបោមជាដើម ក្នុងព្រៃនោះ ដូចដំរីដ៏ប្រសើរអត់ទ្រាំក្នុងទីនៃសង្គ្រាម ។ ភិក្ខុតែម្នាក់ឯង ( រមែងនៅជាសុខ ) ដូចគ្នានឹងព្រហ្ម ភិក្ខុនៅរួមគ្នាពីររូប ( រមែងមានសេចក្តីខ្វាំងខ្វប់ ) ដូចគ្នា

នឹងទេវតា ភិក្ខុ ( នៅរួមគ្នា ) ៣ រូប ដូចគ្នានឹងជន អ្នកស្រុក ភិក្ខុមានចំនួនច្រើនរូបលើសពីនោះទៅ ជាហេតុនាំឲ្យជ្រួលជ្រើម ( ដូចគ្នានឹងពួកមហាជនដែលប្រជុំគ្នា ) ។

ព្រះយសោជត្ថេរ ជាព្រះថេរៈមួយរូប ដែលរាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក ៨០ រូប ជាព្រះថេរៈ ដែលមានវត្តប្រតិបត្តិតឹងរ៉ឹងបំផុតតាមពុទ្ធប្បញ្ញត្តិ និងជាព្រះថេរៈ ដែលមានគុណសម្បត្តិដ៏ល្អ ក្នុងការដឹកនាំភិក្ខុ ដែលជាបរិវាររបស់ខ្លួន ឲ្យប្រសព្វសម្រេចនូវការសិក្សាក្នុងព្រះសាសនានេះ បានដល់បរិញ្ញាជីវិត ដែលជាដំណើរចូលទៅដល់ដែននៃបរមសុខ ពោលគឺព្រះនិព្វាន ។

( ជីវប្រវត្តិរបស់ព្រះយសោជត្ថេរ ចប់ )

# ជីវប្រវត្តិរបស់ព្រះសតិយត្ថេរ

" លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ "

ព្រះសកិយត្ថេរ លោកទ្រទ្រង់នូវគុណធម៌ ដែលជាលោកុត្តរៈ ទាំងខ្លួនលោកក៏សង្គ្រោះចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវ័ក ដែលជាសាវ័កធំរបស់ព្រះពុទ្ធអង្គជាម្ចាស់ ៨០ រូប ទាំងជាអ្នកមានសេចក្តីព្យាយាមឧស្សាហ៍ ក្នុងវត្តប្រតិបត្តិប្រព្រឹត្តទៅតាមពុទ្ធោវាទ ។

ជីវប្រវត្តិដែលសម្តែងដល់បុព្វកម្ម របស់ព្រះសកិយត្ថេរ ដូចមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** មានពោលទុកថា ៈ-

ក្នុងអតីតជាតិ ព្រះសកិយៈ លោកធ្លាប់បានធ្វើបុណ្យកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធ ដែលបានត្រាស់ដឹងរួចមកហើយ ដូចគ្នានឹងព្រះថេរៈរូបមុនៗ ដែរ ជាទម្លាប់ ពេលដែលលោកកើតមក តែងតែសន្សំបុណ្យកុសលនៅក្នុងជាតិនោះៗ ។ ក្នុងជាតិមួយ លោកបានកើតនៅក្នុងត្រកូលអ្នកមានធនធានម្នាក់ ដែលស្របគ្នានឹងពុទ្ធកាលនៃព្រះកក្កុសន្ធោសម្ពុទ្ធ ។ ក្នុងថ្ងៃមួយ ត្រូវនឹងពាក់កណ្តាលខែចេត្រ ជាខែដែលក្តៅ គ្រានោះ ព្រះកក្កុសន្ធោសម្ពុទ្ធ ស្តេចយាងចេញពីទីគន់ប្រថាប់ កុលបុត្រ ( សកិយៈ ) បានជួបនឹងព្រះពុទ្ធអង្គ ដូច្នោះហើយ

ឃើញថា ខែនេះជាខែក្តៅ ជាឱកាសល្អសម្រាប់ខ្លួនធ្វើទាន កាលគិតឃើញដូច្នេះ ទើបចង់បរិច្ចាគទាន ហើយបានប្រគេនស្បែកជើង ដើម្បីកុំឲ្យព្រះភគវាក្តៅព្រះបាទ ព្រោះខែចែត្រនេះក្តៅណាស់ គេទើបបានបង្អោនស្បែកជើងនោះ ចូលទៅប្រគេនចំពោះព្រះកក្កុសន្ធោ ដោយសេចក្តីគោរព និងដោយសេចក្តីជ្រះថ្លា ។ ដោយអានិសង្ស នៃការប្រគេនស្បែកជើងដល់ព្រះកក្កុសន្ធោ ក្រោយអំពីអស់ជីវិតទៅ ក៏បានធ្វើឲ្យកុលបុត្រ ( សភិយៈ ) ទៅកើតនៅក្នុងស្ថានសួគ៌ និងមានការត្រាច់រង្គាត់ជាមនុស្ស និងទេវតាអស់កាលជាយូរអង្វែង ។

លុះមកដល់សម័យ នៃព្រះពុទ្ធព្រះនាមកស្សបសម្ពុទ្ធ តែជាពេលចុងក្រោយនៃព្រះពុទ្ធសាសនា ដូចមានរឿងតំណាលទុកយ៉ាងពិស្តារ តាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលី **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ក្នុង **សភិយសូត្រ** មានន័យថា ៈ-

កាលនៃព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ ពុទ្ធបរិស័ទបាននាំគ្នាកសាងព្រះសុវណ្ណចេតិយឡើង ដើម្បីបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះអង្គ កាលបើកសាងព្រះចេតិយ

នោះរួចស្រេចហើយ ទើបនាំគ្នាអារាធនាព្រះបរមសារីរិកធាតុ របស់ព្រះសម្ពុទ្ធមកបញ្ចុះ ក្នុងព្រះសុវណ្ណចេតិយនោះ ។ កាលតមក មានកុលបុត្រ ៧ នាក់ នាំគ្នាមកបួសក្នុងសម្នាក់ភិក្ខុដែលជាសាវ័ករបស់ព្រះកស្សបសម្ពុទ្ធ ហើយបានរៀនព្រះកម្មដ្ឋាន ដែលសមរម្យដល់និស្ស័យរបស់ខ្លួន រៀងៗ ខ្លួន កាលរៀនចប់ហើយ ទើបនាំគ្នាទៅអាស្រ័យនៅក្នុងបច្ចន្តជនបទមួយកន្លែង ដើម្បីធ្វើសមណធម៌នៅក្នុងព្រៃនោះ ។ តមក ភិក្ខុទាំង ៧ រូបនោះ បាននាំគ្នាចូលទៅក្រុងវិញដោយតាំងចិត្តទៅនមស្ការព្រះសុវណ្ណចេតិយ ដែលបានបញ្ចុះនូវព្រះបរមសារីរិកធាតុនោះ និងចង់បានស្តាប់ឱវាទខ្លះពីព្រះថេរៈ ដូច្នេះរួចហើយ នឹងនាំគ្នាត្រឡប់មកបដិបត្តិធម៌នៅក្នុងព្រៃនេះទៀត សូម្បីតាំងចិត្តប្រព្រឹត្តយ៉ាងហ្នឹងក៏ដោយ ព្រមទាំងជាអ្នកមិនមានសេចក្តីប្រមាទនោះ ក៏មិនអាចធ្វើឲ្យពួកលោកបានសម្រេចគុណធម៌អ្វីឡើយ ក៏ត្រូវពេលដែលព្រះពុទ្ធសាសនាកំពុងតែអន្តរធានទៅដែរ កាលបើលោកឃើញភិក្ខុដែលជាសាវ័ករបស់ព្រះអង្គ មិននាំគ្នាអើពើចំពោះធម៌ និងវិន័យរបស់ព្រះអង្គ ក៏មានសេចក្តីសង្វេគក្នុងចិត្តឡើង ។ ភិក្ខុទាំង ៧ រូបនោះ បានប្រឹក្សាគ្នាថា ប្រសិនបើពួកយើងនាំគ្នាទៅបិណ្ឌបាតក្នុង

ស្រុក ប្រាកដជាមានក្ដីកង្វល់ក្នុងជីវិតនេះហើយ អ្នកដែលមានក្ដីកង្វល់ក្នុងជីវិត មិនអាចបានសម្រេចលោកុត្តរធម៌ឡើយ គឺធម៌ដែលឆ្លងចាកលោកបាន សេចក្ដីស្លាប់ដែលយើងទាំងអស់គ្នា នៅភាពជាបុថុជ្ជននេះរមែងជាទុក្ខ កុំបណ្ដោយឲ្យមានសេចក្ដីទុក្ខនេះ តទៅទៀត គួរពួកយើងកម្ចាត់នូវក្ដីកង្វល់តាមផ្លូវកាយ និងជីវិតចោល កាលបើភិក្ខុទាំងនោះ គិតឃើញដូច្នោះហើយ ទើបនាំគ្នាចងបង្អោងឡើងទៅលើកំពូលភ្នំ ដើម្បីធ្វើសមណធម៌ ហើយពោលថា បើលោកអ្នកដ៏មានអាយុអង្គណា មានការអាល័យនៅក្នុងជីវិត ចូរកុំឡើងអី ប៉ុន្តែភិក្ខុជាមិត្តធម៌ទាំងនោះ ជាអ្នកមិនអាល័យក្នុងជីវិត ទើបនាំគ្នាឡើងទៅលើកំពូលភ្នំ កាលទៅដល់លើកំពូលភ្នំ ក៏នាំគ្នាផាក់បង្អោងឫស្សីចោលមកក្រោម ថែមទាំងបានតាំងកតិកាគ្នាថា បើពួកយើងមិនបានសម្រេចមគ្គផល ពួកយើងកុំឆាន់ចង្ហាន់ ទាំងកុំនាំគ្នាចុះពីលើភ្នំនេះទៅវិញ ។

កាលតមក មានភិក្ខុចាស់មួយរូប ជាសព្រហ្មចារីបានតាំងចិត្តប្រតិបត្តិធម៌ ដោយកន្លងទៅបាន ៥ ថ្ងៃ ក៏បានសម្រេចជាព្រះអរហន្តព្រោះជាអ្នកបរិបូណ៌ទៅដោយឧបនិស្ស័យ ( សេចក្ដីល្អ ដែលបានសន្សំទុកមកគ្រប់គ្រាន់ហើយ ) ។ លុះដល់ព្រឹកព្រហាមឡើង លោក

ក៏បានទៅខ្ពុរមាត់ លាងមុខនៅអនោតត្តស្រះ នាព្រៃហិមពាន្ត ដោយអរិយឫទ្ធិ ហើយទៅបិណ្ឌបាតនៅឧត្តរកុរុទ្វីប ។ ក្រោយពីលោកឆាន់រួចស្រេចរៀបរយ ទើបបានទៅបិណ្ឌបាតក្នុងទីដទៃទៀត កាលបានចង្ហាន់ពេញបាត្រហើយ ក៏បានទៅដងទឹកពីអនោតត្តស្រះ ព្រមដោយយកឈើស្ទន់អំពីព្រៃហិមពាន្ត យកមកប្រគេនដល់ភិក្ខុ ៦ រូបទៀតដែលជាមិត្តធម៌ ដោយពោលជាមួយនឹងភិក្ខុទាំងនោះថា លោកអ្នកដ៏មានអាយុទាំងឡាយ ចូរមើលអានុភាពនេះចុះ ចង្ហាន់នេះជាបិណ្ឌបាតដែលនាំមកពីឧត្តរកុរុទ្វីប សូម្បីទឹក និងឈើស្ទន់ទាំងនេះ ក៏នាំយកមកពីព្រៃហិមពាន្តដែរ ដូច្នេះ សូមលោកអ្នកដ៏មានអាយុទាំងឡាយលុបលាងមុខ ទំពាឈើស្ទន់ ខ្ពុរមាត់ រួចហើយចូរឆាន់ចង្ហាន់នេះចុះ កាលបើលោកអ្នកដ៏មានអាយុទាំងឡាយ ឆាន់ចង្ហាន់នេះរួចហើយ ចូរនាំគ្នាធ្វើសមណធម៌ទៀតចុះ ចំណែកខ្ញុំនឹងទំនុកបម្រុងលោកអ្នកដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះតបថា លោកម្ចាស់បានសម្រេចកិច្ចនៃបព្វជិតហើយ សូមលោកម្ចាស់ឆាន់ចង្ហាន់នេះទៅ កុំមកនិយាយជាមួយនឹងពួកខ្ញុំ ឲ្យខូចពេលវេលាធ្វើសមណធម៌ឡើយ តាំងពីថ្ងៃនេះតទៅ សូមកុំឲ្យលោកម្ចាស់មករកខ្ញុំ និងនាំយកចង្ហាន់បិណ្ឌបាតមក

ឲ្យដល់ពួកខ្ញុំទៀតឡើយ កាលបើភិក្ខុទាំងនោះពោលយ៉ាងដូច្នេះហើយ មិនមានភិក្ខុរូបណាមួយ ព្រមទទួលឆាន់ចង្ហាន់បិណ្ឌបាតនោះឡើយ ។ រីឯភិក្ខុជាព្រះអរហន្តនោះ សូម្បីត្រូវពួកភិក្ខុទាំងនោះ ពោលបដិសេធដូច្នេះហើយ លោកក៏មិនបានសួររកមូលហេតុអ្វីទេ ដោយលោកបានពោលពន្យល់ហេតុផលច្រើនប្រការ តែត្រឡប់ត្រូវភិក្ខុទាំងនោះពោលបដិសេធទៅវិញ និងប្រាប់ឲ្យរឭកដល់កតិកា ដែលព្រមព្រៀងគ្នា ។ កាលលោកមិនអាចនិយាយឲ្យភិក្ខុទាំងនោះ ឃើញពីបំណងល្អរបស់លោកបាន លោកចាំបាច់ត្រូវតែគេចទៅនៅតែមួយព្រះអង្គឯង ។

តពីនោះមក ដល់ថ្ងៃទី ៧ មានភិក្ខុមួយរូបបន្ទាប់ទៀត បានសម្រេចអរិយធម៌ជាព្រះអនាគាមី ហើយបានទៅបិណ្ឌបាត និងនាំចង្ហាន់មកប្រគេនដល់ភិក្ខុ ៥ រូបនោះទៀត ដែលមិនទាន់បានសម្រេចមគ្គផលនោះ ក៏ត្រូវភិក្ខុទាំងនោះ ពោលបដិសេធទៀតដូចគ្នា ដូច្នេះហើយ លោកទើបគេចទៅបំពេញសមណធម៌ តទៅទៀត នៅតែម្នាក់ឯង ។ ប៉ុន្តែ ភិក្ខុទាំង ៥ រូបនោះ ជាអ្នកបានរក្សាសច្ចធម៌ថា បើខ្លួនមិនបានសម្រេចមគ្គផល គុណធម៌ណាទេ នឹងមិនព្រមឆាន់ចង្ហាន់ សុខចិត្តស្លាប់ទៅវិញប្រសើរជាង ។ កាលតមក ព្រះថេរៈ

ដែលជាព្រះអរហន្ត ក៏បានរំលត់ខន្ធបរិនិព្វានទៅ រីឯព្រះថេរៈដែលបានសម្រេចជាព្រះអនាគាមី ក៏ធ្វើមរណកាលទៅកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ។ ចំណែកភិក្ខុ ៥ រូបទៀត ដែលនៅជាបុថុជ្ជននោះកាលបើមិនបានឆាន់ចង្ហាន់ជាច្រើនថ្ងៃមក រាងកាយក៏ស្គាំងស្គមទ្រុឌទ្រោមចុះ ហើយក៏ធ្វើមរណភាពទៅ ក៏បានទៅកើតនៅក្នុងស្ថានសួគ៌អស់មួយពុទ្ធន្តរ ។ រហូតមកដល់ពុទ្ធកាល នៃព្រះសមណគោតមបរមគ្រូនៃយើងនេះ ទេវបុត្រទាំង ៥ អង្គនោះ បានចុតិចាកទេវលោកចុះមកកើតជាមនុស្ស នៅក្នុងត្រកូលផ្សេងៗ គ្នា ។ មួយអង្គបានទៅកើតក្នុងត្រកូលក្សត្រមល្លៈ ក្នុងអនុបិយនិគម ដែនមល្លៈ ក្នុងនគរកុសិនារា មាននាមថា **ទព្វមល្លបុត្រ** ។ មួយអង្គទៀតបានទៅកើតនៅក្នុងត្រកូលក្សត្រ ក្នុងនគរតក្កសិលា ដែនគន្ធារៈ មាននាមថា **ព្រះបាទបុក្កុសាតិ** ។ មួយអង្គទៀត បានទៅកើតក្នុងត្រកូលជាសេដ្ឋីនៅក្នុងក្រុងរាជគ្រឹះ ក្នុងដែនមគធៈ មាននាមថា **កុមារកស្សបៈ** ។ មួយអង្គទៀត បានទៅកើតក្នុងត្រកូលកុដុម្ពិក ក្នុងដែនពាហិយៈ មាននាមថា **ពាហិយទារុចីរិយៈ** ។ ចំណែកមួយអង្គទៀតបានមកបដិសន្ធិ

ក្នុងគភ៌របស់នាងបរិព្វាជិកា ក្នុងដែនបព្វទេយ្យៈ ( កន្លែងខ្លះហៅថា បច្ចន្តិយៈ ) មាននាមថា **សភិយៈ** ។

មានរឿងតំណាលទុកថា នាងបរិព្វាជិកានោះ ទ្រង់ជាព្រះរាជធីតានៃក្សត្រមួយអង្គ ព្រះរាជមាតា និងព្រះរាជបិតា បានប្រគល់ឲ្យទៅសិក្សាជាមួយបរិព្វាជិកាចារ្យម្នាក់ ដោយមានព្រះរាជបំណង នឹងឲ្យព្រះរាជធីតាសិក្សាសិល្បវិជ្ជាផ្សេងៗ នៅក្នុងសម្នាក់បរិព្វាជិកាចារ្យនោះ ។ តែមានបរិព្វាជិក ដែលជាសិស្សរបស់បរិព្វាជិកាចារ្យនោះ មានសេចក្ដីស្នេហា និងរួមអភិរម្យបវេណី ជាបដល់ព្រះរាជធីតានោះ ទ្រង់មានព្រះគភ៌ឡើង ។ ចំណែកនាងបរិព្វាជិកា ដែលជាសិស្សរួមសម្នាក់ជាមួយគ្នានោះ បានឃើញព្រះរាជធីតានោះ ទ្រង់ព្រះគភ៌ ក៏ខ្លាចនឹងកើតការខូចកេរ្តិ៍ឈ្មោះ នៅក្នុងសម្នាក់របស់ពួកខ្លួន ទើបនាំគ្នាបណ្ដេញព្រះនាងបរិព្វាជិកានោះចេញអំពីសម្នាក់ ។ ព្រះរាជធីតាមិនអាចនឹងអត់ទ្រាំតស៊ូចំពោះមុខទៅបាន ទើបស្ដេចសម្រេចចិត្ត ចេញអំពីសម្នាក់បរិព្វាជិកាចារ្យ ដោយធ្វើដំណើរទៅកាន់កន្លែងដទៃ ប៉ុន្តែក្នុងខណៈដែលព្រះនាង ស្ដេចយាងមកដល់ ក្នុងរវាងផ្លូវកន្លែងមួយ ព្រះនាងក៏ប្រសូតបុត្រក្នុងរវាងផ្លូវនោះ ដែលមានឈ្មោះថា **សភិយៈ**

ព្រះនាងទើបទ្រង់កាន់យកឈ្មោះ របស់ផ្លូវនោះជានិមិត្ត ក៏បានដាក់ឈ្មោះឲ្យបុត្រនោះថា **សភិយៈ** ។ កាលសភិយៈធំឡើង ជាលំដាប់ដឹងក្តីហើយ បានចេញបួសជាបរិញ្វាជក ហើយតាំងចិត្តសិក្សាចំណេះដឹងក្នុងគម្ពីរផ្សេងៗ រហូតមានចំណេះដឹង មិនអាចមាននរណាប្រៀបបានក្នុងជម្ពូទ្វីបនឹងចំណេះវិជ្ជារបស់ខ្លួនឡើយ ទើបឲ្យកសាងអាស្រមនៅត្រង់ខ្លោងទ្វារ ហើយបានបង្រៀនសិល្បវិជ្ជាដល់កុមារដទៃជាច្រើនមានខត្តិយកុមារជាដើម បានមកសិក្សានៅក្នុងអាស្រមរបស់ខ្លួននោះដែរ ។ ក៏នៅក្នុងសម័យនោះ ព្រះពុទ្ធជាអង្គម្ចាស់នៃយើង បានត្រាស់ដឹងហើយនៅក្នុងលោក ទ្រង់បានប្រកាសធម្មចក្រដ៏ប្រសើរ និងស្តេចយាងទៅគង់នៅឯវត្តវេឡុវ័នមហាវិហារ ដែលជាកលន្ទកនិវាបស្ថានគឺជាស្ថានទីដែលឲ្យចំណីដល់សត្វកំប្រុក ជិតក្រុងរាជគ្រឹះ ។ ពាក្យថា **វេឡុវ័ននេះ** ជាឈ្មោះរបស់ឧទ្យាន ដែលព័ទ្ធជុំវិញទៅដោយដើមឫស្សីមានកំផែងកម្ពស់ ១៨ ហត្ថ និងមានដើមឈើមានសម្រស់ពណ៌ខៀវគួរឲ្យជាទីមនោរម្យ ទាំងជាវត្តដំបូងបង្អស់ នៅក្នុងព្រះពុទ្ធសាសនានេះ ដែលព្រះបាទពិម្ពិសារកសាងថ្វាយ ។

មួយទៀត ពាក្យដែលពោលថា ជាស្ពានទីឲ្យចំណីដល់សត្វកង្អែននោះ ដូចមានរឿងតំណាលទុកនៅក្នុង **អដ្ឋកថា** ថា ៈ-

កាលពីសម័យមុននោះ មានព្រះរាជាមួយអង្គ ស្ដេចបានយាងទៅប្រពាសក្នុងព្រះរាជឧទ្យាននោះ ព្រះអង្គទ្រង់ស្រវឹងស្រា ហើយក៏ផ្ទំលក់ទៅ ចំណែកពួករាជបរិវារឃើញថា ព្រះរាជាផ្ទំលក់ហើយ ម្នាក់ៗបានដើរចេញទៅបេះផ្កា និងផ្លែឈើជាដើម ដោយមិនបាននៅរង់ចាំមើលព្រះរាជាផ្ទំឡើយ ។ ខណៈនោះ មានពស់វែកជំបូកមួយ លូនចេញមកពីប្រហោងដើមឈើមួយដើម ព្រោះបានធុំក្លិនសុរាពីព្រះរាជា ទើបបានលូនបែរមុខមកកន្លែងដែលព្រះរាជាទ្រង់ផ្ទំ ។ គ្រានោះ មានទេវតាមួយអង្គ ដែលអាស្រ័យនឹងដើមឈើនោះ ដែលនៅជិតៗ នឹងកន្លែងព្រះរាជាផ្ទំលក់នោះៗ បានក្រឡេកឃើញហេតុការណ៍ នឹងកើតឡើងដល់ព្រះរាជា ក៏បានគិតឡើងភ្លាមៗ ថា យើងគួរនឹងជួយឲ្យព្រះរាជាផុតអំពីសេចក្ដីអន្តរាយនេះ ហើយទើបក្លែងខ្លួនធ្វើជាសត្វកង្អែនបញ្ចេញសំឡេងយ៉ាងខ្លាំងៗ នៅក្បែរព្រះកាណ៌របស់ព្រះរាជាៗ ក៏ភ្ញាក់ឡើង ចំណែកពស់វែកជំបូកនោះ ក៏បានលូនត្រឡប់ទៅវិញទៅ ។ កាលព្រះរាជាភ្ញាក់ឡើងហើយ បានជ្រាបហេតុការណ៍សព្វគ្រប់ទាំង

នោះហើយ ទើបទ្រង់ត្រិះរិះថា សត្វកង្អែននេះ ជាអ្នកឲ្យជីវិតយើង ទ្រង់ក៏ផ្តើមតម្កល់ចំណីទុក ដើម្បីឲ្យសត្វកង្អែន ដែលនៅក្នុងស្ពានទីនេះ និងទ្រង់បង្គុកប្រកាសឲ្យដឹងគ្រប់ៗ គ្នាថា សត្វកង្អែនក្នុងទីនេះ ចាប់ពីថ្ងៃនេះតទៅ ស្ពានទីនេះ មិនឲ្យមាននរណាមកបៀតបៀនផ្តាច់ជីវិតសត្វកង្អែនក្នុងទីនេះឡើយ ។ សូម្បីថាព្រះមានព្រះភាគ ក៏ទ្រង់ប្រកាសព្រះធម៌វិន័យ ឲ្យដល់មហាជន និងសាវ័កព្រះអង្គយល់ដឹងជាច្រើន និងសម្រេចមគ្គផលក្នុងទីនោះដែរ តែសកិយបរិព្វាជកនៅមិនទាន់ដឹងថា ព្រះពុទ្ធកើតឡើងហើយនៅក្នុងលោកទេ ។

លំដាប់នោះ ព្រហ្មដែលនៅក្នុងព្រហ្មលោកជាន់សុទ្ធាវាស ក្នុងអតីតជាតិ ធ្លាប់បានជាសម្លាញ់ជាមួយគ្នានឹងសកិយបរិព្វាជក កាលចេញចាកសមាបត្តិហើយ ក៏បានរំពឹងថា យើងមានគុណវិសេសយ៉ាងនេះ ដោយការដែលយើងទៅធ្វើសមណធម៌នៅក្នុងសាសនា នៃព្រះ-ពុទ្ធ ព្រះនាមកស្សបៈ ជាមួយនឹងសម្លាញ់ ៦ រូបទៀត ហើយក៏បានរឭកដល់សម្លាញ់ទាំងនោះ ដោយពិចារណារកមើលសម្លាញ់ទាំងនោះតើទៅកើតក្នុងទីណា ក៏បានដឹងថា សម្លាញ់មួយរូបបានសម្រេចជាព្រះអរហន្ត លោកក៏រំលត់ខន្ធបរិនិព្វានទៅហើយ រីឯសម្លាញ់ ៥ រូប

ទៀត ទៅកើតក្នុងទីណា ក៏បានជ្រាបថា ទៅកើតក្នុងជម្ពូទ្វីបក្នុងស្ថាន ទីផ្សេងៗគ្នា ដោយចំពោះសភិយបរិព្វាជក បានបួសជាអ្នកបួសក្រៅ ព្រះពុទ្ធសាសនា ប៉ុន្តែឥឡូវនេះ បានតាំងខ្លួនជាអាចារ្យ តែគេមិនដឹង ថា ព្រះពុទ្ធកើតឡើងក្នុងលោកឡើយ យើងនឹងទៅប្រាប់គេ ឲ្យបាន ដឹងក្នុងរឿងនេះ ដើម្បីឲ្យគេចូលទៅគាល់ព្រះសម្ពុទ្ធ គិតដូច្នេះហើយ ទើបបានចងជាបញ្ហាឡើង ២០ ១. ។ លុះដល់ពេលអគ្រោត្រព្រហ្មនោះ បានទៅប្រាកដនៅក្នុងអាស្រមរបស់សភិយបរិព្វាជក ដោយឈរនៅ លើអាកាស ហើយស្រែកហៅថា សភិយៈៗ ៗ ។ ចំណែកសភិយៈ កំពុងតែដេកលក់ កាលបើបានឮសំឡេងស្រែកហៅ ឈ្មោះរបស់ខ្លួន រហូតដល់ ៣ ដង ក៏បានភ្ញាក់ឡើង ហើយក៏បានឃើញពន្លឺ ដូច្នេះ ហើយ ក៏ឈរប្រណម្យអញ្ជលីឡើង ។ លំដាប់នោះ ព្រហ្មជាសម្លាញ់ របស់លោក ទើបបាននិយាយប្រាប់ថា **សភិយៈ** យើងបាននាំយក បញ្ហាមកឲ្យលោក ចូរលោករៀនបញ្ហាទាំងនេះទុក ប្រសិនបើមាន សមណៈ ឬព្រាហ្មណ៍ ដែលអាចដោះស្រាយបញ្ហានេះបាន ចូរលោក បួសក្នុងសម្នាក់របស់សមណៈ ឬព្រាហ្មណ៍នោះចុះ ។

កាលដែលព្រហ្មដែលជាសម្លាញ់ បានពោលនឹងសភិយៈយ៉ាង

នេះហើយ សភិយបរិព្វាជក ទើបតាំងចិត្តរៀនបញ្ហា ២០ ខ. ទាំងនោះ បានយ៉ាងធាប់រហ័ស ដោយប្រាប់មួយបទត្រឹមតែម្តងប៉ុណ្ណោះ ។ ព្រហ្ម ដែលជាសម្លាញ់ ក៏បានជ្រាបថា ចំពោះបញ្ហា ២០ ខ.នេះ មិនមាន គណាចារ្យណាទីមួយដោះស្រាយបានឡើយ ក្រៅពីព្រះលោកនាយក ហើយនោះ មានតែព្រះពុទ្ធអង្គប៉ុណ្ណោះ ទើបអាចជាអ្នកដោះស្រាយ បញ្ហានេះបាន សូម្បីលោកដឹងដូច្នោះហើយក៏ដោយ លោកក៏មិនបាន ប្រាប់ដល់សភិយៈ ដោយលោកគិតយល់ថា បើសភិយបរិព្វាជកជា អ្នកមានឧបនិស្ស័យមែននោះ គេគង់តែនឹងបានជួប ឬបានស្គាល់ព្រះ លោកនាថមិនខានឡើយ គេប្រាកដជាយល់ដឹងដោយខ្លួនឯងថា បើ ប្រាសចាកសមណព្រាហ្មណ៍ នៅក្នុងព្រះពុទ្ធសាសនានេះហើយ ជា អ្នកមិនមានគោលការណ៍ នៃពាក្យប្រៀនប្រដៅ ដែលជាខ្លឹមសារដឹក នាំខ្លួន ឲ្យរួចផុតអំពីសេចក្តីទុក្ខបានឡើយ មានតែព្រះសាសនានេះ ប៉ុណ្ណោះ ដែលអាចដឹកនាំខ្លួន ឲ្យរួចផុតអំពីសេចក្តីទុក្ខបានយ៉ាងពិត ប្រាកដមែន ។

ជីវប្រវត្តិរបស់ព្រះសភិយៈ មានសម្តែងទុកនៅក្នុងព្រះបាលី នៃ **សភិយសូត្រ** ក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** មានន័យថា ៖-

កាលសកិយបរិព្វាជករៀនបញ្ហា ២០ ខ.នោះ ពីព្រាហ្មណ៍ដែលជាសម្លាញ់របស់លោកចេះអស់ហើយ បានចេញទៅរកសាកសួរបញ្ហានេះ នឹងសមណព្រាហ្មណ៍ ដែលជាម្ចាស់ពួកគណៈ ឬជាគណាចារ្យដែលជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញជាម្ចាស់លទ្ធិ ដែលមានពួកអ្នកគោរពរាប់អានច្រើន មានបូរណកស្សបៈជាដើម គណាចារ្យទាំងនេះមិនមាននរណាអាចដោះស្រាយបញ្ហា ២០ ខ. ទាំងនោះ បានសូម្បីត្រឹមតែមួយខ.ឡើយ ។

ក្នុងវគ្គនេះ នឹងសូមលើកយកពាក្យអធិប្បាយរបស់ **អដ្ឋកថា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីទាក់ទង នឹងប្រវត្តិរបស់គ្រូទាំង ៦ នាក់ ដែលមានបូរណកស្សបជាដើម មានសម្តែងទុកនៅក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** នៃ **វណ្ណនាសាមញ្ញផលសូត្រ** មានន័យថា ៈ-

ពាក្យថា **សមណព្រាហ្មណ៍** បានដល់ អ្នកដែលសន្មតិថាជាអ្នកបួស ។ ពាក្យថា **ម្ចាស់ពួកគណៈ ឬម្ចាស់លទ្ធិនោះ** គឺពួកសមណព្រាហ្មណ៍ទាំងនោះ បានអះអាងខ្លួនថា ជាសាស្តា ខ្លួនជាសព្វញ្ញូ គឺអ្នកអាចដឹងវត្ថុទាំងពួងបាន ។ **បូរណកស្សបៈ** ពាក្យថា **បូរណៈ** ជាឈ្មោះ **កស្សបៈ** ជានាមត្រកូលរបស់គេ សេចក្តីនេះ

ទាក់ទងនឹងរឿងឈ្មោះរបស់គេនោះ គឺគេជាទាសៈតាំងតែពីកំណើតមកម៉្លេះ គេកើតជាទាសៈ ជាមនុស្សដែលគម្រប់ទី ១០០ ទើបបានមានឈ្មោះថា **បូរណៈ** ប្រែថា **ពេញ** ឬថាធ្វើឲ្យគ្រប់បរិបូណ៌ ហើយតមក បានរត់គេចអំពីភាពជាទាសៈទៅបួស និងតាំងនាមត្រកូលថា **កស្សបៈ** ប្រែថា **អណ្ដើក** ។ **អជិតកេសកម្ពល** ពាក្យថា **អជិតៈ** ជាឈ្មោះ **កេសកម្ពល** ជានាមត្រកូលរបស់គេ ។ ហេតុដែលកើតមាននាមត្រកូលថា **កេសកម្ពលនោះ** បានដល់ គេស្លៀកដណ្ដប់សំពត់ដែលត្បាញដោយសក់មនុស្ស ( **កេសៈ** ប្រែថា សក់, **កម្ពល** គឺសំពត់ដែលត្បាញដោយរោមសត្វ ) ។ **និគ្រន្ថនាដបុត្រ** ពាក្យថា **និគ្រន្ថ** ជាឈ្មោះរបស់លទ្ធិ មានសេចក្ដីថា មិនមានកិលេសដែលជាគ្រឿងចាក់ស្រេះ ដែលជាឧបាយអាក្រក់ ។ ពាក្យថា **នាដបុត្រ** ប្រែថា ជាបុត្ររបស់អ្នករបាំ ។ **បកុទ្ធកច្ចាយនៈ** ពាក្យថា **បកុទ្ធៈ** ជាឈ្មោះរបស់គេ ពាក្យថា **កច្ចាយនៈ** ជានាមត្រកូល ឬគោត្ររបស់គេ ។ **មក្ខលិគោសាល** ពាក្យថា **មក្ខលិ** ជាឈ្មោះ ពាក្យថា **គោសាល** ជានាមត្រកូល ។ ហេតុដែលមាននាមត្រកូលថា **គោសាល** នោះ ព្រោះគេកើតនៅក្នុងក្រោលគោ ឬរោងគោ គេជាទាសៈតាំងអំពីកំណើតមក

ម៉ែះ ថ្ងៃមួយ ត្រូវគេប្រើឲ្យទៅកាន់ផ្ទាំងប្រេង ដោយដើរមិនប្រយ័ត្ន រអិលជើង ក៏ដួលកំពប់ប្រេងអស់ ទើបគេវត់គេចទៅដោយខ្លាចម្ចាស់ទ្រព្យ តែម្ចាស់ទ្រព្យបានឃើញការរត់គេចរបស់គេ ទើបដេញចាប់យ៉ាងប្រផិតប្រភីង ក៏បានចាប់ប៉ះជាយសំពត់ ទើបធ្វើឲ្យសំពត់របូតចេញពីខ្លួន គេក៏បានវត់ទាំងមិនមានសំពត់ជាប់នឹងខ្លួន មានរាងកាយស្រាតនទល មិនមានសំពត់ដណ្ដប់ ដោយកាន់យកនូវភាពអាក្រាតកាយជាភេទអ្នកបួស ហើយតាំងខ្លួនគេជាសព្វញ្ញូ ។ សញ្ជ័យវេលដ្ឋ-បុត្រ ពាក្យថា **សញ្ជ័យ** ជាឈ្មោះ ។ ពាក្យថា **វេលដ្ឋបុត្រ** ជាឈ្មោះបិតារបស់គេ គឺគេជាបុត្ររបស់ជាងតម្បាញកន្ទេល កាលគេមកបួសជាអន្យតិរ្ថិយហើយ មានមនុស្សគោរពរាប់អានច្រើន ពួកកូនសិស្សមិនចង់ឲ្យមានឈ្មោះដូចអ្នកដទៃ ទើបយកឈ្មោះដើម និងឈ្មោះបិតាមករួមគ្នា ។ គណាចារ្យទាំង ៦ នាក់នេះ បានប្រកាសខ្លួនអះអាងជាសព្វញ្ញូ តែម្នាក់ៗ មានបរិវារ ៥០០ នាក់ ។ កាលបើត្រូវសភិយៈសួរបញ្ហា ២០ ខ.នោះ មិនមាននរណាឆ្លើយបានឡើយ ។

រឿងរបស់ព្រះសភិយត្ថេរ ក្នុងព្រះបាលីនៃ **សភិយសូត្រ** ក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** មានសម្ដែងតទៅទៀតថា ៖-

កាលបើសភិយបរិព្វាជក បានសាកសួរបញ្ហា នឹងគណាចារ្យម្ចាស់លទ្ធិទាំងនោះ ក៏មិនអាចមាននរណាឆ្លើយនៅក្នុងបញ្ហាទាំងអស់នោះបានឡើយ ទើបគេគិតថា ព្រះសមណគោតម ទ្រង់អាចដោះស្រាយបញ្ហានេះបានឬទេហ្ន៎ សូម្បីថា ព្រះសមណគោតមនៅក្មេងក៏ពិតមែន តែជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន យ៉ាងណាក៏ដោយ យើងគួរតែសាកល្បងសួរបញ្ហាទាំងអស់នេះមើល កាលគេគិតដូច្នេះហើយ ទើបធ្វើដំណើរទៅកាន់វត្តវេឡុវ័ន ដើម្បីចូលទៅគាល់ព្រះលោកនាយក ហើយក្រាបទូលថា ខ្ញុំព្រះអង្គមានសេចក្តីសង្ស័យបានចូលមករកព្រះអង្គ ដើម្បីទូលសួរបញ្ហា សូមព្រះអង្គទ្រង់ដោះស្រាយបញ្ហា ឲ្យខ្ញុំព្រះអង្គអស់ការសង្ស័យផងចុះ ។ គ្រានោះ ព្រះជិនស្រី ទ្រង់ត្រាស់តបដោយបដិសណ្ឋារៈជាបំណងល្អថា នែសភិយៈអ្នកធ្វើដំណើរមកអំពីផ្លូវឆ្ងាយ ដោយតាំងចិត្តនឹងសួរបញ្ហា តថាគតនឹងដោះស្រាយបញ្ហាឲ្យអ្នកអស់ការសង្ស័យបាន បើអ្នកមានសេចក្តីប៉ុនប៉ងប្រាថ្នាចង់សួរយ៉ាងណា ចូរសួរមកចុះ ? គ្រានោះ សភិយៈបានស្តាប់ព្រះពុទ្ធតម្រាស់ត្រាស់អនុញ្ញាតដូច្នេះហើយ គេគិតឡើងថានេះរាប់ថាជាការអស្ចារ្យក្រៃលែង ដែលយើងមិនធ្លាប់បានទទួលការ

អនុញ្ញាតយ៉ាងនេះសោះ ក្នុងសម្នាក់របស់សមណព្រាហ្មណ៍ពួកដទៃឡើយ ទើបតែនឹងមកបានទទួលការអនុញ្ញាតបែបនេះ ក្នុងសម្នាក់នៃព្រះសមណគោតមទៅវិញ កាលគេនឹកដល់ហេតុអស្ចារ្យ ដែលមិនអាចស្មានបាន ក៏ធ្វើឲ្យចិត្តគេរីករាយសប្បាយណាស់ ទើបក្រាបទូលសួរបញ្ហា ខ.ទី ១ ថា អ្នកប្រាជ្ញទាំងឡាយ ហៅអ្នកណាថា **ជាភិក្ខុ** ? ខ.ទី ២ ថា ភាពស្ងប់ស្ងៀម បានដល់ **ធម្មជាតិអ្វី** ? ខ.ទី ៣ ថា ការទូន្មាន បានដល់ **វត្ថុអ្វី** ? ខ.ទី ៤ ថា បុគ្គលដូចម្ដេច ដែលហៅថា **ជាព្រះពុទ្ធ** ? សូមព្រះសុគត ទ្រង់ត្រាស់ឆ្លើយបញ្ហានេះ ដល់ខ្ញុំព្រះអង្គផងចុះ ព្រះអង្គ ។

គ្រានោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់តបបញ្ហាទាំង ៤ ខ.នោះថា ចំពោះខ.ទី ១ **ភិក្ខុ** បានដល់ បុគ្គលមានតបៈដែលអប់រំបានល្អហើយ បុគ្គលណាបានសម្រេចនូវព្រះនិព្វាន បុគ្គលណាអស់នូវការសង្ស័យ បុគ្គលណាលះភពតូច-ធំបានហើយ បុគ្គលណាបានសម្រេចព្រហ្មចរិយធម៌ហើយ បុគ្គលណា មិនមានការកើតជាបន្តទៀត អ្នកប្រាជ្ញហៅបុគ្គលនោះថា **ជាភិក្ខុ** ។ ខ.ទី ២ **ភាពស្ងប់ស្ងៀម** បានដល់ ភាពព្រងើយ សំដៅដល់ការមានសតិក្នុងទី

ទាំងពួង ការមិនបៀតបៀនសត្វលោកទាំងពួង ការឆ្ងងលោក ការរំងាប់បាប ការមិនមួរហ្មង ការមិនមានកិលេសប៉ុនឡើង ទាំងនេះហៅថា **ភាពស្ងប់ស្ងៀម** ១.ទី ៣ **ការទូន្មាន** បានដល់ ការអប់រំឥន្ទ្រិយឲ្យស្អាតទាំងខាងក្នុង និងខាងក្រៅ រហូតដល់កើតការនឿយណាយលោកនេះ និងលោកខាងមុខ ទាំងនេះ ហៅថា ការទូន្មាន ។ ១.ទី ៤ **ព្រះពុទ្ធ** បានដល់ បុគ្គលអ្នកពិចារណាកប្បទាំងអស់ គឺបានសម្រេចបុព្វេនិវាសានុស្សតិញ្ញាណ គឺការរឭកដល់ជាតិមុនបាន សម្រេចចុតូបបាតិញ្ញាណ គឺការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ បានសម្រេចអាសវក្ខយញ្ញាណ គឺព្រះញាណដែលធ្វើអាសវៈឲ្យអស់ទៅសំដៅដល់អ្នកប្រាសចាកនូវធូលី អ្នកមិនមានទីទួល គឺកិលេស អ្នកដល់នូវការអស់ទៅនៃជាតិហើយ ទាំងនេះ ហៅថា **ជាព្រះពុទ្ធ** ។

គ្រានោះ សភិយបរិព្វាជក បានស្តាប់ព្រះពុទ្ធតម្រាស់ត្រាស់តបដូច្នេះហើយ ក៏កើតសេចក្តីជ្រះថ្លាត្រេកអរណាស់ ទើបក្រាបទូលសួរបញ្ហាតទៅទៀត ក្នុង១.ទី ៥ អ្នកបដិបត្តិយ៉ាងណា ហៅថា **ជាព្រាហ្មណ៍** ? ១.ទី ៦ ថា បុគ្គលដូចម្តេចហៅថា **សមណៈ** ? ១.ទី ៧ បុគ្គលដូចម្តេចហៅថា **អ្នកលាងបាបហើយ** ? ១.ទី ៨ ថា បុគ្គល

ដូចម្ដេចហៅថា **នាគ** ? ហេតុដូច្នេះ សូមព្រះអង្គជាសក្កៈ ទ្រង់ដោះស្រាយបញ្ហានេះដល់ខ្ញុំព្រះអង្គផង ។ លំដាប់នោះ ព្រះពុទ្ធអង្គត្រាស់តបបញ្ហាក្នុង ខ.ទី ៥ ថា ដែលហៅថា **ជាព្រាហ្មណ៍** នោះ គឺបុគ្គលដែលបានបន្សាត់បាបចោលហើយ អ្នកប្រាសចាកមន្ទិល អ្នកមានចិត្តតាំងមាំល្អ អ្នកតម្កល់ខ្លួនទុកដោយល្អហើយ អ្នកឆ្លងសង្សារ អ្នកសម្រេចគុណធម៌ អ្នកមិនមានតណ្ហា-ទិដ្ឋិ អ្នកមានចិត្តតម្កល់ស្មើហើយ ទាំងនេះ ហៅថា **ជាព្រាហ្មណ៍** ។ ខ.ទី ៦ ដែលហៅថា **សមណៈ** គឺអ្នកដែលមានសេចក្ដីស្ងប់ ព្រោះលះបាបបានហើយ អ្នកប្រាសចាកនូវធូលី ព្រោះដឹងលោកនេះ និងលោកដទៃ អ្នកឆ្លងផុតអំពីសេចក្ដីស្លាប់បានហើយ អ្នកមានចិត្តស្មើហើយ ទាំងនេះ ហៅថា **សមណៈ** ។ ខ.ទី ៧ ដែលហៅថា **អ្នកលាងបាប** គឺអ្នកលាងបាបទាំងពួងអស់ហើយ អ្នកមិនមានតណ្ហា មានះ ទិដ្ឋិ ខាងក្នុង និងខាងក្រៅ ទាំងនេះ ហៅថា អ្នកលាងបាប ។ ខ.ទី ៨ ដែលហៅថា **នាគ** គឺអ្នកមិនមានសេចក្ដីអាក្រក់ណាទីមួយ ក្នុងលោកនេះនៅសេសសល់ អ្នកលះបង់គ្រឿងគោងបានហើយ អ្នកមិនជាប់ជំពាក់ ក្នុងទីទាំងពួង អ្នកផុតស្រឡះចាកវត្ថុទាំងពួងហើយ និងជាអ្នកមាន ចិត្តស្មើហើយ ( នាគ

បានដល់ អ្នកមិនធ្វើអំពើអាក្រក់ ) ទាំងនេះ ហៅថា **នាគ** ។

កាលសភិយបរិព្វាជក បានស្ដាប់នូវការបកស្រាយយ៉ាងដូច្នេះហើយ ក៏កើតសេចក្ដីជ្រះថ្លាត្រេកអររីករាយណាស់ ទើបក្រាបទូលសួរបញ្ហាខ.ទី ៩ ជាបន្ដទៅទៀតថា អ្នកប្រាជ្ញទាំងឡាយ ពោលថា **នរណាឈ្មោះខេត្ត** ? ខ.ទី ១០ ថា នរណាហៅថា **អ្នកឆ្លាត** ? ខ.ទី ១១ ថា នរណាហៅថា **បណ្ឌិត** ? ខ.ទី ១២ ថា នរណាហៅថា **មុនី** ? ហេតុដូច្នេះ សូមព្រះសុគត ទ្រង់ត្រាស់បកស្រាយក្នុងបញ្ហាទាំងនេះ ឲ្យខ្ញុំព្រះអង្គបានជ្រាបផង ។ ព្រះលោកនាថ ទ្រង់ត្រាស់ដោះស្រាយខ.ទី ៩ ថា **អ្នកឈ្មោះខេត្ត** គឺអ្នកពិចារណាខេត្តទាំងអស់បានដល់ មនុស្សលោក ទេវលោក ព្រហ្មលោក ជាអ្នករួចផុតពីគ្រឿងចង គឺអវិជ្ជា និងរួចផុតពីកវតណ្ហាជាដើម ដែលជាឫសកែវនៃខេត្ត ហើយមានចិត្តស្មើ ទាំងនេះ ហៅថា អ្នកឈ្មោះខេត្ត ។ មួយទៀត ពាក្យថា **ខេត្ត** បានដល់អាយតនៈទាំងអស់ ដែលមាននៅក្នុងលោកទាំង ៣ ដោយពិចារណាឲ្យឃើញថា ជាអនិច្ចំ ជាទុក្ខំ ជាអនត្តា តែអាចារ្យពួកខ្លះពោលថា ពាក្យថា **ខេត្ត** គឺកម្ម ដូចមានបាលីថា **កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ** ប្រែថា កម្ម

ជាខេត្ត គឺទីព្រោះ វិញ្ញាណជាពូជ សម្រាប់ព្រោះដាំ តណ្ហាជាជ័រ ដែលនៅក្នុងពូជ ព្រោះដូច្នោះ ពាក្យថា ខេត្តដែលមាននៅក្នុងលោក ទាំង ៣ សំដៅដល់កម្ម ដែលនាំឲ្យកើតជាមនុស្ស ទេវតា ព្រហ្មដូច្នេះ ឯង ។ ខ.ទី ១០ **អ្នកច្ចាត** គឺបុគ្គលអ្នកដែលពិចារណា ឃើញចំណែក ទាំងអស់ ដែលមាននៅក្នុងមនុស្សលោក ទេវលោក ព្រហ្មលោក ហើយរួចផុតពីគ្រឿងចងទាំងនោះ ដែលជាឫសកែវ របស់ចំណែក ទាំងអស់ ទាំងនេះ ហៅថា អ្នកច្ចាត ។ ខ.ទី ១១ **បណ្ឌិត** គឺអ្នក ពិចារណាអាយតនៈខាងក្នុង និងខាងក្រៅល្អិតល្អន់ ហើយមានបញ្ញា បរិសុទ្ធ ឆ្លងផុតធម៌ខ្មៅ ( បាប ) និងធម៌ស ( បុណ្យ ) បានហើយ ទាំងនេះ ហៅថា **បណ្ឌិត** ។ ខ.ទី ១២ **មុនី** គឺអ្នកដឹងធម៌ របស់ សប្បុរស និងរបស់អសប្បុរស ហើយជាទីបូជារបស់ទេវតា និង មនុស្សទាំងឡាយ ជាអ្នកឆ្លងសំណាញ់ គឺតណ្ហា និងទិដ្ឋិ ដែលជា គ្រឿងជាប់ជំពាក់ ទាំងនេះ ហៅថា **មុនី** ។

កាលសភិយបរិព្វាជក បានស្តាប់ព្រះពុទ្ធាធិប្បាយតបដូច្នេះ ហើយ ក៏កើតសេចក្តីសោមនស្សរីករាយ ទើបក្រាបទូលសួរបញ្ហា ខ.ទី ១៣ ជាបន្តទៀតថា បុគ្គលយ៉ាងណា ហៅថា ***វេទគូ*** គឺអ្នក

សម្រេចការដឹង ? ១.ទី ១៤ ថា បុគ្គលយ៉ាងណាដែលហៅថា **អ្នកតាមដឹង** ? ១.ទី ១៥ បុគ្គលយ៉ាងណា ហៅថា **អ្នកមានវីរិយៈ** ? ១.ទី ១៦ ថា បុគ្គលយ៉ាងណា ហៅថា **អាជានេយ្យ** ? ហេតុដូច្នេះ សូមព្រះបរមគ្រូ ទ្រង់ព្រះករុណាដោះស្រាយ ឲ្យខ្ញុំព្រះអង្គបានជ្រាបផង ។ ព្រះមានព្រះភាគ បានត្រាស់តបក្នុងបញ្ហា១.ទី ១៣ ដូច្នេះថា ដែលហៅថា **វេទគូ** អ្នកសម្រេចការដឹងនោះ បានដល់ បុគ្គលអ្នកពិចារណាការដឹងទាំងឡាយ ហើយប្រាសចាកសេចក្តីត្រេកអរនៅក្នុងវេទនាទាំងឡាយ ដែលមានចំពោះសមណព្រាហ្មណ៍ទាំងឡាយ អ្នកកន្លងការដឹងទាំងអស់ ទាំងនេះ ហៅថា **វេទគូ** ។ ១.ទី ១៤ ដែលហៅថា **អ្នកតាមដឹង** គឺអ្នកពិចារណាធម៌ ដែលជាគ្រឿងយឹតយូរ បានដល់ តណ្ហា មានះ ទិដ្ឋិ និងនាមរូបដែលជាឫសកែវរបស់លោកទាំងពួង ទាំងខាងក្នុង និងខាងក្រៅ រួចផុតស្រឡះចាកពីគ្រឿងចងដែលជាឫសកែវរបស់លោកហើយ ទាំងនេះ ហៅថា **អ្នកតាមដឹង** ។ ១.ទី ១៥ ដែលហៅថា **អ្នកមានវីរិយៈ** គឺអ្នកមានព្យាយាមវៀរចាកបាបទាំងពួង អ្នកកន្លងទុក្ខក្នុងនរកបាន អ្នកមានការតាំងចិត្តធ្វើ មានភាពក្លៀវក្លា មានសេចក្តីត្រេកអរ ទាំងនេះ ហៅថា **អ្នកមានវីរិយៈ** ។

ខ.ទី ១៦ ដែលហៅថា **អាជានេយ្យ** គឺអ្នកកាត់គ្រឿងចងបានហើយ បានដល់ អវិជ្ជា និងភវតណ្ហាជាដើម ដែលជាឫសកែវនៃគ្រឿងជាប់ជំពាក់ទាំងពួង ទាំងនេះ ហៅថា **អាជានេយ្យ** ។

កាលបើសភិយបរិព្វាជក បានស្តាប់ពុទ្ធព្យាករណ៍ដោះស្រាយបញ្ហាដូច្នេះហើយ ក៏មានចិត្តដូរផង់ត្រេកអរក្រៃលែង បានក្រាបទូលសួរបញ្ហាខ.ទី ១៧ ជាបន្តទៅទៀតថា បុគ្គលយ៉ាងណា ហៅថា **អ្នកស្តាប់ទទួលស្តាប់** ? ខ.ទី ១៨ ថា បុគ្គលយ៉ាងណាហៅថា **អរិយៈ** ? ខ.ទី ១៩ ថា ចរណៈ បានដល់ **អំពើអ្វី** ? ខ.ទី ២០ ថា បុគ្គលយ៉ាងណា ហៅថា **បរិព្វាជក** ? ហេតុដូច្នេះ សូមព្រះអង្គទ្រង់ព្រះករុណាត្រាស់ឆ្លើយឲ្យខ្ញុំព្រះអង្គ បានជ្រាបផង ។ គ្រានោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់ឆ្លើយបញ្ហានៅក្នុងខ.ទី ១៧ នោះថា ដែលហៅថា **អ្នកស្តាប់ទទួលស្តាប់** បានដល់ បុគ្គលអ្នកដឹងធម៌ទាំងពួងនៅក្នុងលោកហើយ គ្របដណ្តប់វត្ថុដែលមានទោស និងមិនមានទោស មិនមានសេចក្តីសង្ស័យ មានការរួចផុត មិនមានការលំបាកចិត្តក្នុងទីទាំងពួង ទាំងនេះ ហៅថា **អ្នកស្តាប់ ទទួលស្តាប់** ។ ខ.ទី ១៨ ដែលហៅថា **អរិយៈ** គឺបុគ្គលអ្នកកាត់សេចក្តីអាល័យនៅក្នុងទីទាំងពួងហើយ ដឹង

អាសវក្កិលេសទាំងឡាយ មិនកើតទៀតឡើយ កម្ចាត់សញ្ញា ៣ យ៉ាង បានដល់ ១- ការយកចិត្តទុកដាក់ក្នុងកាមារម្មណ៍ ២- ការយកចិត្តទុកដាក់ ចង់មាន ចង់រស់ ៣- ការយកចិត្តទុកដាក់ ការមិនចង់មាន មិនចង់រស់ កម្ចាត់កក់ គឺកាមគុណបានហើយ មិនធ្លាក់ទៅក្នុងអំណាចនៃតណ្ហា គឺការកន្លល់ចង់បាន ទាំងនេះ ហៅថា **អរិយៈ** ។ ខ.ទី ១៩ ដែលហៅថា **ចរណៈ** គឺការដល់នូវធម៌ ដែលគួរដល់ក្នុងខណៈទាំងឡាយ បានដល់ ការប្រព្រឹត្តទាំងឡាយ មានសីលជាដើម ការឆ្លាតក្នុងធម៌សព្វកាល ការមិនជាប់នៅក្នុងធម៌ទាំងពួង ការមានចិត្តរួចផុត មិនមានការអាក់អន់ចិត្ត ( ចរណៈ ដោយសេចក្តីថា បដិបទាដែលជាគ្រឿងសម្រេចវិជ្ជា មាន ១៥ ខ. មានសីលសំវរៈ គឺសង្រួមនៅក្នុងសីលជាដើម មានចតុត្ថជ្ឈានជាទីបំផុត ) ទាំងនេះ ហៅថា **ចរណៈ** ។ ខ.ទី ២០ ដែលហៅថា **បរិញ្ញជក** គឺអ្នកវៀរចាកកម្មដែលឲ្យកើតទុក្ខទាំងពួង ទាំងដែលមាននៅខាងក្រោម ខាងលើ ខាងទទឹង និងត្រង់កណ្តាល ហើយនៅដោយការចេះដឹងជ្រៅជ្រះ និងកម្ចាត់មាយា មានះ ទោសៈ កោធៈបានហើយ និងធ្វើនាមរូបឲ្យអស់ទៅ ទាំងនេះ ហៅថា **បរិញ្ញជក** ។

កាលដែលព្រះលោកវិទូ ទ្រង់បានដោះស្រាយបញ្ហាទាំង ២០ ១.ចប់ហើយ សកិយបរិញ្វាជក បានសម្តែងការកោតសរសើរត្រេកអរជាទីបំផុត ទើបក្រោកឡើង ធ្វើសំពត់ឆៀងស្មាម្ខាង ថ្វាយបង្គំព្រះសយម្ភូ ហើយពោលសរសើរព្រះកគរវាថា បពិត្រព្រះអង្គ ទ្រង់មានបញ្ញាញាណ ព្រះអង្គទ្រង់កម្ចាត់នូវទិដ្ឋិ ៦២ ចេញបានហើយ ដែលជាទិដ្ឋិនៃសមណព្រាហ្មណ៍ខាងក្រៅ ដែលធ្លាប់ចងចាំតគ្នាមក ( ទិដ្ឋិ ៦២ ១.នោះ ជាលទ្ធិ និងមាននៅក្នុងគម្ពីររបស់ពួកអន្យតិរ្ថិយ បានធ្វើឲ្យពួកអ្នកល្ងង់ខ្លៅ កើតការយល់ខុសទៅតាមទិដ្ឋិទាំង ៦២ នោះ) ព្រះពុទ្ធអង្គទ្រង់ជាអ្នកដល់នូវទីបំផុតនៃទុក្ខ ទ្រង់ជាអ្នកឆ្លងប្រាំងនៃទុក្ខបានហើយ ខ្ញុំព្រះអង្គយល់ថា ព្រះអង្គជាព្រះអរហន្ត ទ្រង់អស់នូវអាសវក្កិលេសហើយ ព្រះអង្គជាអ្នករុងរឿង ទ្រង់មានសេចក្តីត្រេកអរ ទ្រង់ជាអ្នកមានបញ្ញាច្រើន បានធ្វើឲ្យខ្ញុំព្រះអង្គអស់នូវទុក្ខហើយ ពីព្រោះព្រះអង្គបានដោះស្រាយការសង្ស័យ របស់ខ្ញុំព្រះអង្គឲ្យអស់ទៅហើយ ខ្ញុំព្រះអង្គសូមគោរពនមស្ការ ព្រះអង្គជាលោកនាថ ព្រះអង្គទ្រង់ដល់នូវចំណែក ដែលគួរដល់ក្នុងផ្លូវរបស់មុនី ទ្រង់មិនមានដែកគោល គឺកិលេស ទ្រង់ជាផៅពង្សនៃព្រះអាទិត្យ ទ្រង់ជាអ្នកត្រេកអរ

ក្នុងធម៌ទាំងពួង ។ ការសង្ស័យណា របស់ខ្ញុំព្រះអង្គ ដែលមានមក ហើយក្នុងកាលមុន ព្រះអង្គទ្រង់មានចក្ខុ ទ្រង់បានដោះស្រាយការ សង្ស័យរបស់ខ្ញុំព្រះអង្គហើយ ព្រះអង្គត្រូវតែជាមុនី ទ្រង់ជាមុនី ទ្រង់ ជាព្រះសម្មាសម្ពុទ្ធ ដោយពិតប្រាកដមែន ទ្រង់មិនមាននីវរណៈ ៥ ទ្រង់ជាអ្នកឆ្លងគ្រឿងចង្អៀតចង្អល់ចិត្តបានហើយ ទ្រង់ជាអ្នកប្រាស ចាកឈើបបុស ( ឈើបបុស ជាឈើក្រទើតក្រទម ) គឺមានះ ទ្រង់ ជាអ្នកត្រជាក់ ទ្រង់សម្រេចការហ្វឹកហាត់ហើយ ទ្រង់ជាអ្នកមានការ គិតល្អ ទ្រង់ជាអ្នកតាំងមាំក្នុងសច្ចៈ ទេវតាទាំងឡាយ ដែលអាស្រ័យ នៅក្នុំឈ្មោះថា **នារទៈ** ទាំងពួង រហូតដល់ទេវៈ ដែលអាស្រ័យ នៅក្នុងអាកាស និងភពផែនដី រមែងសរសើរត្រេកអរ ចំពោះពាក្យ ប្រៀនប្រដៅរបស់ព្រះអង្គ ទ្រង់មានភាពក្លាហាន ។

បពិត្រព្រះអង្គ ទ្រង់ជាបុរសអាជានេយ្យ ទ្រង់ជាបុរសដ៏ខ្ពង់ ខ្ពស់បំផុត ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ មិនមានបុគ្គលណា ក្នុងលោក ព្រមទាំងទេវលោក ព្រហ្មលោក ប្រៀបនឹងព្រះអង្គបាន ឡើយ ព្រះអង្គជាព្រះពុទ្ធ ទ្រង់ជាព្រះសាស្តា ទ្រង់ជាអ្នកគ្របសង្កត់ មារ ទ្រង់ជាអ្នកកាត់ផ្តាច់នូវកិលេស ដែលប្រចាំនៅក្នុងសន្តានចិត្តទាំង

អស់បានហើយ ទ្រង់ឆ្លងលោកបានហើយ ទ្រង់ធ្វើឲ្យពួកសត្វឆ្លងលោកបានហើយ ព្រះអង្គជាអ្នកឆ្លងបញ្ចក្ខន្ធបានហើយ ទ្រង់ទម្លាយអាសវៈបានដោយដាច់ខាត ទ្រង់មិនជាប់នៅក្នុងបុណ្យ និងបាប ដូចគ្នានឹងស្លឹកឈូកដែលមិនជាប់ទឹកដូច្នោះដែរ ។ បពិត្រព្រះអង្គ ទ្រង់និរទុក្ខ ទ្រង់មានភាពក្លៀវក្លា សូមព្រះអង្គសណ្ដូកព្រះបាទចេញមក ដើម្បីឲ្យខ្ញុំព្រះអង្គ បានគោរពនមស្ការផងចុះ ។ កាលបើសភិយបរិព្វាជកពោលដូច្នេះហើយ ក៏បង្អោនកាយចុះទៅទៀបព្រះយុគលបាទ របស់ព្រះមហាវីរៈ ដោយក្រាបទូលសរសើរព្រះធម៌ទេសនាថា បពិត្រព្រះមានជោគ ការសម្ដែងព្រះធម៌របស់ព្រះអង្គនេះ គួរឲ្យត្រេកអរណាស់ ដូចបុរសផ្ងាររបស់ដែលផ្កាប់ ឬបើករបស់ដែលផ្កាប់ ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ទ្រោលប្រទីបក្នុងទីងងឹត ដោយបំណងថា ចូរឲ្យអ្នកមានភ្នែកល្អឃើញវត្ថុផ្សេងៗ យ៉ាងណាមិញ ព្រះពុទ្ធអង្គទ្រង់បានប្រកាសព្រះធម៌ទេសនា ដោយអនេកបរិយាយនេះ ដើម្បីឲ្យជាប្រយោជន៍ដល់អ្នកស្ដាប់ទាំងឡាយដូច្នោះដែរ ខ្ញុំព្រះអង្គសូមគោរពនមស្ការចំពោះព្រះមានជោគ ព្រមទាំងព្រះធម៌ និងព្រះសង្ឃ ដែលជាទីពឹងរបស់ពុទ្ធបរិស័ទក្នុងលោកនេះ ខ្ញុំព្រះអង្គសូមបព្វជ្ជាឧបសម្បទានៅក្នុងព្រះ

ពុទ្ធសាសនានេះផង ។

គ្រានោះ ព្រះភគវាទ្រង់ត្រាស់ថា ម្នាលសភិយៈ អន្យតិត្ថិយណា មានបំណងនឹងបព្វជ្ជាឧបសម្បទា ក្នុងធម្មវិន័យនេះ អន្យតិត្ថិយនោះ ត្រូវនៅអប់រំមុន ៤ ខែសិន កាលបើគ្រប់ ៤ ខែហើយ ភិក្ខុទាំងឡាយឃើញថា ល្អប្រពៃហើយនោះ ទើបឲ្យបព្វជ្ជាឧបសម្បទាដល់អ្នកនោះបាន តែតថាគតនឹងដឹងការផ្សេងដោយឡែកអំពីគ្នា នៃបុគ្គលទាំងនោះយ៉ាងនេះឯង ។ ការផ្សេងដោយឡែកអំពីគ្នានៃបុគ្គលតាមដែលព្រះមុនីទ្រង់ត្រាស់នេះ ព្រះអដ្ឋកថាចារ្យបានអធិប្បាយទុកថា បរិព្វាជកខ្លះ ត្រូវនៅអប់រំ ៤ ខែជាមុនសិន ដើម្បីសាកល្បងមើលសទ្ធា និងភាពស្មោះត្រង់ ចំណែកបុគ្គលខ្លះ មិនត្រូវនៅអប់រំទេ ពីព្រោះបុគ្គលនោះ ជាអ្នកមានបុណ្យបារមី ដែលបានសន្សំរួចមកហើយ ដែលអាចទម្លាយកិលេសបាន ជាអ្នកមិនជាប់ជំពាក់ ដូចគ្នានឹងស្លឹកឈូក ដែលមិនជាប់ទឹកដូច្នោះដែរ ដូចពួកជដិលដែលមានឈ្មោះថា ឧរុវេលកស្សបៈជាដើម ដែលបុគ្គលទាំងនោះ មានហេតុគ្រប់គ្រាន់អាចសម្រេចមគ្គផលបាន ។ លុះសភិយបរិព្វាជក បានស្តាប់ព្រះពុទ្ធតម្រាស់យ៉ាងនេះហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏

ចម្រើន កុំថាឡើយ ៤ ខែ សូម្បី ៤ ឆ្នាំ ក៏ខ្ញុំព្រះអង្គនៅដែរ ឲ្យតែបានបព្វជ្ជាឧបសម្បទា ព្រះអង្គ ។ កាលសភិយបរិព្វាជក បានក្រាបទូលដូច្នេះហើយ ដោយលោកមាននូវសេចក្តីព្យាយាម និងមានភាពអត់ធន់យ៉ាងស្មោះត្រង់ ទាំងជាអ្នកសម្បូណ៌ទៅដោយ ហេតុបច្ច័យឧបនិស្ស័យ ដែលអាចសម្រេចមគ្គផលបាន ទើបព្រះអង្គទ្រង់ត្រាស់អនុញ្ញាតឲ្យបព្វជ្ជាឧបសម្បទា ក្នុងសម្នាក់ព្រះមានជោគ ក្នុងពេលនោះឯង ឲ្យសមតាមសេចក្តីប្រាថ្នារបស់លោក ដោយមិនត្រូវនៅអប់រំ ៤ ខែ ឬ ៤ ឆ្នាំជាមុនសិនទេ ។ កាលព្រះសភិយត្ថេរ ឧបសម្បទាជាភិក្ខុហើយ បានសិក្សាព្រះធម៌វិន័យ ល្មមអាចនាំយកទៅប្រព្រឹត្តបដិបត្តិបានហើយ លោកក៏គេចទៅនៅតែម្នាក់ឯង ជាអ្នកមិនមានសេចក្តីប្រមាទ ជាអ្នកមានសេចក្តីព្យាយាម មានចិត្តតាំងមាំចំពោះមគ្គផល តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏បានសម្រេចនូវទីបំផុតនៃព្រហ្មចរិយធម៌ គឺបានជាព្រះអរហន្ត ដែលជាទីត្រូវការរបស់កុលបុត្រទាំងឡាយ ដែលចូលមកបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនានេះ ហើយក៏ដឹងថា អស់ការកើត ព្រោះជាអ្នកបានសម្រេចកិច្ចនៃព្រហ្មចរិយធម៌នេះ ទាំងបានដឹងថា វត្ថុណាដែលគួរធ្វើ

វត្ថុណា ដែលមិនគួរធ្វើ មិនមានកិច្ចដទៃដែលនឹងត្រូវធ្វើ ដើម្បីការកើតជាបន្តទៅទៀត ក្នុងភពថ្មីនោះទេ ។

ផលបុណ្យរបស់ព្រះសកិយៈ មានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** កាលលោកបានសម្រេចជាព្រះអរហន្តហើយ លោកបានពោលប្រៀនប្រដៅពួកព្រះទេវទត្ត ដែលព្យាយាម នឹងធ្វើសង្ឃភេទ គឺបំបែកសង្ឃ ឲ្យបែកគ្នាជាពួក ដោយលោកពោលជាគាថា ៤ គាថា ដូចមានសេចក្តីថា ៖-

*ពាលជនទាំងឡាយ រមែងមិនដឹងថា យើងទាំងឡាយ នឹងវិនាស ក្នុងកណ្តាលនៃពួកនេះ ដូច្នេះឡើយ ចំណែកឯជនទាំងឡាយណា ជាបណ្ឌិតក្នុងពួកនោះ រមែងដឹងច្បាស់ ឯការឈ្លោះប្រកែកតែងស្ងប់រំងាប់អំពីសម្នាក់នៃជនទាំងឡាយ ជាបណ្ឌិតនោះ ។ កាលណា បើជនទាំងឡាយមិនដឹង ( នូវឧបាយនៃការស្ងប់រំងាប់នៃវិវាទ ) រមែងប្រព្រឹត្តទៅ ហាក់ដូចជាមិនស្លាប់ ( កាលនោះ វិវាទក៏មិនស្ងប់រំងាប់ឡើយ ) ចំណែកជនទាំងឡាយណា ដឹងច្បាស់ធម៌ ( ជនទាំងឡាយនោះ ) កាលបើពួកសត្វ មានសេចក្តីក្តៅក្រហាយ ខ្លួនជាអ្នកមិនមានសេចក្តីក្តៅក្រហាយឡើយ ។ កម្មណាមួយធូរថយក្តី វត្តណា*

មួយសៅហ្មងក្តី ព្រហ្មចរិយធម៌ណាមួយ ដែលបុគ្គលរឭក ដោយសេចក្តីរង្កៀសក្តី កម្ម ៣ យ៉ាងនោះ ជារបស់មិនមានផលច្រើនឡើយ ។ បុគ្គលណាមិនមានសេចក្តីគោរព ក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ( បុគ្គលនោះ ) រមែងជាអ្នកឆ្ងាយចាកព្រះសទ្ធម្ម ដូចជាមេឃឆ្ងាយអំពីផែនដី ៕

( ជីវប្រវត្តិរបស់ព្រះសកិយត្ថេរ ចប់ )

## ជីវប្រវត្តិរបស់ព្រះសេលត្ថេរ

### “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះសេលត្ថេរ ជាព្រះថេរៈមួយរូប ដែលជាអ្នកមានបរិវារច្រើន ពេលដែលលោកចេញបួស គឺចេញបួសព្រមជាមួយនឹងបរិវារ

ក្នុងពេលតែមួយព្រមគ្នា ក្រៅអំពីនោះ លោកបានទទួលនូវកិត្តិយស អំពីព្រះលោកនាថ ដោយសង្គ្រោះលោកចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវក បានដល់ សាវកធំរបស់ព្រះលោកនាយក ៨០ រូប ។ ជីវប្រវត្តិរបស់ព្រះសោណៈ មានរឿងសម្តែងគួរឲ្យចាប់អារម្មណ៍ទៀតផង ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះសោណត្ថេរ ដូចមានសម្តែងទុកក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** មានន័យថា ៖-

ព្រះសោណត្ថេរ លោកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅនិគមមួយ ឈ្មោះថា **អាបណៈ** ដែលស្ថិតនៅក្នុងចន្លោះដែន **អង្គៈ** និងដែន **ឧត្តរាបៈ** លោកមានឈ្មោះថា **សោណៈ** ក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** បានពោលថា បិតារបស់លោកមានឈ្មោះថា **វាសេដ្ឋៈ** ។ ការសិក្សាវិជ្ជាជាលើកដំបូងរបស់សោណមាណពនោះ បានដល់ ការសិក្សាវិជ្ជាត្រៃវេទ តាមវង្សត្រកូលរបស់ព្រាហ្មណ៍ រហូតដល់បានសម្រេចតាមបំណងរបស់ខ្លួន ព្រមទាំងបានសិក្សាវិជ្ជាដទៃៗ ជាច្រើន

ហើយតមក បានជាអាចារ្យបង្រៀនដល់ពួកមាណព ៣០០ នាក់ នៅក្នុង **អាបណនិគម** នោះឯង ។

ចំណែកក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត មហាវគ្គទី ៣** នៃ **សេលសូត្រ** និងនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** នៃ **សេលសូត្រ** ដូចមានរឿងតំណាលថា ៖-

សេលព្រាហ្មណ៍ អាស្រ័យនៅក្នុងអាបណនិគម ជាអ្នករៀនចប់វិជ្ជាត្រៃវេទ ទាំងបានជាអាចារ្យបង្រៀនដល់មាណព ដែលជាកូនសិស្ស ៣០០ នាក់ ។

តពីនេះទៅ នឹងពោលដល់ហេតុ ដែលសេលព្រាហ្មណ៍ បានជ្រាបដំណឹងថា ព្រះពុទ្ធអង្គទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ក៏មានសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រហូតដល់ព្រមលះបង់លទ្ធិរបស់ព្រាហ្មណ៍ ចូលមកបួសក្នុងព្រះសាសនានេះ ដូចមានសេចក្ដីថា ៖-

សម័យមួយ ព្រះមានព្រះភាគ ទ្រង់បានចារិកទៅកាន់ជនបទដែលមានឈ្មោះថា ឧត្តរាបៈ ព្រមដោយភិក្ខុសង្ឃប្រមាណ ១២៥០ រូប ស្ដេចបានទៅដល់និគមនៃអ្នកស្រុកអង្គុត្តរាបៈ ដែលមានឈ្មោះថា **អាបណៈ** ។ កេណិយជដិល ( **ក្នុងអដ្ឋកថាបបញ្ចសូទនី** ដែល

ជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៅក្នុងសេលសូត្រ បានពោលដល់ ដំណើរជីវិតរបស់លោកទុកថា **កេណិយជដិល** ឬ **កេណិយតាបស** កាលពីដើមជាព្រាហ្មណ៍មហាសាល មានទ្រព្យសម្បត្តិជាច្រើន តែ បានសមាទានភេទជាតាបស ដើម្បីរក្សាទ្រព្យរបស់ខ្លួនទុក ហើយបាន ថ្វាយគ្រឿងបណ្ណាការដល់ព្រះរាជា និងសូមព្រះរាជទានស្ថានទីមួយ កន្លែងដើម្បីកសាងអាស្រម ប៉ុន្តែសូម្បីបួសជាតាបសហើយក៏ដោយ ក៏នៅតែលក់ដូរទៅដោយរទេះប្រាំរយៗ ។ ហើយកន្លែងអាស្រមនោះ បានជាទីអាស្រ័យរបស់ត្រកូលមួយពាន់ត្រកូល ដែលមានលំនៅក្នុង អាបណនិគមនោះ រីឯកេណិយជដិលបានស្លៀកដណ្តប់សំពត់ ដែល ជ្រលក់ដោយទឹកអម្ចត់ បួងសក់ជាជដិល សោយកាមសម្បត្តិ ក្នុង ពេលរាត្រី ។ កាលកេណិយជដិល បានជ្រាបដំណឹងមកថា ព្រះ សមណគោតមជាសក្យបុត្រ ស្តេចចេញសាងព្រះផ្នួសពីសក្យត្រកូល ទ្រង់បានចារិកទៅនៅក្នុងឧត្តរាបជនបទ ព្រមដោយភិក្ខុសង្ឃប្រមាណ ១២៥០ រូប ទ្រង់យាងមកដល់អាបណនិគមតាមលំដាប់ កិត្តិស័ព្ទដ៏ ល្បីល្បាញ របស់ព្រះសមណគោតម ព្រះអង្គនោះ ខ្ចរខ្ចាយទៅថា **ឥតិបិ សោ ភគវា ។ល។** មានសេចក្តីថា សូម្បីដោយហេតុនេះ

ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ជាព្រះអរហន្ត ទ្រង់រឹកកាយហើយ ទ្រង់ចែកធម៌ ទ្រង់ធ្វើលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោកឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ប្រពៃរបស់ព្រះអង្គ ទ្រង់ដឹកនាំសព្វសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្សឲ្យដឹងតាមព្រះអង្គ ព្រះអង្គទ្រង់សម្តែងធម៌ មានលម្អបទដើម បទកណ្តាល និងបទចុង ព្រមទាំងអត្ថ និងព្យញ្ជនៈ ទ្រង់ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធបរិបូណ៌ គ្មានសេសសល់ ការបានឃើញព្រះអរហន្តទាំងឡាយ ដែលជាអ្នកទ្រទ្រង់នូវគុណដូច្នេះ ជាការប្រពៃណាស់ ។

កាលកេណិយជដិល បានជ្រាបច្បាស់លាស់ថា ព្រះជិនស្រីស្តេចយាងមកដល់ហើយ ទើបចូលទៅគាល់ សម្តែងការសរសើរត្រេកអរ បានប្រាស្រ័យជាមួយនឹងព្រះសម្ពុទ្ធ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះលោកនាយក ទ្រង់បានចង្អុលបង្ហាញឲ្យកេណិយជដិលយល់ច្បាស់ ឲ្យអាចសមាទាន ឲ្យរីករាយ ដោយធម្មីកថានេះហើយ ។ ពេលនោះ កេណិយជដិលបានស្តាប់ធម្មកថារបស់ព្រះលោកនាថ ដែលទ្រង់ចង្អុលបង្ហាញឲ្យយល់ច្បាស់ ឲ្យអាចសមាទាន ឲ្យរីករាយ ដោយធម្មីកថានោះហើយ ទើបក្រាបទូលឡើង

ថា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃនិមន្តទទួលចង្ហាន់ ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះផង នៅឯអាស្រមរបស់ខ្ញុំព្រះអង្គឯណោះ ។ គ្រានោះ ព្រះភគវាត្រាស់តបថា ម្នាលកេណិយៈ ភិក្ខុសង្ឃមានច្រើនណាស់ ប្រមាណ ១២៥០ រូប ( អ្នកនឹងនិមន្តទាំងអស់ឬ ) ទាំងអ្នកក៏ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ដែរ ។ គ្រានោះ កេណិយជដិល ទើបក្រាបទូលឡើង ជាគម្រប់ពីរដងទៀតថា បពិត្រព្រះគោតមដ៏ចម្រើន សូម្បីភិក្ខុសង្ឃមានចំនួន ១២៥០ រូបក៏ដោយ ឬសូម្បីខ្ញុំព្រះអង្គធ្លាប់មានសេចក្តីជ្រះថ្លា នៅក្នុងពពួកព្រាហ្មណ៍ក៏ដោយ សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃទទួលចង្ហាន់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ពេលនោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់នឹងកេណិយជដិល ជាលើកទីពីរទៀតថា នែកេណិយៈ ភិក្ខុសង្ឃមានប្រមាណ ១២៥០ រូប ទាំងខ្លួនអ្នកក៏ធ្លាប់ជ្រះថ្លា ក្នុងពពួកព្រាហ្មណ៍មកអំពីមុនហើយ ។ គ្រានោះ កេណិយៈ ទើបបានក្រាបទូលអារាធនាឡើងទៀត ជាគម្រប់បីដងថា បពិត្រព្រះគោតមដ៏ចម្រើន សូម្បីភិក្ខុសង្ឃមានចំនួន ១២៥០ រូបក៏ដោយ សូម្បីខ្ញុំព្រះអង្គពីដើមធ្លាប់ជ្រះថ្លា ក្នុងពពួកព្រាហ្មណ៍ក៏ដោយ សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃទទួលចង្ហាន់ខ្ញុំព្រះអង្គក្នុង

ថ្ងៃស្អែកនេះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព គឺអាការនៅស្ងៀម ។

( **ក្នុងអដ្ឋកថាបបញ្ចសូទនី** បានពោលដល់ការដែលព្រះមុនីទ្រង់មិនទទួលការនិមន្តន៍ក្នុងគ្រាទីពីរនោះ ដោយទ្រង់យល់ឃើញថា ភិក្ខុសង្ឃមានចំនួនច្រើន ចង្ហាន់បិណ្ឌបាតមិនគ្រប់គ្រាន់ ពួកមនុស្សទាំងឡាយ ប្រាកដជានឹងតិះដៀលកេណិយជដិលថា ថ្វាយចង្ហាន់បិណ្ឌបាតមិនគ្រប់គ្រាន់ កេណិយជដិលនឹងខូចចិត្ត ការហាមរបស់ព្រះអង្គ មនុស្សទាំងឡាយ នឹងបានដឹងកិច្ច ដែលព្រះអង្គទ្រង់ហាមដោយទ្រង់មានព្រះបំណង ឲ្យកេណិយជដិលអញ្ជើញពួកព្រាហ្មណ៍ផង និងដើម្បីរក្សាសទ្ធា របស់កេណិយជដិលផង ) ។ កេណិយៈបានជ្រាបថា ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តហើយ ក៏បានថ្វាយបង្គំលាទៅកាន់អាស្រមរបស់ខ្លួនវិញ លុះទៅដល់អាស្រមរបស់ខ្លួនហើយ បានហៅពួកញាតិសាលោហិតទាំងឡាយថា អ្នកទាំងឡាយដ៏ចម្រើន ខ្ញុំបាននិមន្តព្រះសមណគោតម ព្រមទាំងភិក្ខុសង្ឃ ដែលជាអ្នកទ្រទ្រង់នូវគុណដ៏ធំក្រៃលែង ភិក្ខុសង្ឃមានប្រមាណ ១២៥០ រូប ដើម្បីមកឆាន់ក្នុងថ្ងៃស្អែកនេះ សូមអ្នកទាំងឡាយ ជួយធ្វើកិច្ចការ

គ្នាផង ។ ពួកញាតិរបស់កេណិយជដិល ទទួលព្រមគ្រប់ៗគ្នាថា ល្អហើយលោក ពួកយើងនឹងជួយលោក ថាហើយ ពួកខ្លះបានជីកដីធ្វើចង្ក្រាន ដាំបាយ ស្ល ពួកខ្លះពុះឧស ពួកខ្លះលាងភាជនៈ ពួកខ្លះជួយលើកឆ្នាំងទឹក ពួកខ្លះរៀបចំអាសនៈ គ្រប់គ្នា គ្មាននរណាទំនេរដៃឡើយ ។

ចំណែកកេណិយជដិល បានតាក់តែងមណ្ឌប ប្រក់ដោយសំពត់ស ។ ក្នុងគ្រានោះ សេលព្រាហ្មណ៍ បានហែហមទៅដោយមាណព ៣០០ នាក់ ដើរលេងបន្ធូរអារម្មណ៍ ហើយបានចៀងចូលអាស្រមរបស់កេណិយជដិល ក៏បានឃើញមនុស្សទាំងឡាយ កំពុងជួយគ្នាធ្វើការងារផ្សេងៗ នោះ យ៉ាងខ្នះខ្នែងដូច្នោះ ក៏សួរកេណិយៈថា លោកកេណិយៈ លោកធ្វើអាវាហមង្គល ( នាំស្រីមករៀបការនៅផ្ទះខាងប្រុស ) វិវាហមង្គល ( នាំប្រុសមករៀបការនៅផ្ទះខាងស្រី ) ឬចាត់ចែងមហាយញ្ញ ឬលោកយាងព្រះបាទពិម្ពិសារ និងពលសេនា ឲ្យស្ដេចមកសោយនៅទីនេះ ក្នុងថ្ងៃស្អែក ? កេណិយៈឆ្លើយថា លោកសេលៈដ៏ចម្រើន ខ្ញុំមិនបានរៀបចំអាពាហ៍ពិពាហ៍អ្វីទេ សូម្បីព្រះបាទពិម្ពិសារ ព្រមទាំងពលសេនា ក៏ខ្ញុំមិនបានក្រាប

ទូល ឲ្យស្ដេចយាងមកសោយក្រយា ក្នុងថ្ងៃស្អែកនេះដែរ តែខ្ញុំបានចាត់ចែងបូជាយញ្ញចំពោះព្រះសមណគោតម ដែលស្ដេចចេញចាកសក្យត្រកូលចេញសាងព្រះផ្នួស ឥឡូវនេះ ស្ដេចបានចារិកទៅកាន់ឧត្តរាបថជនបទ ព្រមទាំងភិក្ខុសង្ឃប្រមាណ ១២៥០ រូប ស្ដេចយាងមកដល់អាបណនិគមហើយ កិត្តិស័ព្ទដ៏ល្បីល្បាញរបស់ព្រះសមណ-គោតម បានផ្សព្វផ្សាយខ្ទរខ្ទាយទូទៅ ខ្ញុំបាននិមន្តព្រះអង្គ ព្រមទាំងភិក្ខុសង្ឃ ដើម្បីទទួលភត្តាហារក្នុងថ្ងៃស្អែកនេះ ។ សេលព្រាហ្មណ៍គ្រាន់តែបានស្ដាប់ថា **ពុទ្ធោ** ក៏បានសួរចំពោះកេណិយជដិល ដោយការចាប់អារម្មណ៍យ៉ាងក្រៃលែងថា នែកេណិយៈដ៏ចម្រើន លោកបានពោលថា **ពុទ្ធោ** ឬ ? កេណិយជដិលតបថា ពិតមែនហើយ សេលៈដ៏ចម្រើន ខ្ញុំបានពោលថា **ពុទ្ធោ** មែន ។ កាលបើកេណិយៈប្រាប់ហើយ សេលព្រាហ្មណ៍បានសួរដដែលៗ ទៀត ហើយបានស្ដាប់ពាក្យបញ្ជាក់ដូចគ្នានឹងពាក្យមុន ។ សេលព្រាហ្មណ៍ត្រិះរិះថា សំឡេងថា **ពុទ្ធោ** ជាសំឡេង ដែលកម្របានស្ដាប់ឮក្នុងលោកនេះណាស់ ក្នុងតម្រារបស់យើង ក៏មានពោលទុកថា ព្រះមហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ រមែងមានគតិតែ

២ យ៉ាងប៉ុណ្ណោះ គឺបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិទ្រទ្រង់ធម៌ ជាធំលើផែនដី មានមហាសមុទ្រ ៤ ជាព្រំដែន ជាអ្នកឈ្នះសត្រូវ មិនមានបុគ្គលណាទប់ទល់បាន មានអាណាចក្រស្ថិតស្ថេរ ជាអ្នកសម្បូរដោយរតនៈ ៧ ប្រការ គឺចក្រកែវ ១ ដំរីកែវ ១ សេះកែវ ១ កែវមណី ១ នាងកែវ ១ ( អគ្គមហេសី ) គហបតីកែវ ១ បរិនាយកកែវ ១ និងមានព្រះរាជឱរស ១០០០ អង្គ សុទ្ធតែជាអ្នកក្លាហាន មានរូបសមជាវីរក្សត្រ អាចញាំញីកងទ័ពសត្រូវបាន ទ្រង់ឈ្នះដោយធម៌ មិនបានប្រើអាជ្ញា ឬសស្ត្រាវុធឡើយ ។ បើមហាបុរសនោះ ទ្រង់ចេញសាងព្រះផ្នួស នឹងបានជាព្រះអរហន្តសម្មាសម្ពុទ្ធ មានដំបូលគឺកិលេសរបើកហើយក្នុងលោក ។ សេលព្រាហ្មណ៍គិតដូច្នេះហើយ បានសួរដល់កេណិយៈថា ឥឡូវនេះ ព្រះសមណគោតមនោះ ទ្រង់គង់ប្រថាប់នៅក្នុងទីណា ? កេណិយៈ បានលើកដៃឡើងចង្អុលប្រាប់ថា ព្រះភគវា ទ្រង់គង់ប្រថាប់ នៅទៀបដើមឈើពណ៌ស្រស់នោះ ។

គ្រានោះ សេលព្រាហ្មណ៍ និងមាណព ៣០០ នាក់ បានឮដូច្នេះហើយ បាននាំគ្នាចូលទៅគាល់ ព្រះមានបុណ្យនៅទីគង់ប្រថាប់ តែមុននឹងចូលទៅកាន់ទីគង់ប្រថាប់នោះ បានពោលជាស់តឿន ដល់

មាណពទាំងនោះថា អ្នកទាំងអស់គ្នា នាំគ្នានិយាយនូវសំឡេងតិចៗ ដើរតាមគ្នាមក ដោយដើរជាន់ស្នាមជើងគ្នា ឲ្យដូចនឹងរាជសីហ៍ទាំងឡាយ ត្រាច់ទៅដូច្នោះដែរ ទាំងក្នុងពេលដែលយើងសន្ទនានឹងព្រះសមណគោតមនោះ អ្នកទាំងឡាយកុំនិយាយជ្រៀតចូល ក្នុងពេលដែលយើងកំពុងតែសន្ទនាជាដាច់ខាត កាលពោលដាស់តឿន ពួកមាណព ដែលជាកូនសិស្សទាំងនោះរួចហើយ ទើបបាននាំគ្នា ចូលទៅគាល់ព្រះមានជោគ ហើយក៏បានប្រាស្រ័យចរចា ជាមួយនឹងព្រះអង្គ រួចក៏អង្គុយក្នុងទីដ៏សមគួរ ។ ក្នុងខណៈដែលសេលព្រាហ្មណ៍អង្គុយនោះ ( គាត់ ) បានពិនិត្យមើល មហាបុរិសលក្ខណៈ ៣២ ប្រការ នៃព្រះវរកាយរបស់ព្រះអង្គ ក៏បានឃើញគ្រប់លក្ខណៈ ទាំងអស់ នៅខ្វះតែ ២ លក្ខណៈប៉ុណ្ណោះ គឺព្រះគុយ្ហដែលលាក់នៅក្នុងស្រោម ១ ព្រះជិវ្ហាធំ ១ ទើបស្ទាក់ស្ទើរនៅមិនទាន់ជឿ មិនទាន់ជ្រះថ្លា ពីព្រោះនៅសល់លក្ខណៈ ២ ប្រការទៀតនោះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា សេលព្រាហ្មណ៍នេះ ឃើញមហាបុរិសលក្ខណៈ ៣០ ប្រការ របស់តថាគតហើយ តែនៅពីរប្រការទៀត ទើបសង្ស័យនៅមិនទាន់ជឿ មិនទាន់ជ្រះថ្លា

ព្រោះនៅសល់លក្ខណៈ ២ ប្រការនោះទៀត ។ រំពេចនោះ ព្រះមុនីទ្រង់ដឹងចិត្តរបស់សេលព្រាហ្មណ៍ហើយ ទើបទ្រង់បានសម្ដែងនូវឥទ្ធាភិសង្ខារ ( ការសម្ដែងឫទ្ធិ ) ឲ្យសេលព្រាហ្មណ៍បានឃើញព្រះគុយ្ហៈដែលលាក់នៅក្នុងស្រោម ( គឺទ្រង់សម្ដែងឲ្យឃើញស្រមោល របស់ព្រះគុយ្ហលាក់នៅក្នុងស្រោម ) ហើយទ្រង់លៀនព្រះជិវ្ហាចេញមកស៊កចូលទៅក្នុងរន្ធត្រចៀក ទាំងសងខាងហើយ ត្រឡប់ទៅស៊កចូលក្នុងរន្ធព្រះនាសិកទាំងសងខាងវិញ ដោយត្រឡប់ទៅ ត្រឡប់មក និងទ្រង់លៀនអណ្ដាតបិទព្រះនលាដ ( ថ្ងាស ) របស់ព្រះអង្គរហូតជិត ។ ពេលនោះ សេលព្រាហ្មណ៍ បានក្រឡេកឃើញមហាបុរិសលក្ខណៈគ្រប់សព្វហើយ ទើបគិតថា ព្រះសមណគោតម ទ្រង់ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ គ្រប់បរិបូណ៌ មិនខ្វះ តែយើងមិនទាន់បានជ្រាបថា ព្រះអង្គបានត្រាស់ជាព្រះពុទ្ធហើយ ឬមិនទាន់បានត្រាស់ជាព្រះពុទ្ធនៅឡើយ ទាំងយើងក៏មិនដែលធ្លាប់ឮអាចារ្យ ឬបាចារ្យ ( អាចារ្យរបស់អាចារ្យ ) បានពោលមកថា ធម្មតាព្រះសម្មាសម្ពុទ្ធ ដែលទ្រង់បង្ហាញព្រះអង្គឲ្យដឹងប្រាកដថា ជាព្រះពុទ្ធពិតប្រាកដនោះ នៅពេលដែលមានបុគ្គល បានពោលសរសើរអំពីគុណ

របស់ព្រះទសពល ។ ដូច្នេះ យើងសាកល្បងមើល ក្នុងការពោល សរសើរព្រះសមណគោតម ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះអង្គ គេគិតដូច្នេះហើយ ទើបបានពោលសរសើរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានព្រះកាយបរិបូណ៌ ល្អស្អាត មានព្រះនេត្រថ្លាស្អាត មានឆវីវណ្ណដូចមាស មានព្រះចង្កូមទាំង ៤ ( ព្រះទាឋ ) ដ៏សក្បុស ព្រះអង្គជាអ្នកមាននូវសេចក្តីព្យាយាម អវយវៈតូច-ធំទាំងឡាយ ក៏សមរម្យល្អ អវយវៈតូច-ធំទាំងអស់នោះ ក្នុងព្រះកាយរបស់ព្រះអង្គជាមហាបុរិសលក្ខណៈ ព្រះអង្គមានព្រះនេត្រថ្លា មានភក្ត្រល្អ មានព្រះកាយធំសមសួន ត្រង់ដូចគ្នានឹងព្រហ្ម មានរស្មីរុងរឿង នៅក្នុងកណ្តាលនៃពួកភិក្ខុសង្ឃ ដូចជាដួងព្រះអាទិត្យ ព្រះអង្គជាអ្នកមានការគិតល្អ មានព្រះឆវីវណ្ណស្អាតភ្លឺថ្លាដូចមាស ប្រយោជន៍អ្វីក្នុងភាពដែលបានជាស្តេចចក្រពត្តិ ជាអ្នកប្រសើរនៅក្នុងរាជសម្បត្តិ ជាអ្នកធំគ្រប់គ្រងលើផែនដី មានមហាសមុទ្រទាំង ៤ ជាព្រំដែន មានជ័យជម្នះជាធំក្នុងជម្ពូទ្វីប មានក្សត្រប្រទេសតូចៗ តាមហែហមចោមរោម បពិត្រព្រះគោតម សូមព្រះពុទ្ធអង្គទ្រង់ជាព្រះរាជា ដែលជាព្រះរាជា

សមគួរទទួលការបូជា ជាកំពូលនៃមនុស្ស ទ្រង់គ្រប់គ្រងរាជសម្បត្តិប្រកបដោយធម៌ចុះ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា នែសេលព្រាហ្មណ៍ តថាគតជាព្រះរាជាប្រសើរបំផុត ជាធម្មរាជ តថាគតប្រកាសធម្មចក្កបានដោយមិនមាននរណាមួយ អាចប្រព្រឹត្តទៅបានដូច ។ សេលៈទើបក្រាបទូលសួរថា បពិត្រព្រះគោតម ព្រះអង្គបានប្តេជ្ញាថា ជាព្រះសម្មាសម្ពុទ្ធ ជាព្រះធម្មរាជដ៏ប្រសើរ បពិត្រព្រះគោតម ព្រះអង្គត្រាស់ថា ប្រកាសធម្មចក្រ គឺចក្រដែលប្រព្រឹត្តទៅដោយធម៌ អ្នកណាជាសាវ័កសេនាបតីរបស់ព្រះអង្គ ប្រព្រឹត្តតាមសាស្តា ភិក្ខុណាញុំាងធម្មចក្កនេះជំនួសព្រះអង្គបាន ។ ព្រះលោកនាថទើបត្រាស់ទៀតថា នែសេលព្រាហ្មណ៍ សារីបុត្រជាអនុជាតិរបស់តថាគត នឹងជាអ្នកប្រកាសធម្មចក្រដ៏ប្រសើរជំនួសតថាគតបាន នែសេលព្រាហ្មណ៍ ធម្មៈដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ ធម៌ដែលគួរចម្រើន តថាគតចម្រើនហើយ ធម៌ដែលគួរលះបង់ តថាគតលះបង់ហើយ ព្រោះហេតុនោះ តថាគតទើបជាព្រះពុទ្ធ អ្នកចូរកម្ចាត់បង់នូវសេចក្តីសង្ស័យស្មាក់ស្មើរចេញនៅក្នុងតថាគត ចូរបង្អោនចិត្តជឿ

តថាគតចុះ ការបានជួបប្រទះព្រះសម្មាសម្ពុទ្ធទាំងឡាយ ជារឿយៗ នោះ ជាកិច្ចដែលរកបានដោយកម្រ ។ ការប្រាកដឡើងរឿយៗ នៃព្រះសម្មាសម្ពុទ្ធណា រកបានដោយកម្រក្នុងលោក តថាគតជាព្រះសម្មាសម្ពុទ្ធ តថាគតជាគ្រូពេទ្យដ៏ប្រសើរ តថាគតជាបុគ្គលដ៏ប្រសើរ មិនមានបុគ្គលណាប្រៀបផ្ទឹមបាន ឬអាចញាំញីមារ និងសេនាមារបាន ធ្វើបច្ចាមិត្រឲ្យធ្លាក់ក្នុងអំណាចរបស់ខ្លួនបាន ជាអ្នកមិនមានភ័យពីទីណាៗ ហើយនៅដោយការរីករាយ ។

ពេលដែលសេលព្រាហ្មណ៍ បានស្ដាប់ដូច្នេះហើយ ក៏កើតសេចក្ដីជ្រះថ្លា មានបំណងនឹងបព្វជ្ជា ទើបប្រកាសជាមួយនឹងអន្តេវាសិកថា នែអ្នកទាំងឡាយដ៏ចម្រើន ចូរស្ដាប់ពាក្យដែលព្រះមានព្រះភាគ ទ្រង់ជាមហាបុរស ទ្រង់មានបញ្ញាចក្ខុ ទ្រង់ជាគ្រូពេទ្យដ៏ចំណាន ឬដូចជាសីហៈបន្លឺសំឡេងនៅក្នុងព្រៃដូច្នោះ ទោះបីព្រះអង្គជាអ្នកកើតនៅក្នុងត្រកូលថោកទាបក៏ដោយ បុគ្គលណាៗបានឃើញព្រះអង្គ ជាបុគ្គលដ៏ប្រសើរ មិនមានបុគ្គលណាប្រៀបផ្ទឹមបាន ឬអាចញាំញីមារ និងសេនាមារបាន ខ្ញុំជ្រះថ្លាចំពោះព្រះអង្គ បើអ្នកណាប្រាថ្នាចង់បព្វជ្ជា ចូរតាមយើងមក បើអ្នកណាមិនប្រាថ្នាបព្វជ្ជា

ទេ ចូរត្រឡប់ទៅវិញចុះ ( តាមអធ្យាស្រ័យ ) យើងនឹងបួសនៅក្នុង សម្នាក់ព្រះសមណគោតម ដែលទ្រង់ជាអ្នកមានបញ្ញាចក្ខុដ៏ប្រសើរ ។ ពេលនោះ អន្តេវាសិក ទើបនាំគ្នាពោលថា បពិត្រលោកអាចារ្យ កាលបើលោកអាចារ្យពេញចិត្ត ចំពោះពាក្យប្រៀនប្រដៅនៃព្រះមុនី ហើយ ពួកខ្ញុំទាំងអស់គ្នា ក៏បួសនៅក្នុងសម្នាក់ព្រះអង្គដែរ ពីព្រោះ ព្រះអង្គ ជាអ្នកមានទូវបញ្ញាចក្ខុ ។

លំដាប់នោះ អន្តេវាសិកទាំង ៣០០ នាក់នោះ បានប្រណម្យ អញ្ជលីឡើង ក្រាបទូលថា បពិត្រព្រះលោកនាយក ពួកខ្ញុំព្រះអង្គ ទាំងឡាយ សូមប្រព្រឹត្តព្រហ្មចរិយធម៌ នៅក្នុងសម្នាក់របស់ព្រះអង្គ ដែរ ។ ព្រះលោកនាថ ទើបទ្រង់ត្រាស់ថា ម្នាលសេលព្រាហ្មណ៍ ព្រហ្មចរិយធម៌ ដែលតថាគតត្រាស់ទុកហើយដោយល្អ ជាធម៌ដែល គួរជាក់ច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល បុគ្គល ណា ចេញមកបួសក្នុងសម្នាក់របស់តថាគត បុគ្គលនោះ ជាអ្នកមិន សូន្យចាកប្រយោជន៍ឡើយ ព្រោះតែបុគ្គលនោះ ជាអ្នកមិនប្រមាទ ជា អ្នកសិក្សាល្អ ក្នុងព្រហ្មចរិយធម៌នោះ ការប្រព្រឹត្តយ៉ាងនេះ មិនឥត អំពើឡើយ ។ កាលបើសេលព្រាហ្មណ៍ ព្រមទាំងអន្តេវាសិក បាន

បព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះទសពលរួចហើយ ។ លុះរាត្រីកន្លងផុតទៅ ឈានចូលដល់ព្រឹកថ្ងៃស្អែក កេណិយជដិល បានប្រាប់ឲ្យមនុស្សទាំងឡាយតាក់តែងភោជនីយាហារដ៏ប្រណីត ទុកក្នុងអាស្រមរបស់ខ្លួនរួចស្រេចហើយ ទើបប្រើឲ្យមនុស្សទៅក្រាបទូលអារាធនាប្រាប់នូវភត្តកាល ចំពោះព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន ភត្តសម្រេចហើយ សូមព្រះសុគតអារាធនានិមន្ត ។ ព្រះសយម្ភូ ទ្រង់ស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ស្តេចនិមន្តទៅព្រមដោយភិក្ខុសង្ឃ ចូលទៅកាន់អាស្រមនៃកេណិយជដិល ហើយស្តេចឡើងគង់ប្រថាប់លើអាសនៈ ដែលគេចាត់ចែងថ្វាយ ព្រមទាំងភិក្ខុសង្ឃ ។ ចំណែកកេណិយជដិល ក៏បានអង្គាសខាទនីយភោជនីយាហារ ចំពោះព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ឲ្យឆ្អែតស្កប់ស្កល់ដោយដៃខ្លួនឯង លុះត្រាតែព្រះលោកនាថ និងភិក្ខុសង្ឃលែងទទួល ។

កាលព្រះលោកនាយក សោយរួចស្រេចហើយ ទ្រង់លែងលូកព្រះហស្តទៅក្នុងបាត្រ ក្នុងគ្រានោះ កេណិយជដិល ក៏បានទៅអង្គុយលើអាសនៈសមគួរដល់ខ្លួន ព្រះវិជិតមារទ្រង់អនុមោទនាគាថាដល់កេណិយជដិល ដោយព្រះគាថាទាំងនេះថា ៖-

*ការបូជាភ្លើង ជាប្រមុខនៃយញ្ញទាំងឡាយ សាវិត្តឆន្ទៈ ជាប្រមុខនៃឆន្ទៈទាំងឡាយ ព្រះរាជា ជាប្រមុខនៃមនុស្សទាំងឡាយ ព្រះចន្ទ ជាប្រមុខនៃហ្វូងផ្កាយទាំងឡាយ ព្រះអាទិត្យ ជាប្រមុខនៃកម្តៅទាំងឡាយ ព្រះសង្ឃ ជាប្រមុខនៃបរិស័ទទាំងឡាយ អ្នកប្រាថ្នាបុណ្យចូរនាំគ្នាបូជា ចំពោះបុគ្គលដែលគួរបូជា ។*

កាលព្រះទសពល ទ្រង់អនុមោទនាគាថា ដល់កេណិយជដិលយ៉ាងនេះហើយ ទ្រង់ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកព្រះសេលត្ថេរ ព្រមដោយភិក្ខុដែលជាបរិស័ទទាំងអស់ ម្នាក់ៗ នាំគ្នាគេចចេញពីពួកគណៈទៅនៅតែម្នាក់ឯង ជាអ្នកមិនមានសេចក្តីប្រមាទបានតាំងចិត្តព្យាយាម មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផលជាព្រះអសេក្ខបុគ្គល គ្រប់ៗ រូបទៅ ។ កាលព្រះសេលត្ថេរ ព្រមដោយភិក្ខុដែលជាបរិស័ទទាំងនោះ បានសម្រេចជាព្រះអរហន្តហើយក៏បាននាំគ្នាចូលទៅគាល់ព្រះបរមគ្រូ ដល់ទីគង់ប្រថាប់ កាលទៅដល់ទើបបានគ្រងចីវរធៀងស្មាម្ខាង ប្រណម្យអញ្ជលី បែរមុខឆ្ពោះទៅរកព្រះមុនី ហើយបានក្រាបទូលនឹងព្រះសម្ពុទ្ធជាម្ចាស់ថា បពិត្រព្រះមុនីព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំព្រះអង្គទាំងឡាយ សូមគោរពចំពោះព្រះអង្គ

ជាសរណៈ ។ ក្នុងថ្ងៃទី ៨ រាប់ថយក្រោយពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គទាំងឡាយ បានមកទូន្មានខ្លួន នៅក្នុងសាសនារបស់ព្រះអង្គ ៧ រាត្រី ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាសាស្តា ព្រះអង្គជាមុនី ទ្រង់គ្របសង្កត់មារបាន ព្រះអង្គកាត់ផ្តាច់នូវកិលេសបានហើយ ទ្រង់ឆ្លងលោកបានហើយ និងទ្រង់ជួយចម្លងសត្វលោក ឲ្យឆ្លងតាមបានផង ព្រះអង្គឆ្លងឧបធិ ( គឺវត្ថុដែលនៅលាយដោយកិលេស ) បានហើយ ទ្រង់ទម្លាយអាសវក្កិលេសទាំងឡាយបានហើយ ព្រះអង្គអស់នូវការប្រកាន់មាំវត្ថុណាៗ ក្នុងលោកនេះហើយ ទ្រង់រំសាយចេញនូវភាពភ័យខ្លាចបានហើយ ដូចរាជសីហ៍ ។ ភិក្ខុទាំង ៣០០ រូបនោះ បានក្រាបទូលដូច្នេះហើយ ក៏សូមឲ្យព្រះអង្គទ្រង់សណ្តូកព្រះយុគលបាទចេញមក ឲ្យខ្ញុំព្រះអង្គទាំងឡាយ បានថ្វាយបង្គំផង ។

ជីវប្រវត្តិនៅក្នុងអតីតជាតិ របស់ព្រះសេលត្ថេរ ដែលពោលដល់ការសន្សំបុណ្យបារមីទុក ក្នុងភពផ្សេងៗ ដែលលោកកើតហើយនោះ ដែលជាហេតុ ជាបច្ច័យធ្វើឲ្យលោកបានសម្រេចមគ្គផល ក្នុងបច្ចុប្បន្នជាតិនេះ ដូចមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថាៈ-

ក្នុងពុទ្ធកាល នៃព្រះបទុមុត្តរសម្ពុទ្ធ ព្រះសេលៈកើតនៅក្នុងត្រកូលមួយ កាលចម្រើនវ័យធំដឹងក្ដីឡើង ក៏បានជាប្រធានពួកគណៈដឹកនាំមាណពប្រមាណ ៣០០ នាក់ ឲ្យជួយគ្នាកសាងព្រះគន្ធកុដិថ្វាយដល់ព្រះបទុមុត្តរៈ កាលបើកសាងព្រះគន្ធកុដិរួចស្រេចហើយ ទើបបានរៀបចំការថ្វាយទានដល់ព្រះបទុមុត្តរៈ ព្រមដោយភិក្ខុសង្ឃ ក្រៅពីការថ្វាយភត្តាហារ ក៏បានថ្វាយត្រៃចីវរដល់ភិក្ខុសង្ឃ ដែលមានព្រះបទុមុត្តរៈជាប្រធាន ។ ដោយអានិសង្សនៃបុណ្យកុសលនោះ ធ្វើឲ្យលោកមានការត្រាច់រង្គាត់ សោយទិព្វសម្បត្តិនៅក្នុងទេវលោក អស់មួយពុទ្ធន្តរ លុះចុតិចាកទេវលោកមក ក៏បានកើតជាមនុស្ស និងទេវតាអស់កាលដ៏យូរអង្វែងទៀត រហូតមកដល់ពុទ្ធកាលនេះ ទើបលោកមកកើតក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងអាបណនិគម ដូចមានរឿងតំណាលរួចមកហើយអំពីខាងដើមនោះ ។

ចំណែកជីវប្រវត្តិក្នុងអតីតជាតិ របស់ព្រះសេលត្ថេរ ដូចមានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយលោកបានតំណាលប្រវត្តិខ្លួនលោកផ្ទាល់ តាមដែលមានសេចក្ដីថា ៖-

ខ្ញុំជាម្ចាស់ថ្កល់ នៅក្នុងនគរហង្សវតី ប្រមូលពួកញាតិរបស់ខ្ញុំមក ហើយពោលពាក្យនេះថា ព្រះពុទ្ធជាបុញ្ញក្ខេត្តដ៏ប្រសើរ កើតហើយក្នុងលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា របស់សត្វលោកទាំងពួង ។ ពួកក្សត្រ ពួកអ្នកនិគម និងពួកព្រាហ្មណមហាសាល មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពលដំរី ពលសេះ ពលរថ ពលថ្មើរជើង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកឧគ្គជន ( ម្តាយជាសូទ្រ: ឪពុកជាក្សត្រ ) ពួករាជបុត្រ ពួកវេស្ស: និងពួកព្រាហ្មណ៍ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកដាំស្ល ពួកអ្នកគ្រួ អ្នកកាត់សក់ និងអ្នកធ្វើកម្រងផ្កា មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងជ្រលក់ ជាងតម្បាញ ជាងដេរប៉ាក់ និងអ្នកកាត់សក់ មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងធ្វើកូនសរ ជាងក្រឡឹង ជាងធ្វើស្បែក និងជាងចាំង មានចិត្តជ្រះថ្លា មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកជាងដែក ពួកជាងមាស ជាងសំណ និងលោហ: មានចិត្តជ្រះថ្លា

មានចិត្តរីករាយ ពួកជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា ។ ពួកអ្នកស៊ីឈ្នួល ពួកអ្នកកាន់ទង់សំពត់ និងពួកទាសកម្មករជាច្រើន ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកដងទឹក ពួកអ្នករកឧស ពួកអ្នកក្ដូររាស់ ពួកអ្នកនាំស្មៅ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ពួកអ្នកបេះផ្កា ពួកអ្នកក្រងផ្កា ពួកអ្នកលក់បន្លែ និងអ្នកនាំផ្លែឈើ ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ។ ស្រីពេស្យា នាងកុម្ភទាសី ស្រីអ្នកលក់នំ និងអ្នកនេសាទត្រី ជនទាំងនោះ បានធ្វើនូវការប្រជុំគ្នា តាមកម្លាំងរបស់ខ្លួន ជនទាំងអស់នោះឯង មកប្រជុំគ្នា ចងគ្នាជាពួកក្នុងទីមួយ ( ហើយពោលថា ) យើងទាំងឡាយ នឹងធ្វើនូវការកសាងចំពោះព្រះពុទ្ធ ជាបុញ្ញក្ខេត្តដ៏ប្រសើរ ជនទាំងអស់នោះ បានស្ដាប់ពាក្យរបស់ខ្ញុំហើយ ក៏ចងពួកនៅក្នុងខណៈនោះ បានឲ្យពួកជាងធ្វើឧបដ្ឋានសាលា ដែលធ្វើដោយល្អ ថ្វាយភិក្ខុសង្ឃ ។ ខ្ញុំធ្វើសាលានោះរួចហើយ ក៏មានចិត្តរីករាយ មានចិត្តត្រេកអរ មានពួកជនទាំងអស់នោះហែហម ចូលទៅគាល់ព្រះសម្ពុទ្ធ ។ លុះចូលទៅគាល់ព្រះលោកនាថ ព្រះអង្គជាទីពឹងនៃលោក ប្រសើរជាងជន ហើយថ្វាយ

បង្គំព្រះបាទាព្រះសាស្ដា រួចពោលនូវពាក្យនេះថា បពិត្រព្រះភគវា ជាវីរបុរស ពួកបុរស ៣០០ នាក់នេះ ជាពួកតែមួយ បានវេរថ្វាយ ឧបដ្ឋានសាលា ដែលធ្វើយ៉ាងល្អ ចំពោះព្រះអង្គ សូមព្រះអង្គមាន បញ្ញាចក្ខុទទួល ( នូវសាលា ) ចំពោះមុខភិក្ខុសង្ឃ ។ ព្រះទសពល ទ្រង់ត្រាស់សម្ដែងនូវគាថាទាំងឡាយនេះ ចំពោះមុខបុរសទាំង ៣០០ នាក់ថា បុរស ៣០០ នាក់ នឹងជាបុរសធំ ប្រព្រឹត្តត្រូវគ្នាតែបែបមួយ ត្បិតពួកអ្នកទាំងអស់គ្នា ធ្វើអំពើនេះហើយ នឹងបានទទួលសម្បត្តិ សុខ ។ លុះដល់បច្ឆិមភព អ្នកទាំងឡាយ នឹងឃើញច្បាស់ព្រះនិព្វាន មានភាពដ៏ត្រជាក់ត្រជុំ ជាគុណជាតដ៏ប្រសើរ ឥតចាស់ឥតស្លាប់ ជា ទីក្សេមក្សាន្ត ។ ព្រះសព្វញ្ញុពុទ្ធជាបុគ្គលដ៏ប្រសើរ បានព្យាករយ៉ាង នេះ ខ្ញុំបានស្ដាប់ព្រះពុទ្ធដីកាហើយ ក៏ទទួលនូវសេចក្ដីសោមនស្ស ។ ខ្ញុំរីករាយនៅក្នុងទេវលោក អស់ ៣០ ពាន់កប្ប ខ្ញុំជាធំជាងទេវតា សោយទេវរាជ្យ អស់ ៥០០ ដង ។ ខ្ញុំបានជាស្ដេចចក្រពត្តិ អស់ មួយពាន់ដង បានសោយរាជ្យក្នុងប្រទេសដ៏ធំទូលាយ រាប់បានមួយ អសង្ខេយ្យកប្ប ។ ពួកបរិស័ទបានមកជាផៅពង្ស ក្នុងរាជ្យជារបស់ មនុស្សនេះ លុះបច្ឆិមភព មានព្រាហ្មណ៍ឈ្មោះវាសេដ្ឋៈ សន្សំទ្រព្យ

ទុកបាន ៨០ កោដិ ។ ខ្ញុំបានជាកូន របស់វាសេដ្ឋព្រាហ្មណ៍នោះ ពាក្យថា សេលព្រាហ្មណ៍ ជាឈ្មោះរបស់ខ្ញុំៗ ជាអ្នកដល់នូវបារមី ក្នុងធម្មទាន ។ កាលខ្ញុំដើរទៅកាន់ទីសម្រាកស្មុង ពួកសិស្សរបស់ខ្ញុំនចោមរោម ខ្ញុំឃើញគ្រឿងបូជាដែលគេចាត់ចែង ក៏ពោលពាក្យនេះនឹងកេណិយតាបស ដែលពេញដោយការៈ គឺផ្នួងសក់ថា លោកធ្វើអាវាហមង្គល ឬវិវាហមង្គល ឬក៏លោកអញ្ជើញព្រះរាជាមក ។ ( កេណិយតាបសតបថា ) ខ្ញុំមានប្រាថ្នាបូជានូវគ្រឿងបូជា ចំពោះព្រាហ្មណ៍ដែលទេវតាសន្មតិហើយ ខ្ញុំមិនមែនអញ្ជើញព្រះរាជាទេ គ្រឿងបូជា មិនមានដើម្បីខ្ញុំទេ ។ អាវាហមង្គលរបស់ខ្ញុំ ក៏មិនមាន ទាំងវិវាហមង្គលរបស់ខ្ញុំ ក៏មិនមានដែរ ព្រះពុទ្ធព្រះអង្គ ទ្រង់ញ៉ាំងសេចក្តីរីករាយ របស់ពួកសក្យៈឲ្យកើតឡើង ជាបុគ្គលប្រសើរក្នុងលោក ព្រមទាំងទេវលោក ។ ព្រះពុទ្ធជាបុគ្គលមានប្រយោជន៍ និងសេចក្តីចម្រើន ដល់សត្វលោកទាំងពួង នាំមកនូវសេចក្តីសុខ ដល់សព្វសត្វ ព្រះពុទ្ធនោះ ខ្ញុំបានអារាធនាហើយ ក្នុងថ្ងៃនេះ ការចាត់ចែងនោះ ដើម្បីព្រះសាស្តានោះទេតើ ។ ព្រះពុទ្ធទ្រង់មានពន្លឺនៃពណ៌ដូចផ្លែទន្លាប់ទុំ មានប្រមាណមិនបាន មិនមានបុគ្គលប្រៀបផ្ទឹម មិន

មានបុគ្គលស្មើដោយរូប ខ្ញុំបានអាភាធនាហើយ ដើម្បីបានទៅក្នុងថ្ងៃស្អែក ។ ព្រះពុទ្ធជាទីពឹងនោះ ព្រះអង្គរីករាយដូចមាត់បាវមាសផង ប្រាកដស្មើដូចរងើកភ្លើងគគីរ ជាមហាវីរបុរស ឧបមាដូចផ្ទេកបន្ទោរ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ដូចជាភ្លើងលើកំពូលភ្នំ ឬដូចព្រះច័ន្ទក្នុងថ្ងៃពេញបូណ៌មី ពុំនោះសោត ប្រាកដស្មើពណ៌ភ្លើងដែលឆេះព្រៃបបុស ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ មិនតក់ស្លុត មានភ័យកន្លងផុតហើយ ធ្វើនូវទីបំផុតនៃភព ជាមហាវីរបុរស ឧបមាដូចជាសីហៈ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកឈ្លាសវៃ ក្នុងធម៌របស់ព្រះពុទ្ធទាំងឡាយ ដែលពួកបុគ្គលដទៃកំហែងមិនបាន ជាមហាវីរបុរស ឧបមាដូចដំរី ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ទ្រង់ឈ្លាសវៃក្នុងត្រើយ នៃព្រះសទ្ធម្ម ជាព្រះពុទ្ធនាគ មិនមានបុគ្គលស្មើ ជាមហាវីរបុរស ឧបមាដូចគោឧសភៈ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ មានគុណឥតមានទីបំផុត មានយសរាប់មិនបាន មានលក្ខណៈទាំងអស់ដ៏វិចិត្រ ជាមហាវីរបុរស ឧបមាដូចព្រះឥន្ទ្រ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ទ្រង់ស្ទាត់ផង មានពួកផង ជាមហាវីរបុរស ឧបមាដូចព្រហ្ម

ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គមានធម៌ដ៏ប្រសើរលើស មានកម្លាំង ១០ ប្រការ ដល់នូវត្រើយនៃកម្លាំងតូច-ធំ ជាមហាវីរៈ ឧបមាដូចផែនដី ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គកុះករដោយសីល និងមានសេចក្តីព្យាយាម ទ្រង់ញុំាងធម្មវិញ្ញាណឲ្យរំជួល ជាមហាវីរបុរស ឧបមាដូចសមុទ្រ ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ គេបៀតបៀនមិនបាន គេគ្របសង្កត់បានដោយក្រ ជាបុគ្គលមិនញាប់ញ័រ ខ្ពង់ខ្ពស់ដ៏ប្រសើរ ជាមហាវីរបុរស ឧបមាដូចភ្នំសិនេរុ ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ទ្រង់មានញាណរកទីបំផុតគ្មាន ឥតមានបុគ្គលស្មើ រកបុគ្គលថ្លឹងស្មើមិនបាន ដល់នូវភាពជាបុគ្គលប្រសើរ ជាមហាវីរបុរស ឧបមាដូចមេឃ ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាទីពឹងរបស់ពពួកសត្វ ដែលមានភ័យភិត ជាទីពំនាក់នៃពួកសត្វដែលដល់នូវសរណៈ ជាមហាវីរបុរស ញុំាងសត្វឲ្យស្រស់ស្រាយ ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាទីអាស្រ័យ នៃពួកបុគ្គលមានប្រាជ្ញា ជាបុញ្ញក្ខេត្តរបស់ពួកជនអ្នកស្វែងរកសុខ ព្រះអង្គជាអណ្តូងនៃរតនវត្ថុ ជាមហាវីរបុរស ខ្ញុំបានអារាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គញុំាងសត្វឲ្យស្រស់ស្រាយ ធ្វើឲ្យទៅ

ជាទេវតា ទ្រង់ឲ្យនូវសាមញ្ញផល ជាមហាវីរបុរស ឧបមាដូចមេឃ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ជាវីរបុរស ផុសឡើងហើយក្នុងលោក ទ្រង់បន្ទោបង់នូវងងឹតទាំងពួង ជាមហាវីរបុរស ឧបមាដូចព្រះអាទិត្យ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់បង្ហាញនូវសេចក្តីពិត ក្នុងអារម្មណ៍ និងវិមុត្តិទាំងឡាយ ជាមហាវីរបុរស ឧបមាដូចព្រះច័ន្ទ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ព្រះអង្គផុសឡើងហើយក្នុងលោក ប្រដាប់ហើយដោយលក្ខណៈទាំងឡាយ ជាមហាវីរបុរស មិនមានប្រមាណ ខ្ញុំបានអាភាធនាហើយ ។ ញាណរបស់ព្រះពុទ្ធណា មិនមានប្រមាណ សីលរបស់ព្រះពុទ្ធណា រកសេចក្តីប្រដូចគ្មាន វិមុត្តិរបស់ព្រះពុទ្ធណា រកអ្វីស្មើគ្មាន ព្រះពុទ្ធនោះ ខ្ញុំបានអាភាធនាហើយ ។ សេចក្តីព្យាយាមរបស់ព្រះពុទ្ធណា ឥតមានអ្វីស្មើ កម្លាំងរបស់ព្រះពុទ្ធណា ដែលបុគ្គលគិតមិនឃើញ សេចក្តីប្រឹងប្រែងរបស់ព្រះពុទ្ធណា ជាឧបាយដ៏ប្រសើរ ព្រះពុទ្ធនោះ ខ្ញុំបានអាភាធនាហើយ ។ ពិសទាំងពួង គឺរាគៈ ទោសៈ មោហៈ ដែលព្រះពុទ្ធអង្គណា គាស់រំលើងហើយ ព្រះពុទ្ធអង្គនោះ ជាមហាវីរៈមានឧបមាដូចឱសថ ខ្ញុំបានអាភាធនាហើយ ។ ព្រះពុទ្ធនោះ ដូចបុគ្គល

មានឱសថ ព្រះអង្គជាអ្នកបន្ទោបង់នូវព្យាធិ គឺកិលេស ដែលជាទុក្ខច្រើនប្រការ ជាមហាវីរៈ ឧបមាដូចផ្ទៃកបន្ទោរ ខ្ញុំបានអាពធនាហើយ ។

កេណិយតាបស បានពោលឃោសនាថា ព្រះពុទ្ធៗ ដូច្នេះការឃោសនានោះ ខ្ញុំបានឮដោយកម្រណាស់ ខ្ញុំមានបីតិកើតឡើងព្រោះឮពាក្យឃោសនាថា ព្រះពុទ្ធ ។ ចិត្តរបស់ខ្ញុំឥតប្រកាន់ បីតិរបស់ខ្ញុំ ក៏ផ្សាយចេញទៅខាងក្រៅ ខ្ញុំនោះ មានចិត្តប្រកបដោយបីតិមានចិត្តស្ងប់ បានពោលពាក្យនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គជាចម្បងក្នុងលោក ប្រសើរជាងជន គង់នៅក្នុងទីណា ខ្ញុំនឹងទៅនមស្ការព្រះអង្គ ក្នុងទីនោះ ទ្រង់ជាអ្នកឲ្យនូវសាមញ្ញផល ។ ខ្ញុំមានសេចក្ដីត្រេកអរកើតឡើង ធ្វើអញ្ជលីលើកដៃខាងស្ដាំ ( សួរថា ) លោកចូរប្រាប់ខ្ញុំផង នូវព្រះពុទ្ធជាស្ដេចហេតុធម៌ ទ្រង់បន្ទោបង់នូវសរ គឺសេចក្ដីសោក ។ ( កេណិយតាបសប្រាប់ថា ) អ្នកចូរមើលព្រៃធំនោះ ដែលហាក់ដូចជាមហាមេឃបើកស្រឡះ ឬដូចផ្កាអញ្ចនខៀវ ឬក៏ប្រាកដដូចជាសាគរ ព្រះពុទ្ធនោះ ជាអ្នកប្រាជ្ញ ទូន្មាននូវបុគ្គល ដែលមានខ្លួនមិនទាន់បានទូន្មាន ទ្រង់ប្រៀនប្រដៅ នូវពួកវេនេយ្យសត្វ ញុំាងវេនេយ្យសត្វ ឲ្យត្រាស់ដឹងនូវពោធិបក្ខិយធម៌

ទ្រង់គង់នៅក្នុងព្រៃធំនោះ ។ ខ្ញុំក៏ពិនិត្យមើលនូវព្រះជិនស្រី គួរនា ដូចជាបុគ្គលស្រេកទឹក ឬដូចបុគ្គលឃ្លានបាយ ឬក៏ដូចមេគោ ដែលជាប់ជំពាក់នឹងកូនគោ ខ្ញុំជាអ្នកស្គាល់នូវអាចារៈ និងគោចរៈ បាន ញ៉ាំងពួកសិស្សរបស់ខ្លួន ដែលកំពុងដើរទៅកាន់សម្នាក់ព្រះជិនស្រី ឲ្យសិក្សានូវការប្រុង ឲ្យសមតាមប្រពៃណីថា ម្នាលមាណពទាំងឡាយ ព្រះមានព្រះភាគទាំងឡាយ គេចូលទៅរកបានដោយក្រ ដូចជាសីហៈដែលត្រាច់ទៅតែឯង អ្នកទាំងឡាយ ចូរដើរដាក់ជើងជិតជើង ( សន្សឹមៗ ) ដើរមកចុះ ។ ព្រះពុទ្ធទាំងឡាយ អ្នកផងចូលទៅរកបានដោយក្រ ដូចជាពស់អាសិរពិស ដ៏ឃោរឃៅ ដូចជាកេសររាជសីហ៍ ជាស្តេចម្រឹគ ឬដូចជាដំរីកុញ្ជរ មានបទដែលចុះប្រេង ។ ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយ ចូរទប់នូវអាការក្អក និងកណ្តាស ចូរដើរដាក់ជើងជិតជើង ចូលទៅកាន់សម្នាក់ព្រះពុទ្ធចុះ ។ ព្រះពុទ្ធទាំងឡាយ ព្រះអង្គធ្ងន់ព្រះទ័យក្នុងការពួនសំងំ ពេញព្រះហឫទ័យនឹងសំឡេងតិចៗ អ្នកផងចូលទៅរកបានដោយក្រ ចូលទៅជិតបានដោយលំបាក ជាគ្រូនៅក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ កាលណាខ្ញុំកំពុងសាកសួរប្រស្នា ឬកំពុងនិយាយរាក់

ទាក់ កាលនោះ អ្នកទាំងឡាយ ចូរនិយាយសំឡេងតិចៗ ចូរស្ថិតនៅស្ងៀម ។ កាលណា ព្រះពុទ្ធនោះ ទ្រង់សម្តែងព្រះសទ្ធម្ម ជាធម៌ក្សេម ដើម្បីដល់ព្រះនិព្វាន ( កាលនោះ ) អ្នកទាំងឡាយ ចូរត្រងត្រាប់ស្តាប់សេចក្តីនោះ ត្បិតការស្តាប់នូវព្រះសទ្ធម្ម ជាការល្អ ។ ខ្ញុំបានចូលទៅគាល់ព្រះសម្ពុទ្ធ ហើយនិយាយរាក់ទាក់ ( ជាមួយ ) នឹងព្រះសម្ពុទ្ធជាអ្នកប្រាជ្ញ លុះបញ្ចប់ពាក្យនោះហើយ ក៏ពិនិត្យមើលលក្ខណៈទាំងឡាយ ។ ខ្ញុំមិនទាន់ឃើញលក្ខណៈ ២ ប្រការ ឃើញតែលក្ខណៈ ៣០ ប្រការ ទើបព្រះមុនីទ្រង់បង្ហាញដោយឫទ្ធិ នូវគុយ្ហ ជាវត្ថុបិទបាំងដោយស្រោម ។ ព្រះជិនស្រី ទ្រង់លៀនព្រះជិវ្ហា ហើយប៉ះពាល់នូវព្រះកាណ៌ និងព្រះនាសិកៈ បាំងនូវទីបំផុតព្រះនលាដៈទាំងអស់ លុះខ្ញុំឃើញលក្ខណៈរបស់ព្រះអង្គ ដ៏បរិបូណ៌ព្រមទាំងអនុព្យញ្ជនៈ ក៏ដល់នូវសេចក្តីចូលចិត្តថាជាព្រះពុទ្ធ ហើយបួសជាមួយនឹងពួកសិស្ស ។ លុះខ្ញុំ ព្រមទាំងពួកសិស្ស ៣០០ នាក់ចូលទៅកាន់ផ្នួសហើយ កាលមិនទាន់ដល់កន្លះខែនៅឡើយ ពួកយើងទាំងអស់ ក៏ដល់នូវសេចក្តីរលត់ទុក្ខ ។ ជនទាំងឡាយបានធ្វើនូវបុញ្ញកម្មជាមួយគ្នា ចំពោះបុញ្ញក្ខេត្តដ៏ប្រសើរ អន្ទោលទៅក្នុងទី

ជាមួយគ្នា វិលមកកើតនៅក្នុងទីជាមួយគ្នា ។ ខ្ញុំបានប្រគេនបង្កង់ទាំងឡាយ ( ចំពោះព្រះសង្ឃ ) ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ និងអានិសង្ស ៨ ប្រការ គឺខ្ញុំត្រូវគេបូជាក្នុងទិសទាំងឡាយ ១ ភោគៈទាំងឡាយរបស់ខ្ញុំរាប់មិនអស់ ១ ខ្ញុំជាទីពឹងរបស់ពួកជនទាំងពួង ១ ខ្ញុំមិនមានសេចក្ដីតក់ស្លុត ១ ខ្ញុំមិនមានជំងឺទាំងឡាយ ១ ខ្ញុំរមែងរក្សាអាយុឲ្យរស់នៅវែង ១ ជាអ្នកមានសម្បុរថ្ងៃដ៏ល្អិត ១ កាលដែលភ្លៀងធ្លាក់ក្នុងវាល ខ្ញុំឲ្យបង្កង់ ៨ ហើយនៅក្នុងពួក អំពើជាកុសលនេះ នាំឲ្យខ្ញុំបានបដិសម្ភិទា និងអរហត្តផល នេះជាអានិសង្សគម្រប់ ៨ ។ បពិត្រព្រះមហាមុនី កូនរបស់ព្រះអង្គ ឈ្មោះអដ្ឋគោបានសី មានព្រហ្មចរិយធម៌ជាទីបំផុត នៅចប់សព្វគ្រប់ហើយ មានសោឡសកិច្ចធ្វើរួចស្រេចហើយ មិនមានអាសវៈ ។ ខ្ញុំបានឲ្យសសរ ៥ ហើយនៅក្នុងពួក ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺបានអានិសង្ស ៥ ប្រការ គឺខ្ញុំជាអ្នកមិនកក្រើកចាកមេត្តា ១ មានភោគៈមិនខ្វះខាត ១ មានពាក្យសម្ដីគួរឲ្យអ្នកផងកាន់យក ១ មិនកម្ចាត់បង់ ( នូវគុណនៃបុគ្គលដទៃ ) ១ ចិត្តរបស់ខ្ញុំមិនកន្ត្រប់ ខ្ញុំជាអ្នកមិនរឹងចចេស ចំពោះ

បុគ្គលណាមួយ ១ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំជាអ្នកមិនមានមន្ទិលក្នុងសាសនា ។ បពិត្រព្រះមុនី ជាមហាវីរបុរស ភិក្ខុជាសាវករបស់ព្រះអង្គ ប្រកបដោយសេចក្ដីគោរព ប្រកបដោយការកោតក្រែង មានកិច្ចធ្វើរួចហើយ ជាអ្នកមិនមានអាសវៈ រមែងថ្វាយបង្គំព្រះអង្គ ។ ខ្ញុំបានធ្វើនូវបល្ល័ង្ក ដែលធ្វើដ៏ល្អ ហើយតាំងទុកក្នុងសាសនា ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបាននូវហេតុ គឺអានិសង្ស ៥ ប្រការ គឺខ្ញុំកើតក្នុងត្រកូលខ្ពង់ខ្ពស់ ១ ជាអ្នកមានភោគៈច្រើន ១ ជាអ្នកមានសម្បត្តិគ្រប់មុខ ១ ខ្ញុំមិនមានសេចក្ដីកំណាញ់ ១ បល្ល័ង្ករមែងផុសឡើងដល់ខ្ញុំ ក្នុងដំណើរដែលខ្ញុំប្រាថ្នា ១ ខ្ញុំរមែងទៅកាន់ទីដែលខ្ញុំប្រាថ្នា ព្រមដោយបល្ល័ង្កដ៏ប្រសើរ ។ ខ្ញុំបន្ទោបង់នូវងងឹតទាំងពួងបាន ព្រោះទាននៃបល្ល័ង្កនោះឯង បពិត្រព្រះមុនី ព្រះថេរៈដែលដល់នូវកម្លាំង នៃអភិញ្ញាទាំងពួង រមែងថ្វាយបង្គំព្រះអង្គ ។ ខ្ញុំញុំាងកិច្ចទាំងពួង ដែលជាកិច្ចរបស់អ្នកដទៃ និងកិច្ចរបស់ខ្លួនឲ្យសម្រេច ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបខ្ញុំបានចូលទៅកាន់បុរី ឥតមានភ័យ ។ ខ្ញុំបានឲ្យគ្រឿងប្រើប្រាស់ទុកក្នុងសាលាដែលកសាងស្រេចហើយ ដោយអំពើដែលខ្ញុំធ្វើល្អនោះ ទើបបាន

ដល់នូវភាពនៃខ្លួន ជាបុគ្គលប្រសើរ ។ ពួកជនអ្នកទូន្មានណាទីមួយ ក្នុងលោក ពួកជនអ្នកទូន្មានទាំងនោះ រមែងទូន្មាននូវដំរី និងសេះទាំងឡាយ ពួកជនអ្នកទូន្មានទាំងនោះ ធ្វើដោយហេតុផ្សេងៗ ហើយទូន្មានដោយអំពើដ៏អាក្រក់ ។ បពិត្រព្រះមហាវីរបុរស ព្រះអង្គមិនមែនទូន្មាននូវពួកបុរសស្ត្រី ដូច្នោះទេ ព្រះអង្គតែងទូន្មាននូវពពួកជនដ៏ខ្ពង់ខ្ពស់ ដែលគួរទូន្មាន ដោយហេតុមិនបាច់ប្រើដំបង មិនបាច់ប្រើគ្រឿងសស្ត្រាវុធ ។ បពិត្រព្រះមហាមុនី ព្រះអង្គឈ្លាសវៃ ក្នុងការទេសនា ទ្រង់សរសើរគុណនៃទាន បពិត្រព្រះមុនី ព្រះអង្គ កាលសម្តែងនូវប្រស្នាតែមួយសោះ ក៏ញុំាងពួកបុរសទាំង ៣ រយនាក់ ឲ្យត្រាស់ដឹងធម៌បាន ។ ពួកយើងដែលព្រះអង្គជាសារថី បានទូន្មានហើយ ជាអ្នកមានចិត្តរួចស្រឡះ មិនមានអាសវៈ ដល់នូវកម្លាំងនៃអភិញ្ញាទាំងពួង មានទុក្ខរលត់ហើយ ព្រោះអស់ទៅនៃឧបធិក្កិលេស ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ភ័យគ្រប់យ៉ាង ខ្ញុំកន្លងផុតហើយ នេះជាផលនៃការឲ្យសាលា ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ ព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ប្រការ ខ្ញុំបានដល់ហើយ ទាំងសាសនធម៌

របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើចប់ហើយ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ផ្តាច់នូវទន្ទឹង ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រព្រឹត្តហើយ ។

សេចក្តីថា ជីវប្រវត្តិរបស់ព្រះសោលគ្គេរ ដែលជាមហាសាវ័កដែលបានកសាងសន្សំសេចក្តីល្អ ទុកជាតួយ៉ាងនៅក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិ ដូចដែលបានពោលទុករួចមកហើយ ដើម្បីសម្តែងឲ្យឃើញថា នៅក្នុងដំណើរជីវិតនៃសព្វសត្វទាំងអស់ ប្រព្រឹត្តទៅតាមអំណាចកម្ម ដូច្នេះ បណ្ឌិតអ្នកមានប្រាជ្ញា តែងតែធ្វើនូវអំពើណាដែលជាហេតុមិនបៀតបៀនខ្លួនឯងផង និងបៀតបៀនអ្នកដទៃផង ដូចជាព្រះសោលគ្គេរជាតួយ៉ាងស្រាប់ហើយ ។

ព្រះសោលគ្គេរ លោកបានធ្វើសេចក្តីល្អទុកជាច្រើន ដោយលោកបានជួយផ្សព្វផ្សាយព្រះធម៌វិន័យ របស់ព្រះលោកនាយក ឲ្យមហាជនបានយល់ដឹងក្នុងរឿងធម្មៈ ដើម្បីបានជាកិច្ចបដិបត្តិក្នុងជីវិតឲ្យប្រព្រឹត្តទៅដើម្បីប្រយោជន៍ ។

ព្រះសោលត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។៚

( ជីវប្រវត្តិរបស់ព្រះសោលត្ថេរ ចប់ )

## ជីវប្រវត្តិរបស់ព្រះឧទាយិត្ថេរ

### “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះឧទាយិត្ថេរ លោកជាព្រះអរិយបុគ្គលទ្រទ្រង់នូវគុណ ជាពិសេសនោះ លោកក៏បានទទួលនូវការលើកតម្កើង ពីព្រះទសពល

ដោយសង្គ្រោះលោកចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវក គឺជាសាវកធំរបស់ព្រះពុទ្ធ ៨០ រូប លោកក៏បានជាកម្លាំងដ៏សំខាន់នៅក្នុងការប្រកាសសាសនព្រហ្មចរិយធម៌នេះ ឲ្យផ្សព្វផ្សាយទៅដល់មហាជន ឲ្យបានយល់ដឹង ទាំងមហាជនក៏បានស្គាល់លោក ដោយព្រះឧទាយិត្ថេរ លោកជាអ្នកមានប្រក្រតីពោលនូវសោឡសធម្មោវាទទុកជាវចនសារគតិ ដែលជាលក្ខគោលសម្ដែងថា លោកតែងតែមាននូវអធ្យាស្រ័យលើកនូវពុទ្ធោវាទមក ដើម្បីដោះស្រាយ ដល់បុគ្គលដែលមានការយល់ខុស ឲ្យត្រឡប់មកយល់ត្រូវវិញ ។

ជីវប្រវត្តិរបស់ព្រះឧទាយិត្ថេរ មានសម្ដែងទុកទាំងអតីតជាតិនិងបច្ចុប្បន្នជាតិ ដូចមានសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** មានសេចក្ដីថា ៈ-

ព្រះឧទាយិត្ថេរ លោកក៏ធ្លាប់បានធ្វើបុណ្យកុសល ទុកមកជាច្រើនណាស់ហើយ ដូចធ្វើទុកក្នុងសម្នាក់ព្រះពុទ្ធ ក្នុងអតីតជាតិដែលត្រាស់ដឹងកន្លងរួចមកហើយ ដើម្បីឲ្យបានជាឧបនិស្ស័យនៃព្រះនិព្វាន ដោយអំណាចបុណ្យកុសលនេះ ក៏បានធ្វើឲ្យលោកមានការ

ត្រាច់វង្គាត់ជាមនុស្ស និងទេវតាអស់កាលដ៏យូរអង្វែង ។ លុះមកដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូនៃយើងនេះ លោកក៏បានមកកើតនៅក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងក្រុងកបិលពស្តុ ដែលមានឈ្មោះថា **ឧទាយិ** ។ បិតារបស់លោកមានឈ្មោះថា **មហាឧទាយិ** ។ ការសិក្សារបស់លោក ដែលចាប់ផ្តើមជាមុនដំបូងនោះ ក្រោយអំពីលោកធំដឹងក្តី ល្មមអាចនឹងសិក្សារៀនសូត្របានហើយ លោកក៏បានសិក្សាវិជ្ជាត្រៃវេទ ដែលជាវិជ្ជាប្រចាំវង្សត្រកូល នៃបុព្វបុរសរបស់លោក ព្រោះជាទំនៀមរបស់ពពួកព្រាហ្មណ៍ ដែលនឹងតម្រូវឲ្យកូនរបស់ខ្លួន សិក្សាវិជ្ជាត្រៃវេទ ទុកជាកិត្តិយសប្រចាំខ្លួន និងដើម្បីក្នុងការចិញ្ចឹមជីវិតទៅអនាគត ។ ហេតុដែលឧទាយិមាណព ចូលមកជួបពន្លឺនៃព្រះធម៌ ក្នុងព្រះពុទ្ធសាសនានេះ ព្រមទាំងបានយកព្រះរតនត្រៃជាទីពឹង ជាទីរឭក និងចូលមកប្រព្រឹត្តក្នុងសាសនមណ្ឌលនេះ ដោយសារលោក បានឃើញនូវពុទ្ធានុភាព ដែលព្រះអង្គទ្រង់សម្តែងក្នុងទីប្រជុំនៃព្រះញាតិ ដើម្បីឲ្យព្រះញាតិលះបង់នូវទិដ្ឋិ មានះ ហើយមកគោរពប្រតិបត្តិព្រះអង្គ ។

ដូចមានរឿងតំណាលទុកក្នុង **អដ្ឋកថាតតិយសមន្តប្បាសាទិកា** នៃ **រឿងពាហុលវត្ថុកថា** ក្នុង **អដ្ឋកថាខុទ្ទកនិកាយជាតក** ក្នុង **រឿងវេស្សន្តរ** និងក្នុង **អដ្ឋកថាវិសុទ្ធិជនបទ** និងក្នុង **គម្ពីរបឋមសម្ពោធិកថា** មានសេចក្តីថា ៖-

សម័យមួយ ព្រះមានជោគ ស្តេចយាងចេញចាកក្រុងរាជគ្រឹះមកកាន់នគរកបិលពស្តុជាលើកដំបូងនោះ តាមព្រះរាជបំណងរបស់ព្រះបាទសុទ្ធោទនៈ ដែលជាពុទ្ធបិតា ដោយមានព្រះកាឡុទាយិត្ថេរជាមគ្គុទ្ទេសក៏ ក៏បាននាំព្រះអង្គយាងមកកាន់នគរកបិលពស្តុ ។ គ្រានោះ ពួកសក្យរាជទាំងឡាយ បានប្រឹក្សាគ្នាថា ពួកយើងនឹងបានឃើញព្រះសិទ្ធត្ថកុមារ ទ្រង់ជាព្រះញាតិ ដ៏ប្រសើររបស់ពួកយើងៗគួរនឹងរៀបចំនិគ្រោធារាម ថ្វាយជាទីប្រថាប់គង់សម្រាក ហើយទើបនាំគ្នាចាត់ចែងរៀបចំធ្វើបានយ៉ាងល្អ ពេលដែលពពួកព្រះញាតិចេញទៅទទួល ទ្រង់នាំគ្នាកាន់ផ្កាឈើ ព្រមទាំងគ្រឿងក្រអូបជាដើមចេញទៅព្រមគ្នា និងបានត្រាស់បញ្ជាឲ្យពួកក្មេងប្រុស-ស្រី នៅក្នុងក្រុងឲ្យតាក់តែងរាងកាយយ៉ាងរៀបរយល្អឥតខ្ចោះ ចេញដើរនាំមុខ លំដាប់តមកពពួករាជកុមារ-កុមារី ហើយលំដាប់តមក ទើបពពួកព្រះញាតិ

ចាស់ៗ មានព្រះបាទសុទ្ធោទនៈ ជាព្រះប្រធាន ស្តេចបានចេញទៅទទួល និងក្រាបទូលអារាធនា ព្រះមានព្រះភាគឲ្យស្តេចទៅសម្រាកនៅក្នុងនិគ្រោធារាម ។ ពួកសក្យរាជចាស់ៗ មួយព្រះអង្គៗ មានមានះក្រអឺតក្រទម មិនព្រមថ្វាយបង្គំ ដោយទ្រង់គិតថា សិទ្ធត្ថកុមារនៅក្មេងជាងយើង មានព្រះជន្មស្មើគ្នា នឹងព្រះកនិដ្ឋា គឺប្អូន ស្មើនឹងព្រះភាគិនេយ្យ គឺក្មួយ ( ជាកូនរបស់ ប្អូនស្រី-ប្រុស ) ស្មើគ្នានឹងព្រះរាជឱរស ឬកូនប្រុស ឬស្មើគ្នានឹងព្រះរាជនត្តា គឺចៅនៃប្អូនយើង ទើបបញ្ជាព្រះរាជកុមារក្មេងៗ កំលោះថា ពួកអ្នកចូរថ្វាយបង្គំព្រះមុនី ពួកខ្ញុំនឹងអង្គុយខាងក្រោយពួកអ្នក ។ កាលបើពួកសក្យរាជទាំងនោះមិនព្រមថ្វាយបង្គំព្រះមុនី បាននៅគង់ប្រថាប់ធ្វើជាព្រងើយ គ្រានោះព្រះអង្គទ្រង់ជ្រាប ដល់អធ្យាស្រ័យរបស់សក្យរាជទាំងនោះ ព្រះអង្គត្រិះរិះគិតថា ពួកព្រះញាតិមិនព្រមសំពះ ឬថ្វាយបង្គំតថាគតៗ គួរនឹងធ្វើឲ្យពពួកព្រះញាតិថ្វាយបង្គំតថាគតទាល់តែបាន ទើបព្រះភគវាទ្រង់ចូលចតុត្ថជ្ឈាន ( ឈានទី ៤ ជាអ្នកបានចូលទៅកាន់ចតុត្ថជ្ឈានហើយ ទើបបានអភិញ្ញា ៦ គឺសម្តែងឫទ្ធិបាន ) ដែលជាទីតាំងនៃអភិញ្ញា ទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ទើបទ្រង់ហោះឡើងទៅលើ

អាកាសដោយឫទ្ធិ ទ្រង់បានសម្តែងបាដិហារិយ៍ ដែលស្រដៀងប្រហាក់ប្រហែលគ្នានឹងយមកបាដិហារិយ៍ ដែលទ្រង់សម្តែងនៅទៀបគល់ពោធិព្រឹក្ស ហាក់បីដូចថា ទ្រង់នឹងរោយធូលីព្រះបាទ ធ្លាក់ចុះលើព្រះសិរនៃពពួកញាតិទាំងនោះ ។ លំដាប់នោះ ព្រះបាទសុទ្ធោទនៈទ្រង់បានទត ឃើញនូវភាពអស្ចារ្យទាំងនោះហើយ ទើបទ្រង់ត្រាស់ថា បពិត្រព្រះមុនី ក្នុងថ្ងៃដែលគេលៀងនាំព្រះអង្គចូលទៅ ដើម្បីនឹងឲ្យកាឡទេវិលតាបសបានឃើញនោះ ព្រះយុគលបាទរបស់ព្រះអង្គ ក៏ត្រឡប់ឡើងទៅប្រតិស្ឋាន នៅលើព្រះសិរសារបស់កាឡទេវិលតាបស ទូលព្រះបង្គំបានឃើញហើយក៏ថ្វាយបង្គំ ការថ្វាយបង្គំក្នុងគ្រានោះ ជាបឋមវន្ទនា គឺការថ្វាយបង្គំជាលើកទី ១ ។

ក្នុងថ្ងៃវប្បមង្គល គឺថ្ងៃធ្វើការសាបព្រោះ ឬរដូវសាបព្រោះ, ឬក៏ព្រះរាជពិធីច្រត់ព្រះនង្គ័ល ( សំដៅដល់ការធ្វើស្រែ មានការភ្ជួររាស់ សាបព្រោះ ) ។ កាលព្រះអង្គ ទ្រង់គង់នៅខាងក្រោមដើមព្រីង ទូលព្រះបង្គំ បានក្រឡេកឃើញស្រមោលនៃដើមព្រីង មិនបានងាកបែរផ្លាស់ប្តូរទៅណា ដោយនៅដដែល ទើបធ្វើឲ្យខ្ញុំព្រះអង្គថ្វាយបង្គំជាទុតិយវន្ទនា គឺការក្រាបថ្វាយបង្គំជាលើកទី ២ ។ នៅក្នុងគ្រានេះ

ទូលព្រះបង្គំបានឃើញបាដិហារិយ៍ ដែលមិនធ្លាប់បានឃើញមកពីមុនសោះ ហេតុដូច្នេះ សូមក្រាបថ្វាយបង្គំព្រះបាទារបស់ព្រះពុទ្ធអង្គ ជាតតិយវន្ទនា គឺការក្រាបថ្វាយបង្គំជាលើកទី ៣ ។ ព្រះបាទសុទ្ធោទនៈបានថ្វាយបង្គំព្រះទសពលយ៉ាងនេះហើយ សក្យសូម្បីត្រឹមតែមួយអង្គមិនថ្វាយបង្គំព្រះមានបុណ្យនោះមិនមានឡើយ ដោយមួយអង្គៗ នាំគ្នាក្រាបថ្វាយបង្គំព្រមគ្នាទាំងអស់ ។ ដោយមានសេចក្តីថា ព្រះភគវាទ្រង់ធ្វើឲ្យពពួកព្រះញាតិ ថ្វាយបង្គំព្រះអង្គហើយ ទើបស្តេចចុះចាកអាកាសមកគង់ប្រថាប់នៅលើអាសនៈ ដែលគេតាក់តែងទុកថ្វាយ ។ ពេលដែលព្រះមហាវីរៈ ទ្រង់គង់ប្រថាប់រៀបរយហើយ សមាគមនៃពពួកព្រះញាតិ បានដល់នូវទីបំផុត ( គឺអស់មានះ ) និងទាំងពពួកព្រះញាតិ ក៏មានព្រះទ័យត្រេកអរ ហើយអង្គុយប្រជុំគ្នា ក្នុងទីជាមួយគ្នា ។ គ្រានោះ មហាមេឃមីរដេរដាស ស្រទំ ហើយបង្អុរនូវទឹកភ្លៀងបោក្ខរព័ស៌ចុះមក មានពណ៌ក្រហមដូចទឹកល័ខ ឬមានសម្បុរដូចជាជើងព្រាប កាលបើបង្អុរចុះមកហើយ ក៏ហូរជ្រាបចូលទៅក្នុងដីជរាបទាល់តែអស់ ( មិនមានសេសសល់ឡើយ ដោរជន់នៅលើផ្ទៃដី ដូចទឹកភ្លៀងតាមធម្មតានោះទេ បើអ្នកណាប្រាថ្នាទទឹក ក៏ទទឹក បើអ្នក

ណាមិនប្រាថ្នាទទឹកទេ ក៏មិនទទឹកដែរ ) ទឹកភ្លៀងទាំងនោះ សូម្បីតែមួយតំណក់ ក៏មិនបានស្រក់ដាក់លើសិរសាអ្នកណាៗ ឡើយ ។ ពពួកព្រះញាតិទាំងនោះ បានឃើញហេតុដ៏អស្ចារ្យទាំងនោះហើយ ក៏បាននាំគ្នាពោលឡើងថា គួរឲ្យអស្ចារ្យពិតមែនៗ ។ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ភ្លៀងបោក្ខរពស៌បង្អុរចុះមកក្នុងសមាគមនៃពពួកញាតិរបស់តថាគត មិនមែនមានតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ដែលតថាគតជាព្រះពោធិសត្វ ក៏បានធ្លាប់ធ្លាក់ចុះមកមានសភាពយ៉ាងនេះដែរ ព្រះអង្គក៏ទ្រង់ត្រាស់តំណាលរឿង ព្រះវេស្សន្តរជាតកប្រោសដល់ពពួកព្រះញាតិ ។ ចំណែកពពួកព្រះញាតិទាំងអស់នោះបានស្តាប់ព្រះធម៌ទេសនាចប់ហើយ ស្តេចក៏ក្រោកឡើង ថ្វាយបង្គំព្រះពុទ្ធអង្គរួចហើយ ធ្វើប្រទក្សិណ គឺដើរវិលខាងស្តាំជុំវិញព្រះមុនីហើយ ទ្រង់នាំគ្នាគេចចេញទៅ ។

ចំណែករឿងការចេញបួសរបស់ព្រះឧទាយិត្ថេរ មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៈ-

កាលឧទាយិមាណព បានឃើញពុទ្ធានុភាព ដែលព្រះពុទ្ធជាម្ចាស់ ទ្រង់ធ្វើបាដិហារិយ៍ ដើម្បីកម្ចាត់នូវមានះ គឺការប្រកាន់ខ្លួននៃពពួកព្រះញាតិនោះហើយ ពពួកព្រះញាតិទាំងនោះ ក៏មានសេចក្ដីជ្រះថ្លា ចំពោះព្រះមានបុណ្យយ៉ាងស៊ប់ស្លួន ទើបនាំគ្នាសម្រេចចិត្តចេញបព្វជ្ជាឧបសម្បទា នៅក្នុងព្រះពុទ្ធសាសនានេះជាច្រើន ។ កាលឧទាយិបួសជាភិក្ខុហើយ លោកក៏ជាអ្នកមិនទាន់មានចំណេះដឹង ក្នុងព្រះធម៌វិន័យអ្វីប៉ុន្មានដែរ ដូចមានរឿងតំណាល ដែលទាក់ទង ក្នុងការអួតអាងចំណេះដឹងរបស់លោក ដោយភិក្ខុខ្លះយល់ច្រឡំថា ព្រះឧទាយិជាអ្នកចេះដឹង ឬជាព្រះថេរៈ ។

រឿងទំនងយ៉ាងនេះ ដូចមានរឿងតំណាលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ពាលវគ្គ** **ក្នុងរឿងព្រះឧទាយិត្ថេរ** មានសេចក្ដីថា ៖-

សម័យមួយ ព្រះទសពល ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ត្រាស់សម្ដែងព្រះធម៌ប្រារព្ធចំពោះព្រះឧទាយិ ដោយព្រះឧទាយិកាលដែលភិក្ខុជាព្រះថេរៈ បានក្រោកចាកសាលាធម្មសភាចេញទៅហើយ ព្រះឧទាយិត្ថេរ ក៏បានឡើងទៅគង់លើធម្មាសនៈ ។ នៅក្នុងថ្ងៃមួយ មានភិក្ខុជាអាគន្តុកៈ ( ភិក្ខុដែលទើបតែមកដល់ថ្មី ) ភិក្ខុ

ទាំងនោះ បានក្រឡេកឃើញព្រះឧទាយិត្ថេរ ដោយយល់ថា ភិក្ខុរូបនេះជាមហាថេរៈ ជាពហូសូត គឺជាអ្នកចេះដឹងច្រើន ទើបបានសួរបញ្ហាដែលប្រកបដោយខន្ធជាដើម តែព្រះឧទាយិត្ថេរ មិនអាចឆ្លើយបាន ភិក្ខុអាគន្តុកៈទាំងនោះ ក៏នាំគ្នាពោលតិះដៀលថា ព្រះឧទាយិមិនគួរនឹងមិនចេះនូវពុទ្ធវចនៈអ្វីៗ សោះ តើសមជាព្រះថេរៈដូចម្តេចទៅថែមទាំងជាអ្នកនៅរួមជាមួយនឹងព្រះសម្ពុទ្ធទៀត ដូច្នេះ មិនសមជាអ្នកមិនចេះដឹងក្នុងធម៌សូម្បីថា ខន្ធ ធាតុ និងអាយតនៈសោះ ពោលដូច្នេះហើយ ទើបនាំគ្នាចូលទៅក្រាបទូល ការប្រព្រឹត្តរបស់ព្រះឧទាយិដល់ព្រះលោកនាយក ។ ព្រះទសពល កាលបើបានស្តាប់ការក្រាបទូលរបស់ភិក្ខុអាគន្តុកៈនោះហើយ ព្រះភគវាក៏បានសម្តែងធម៌ឲ្យដល់ភិក្ខុអាគន្តុកៈនោះបានស្តាប់ ដោយទ្រង់ត្រាស់ព្រះគាថាថា បុគ្គលពាលសូម្បីនៅអង្គុយជិតបណ្ឌិត សូម្បីរហូតអស់មួយជីវិត ក៏គេរមែងមិនដឹងធម៌ ដូចវែកដែលមិនដឹងរសជាតិនៃសម្ល ។ ក្នុងសេចក្តីនេះ ព្រះអដ្ឋកថាចារ្យ បានពោលអធិប្បាយសេចក្តីនៃពាក្យថា **ដូចវែកមិនដឹងរសជាតិនៃសម្លថា** វែកសូម្បីមនុស្សប្រើ ដោយវិធីផ្សេងៗ រហូតដល់សឹករិចរិល ក៏រមែងមិនដឹងរសជាតិនៃសម្លថា នេះរសប្រៃ សាប ល្វីង

ជូរ ចត់ ហឹរ ឬរសនេះមិនជូរជាដើម យ៉ាងណាមិញ បុគ្គលពាល សូម្បីអង្គុយនៅជិតបណ្ឌិត រហូតអស់មួយជីវិត រមែងមិនដឹងនូវព្រះធម៌វិន័យដូច្នោះដែរ ។

ចំណែករឿងការសម្តែងធម៌របស់ព្រះឧទាយិត្ថេរ ដែលជាដើមហេតុឲ្យព្រះបរមគ្រូ ទ្រង់ត្រាស់សម្តែងអង្គនៃធម្មកថិក ( អ្នកសម្តែងធម៌ ) មាន ៥ ប្រការ តាមដែលមានពោលនៅក្នុង **គម្ពីរខុទ្ទកនិកាយ បញ្ចកនិបាត** នៃ **ឧទាយិសូត្រ** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះភគវា ទ្រង់គង់ប្រថាប់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ ក៏ក្នុងសម័យនោះឯង ព្រះឧទាយិ គង់សម្តែងធម៌នៅកណ្តាលពួកបរិស័ទ ដែលមកប្រជុំគ្នាយ៉ាងកុះករ ។ គ្រានោះព្រះអានន្ទត្ថេរ បានឃើញព្រះឧទាយិត្ថេរ មានពួកបរិស័ទជាគ្រហស្ថអង្គុយនៅពទ្ធជុំវិញជាច្រើន ដោយលោកកំពុងតែសម្តែងព្រះធម៌នោះ ព្រះអានន្ទ កាលបើបានជ្រាបដូច្នេះហើយ ទើបចូលទៅគាល់ព្រះមុនីដល់ទីគង់ប្រថាប់ ថ្វាយបង្គំរួចហើយ អង្គុយក្នុងទីដ៏សមគួរ បន្ទាប់មកបានទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧទាយិត្ថេរ មានគ្រហស្ថបរិស័ទជាច្រើនអង្គុយនៅជុំវិញ ដោយព្រះឧទាយិកំពុងតែសម្តែងព្រះ

ធម៌ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់ថា ម្នាលអានន្ទ ការសម្ដែងព្រះធម៌ដល់អ្នកដទៃ មិនមែនជាការធ្វើបានដោយងាយៗទេ ភិក្ខុកាលសម្ដែងធម៌ឲ្យដល់អ្នកដទៃ គប្បីប្រកបដោយអង្គ ៥ ប្រការ ហើយទើបសម្ដែងធម៌ឲ្យដល់អ្នកដទៃស្ដាប់ ។ ធម៌ ៥ ប្រការនោះ បានដល់អ្វីខ្លះ ? ១- សម្ដែងទៅដោយលំដាប់មិនកាត់ឲ្យខាតខូចសេចក្ដី ។ ២- លើកអាងហេតុផលមកណែនាំឲ្យអ្នកស្ដាប់យល់ចូលចិត្ត ។ ៣- តាំងចិត្តមេត្តាប្រាថ្នាឲ្យជាប្រយោជន៍ដល់អ្នកស្ដាប់ ។ ៤- មិនសម្ដែងធម៌ព្រោះឃើញដល់លាភ ។ ៥- មិនសម្ដែងធម៌បន្ទាបខ្លួន និងអ្នកដទៃ គឺមិនលើកខ្លួនឯង សង្កត់សង្កិនអ្នកដទៃ ។ ម្នាលអានន្ទការសម្ដែងធម៌ដល់អ្នកដទៃ មិនមែនជាការធ្វើបានដោយងាយទេ កាលភិក្ខុនឹងសម្ដែងធម៌ឲ្យដល់អ្នកដទៃនោះ គប្បីប្រកបដោយអង្គ ៥ ប្រការនេះ ហើយទើបគួរសម្ដែងធម៌ឲ្យដល់អ្នកដទៃបាន ។

ការក្រាបទូលទាក់ទងនឹងរឿងការឆាន់ក្នុងវេលាវិកាល គឺតាំងពីពេលថ្ងៃជ្រេរទៅហើយ របស់ព្រះឧទាយិត្ថេរ រាប់ថាជារឿងដែលមានប្រយោជន៍ ដែលជាហេតុធ្វើឲ្យព្រះជិនស្រី ទ្រង់បញ្ញត្តសិក្ខាបទដោយឲ្យភិក្ខុទាំងឡាយ វៀរចាកការឆាន់នៅក្នុងពេលវិកាល ដូចមាន

រឿងសម្ដែងប្រាកដនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** នៃ **លដុកិកោបមសូត្រ** គឺពោលដោយផលនៃ **វិកាលភោជនៈ** ដូចមាន សេចក្ដីថា ៖-

សម័យមួយ ព្រះភគវា ទ្រង់គង់ប្រថាប់នៅក្នុងអាបណនិគម នៃដែនអង្គុត្តរាបៈ ដោយទ្រង់អាស្រ័យនៅក្នុងនិគមនៃអ្នកអង្គុត្តរាបៈ ជាទីគោចរ ។ ពេលព្រឹកថ្ងៃមួយ ព្រះភគវា ទ្រង់ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរចូលទៅបិណ្ឌបាតក្នុងអាបណនិគម ។ កាលស្ដេចត្រឡប់ពីបិណ្ឌបាតក្នុងពេលសោយរួចស្រេចហើយ ទើបស្ដេចទៅគង់សម្រាកពេលថ្ងៃ នៅទៀបគល់នៃដើមឈើមួយដើម ដែលនៅក្នុងព្រៃមួយកន្លែង ។ ចំណែកព្រះឧទាយិត្ថេរ ពេលត្រឡប់ពីបិណ្ឌបាត នៅក្នុងអាបណនិគមហើយ ទើបចូលទៅគង់សម្រាកពេលថ្ងៃ នៅទៀបគល់នៃដើមឈើមួយដើមដែលនៅក្នុងព្រៃ ដែលព្រះលោកនាថ ទ្រង់គង់សម្រាកនោះ ( នៅក្នុងព្រៃជាមួយគ្នា ) ។ ពេលដែលព្រះឧទាយិត្ថេរ នៅក្នុងទីពួនសំងំដូច្នោះ បាននឹកគិតឡើងថា ព្រះសាស្ដា ទ្រង់ជាអ្នកចេញចាកនូវវត្ថុដែលជាទុក្ខ ទ្រង់ជាអ្នកនាំចូលនូវវត្ថុដែលជាសុខដល់ពួកសត្វទាំងឡាយ ទ្រង់ជាអ្នកនាំចេញនូវអកុសលធម៌ ទ្រង់ជាអ្នកនាំ

ចូលនូវកុសលធម៌ដល់សត្វលោកដោយច្រើន ។ លុះដល់ពេលល្ងាច ព្រះឧទាយិបានចេញអំពីទីពួនសំងំនោះហើយ បានចូលទៅគាល់ព្រះមហាមុនី រួចថ្វាយបង្គំ ហើយទើបអង្គុយនៅក្នុងទីដ៏សមគួរ ។ កាលលោកអង្គុយរៀបរយហើយ បានក្រាបទូលដល់ការគិតរបស់ខ្លួន ឲ្យព្រះមានបុណ្យទ្រង់ជ្រាប និងក្រាបទូលតទៅថា បពិត្រព្រះទសពល កាលខ្ញុំព្រះអង្គឆាន់ចង្ហាន់ទាំងក្នុងពេលល្ងាច និងព្រឹក រហូតដល់ពេលដែលជាវិកាល តែព្រះមានជោគទ្រង់ហាមថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់ការឆាន់ក្នុងពេលវិកាល ខ្ញុំព្រះអង្គកើតការតូចចិត្ត កើតការអន់ចិត្ត ពួកគហបតីដែលមានសទ្ធា បានថ្វាយចង្ហាន់ដ៏ប្រណីត ដល់ពួកខ្ញុំព្រះអង្គក្នុងពេលវិកាល គឺក្នុងពេលតាំងអំពីថ្ងៃជ្រេទៅហើយ តែព្រះពុទ្ធអង្គទ្រង់ហាម ទ្រង់ឲ្យឈប់ ពួកខ្ញុំព្រះអង្គកាលក្រឡេកឃើញសេចក្ដីស្រឡាញ់ ការគោរព ការអៀនខ្មាស និងការកោតក្រែងចំពោះព្រះមហាមុនី ក៏នាំគ្នាឈប់ឆាន់ចង្ហាន់ ក្នុងពេលវិកាល គឺពេលថ្ងៃរសៀល តែនៅឆាន់ចង្ហាន់ក្នុងពេលព្រឹក និងល្ងាចប៉ុណ្ណោះ ហើយព្រះជិនស្រីទ្រង់ហាមទៀតថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយ ចូរឈប់ឆាន់ចង្ហាន់ក្នុងពេលវិកាល គឺតាំងពីពេល

ល្ងាចទៅ រហូតដល់ពេលអរុណរះឡើង ( អរុណ ពេលជិតរះឡើង នៃព្រះអាទិត្យ មានពីររយៈ គឺមានពន្លឺសព្រាងៗ ( ពន្លឺប្រាក់ ) និង ពន្លឺក្រហម ( ពន្លឺមាស ) ។

ខ្ញុំព្រះអង្គក៏កើតការទោមនស្ស គឺខូចចិត្តថា ព្រះលោកនាយក ទ្រង់បានហាមនូវអាហារដ៏ប្រណីត ដែលជាអាហារល្ងាចរបស់បុគ្គល ទាំងឡាយ បពិត្រព្រះសុគត កាលពីមុនមានបុរសម្នាក់ បានបាយ ក្នុងពេលថ្ងៃ ទើបប្រាប់ភរិយាថា នាងចូររក្សាទុកសម្រាប់ទទួលទាន ព្រមគ្នាក្នុងពេលល្ងាច ព្រោះពេលយប់ត្រូវការបរិភោគអាហារច្រើន ចំណែកពេលថ្ងៃ បរិភោគត្រឹមតែបន្តិចបន្តួចក៏បាន តែពួកខ្ញុំព្រះអង្គ ឃើញដល់ការស្រឡាញ់ ការគោរព ការអៀនខ្មាស ការកោតក្រែង ចំពោះព្រះសម្មាសម្ពុទ្ធ ទើបបាននាំគ្នាឈប់ឆាន់ចង្ហាន់ក្នុងពេលវិកាល និងពេលយប់ ។ បពិត្រព្រះសាស្តា រឿងធ្លាប់មានរួចមកហើយ ដោយភិក្ខុពួកខ្លះ ត្រាច់ទៅបិណ្ឌបាត ក្នុងពេលយប់ងងឹត ដើរទៅ ធ្លាក់ក្នុងអណ្តូងទឹកខ្លះ ធ្លាក់ក្នុងរណ្តៅស្មោកគ្រោកខ្លះ ដោយដើរជាន់ លើបន្លាខ្លះ ដោយដើរជាន់ឡើងទៅលើខ្នងគោ ដែលកំពុងដេកលក់ ខ្លះ ដោយដើរទៅជួបនឹងពពួកចោរ កំពុងធ្វើចោរកម្មខ្លះ ឬនៅមិន

ទាន់ធ្វើសកម្មភាពល្អចុះ ដោយដើរទៅជួបនឹងមាតុគ្រាម ហើយបបួលភិក្ខុទាំងនោះ ក្នុងរឿងអសទ្ធម្មខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានរួចមកហើយ ខ្ញុំព្រះអង្គបានត្រាច់ទៅបិណ្ឌបាត នៅក្នុងពេលងងឹតថ្ងៃមួយ បានទៅជួបនឹងស្រីម្នាក់ ដែលកំពុងតែលាងភាជនៈ ហើយបានក្រឡេកឃើញខ្ញុំព្រះអង្គ ដោយមានពន្លឺផ្លេកបន្ទោរ ក្នុងពេលនោះ នាងក៏ភ័យរន្ធត់ចិត្ត ស្រែកភ្ញាក់មាត់ឡើងថា បិសាចនឹងស៊ីយើងហើយ ខ្ញុំព្រះអង្គទើបពោលថា នែប្អូនស្រី អាត្មាមិនមែនបិសាចទេ អាត្មាជាភិក្ខុមកដើម្បីបិណ្ឌបាត ស្រីនោះទើបពោលថា លោកម្ចាស់ មាតាបិតា លោកម្ចាស់ស្លាប់អស់ហើយឬ ការដែលលោកម្ចាស់ យកកាំបិតដ៏មុត ដែលមនុស្សសម្រាប់យកទៅពន្លះគោ យកមកកាត់ផ្ទៃរបស់លោកម្ចាស់ ចោលចេញទៅ នៅតែល្អជាង ការដែលលោកម្ចាស់ ត្រាច់បិណ្ឌបាតក្នុងពេលកណ្តាលយប់ងងឹត ព្រោះហេតុឃើញតែផ្ទៃ ដូច្នេះ មិនមែនជាការល្អឡើយ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គ នឹកដល់រឿងទាំងនោះ ទើបធ្វើឲ្យខ្ញុំព្រះអង្គកើតការគិតឡើងថា ព្រះមានព្រះភាគទ្រង់បាននាំនូវសេចក្តីទុក្ខជាច្រើន របស់ខ្ញុំព្រះអង្គចេញទៅ ទ្រង់បាន

នាំនូវសេចក្តីសុខចូលមកឲ្យខ្ញុំព្រះអង្គវិញ ។ ព្រះមានជោគ ព្រះអង្គបាននាំនូវអកុសលធម៌ របស់ខ្ញុំព្រះអង្គចេញទៅហើយ ព្រះអង្គក៏បាននាំកុសលធម៌ ចូលមកឲ្យខ្ញុំព្រះអង្គវិញ ។ គ្រានោះ ព្រះមានបុណ្យទ្រង់ត្រាស់ឧបមាឲ្យស្តាប់ថា ម្នាលឧទាយិ ភិក្ខុជាមោឃបុរសពួកខ្លះក្នុងធម្មវិន័យនេះ កាលតថាគតពោលថា អ្នកទាំងឡាយចូរលះបង់ទោសនេះចេញ គេត្រឡប់ជាពោលយ៉ាងនេះវិញថា ដូចម្តេច ក៏ព្រះលោកនាយកនឹងត្រូវពោលថា ព្រោះហេតុនៃទោសត្រឹមតែបន្តិចបន្តួចដូចនេះ ព្រះសមណគោតម ពូកែខាងដុសខាត់ហួសពេក ពួកមោឃបុរសទាំងនោះ ទើបមិនលះបង់នូវទោសនោះចេញ និងមិនមានការគោរពកោតក្រែង ចំពោះតថាគតឡើយ ទាំងក្នុងពួកភិក្ខុដែលជាព្រះថេរៈ ម្នាលឧទាយិ ពួកមោឃបុរសទាំងនោះ មានគ្រឿងចងដ៏មានកម្លាំងមាំមួន មិនពុកផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលចងជាប់ទុកនៅត្រង់-ក ដូច្នោះ ។ ម្នាលឧទាយិ សត្វប្រចៀចញី ដែលគេចងដោយវល្លិ៍ត្អើក រមែងរង់ចាំតែពេលស្លាប់ ពេលជាប់ឃុំ ឬស្លាប់នៅក្នុងទីនោះ បុគ្គលគប្បីពោលថា គ្រឿងចងរបស់សត្វប្រចៀចញីគឺវល្លិ៍ត្អើកនោះ ជាគ្រឿងចងមិនមានកម្លាំង មានសរសៃតូចឆ្មារ ពុក

ផុយ មិនមានខ្លឹមសារ នឹងហៅបុគ្គលនោះថា ពោលត្រូវឬទេ ? គ្រានោះ ព្រះឧទាយិក្រាបទូលថា មិនត្រូវទេព្រះអង្គ ព្រោះគ្រឿងចងរបស់សត្វប្រចៀចញី គឺវល្លិត្រអ៊ុកនោះ ជាគ្រឿងចង ដ៏មានកម្លាំងមាំមួន រឹងមាំ ជាគ្រឿងចងដែលមិនងាយពុកផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលចងទុកនៅត្រង់-ក ។

គ្រានោះ ព្រះសម្ពុទ្ធ ទើបទ្រង់ត្រាស់ទៀតថា ម្នាលឧទាយិ ពួកមោឃបុរសពួកខ្លះក្នុងធម្មវិន័យនេះ ក៏ដូច្នោះដែរ កាលបើតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ទោសនេះចេញ តែគេត្រឡប់ពោលយ៉ាងនេះវិញថា ដូចម្តេចព្រះគោតមនឹងត្រូវពោលថា ព្រោះហេតុនៃទោសត្រឹមតែបន្តិចបន្តួចដូច្នេះសោះ ព្រះសមណគោតមនេះទ្រង់ជំនាញខាងដុសខាត់ហួសពេក ពួកមោឃបុរសទាំងនោះ ទើបមិនព្រមលះបង់នូវទោសនោះចេញ ទាំងមិនព្រមធ្វើការគោរពកោតក្រែងចំពោះតថាគតឡើយ និងភិក្ខុដែលជាថេរៈ ម្នាលឧទាយិ មោឃ-បុរសទាំងនោះ មាននូវគ្រឿងចង មានកម្លាំងរឹងមាំ មាំមួន ជាគ្រឿងចង ដែលមិនងាយរលួយផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលចងជាប់ទុកនៅត្រង់-ក ដូច្នោះដែរ ។ ព្រះអង្គក៏ទ្រង់ត្រាស់ប្រៀប

ជៀបបន្តទៅទៀតថា ម្នាលឧទាយិ ចំណែកកុលបុត្រពួកខ្លះ នៅក្នុងធម្មវិន័យនេះ កាលបើតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវទោសនេះចេញ គេត្រឡប់ជាពោលយ៉ាងនេះថា ដូចម្តេចនឹងត្រូវឲ្យព្រះវិជិតមារ ទ្រង់ជាអ្នកជាស់តឿន ព្រោះហេតុនៃទោសបន្តិចបន្តួចប៉ុណ្ណោះដែលគួរលះបង់ ដោយព្រះជិនស្រីទ្រង់ត្រាស់ឲ្យពួកយើងលះបង់ គេរមែងលះបង់ទោសនោះ នឹងមានការគោរពកោតក្រែងចំពោះតថាគត ទាំងនៅក្នុងពួកភិក្ខុដែលជាថេរៈ ៗ មួយទៀត ភិក្ខុទាំងនោះលះបង់នូវទោសនោះហើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មានការចិញ្ចឹមជីវិតដោយវត្ថុ ដែលអ្នកដទៃឲ្យ នៅដោយចិត្តដូចគ្នានឹងសត្វម្រឹគក្នុងព្រៃ ទោសសូម្បីត្រឹមតែបន្តិចបន្តួច របស់ភិក្ខុទាំងនោះប្រៀបដូចដំរី មានភ្លុកដ៏ល្អឥតខ្ចោះ ជារាជពាហនៈដ៏ប្រសើរ ធ្លាប់ចូលទៅក្នុងសង្គ្រាម ហ្មដំរីចងដោយខ្សែដ៏មាំមួន កាលងាកខ្លួនទៅបានបន្តិច ក៏ធ្វើឲ្យគ្រឿងចងទាំងនោះដាច់អស់ ហើយគេរត់គេចទៅតាមការពេញចិត្តរបស់ខ្លួន យ៉ាងណាមិញ បុគ្គលណា ដែលពោលយ៉ាងនេះថា គ្រឿងចងដំរីដោយខ្សែនេះ ជាគ្រឿងចងមានកម្លាំងមាំមួន រឹងមាំ មិនពុកផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលបុគ្គល

ចងទុកត្រង់-ក នឹងហៅថា បុគ្គលនោះពោលត្រឹមត្រូវឬទេ ? ព្រះឧទាយិក្រាបទូលតបថា មិនត្រឹមត្រូវទេ ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ពីព្រោះកាលដំរីនោះរាកខ្លួនទៅបានបន្តិច ក៏ធ្វើឲ្យគ្រឿងចងទាំងនោះដាច់អស់ ហើយគេរត់គេចទៅតាមចិត្ត គ្រឿងចងដំរីនោះជាគ្រឿងចងមិនមានកម្លាំង ពុកផុយ ដាច់អស់មិនមានខ្លឹមសារ ។

ព្រះមានព្រះភាគទើបទ្រង់ត្រាស់ទៀតថា ពួកកុលបុត្រពួកខ្លះក្នុងធម្មវិន័យនេះ ក៏ដូច្នោះដែរ កាលតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវទោសនោះចេញ គេក៏ត្រឡប់ជាពោលយ៉ាងនេះវិញថា ដូចម្តេចនឹងត្រូវឲ្យព្រះគោតម ទ្រង់ដាស់តឿន ឲ្យលះបង់ទោសបន្តិចបន្តួចដែលគួរលះបង់នេះ ដោយព្រះពុទ្ធអង្គ ទ្រង់ត្រាស់ឲ្យពួកយើងលះបង់ ហើយគេរមែងលះបង់នូវទោសនោះ និងមានសេចក្តីគោរពកោតក្រែងចំពោះតថាគត ទាំងពួកភិក្ខុដែលជាថេរៈ ។ មួយវិញទៀតភិក្ខុទាំងនោះ លះបង់ទោសនោះហើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មានការចិញ្ចឹមជីវិតដោយវត្ថុ ដែលអ្នកដទៃឲ្យ នៅដោយចិត្តដូចគ្នានឹងសត្វម្រឹគនៅក្នុងព្រៃ ។ ម្នាលឧទាយិ ទោសសូម្បីត្រឹមតែបន្តិចបន្តួច ដែលភិក្ខុទាំងនោះ គួរតែលះបង់ ជាគ្រឿងចងដែលមិន

មានកម្លាំង ពុកផុយ មិនមានខ្លឹមសារ ។ ព្រះសម្ពុទ្ធ ក៏ទ្រង់ត្រាស់អធិប្បាយ ដោយធ្វើសេចក្តីឧបមាតទៅទៀតថា ម្នាលឧទាយិ ប្រៀបដូចជាបុរសទីទ័លក្រ មិនមានយស មិនមានទ្រព្យសម្បត្តិស្តុកស្តម្ភ គេមានតែខ្ទមតូចមួយ ដែលមានគ្រឿងប្រក់បិទបាំង និងមានគ្រឿងចង់ពុកផុយ ត្រូវចាំស្រែកដេញក្អែក ក្នុងពេលបរិភោគបាយ មានគ្រែមួយចាស់គ្រាំគ្រា មានរូបមិនស្អាត មានស្រូវ និងគ្រាប់ពូជសម្រាប់ព្រោះ ប្រចាំឆ្នាំមួយល្អី និងមិនមានគ្រាប់ពូជល្អ មានស្នុកចាស់គ្រាំគ្រាមួយ មិនល្អ មានឆ្នាំងបាយ និងឆ្នាំងសម្លតែមួយ មានភរិយាម្នាក់ ជាអ្នកមានរូបរាងអាក្រក់ ពេលដែលបុរសនោះ ទៅឃើញភិក្ខុនៅឯវត្ត មានដៃ និងជើងលាងស្អាតល្អ ឆាន់ចង្ហាន់មានរសជាតិឆ្ងាញ់ ហើយអង្គុយធ្វើសមណធម៌នៅក្រោមម្លប់ដ៏ត្រជាក់ បុរសនោះ ទើបគិតថា ភិក្ខុនេះជាអ្នកមានសេចក្តីសុខណាស់ហ្ន៎ ភាពជាសមណៈនេះសុខពិត ភាពជាសមណៈនេះមិនមានរោគ យើងគួរនឹងកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ ចេញបួសជាបព្វជិត តែគេមិនអាចលះបង់ចោលខ្ទមតូចរបស់គេបាន ។ល។ និងភរិយា ដែលមានរូបអាក្រក់របស់គេ ការចេញបួស ជាបព្វជិតបាន

យ៉ាងណាមិញ ម្នាលឧទាយិ បុគ្គលណាពោលយ៉ាងនេះថា គ្រឿងចងរបស់បុរសទីទ័លក្រនោះ ជាគ្រឿងចងដែលមិនមានកម្លាំង ស្គមតកញ៉ែកផុយ ជាគ្រឿងចងដែលមិនមានខ្លឹមសារ បុគ្គលនោះ កាលបើពោលដូច្នោះ ហៅថា ជាការពោលត្រឹមត្រូវដែរឬទេ ? ព្រះឧទាយិក្រាបទូលតបថា មិនត្រឹមត្រូវទេ ព្រះអង្គ ពីព្រោះបុរសជាទីទ័លក្រនោះ មិនអាចលះបង់ចោលនូវរបស់ទាំងនោះ ទៅបួសជាបព្វជិតបាន គ្រឿងចងរបស់គេ ជាគ្រឿងចងដែលមានកម្លាំងមាំមួន រឹងមាំ មិនផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលចងជាប់ទុកនៅត្រង់-ក ។

ព្រះលោកនាថទើបទ្រង់ត្រាស់ជាបន្តទៅទៀតថា ម្នាលឧទាយិ ខ.នេះក៏ដូច្នោះដែរ មានពួកមោឃបុរសពួកខ្លះ នៅក្នុងធម្មវិន័យនេះ កាលតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់នូវទោសនេះចេញ គេត្រឡប់ជាពោលយ៉ាងនេះថា ដូចម្តេចព្រះសមណគោតម នឹងទ្រង់ត្រូវពោលថា ព្រោះហេតុនៃទោសបន្តិចបន្តួចប៉ុណ្ណោះ ព្រះសមណ-គោតមនេះ ទ្រង់ជំនាញខាងជុសខាត់ហួសពេក ពួកគេទាំងនោះ ក៏មិនលះបង់នូវទោសនោះចេញ និងមិនមានការគោរព កោតក្រែងចំពោះតថាគត ទាំងពួកភិក្ខុដែលជាថេរៈ ។ ម្នាលឧទាយិ គ្រឿងចងរបស់

មោយបុរសនោះ ជាគ្រឿងចងដែលមានកម្លាំង រឹងមាំ មាំមួន មិនផុយ ដូចជាកំណាត់ឈើមួយដុំធំ ដែលគេចងជាប់ទុកត្រង់-ក ដូច្នោះឯង ។ គ្រានោះ ព្រះពុទ្ធអង្គទ្រង់បានត្រាស់ប្រៀបធៀបដោយមនុស្សមានទ្រព្យសម្បត្តិស្តុកស្តម្ភតទៅទៀតថា ម្នាលឧទាយិ គហបតី ឬបុត្ររបស់គហបតី ដែលជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានស្រូវ អង្ករច្រើន មានដីស្រែចម្ការ ករិយា ទាសាទាសីជាច្រើន គេបានទៅឃើញភិក្ខុដែលនៅក្នុងអារាម មានដៃ និងជើងលាងស្អាតល្អហើយ ឆាន់ចង្ហាន់មានរសជាតិដែលឆ្ងាញ់ ហើយអង្គុយធ្វើសមណធម៌ នៅត្រង់ម្លប់ដ៏ត្រជាក់ បុគ្គលនោះ ទើបគិតថា ភាពជាសមណៈ នៃភិក្ខុនេះ ជារបស់ខ្ពង់ខ្ពស់ ភាពជាសមណៈរបស់ភិក្ខុនេះ មានសេចក្តីសុខណាស់ មិនមានរោគ យើងគួរកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ចេញបួសជាបព្វជិត គេអាចលះបង់ចោលទ្រព្យសម្បត្តិទាំងអស់ ចេញបួសជាបព្វជិតបាន យ៉ាងណាមិញ ម្នាលឧទាយិ បុគ្គលណាបានពោលថា គ្រឿងចងនៃគហបតី ឬបុត្រនៃគហបតីនោះ ជាគ្រឿងចងដែលមានកម្លាំងមាំមួន រឹងមាំ មិនផុយ ដូចជាកំណាត់

ឈើមួយដុំធំ ដែលចងជាប់ទុកត្រង់-ក បុគ្គលនោះ កាលពោលដូច្នេះ ហៅថា ជាអ្នកពោលត្រឹមត្រូវឬទេ ? ព្រះឧទាយិត្ថេរក្រាបទូលតបថា មិនត្រឹមត្រូវទេព្រះអង្គ ព្រោះគេអាចលះបង់សម្បត្តិទាំងនោះ ចេញបួសជាបព្វជិតបាន ។

ព្រះលោកនាយក ទ្រង់បានត្រាស់សម្តែងតទៅទៀតថា ម្នាលឧទាយិ កុលបុត្រពួកខ្លះក្នុងធម្មវិន័យនេះក៏ដូច្នោះដូចគ្នា កាលតថាគតពោលថា ចូរលះបង់ចោលនូវទោសនោះចេញ គេត្រឡប់ជាពោលយ៉ាងនេះថា ដូចម្តេចនឹងត្រូវឲ្យព្រះភគវាទ្រង់ជាស់តឿន ឲ្យលះបង់ចោលនូវទោសសូម្បីបន្តិចបន្តួច ដែលគួរលះនេះ ដែលព្រះមហាមុនីទ្រង់ត្រាស់ឲ្យពួកយើងទាំងឡាយលះបង់ចោល កុលបុត្រទាំងនោះរមែងលះបង់ចោលនូវទោសនោះ និងមានសេចក្តីគោរពកោតក្រែងចំពោះតថាគត ទាំងភិក្ខុដែលជាថេរៈ កាលលះបង់ចោលនូវទោសនោះហើយ ក៏ជាអ្នកមានការខ្វល់ខ្វាយតិច ហើយមានការចិញ្ចឹមជីវិតដោយរបស់ដែលអ្នកដទៃឲ្យ នៅដោយចិត្ត ដូចជាសត្វម្រឹគ នៅក្នុងព្រៃ ។ ម្នាលឧទាយិ ទោសសូម្បីត្រឹមតែបន្តិចបន្តួចរបស់ភិក្ខុទាំងនោះ ជាគ្រឿងចងដែលមិនមានកម្លាំង ពុកផុយ មិនមានខ្លឹមសារអ្វីឡើយ ។

ក្នុងទីបំផុតព្រះមុនី ទ្រង់បានត្រាស់ជាមួយនឹងព្រះឧទាយិត្ថេរ ទាក់ទងនឹងបុគ្គល ៤ កាមគុណ ៤ កាមសុខ និងនេក្ខម្មសុខតទៅថា ៈ-

ម្នាលឧទាយិ ក្នុងលោកនេះ មានបុគ្គល ៤ ចំពូក បានដល់ចំពូកណាខ្លះ ? ម្នាលឧទាយិ ១- ចំពូកដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ( គឺវត្ថុដែលជាគ្រឿងកង្វល់ ) តែមានសេចក្តីត្រិះរិះដែលទាក់ទងនឹងឧបធិ គេត្រិះរិះដូច្នេះហើយ ក៏មិនដើម្បីបន្ទោបង់ ឬមិនធ្វើការត្រិះរិះទាំងអស់នោះឲ្យអស់ទៅ មិនធ្វើការត្រិះរិះទាំងនោះឲ្យដល់នូវការមិនមាន បុគ្គលចំពូកនេះ តថាគតហៅថា ជាបុគ្គលដែលមានកិលេសប្រកបទុក មិនមែនជាបុគ្គលដែលបន្ទោបង់កិលេស សេចក្តីនោះព្រោះហេតុអ្វី ព្រោះតថាគតដឹងនូវឥន្ទ្រិយ នៃបុគ្គលផ្សេងៗ គ្នាដែលមាននៅក្នុងបុគ្គលចំពូកនេះ ។ ២- ចំពូកបុគ្គលដែលបដិបត្តិដើម្បីលះបង់ឧបធិ ដោយមានការត្រិះរិះទាក់ទងនឹងឧបធិ តែគេមិនទទួលការត្រិះរិះនោះទុក គឺគេបានលះ បានបន្ទោបង់ បានធ្វើឲ្យអស់ផុតទៅ បានធ្វើឲ្យដល់នូវការមិនមាន សូម្បីបុគ្គលចំពូកនេះ តថាគតក៏ពោលថា ជាបុគ្គលដែលកិលេសប្រកបទុក មិនមែនបុគ្គលដែលបន្ទោបង់កិលេសឡើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះតថាគតដឹង

នូវឥន្ទ្រិយនៃបុគ្គលផ្សេងៗ គ្នា ដែលមាននៅក្នុងចំពូកបុគ្គលនេះ ។

៣- ចំពូកបុគ្គលដែលបដិបត្តិដើម្បីលះនូវឧបធិ តែគេមានការត្រិះរិះទាក់ទង នឹងឧបធិម្តងម្កាល ព្រោះការភ្លាំងភ្លាត់សតិ សូម្បីយ៉ាងនោះគេក៏លះបន្ទោបង់បាន ធ្វើឲ្យដល់នូវការមិនមាននៃការត្រិះរិះទាំងនោះ ដោយឆាប់រហ័ស ម្នាលឧទាយិ មានបុរសម្នាក់យកទឹក ២ ឬ ៣ តំណក់ ដាក់ទៅក្នុងខ្ទះដែកដ៏ក្តៅពេញមួយថ្ងៃ តំណក់ទឹកធ្លាក់ចុះទៅយូរៗ មួយតំណក់ រមែងស្ងួតទៅ រមែងអស់ទៅ យ៉ាងណាមិញ ម្នាលឧទាយិ ចំពូកបុគ្គលដែលប្រតិបត្តដើម្បីលះបង់ឧបធិ តែគេមានការត្រិះរិះ ដែលទាក់ទងនឹងឧបធិម្តងម្កាល ព្រោះការភ្លេចភ្លាំងសតិទោះបីថា សតិរបស់គេយូរៗ កើតម្តងក៏ដោយ គេក៏លះ ក៏បន្ទោបង់ធ្វើឲ្យអស់ទៅបាន ធ្វើឲ្យដល់នូវការមិនមាន នៃការត្រិះរិះទាំងនោះដោយឆាប់រហ័សភ្លាមៗ សូម្បីចំពូកបុគ្គលនេះ តថាគតក៏ពោលថាជាបុគ្គលដែលត្រូវកិលេសប្រកបទុក មិនមែនបុគ្គលដែលបន្ទោបង់នូវកិលេសឡើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះតថាគតដឹងនូវឥន្ទ្រិយនៃបុគ្គលផ្សេងៗ គ្នា ដែលមាននៅក្នុងចំពូកនៃបុគ្គលនេះ ។

៤- ចំពូកបុគ្គលដែលដឹងថា បញ្ចក្ខន្ធជាឫសគល់នៃសេចក្តីទុក្ខ ការ

ដឹងដូច្នេះហើយ ជាបុគ្គលមិនមានឧបធិ ហើយបង្អោនចិត្តទៅកាន់ព្រះនិព្វាន ដែលជាទីអស់ទៅនៃឧបធិ ចំពូកបុគ្គលនេះ តថាគតហៅថាជាបុគ្គលដែលប្រាសចាកកិលេសហើយ មិនមែនជាបុគ្គលដែលត្រូវកិលេសប្រកបទុក សេចក្តីនោះព្រោះហេតុអ្វី ព្រោះតថាគតដឹងនូវឥន្ទ្រិយនៃបុគ្គលផ្សេងៗ គ្នា ដែលមាននៅក្នុងចំពូកបុគ្គលនេះ ។ ម្នាលឧទាយិ បុគ្គល ៤ ចំពូកនេះ មានពាសពេញក្នុងលោក ។

ព្រះអង្គទ្រង់ត្រាស់ជាបន្តទៀត ក្នុងរឿងកាមគុណទាំង ៥ នោះថា ម្នាលឧទាយិ កាមគុណមាន ៥ ប្រការ បានដល់ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលបុគ្គលត្រូវឃើញច្បាស់ដោយភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ដែលជាទីពេញចិត្តតម្រេកត្រេកអរ ។ ម្នាលឧទាយិ សេចក្តីសុខសោមនស្សឯណា ដែលកើតឡើង ពីព្រោះអាស្រ័យកាមគុណ ៥ នេះ សេចក្តីសុខសោមនស្សនោះ ហៅថាកាមសុខ ជាសេចក្តីសុខមិនស្អាត ជាសេចក្តីសុខរបស់បុថុជ្ជន មិនមែនជាសេចក្តីសុខ របស់ព្រះអរិយបុគ្គលទេ សេចក្តីសុខបែបនេះបព្វជិតមិនគួរសេព មិនគួរចម្រើន តថាគតហៅថា សេចក្តីសុខនេះជាសុខដែលគួរខ្លាច ។ ម្នាលឧទាយិ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នក

ស្ងប់ស្ងាត់ចាកកាម ជាអ្នកស្ងប់ស្ងាត់ចាកអកុសលធម៌ បានចូលដល់បឋមជ្ឈាន ដោយមានវិតក្ក វិចារៈ បីតិ សុខៈ និងឯកគ្គតា ដែលកើតមកអំពីវិវេក ៗ ជាអ្នកបានចូលដល់ទុតិយជ្ឈាន ព្រោះវិតក្ក និងវិចារៈស្ងប់ទៅ បីតិ និងសុខៈក៏កើតពីសមាធិ មានឧបេក្ខា មានសតិមានសម្បជញ្ញៈ សោយសុខដោយនាមកាយ ព្រោះបីតិអស់ទៅ ជាអ្នកបានចូលដល់តតិយជ្ឈាន ដែលព្រះអរិយបុគ្គលទាំងឡាយសរសើរថា បុគ្គលបានឈានទេះ ជាបុគ្គលមានឧបេក្ខា មានសតិនៅជាសុខជាអ្នកបានចូលដល់ចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ ព្រោះលះសុខ និងទុក្ខ និងរំលត់សោមនស្ស និងទោមនស្សមុនៗ បាន មានឧបេក្ខាជាហេតុឲ្យសតិបរិសុទ្ធ ។

ឈានទាំង ៤ នេះ តថាគតពោលថា សេចក្តីសុខកើតពីការចេញចាកកាម ( ហៅថា នេក្ខម្មៈ ) សេចក្តីសុខដែលកើតអំពីការស្ងប់ស្ងាត់ សេចក្តីសុខដែលកើតពីសម្ពោធិ ( ការត្រាស់ដឹង ) ដែលបុគ្គលគួរគប្បីសេព គួរបម្រើនឲ្យច្រើន តថាគតពោលថា សេចក្តីសុខទាំងនេះ ជាសេចក្តីសុខ ដែលមិនគួរឲ្យខ្លាច ។ ម្នាលឧទាយិបឋមជ្ឈាន ហៅថា នៅញាប់ញ័រ ធម្មជាតដែលនៅក្នុងបឋមជ្ឈាន

ដែលចាត់ថា ជាធម្មជាតធ្វើឲ្យនៅញាប់ញ័រ ។ វិតក្ក និងវិចារៈក្នុងបឋមជ្ឈាន ដែលមិនទាន់រលត់ទៅនោះឯង ហៅថា ជាសភាពនៅញាប់ញ័រ ។ ម្នាលឧទាយិ ទុតិយជ្ឈានហៅថា នៅញាប់ញ័រ ក៏ធម្មជាតដែលនៅញាប់ញ័រ ក្នុងទុតិយជ្ឈាន បានដល់អ្វី ? បីតិ និងសុខៈ ក្នុងទុតិយជ្ឈាន ដែលនៅមិនទាន់រលត់ទៅ ហៅថា ជាការញាប់ញ័រ ។ ម្នាលឧទាយិ ក្នុងតតិយជ្ឈានក៏ហៅថា នៅញាប់ញ័រ ក៏ធម្មជាតដែលញាប់ញ័រ ក្នុងតតិយជ្ឈាន បានដល់អ្វី ? ឧបេក្ខា និងសុខៈ ក្នុងតតិយជ្ឈាន ដែលនៅមិនទាន់រលត់ទៅ ហៅថា ជាការញាប់ញ័រ ។ ម្នាលឧទាយិ ភិក្ខុក្នុងធម្មវិន័យនេះសម្រេចចតុត្ថជ្ឈានហើយ មិនមានទុក្ខ មិនមានសុខ ព្រោះលះសុខ និងទុក្ខ និងរំលត់សោមនស្ស និងទោមនស្សមុនៗ បាន មានឧបេក្ខាជាហេតុឲ្យសតិបរិសុទ្ធ ចតុត្ថជ្ឈានតថាគតហៅថា មិនញាប់ញ័រ ។ ម្នាលឧទាយិ បឋមជ្ឈានតថាគតពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះបោល ចូរឈានកន្លងទៅចុះ ។ ការឈានកន្លងបឋមជ្ឈានទៅ បានដល់ធម្មជាតអ្វី ? ការធ្វើឲ្យបានទុតិយជ្ឈាន ។ ទោះបីថា ទុតិយជ្ឈានតថាគតក៏ពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះបោល ចូរឈានកន្លងទៅ

ចុះ ។ ការឈានកន្លងទុតិយជ្ឈានទៅ បានដល់ ធម្មជាតអ្វី ? បាន ដល់ ការធ្វើឲ្យបានតតិយជ្ឈាន ។ ទោះបីថា តតិយជ្ឈានតថាគតក៏ ពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះចោល ចូរឈាន កន្លងទៅចុះ ។ ការឈានកន្លងតតិយជ្ឈាន បានដល់ ធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបានចតុត្ថជ្ឈាន ។ ទោះបីថា ចតុត្ថជ្ឈានតថាគតក៏ ពោលថាមិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះចេញ ចូរឈាន កន្លងទៅចុះ ។ ការឈានកន្លងចតុត្ថជ្ឈានទៅ បានដល់ ធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបានអាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ព្រោះកន្លងការចងចាំរូបដោយប្រការ ទាំង ពួង ព្រោះរលត់បដិឃសញ្ញាបាន ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវការ ចងចាំផ្សេងៗ នោះទេ ។

ម្នាលឧទាយិ សូម្បីអាកាសានញ្ចាយតនជ្ឈាននេះ តថាគតក៏ ពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះចេញ ចូរឈាន កន្លងទៅចុះ ។ ការឈានកន្លងអាកាសានញ្ចាយតនជ្ឈានទៅ បានដល់ ធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបានវិញ្ញាណញ្ចាយតនជ្ឈាន ដោយ បរិកម្មថា វិញ្ញាណមិនមានទីបំផុត ព្រោះកន្លងអាកាសានញ្ចាយតនជ្ឈាន

បានដោយប្រការទាំងពួង ។ ម្នាលឧទាយិ សូម្បីវិញ្ញាណញ្ចាយតនជ្ឈាននេះ តថាគតក៏ពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះចេញ ចូរឈានកន្លងទៅចុះ ។ ការឈានកន្លងវិញ្ញាណញ្ចាយតនជ្ឈានទៅ បានដោយធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបានអាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា មិនមានអ្វី ព្រោះកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។ សូម្បីអាកិញ្ចញ្ញាយតនជ្ឈាននេះ តថាគតក៏ពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះបង់ចេញ ចូរឈានកន្លងទៅចុះ ។ ការឈានកន្លងអាកិញ្ចញ្ញាយតនជ្ឈានទៅ បានដល់ ធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបាននេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា ភាវៈដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះកន្លងអាកិញ្ចញ្ញាយតនជ្ឈានបាន ដោយប្រការទាំងពួង ។ ទោះបីនេវសញ្ញានាសញ្ញាយតនជ្ឈាននេះ តថាគតពោលថា មិនគួរធ្វើការអាល័យ អ្នកទាំងឡាយចូរលះចេញ ចូរឈានកន្លងទៅចុះ ។ ការឈានកន្លងនេវសញ្ញានាសញ្ញាយតនជ្ឈានទៅ បានដល់ធម្មជាតអ្វី ? បានដល់ ការធ្វើឲ្យបានសញ្ញាវេទយិតនិរោធ គឺការរលត់សញ្ញា និងវេទនា ព្រោះកន្លង

នេវសញ្ញានាសញ្ញាយតនជ្ឈានបាន ដោយប្រការទាំងពួង ម្នាលឧទាយិ តថាគតក៏ពោលថា ការលះរហូតដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការដូច្នេះឯង ។ ម្នាលឧទាយិ តថាគតពោល ដល់ការលះវត្ថុណា អ្នកឃើញវត្ថុនោះថា មានសំយោជនៈល្អិត ឬគ្រោតគ្រាត ឬទេ ? ព្រះឧទាយិក្រាបទូលថា មិនឃើញមានទេ ព្រះអង្គ ។ កាលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្តែងព្រះសូត្រនេះចប់ហើយ ព្រះឧទាយិត្ថេរក៏មានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះសម្ពុទ្ធ។

មានរឿងការសាកសួរបញ្ហា របស់ព្រះឧទាយិត្ថេរ ដែលមានសម្តែងនៅក្នុង **គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ** នៃ **ឧទាយិសូត្រ** ដូចមានសេចក្តីថា ៖-

សម័យមួយ ព្រះអានន្ទ និងព្រះឧទាយិត្ថេរ បានគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះ ជាវេលាល្ងាច ព្រះឧទាយិត្ថេរ បានចេញអំពីទីពួនសំងំ បានចូលទៅរកព្រះអានន្ទដល់ទីគង់ប្រថាប់ ហើយបានពោលប្រាស្រ័យចរចាគ្នានឹងព្រះអានន្ទ លុះសមគួរហើយ ក៏បានគង់នៅក្នុងទីដ៏សមគួរ រួចព្រះឧទាយិត្ថេរបានសួរទើងព្រះអានន្ទត្ថេរថា អាវុសោអានន្ទ រាងកាយនេះ ព្រះមានព្រះ

កាគ ទ្រង់ត្រាស់ប្រាប់ដោយបរិយាយផ្សេងៗ ថា រាងកាយនេះ ជាអនត្តា ទោះបីវិញ្ញាណនេះ លោកអាចប្រាប់សម្ដែង បញ្ញត្តិ តែងតាំង បែក និងធ្វើឲ្យរឭកដឹងទាន់ឡើងថា វិញ្ញាណនេះក៏ជាអនត្តា ។ នែឧទាយិ ចក្ខុវិញ្ញាណ រមែងកើតឡើងព្រោះអាស្រ័យចក្ខុ និងរូប យ៉ាងនេះមិនមែនឬ ? ព្រះឧទាយិត្ថេរតបថា យ៉ាងនោះឯង អាវុសោអានន្ទ ។ ព្រះអានន្ទត្ថេរ សួរចំពោះព្រះឧទាយិថា លោកអ្នកដ៏មានអាយុ ហេតុ និងបច្ច័យដែលអាស្រ័យវិញ្ញាណកើតឡើង គប្បីរលត់ទៅទាំងអស់ រកចំណែកដែលនៅសល់មិនមាន ចក្ខុវិញ្ញាណ នឹងប្រាកដបានឬ អាវុសោឧទាយិ ? មិនប្រាកដឡើយលោកម្ចាស់អានន្ទ ។ ព្រះអានន្ទបានសួរទៀតថា លោកដ៏មានអាយុឧទាយិ សូម្បីដោយបរិយាយយ៉ាងនេះឯង ចក្ខុវិញ្ញាណនេះ ព្រះភគវាទ្រង់ត្រាស់ប្រាប់ថា វិញ្ញាណនេះជាអនត្តា នែឧទាយិ សោតវិញ្ញាណ រមែងកើតឡើងព្រោះអាស្រ័យសោតៈ និងសំឡេង, ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យឃានៈ និងក្លិន, ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យជិវ្ហា និងរស, កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ, មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍យ៉ាងនោះ

មិនមែនឬ លោកដ៏មានអាយុឧទាយិ ? ព្រះឧទាយិតបថា យ៉ាងហ្នឹង ហើយលោកម្ចាស់អានន្ទ ។ ព្រះអានន្ទក៏បានសួរទៀតថា លោកអ្នកដ៏មានអាយុឧទាយិ ប្រសិនបើយ៉ាងនោះ កាលបើហេតុ និងបច្ច័យដែលធ្វើឲ្យសោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណរលត់ទៅអស់ រកចំណែកសល់មិនមាន សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ នឹងប្រាកដបានឬ ? ព្រះឧទាយិតបថា ប្រាកដមិនបានទេលោកម្ចាស់អានន្ទ ។ ព្រះអានន្ទពោលទៀតថា នែឧទាយិ សូម្បីដោយបរិយាយនេះ ព្រះសាស្តាទ្រង់ត្រាស់ប្រាប់ថា វិញ្ញាណជាអនត្តា ។ នែឧទាយិ បុរសត្រូវការខ្លឹមឈើ ត្រាច់ស្វែងរកខ្លឹមឈើ បានកាន់ពូថៅដ៏មុតចូលទៅក្នុងព្រៃ លុះបានទៅជួបនឹងដើមចេកធំមួយដើម មានដើមត្រង់ ទើបកាត់គល់ និងចុងហើយ បកសម្បកស្រទបចេញ សូម្បីតែស្រោយនៃដើមចេក គេក៏មិនបានជួប គេនឹងជួបខ្លឹមបានពីចំណែកណា សេចក្តីឧបមានេះយ៉ាងណា ភិក្ខុពិចារណារកខ្លួន និងវត្ថុដែលជារបស់ខ្លួន ក្នុងអាយតនៈ ៦ ក៏ដូច្នោះ ដូចគ្នា កាលបើភិក្ខុឃើញត្រូវយ៉ាងនេះហើយ ក៏មិនប្រកាន់វត្ថុណាក្នុងលោក កាលបើមិនប្រកាន់ ក៏មិនកង្វល់ក្តៅ

ក្រហាយ កាលបើមិនកន្លល់ក្តៅក្រហាយ ក៏បរិនិព្វានដោយពិតប្រាកដ រមែងដឹងច្បាស់ថា ជាតិ គឺការកើតអស់ហើយ ព្រហ្មចរិយធម៌ នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចអស់ហើយ កិច្ចយ៉ាងដទៃដែលត្រូវធ្វើទៀតនោះមិនមានឡើយ ។

ចំណែករឿងរបស់ព្រះឧទាយិត្ថេរ ដែលពោលដល់រឿងលោកថា ជាអ្នកមានការពេញចិត្តក្នុងការសោកសួរធម៌ ដែលជាបច្ច័យអស់ទៅនៃតណ្ហា តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** នៃ **ខយសូត្រ** ក្នុង **ឧទាយិវគ្គទី ៣** មានសេចក្តីថា ៖-

សម័យមួយ ព្រះទសពល ទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ដោយព្រះពុទ្ធអង្គត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ មគ្គ និងបដិបទាណា រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា អ្នកទាំងឡាយ ចូរចម្រើនមគ្គ និងបដិបទានោះ ។ មគ្គ និងបដិបទា ដែលប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា តើដូចម្តេច ? មគ្គ និងបដិបទា ដែលប្រព្រឹត្តទៅនោះ បានដល់ ពោជ្ឈង្គ ៧ ប្រការ ។ ពោជ្ឈង្គ ៧ ប្រការនោះ បានដល់អ្វីខ្លះ ? ពោជ្ឈង្គ គឺអង្គនៃធម៌ជាគ្រឿងត្រាស់ដឹង

មាន ៧ ប្រការ បានដល់ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ កាលព្រះទសពល ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយិត្ថេរ បានក្រាបទូលសួរតទៅទៀតថា បពិត្រព្រះមានជោគ ពោជ្ឈង្គ ៧ ប្រការ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយយ៉ាងណា ទើបប្រព្រឹត្តទៅដើម្បីការអស់ទៅនៃតណ្ហា គឺសេចក្តីប្រាថ្នាចង់បាន ។ ព្រះពុទ្ធអង្គ ទ្រង់ត្រាស់ទៀតថា ម្នាលឧទាយិ ភិក្ខុនៅក្នុងធម្មវិន័យនេះ រមែងចម្រើនសតិសម្ពោជ្ឈង្គដែលអាស្រ័យវិវេក ( គឺការស្ងប់ស្ងាត់ ) អាស្រ័យវិរាគៈ ( គឺការប្រាសចាកតម្រេក ) អាស្រ័យនិរោធ ( គឺការរលត់ ) រកប្រមាណមិនបាន មិនមានការបៀតបៀន កាលបើភិក្ខុនោះ បានចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក វិរាគៈ និងនិរោធ ដែលរកប្រមាណមិនបាន មិនមានការបៀតបៀន ទើបអាចលះបង់តណ្ហាបាន ។ ភិក្ខុនៅក្នុងធម្មវិន័យនេះ រមែងចម្រើនធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក វិរាគៈ និងនិរោធ រកប្រមាណមិនបាន មិនមានការបៀតបៀន កាលបើភិក្ខុ

នោះ ចម្រើនធម៌ទាំងនោះហើយ ដោយអាស្រ័យគោលធម៌ផ្សេងៗ នោះ ដូចដែលបានពោលមកហើយនេះ រមែងអាចលះបង់តណ្ហាបាន ព្រោះការលះបង់តណ្ហាបាន ទើបលះបង់កម្មបាន ព្រោះការលះបង់កម្មបាន ទើបលះបង់ទុក្ខបាន ។ ម្នាលឧទាយិ ព្រោះការអស់ទៅនៃតណ្ហា ទើបអស់កម្ម ព្រោះការអស់កម្ម ទើបអស់ទុក្ខ ។

ព្រះឧទាយិត្ថេរ លោកធ្លាប់បានចូលទៅគាល់ព្រះភគវា ដើម្បីក្រាបទូលសួរបញ្ហាផ្លូវចិត្ត និងការសម្រេចមគ្គផលរបស់លោក ដូចមានរឿងសម្ដែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** នៃ **ឧទាយិសូត្រ** ដូចមានសេចក្ដីថា ៈ-

សម័យមួយ ព្រះលោកនាថ ទ្រង់គង់ប្រថាប់នៅនិគម របស់អ្នកស្រុក **សុមភៈ** ដែលមានឈ្មោះថា **សេតកៈ** ក្នុងដែន **សុមភៈ** ។ គ្រានោះ ព្រះឧទាយិត្ថេរ បានចូលទៅគាល់ព្រះមានបុណ្យ ដល់ទីគង់ប្រថាប់ ថ្វាយបង្គំព្រះមានជោគហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ហើយបានក្រាបបង្គំទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន គួរឲ្យអស្ចារ្យពេកណាស់ រឿងដែលមិនធ្លាប់កើតមានមក ក៏កើតមានឡើង សេចក្ដីស្រឡាញ់ ការគោរព ការអៀនខ្មាស និងការកោត

ក្រែងរបស់ខ្ញុំព្រះអង្គ បានកើតមានចំពោះព្រះទសពលយ៉ាងក្រៃលែង ដោយថា ខ្ញុំព្រះអង្គកាលនៅជាគ្រហស្ថ នៅគ្រប់គ្រងផ្ទះក្នុងកាលមុន មិនបានធ្វើការស្និទ្ធស្នាល នឹងព្រះធម៌ច្រើនប៉ុន្មានទេ មិនបានធ្វើការស្និទ្ធស្នាលជាមួយនឹងព្រះសង្ឃ ដោយហេតុដែលខ្ញុំព្រះអង្គ មានការគោរពកោតក្រែងចំពោះព្រះលោកនាថ ទើបចេញបួសជាបព្វជិត ។ ព្រះមានព្រះភាគក៏ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គថា **នេះរូប** ( រមែងមកប្រាកដតាមក្អែក ) នេះជាការកើតឡើងនៃរូប នេះជាការរលត់ទៅនៃរូប **នេះវេទនា** ( ការសោយអារម្មណ៍ ) នេះជាការកើតឡើងនៃវេទនា នេះជាការរលត់ទៅនៃវេទនា **នេះសញ្ញា** ( ការចាំបាន ) នេះជាការកើតឡើងនៃសញ្ញា នេះជាការរលត់ទៅនៃសញ្ញា **នេះសង្ខារ** ( គ្រឿងតាក់តែង ) នេះជាការកើតឡើងនៃសង្ខារ នេះជាការរលត់ទៅនៃសង្ខារ **នេះវិញ្ញាណ** ( ការដឹងច្បាស់ ) នេះជាការកើតឡើងនៃវិញ្ញាណ នេះជាការរលត់ទៅនៃវិញ្ញាណ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គបានសម្រេចហើយ និងមគ្គដែលព្រះអង្គបានហើយនោះ ដែលខ្ញុំព្រះអង្គបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ នឹងបង្អោនទាំខ្ញុំព្រះអង្គទៅដោយអាការយ៉ាងនោះៗ ដោយខ្ញុំព្រះអង្គយល់

ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចហើយ កិច្ចដទៃដែលនឹងត្រូវធ្វើនោះ មិនមានឡើយ ។

**សតិសម្ពោជ្ឈង្គ** ( អង្គនៃការត្រាស់ដឹង គឺសតិ ) ដែលខ្ញុំព្រះអង្គបានហើយនោះ ដែលខ្ញុំព្រះអង្គបានចម្រើនហើយនោះ បានធ្វើឲ្យច្រើនហើយនោះ នឹងបង្អោនទាំខ្ញុំព្រះអង្គទៅដោយអាការយ៉ាងនោះៗ ដោយខ្ញុំព្រះអង្គយល់ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈនៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចហើយ កិច្ចដទៃដែលនឹងត្រូវធ្វើទៀតនោះមិនមានឡើយ និងវីរិយៈ បីតិ ធម្មវិចយៈ បស្សទ្ធិ សមាធិ ( ដោយន័យដូចគ្នានឹងសតិសម្ពោជ្ឈង្គ ) ។ ចំណែកឧបេក្ខាសម្ពោជ្ឈង្គ ( អង្គនៃការត្រាស់ដឹង គឺឧបេក្ខា ) ដែលខ្ញុំព្រះអង្គបានហើយនោះ ដោយខ្ញុំព្រះអង្គបានចម្រើនហើយនោះ បានធ្វើឲ្យច្រើនហើយ នឹងបង្អោនទាំខ្ញុំព្រះអង្គទៅដោយអាការនោះៗ ដោយខ្ញុំព្រះអង្គយល់ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈ នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចហើយ កិច្ចដទៃដែលនឹងត្រូវធ្វើនោះ មិនមានឡើយ ។ មគ្គដែលខ្ញុំព្រះអង្គបានហើយនោះឯង ដោយខ្ញុំព្រះអង្គបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ នឹងបង្អោនទាំខ្ញុំព្រះអង្គទៅ

ដោយអាការនោះៗ ដោយខ្ញុំព្រះអង្គយល់ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈ នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃដែលត្រូវធ្វើនោះមិនមានឡើយ ។ ព្រះមានព្រះភាគត្រាស់ថា ល្អហើយៗ ឧទាយិ មគ្គដែលអ្នកបានហើយនោះឯង ដោយអ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ នឹងបង្អោននាំអ្នកទៅដោយអាការនោះៗ ដោយអ្នកយល់ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈនៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ កិច្ចដទៃដែលនឹងត្រូវធ្វើទៀតនោះមិនមានឡើយ ។

ព្រះឧទាយិ ក្រោយពីបានក្រាបទូលដល់ការសម្រេចមគ្គផលរបស់លោក ក្នុងទីចំពោះព្រះភក្ត្រនៃព្រះសយម្ភូហើយ លោកក៏បានក្រាបទូលសរសើរព្រះលោកនាថ ក្នុងទីចំពោះព្រះភក្ត្រទៀត ដូចគ្នាដូចមានរឿងតំណាលប្រាកដនៅក្នុង **គម្ពីរទីឃនិកាយ បដិក្កវគ្គ** នៃ **សម្បសាទនីយសូត្រ** ( សូត្រដែលពោលដល់គុណធម៌ ដែលគួរឲ្យជ្រះថ្លាចំពោះព្រះសម្មាសម្ពុទ្ធ ) មានសេចក្តីថា ៖-

សម័យមួយ ព្រះលោកវិទូ ព្រះអង្គបានទ្រង់គង់ប្រថាប់នៅក្នុងសួនស្វាយរបស់បាវារិកសេដ្ឋី នៅក្នុងក្រុងនាលន្ទា ។ គ្រានោះ ព្រះ

ឧទាយិត្ថេរ បានពោលសរសើរព្រះកិត្តិគុណ ក្រោយពីព្រះសារីបុត្រ បានពោលសរសើរព្រះទសពលថា ព្រះអង្គជាអ្នកទ្រទ្រង់នូវគុណធម៌ ផ្នែកខាងសម្ពោធិញ្ញាណ (ញាណ គឺការត្រាស់ដឹងដោយខ្លួនឯង) និង ខាងសម្ដែងព្រះធម៌ដ៏ប្រសើរជាងបណ្ដាសមណព្រាហ្មណ៍ ក្នុងកាល ទាំងបី ដោយទ្រង់បញ្ចេញព្រះវាចាដ៏អង់អាច បន្លឺសីហនាទ បញ្ជាក់ អះអាង ជាក់លាក់ពិតប្រាកដ នៅដោយចំណែកមួយ សូម្បីសេចក្ដី ក៏មានតែមួយ មិនមានពីរឡើយ ហើយក្នុងទីបំផុត ព្រះពុទ្ធអង្គទ្រង់ បានត្រាស់ទទួលរ៉ាប់រងភាសិតរបស់ព្រះសារីបុត្រ ។ កាលព្រះភគវា ទ្រង់បានត្រាស់រ៉ាប់រងព្រះវាចារបស់ព្រះសារីបុត្ររួចហើយ ព្រះឧទាយិ បានក្រាបទូលឡើងថា បពិត្រព្រះអង្គដ៏ចម្រើន គួរឲ្យអស្ចារ្យពេក ណាស់ ព្រះពុទ្ធអង្គជាអ្នកប្រាថ្នាតិច មានសេចក្ដីសន្ដោស ត្រេកអរ ចំពោះវត្ថុដែលមាន ឬរកបានមកក្នុងផ្លូវសុចរិត វិសុទ្ធិគុណទាំងនេះ នឹងមានចំពោះព្រះជិនស្រី ព្រះអង្គជាអ្នកមានឫទ្ធិ មានអានុភាពច្រើន តែព្រះអង្គមិនបានសម្ដែងព្រះអង្គឲ្យប្រាកដ (មិនអួតអាង) បពិត្រ ព្រះអង្គដ៏ចម្រើន ប្រសិនបើពួកអន្យតិត្ថិយបរិព្វាជក បានយល់ធម៌ សូម្បីត្រឹមតែបន្តិចបន្តួច ពីធម៌ដែលព្រះអង្គ បានសម្ដែងហើយនោះ

ក្នុងខ្លួនហើយ ពួកគេនឹងត្រូវលើកទង់ទៅប្រកាស ( និយាយអួតខ្លួនឯង ) ដោយហេតុត្រឹមតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ដែលគួរឲ្យអស្ចារ្យពេកណាស់ ការប្រាថ្នាតិច សេចក្តីសន្តោស វិសុទ្ធិគុណទាំងនេះ មាននៅក្នុងព្រះតថាគត ដែលទ្រង់ជាអ្នកមាននូវឫទ្ធិ មានអានុភាពច្រើន តែព្រះអង្គទ្រង់មិនសម្តែងឲ្យប្រាកដឡើយ ។ គ្រានោះព្រះភគវា ទ្រង់បានត្រាស់នឹងព្រះឧទាយិត្ថេរថា ម្នាលឧទាយិ អ្នកចូរមើលការប្រាថ្នាតិច សេចក្តីសន្តោស វិសុទ្ធិគុណទាំងនេះ របស់តថាគត ដែលជាអ្នកមានឫទ្ធិ មានអានុភាពច្រើន តែមិនសម្តែងខ្លួនឲ្យប្រាកដ ព្រោះហេតុនោះ ប្រសិនបើពួកអន្យតិរ្ថិយបរិព្វាជក បានយល់ធម៌សូម្បីត្រឹមតែបន្តិចបន្តួច ពីធម៌ដែលតថាគតសម្តែងហើយនោះក្នុងខ្លួនហើយ ពួកគេនឹងត្រូវលើកទង់ទៅប្រកាស តែតថាគតមិនធ្វើយ៉ាងនោះឡើយ ។

ព្រះឧទាយិត្ថេរ ក៏ជាព្រះថេរៈមួយរូប ដែលជាអ្នកមានកត្តីភាព និងមានការគោរពចំពោះព្រះបរមគ្រូយ៉ាងស្មោះដើម និងស្មោះចុង គឺទាំងចំពោះមុខ និងកំបាំងមុខ ដូចដែលបានឃើញថា លោកបានពោលសរសើរនៅចំពោះព្រះភក្ត្រនៃព្រះលោកនាយក ឲ្យមហាជនបានស្តាប់

ដូចមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថា អធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា :-

ថ្ងៃមួយ លោកបានឃើញមហាជន នាំគ្នាពោលសរសើរដំរី របស់ព្រះមហាក្សត្រ លោកទើបគិតថា មហាជនទាំងនេះ បាននាំគ្នា ពោលសរសើរសត្វតិរច្ឆានទៅវិញ តែមិននាំគ្នាពោលសរសើរគុណ របស់ព្រះពុទ្ធ ដែលទ្រង់ជាដំរីដ៏ប្រសើរ យើងគួរនឹងធ្វើនូវព្រះគុណ របស់ដំរីប្រសើរ គឺព្រះពុទ្ធឲ្យប្រាកដដល់មហាជន គិតដូច្នេះហើយ ទើបបានពោលសរសើរគុណព្រះភគវា រហូតដល់ ១៦ គាថា ។

តាមដែលមានសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ ថេរគាថា** នៃ **សោឡសកនិបាត** ដូចមានសេចក្តីថា :-

ខ្ញុំព្រះអង្គបានស្តាប់មក អំពីព្រះអរហន្តទាំងឡាយថា មនុស្ស ទាំងឡាយ តែងនមស្ការនូវព្រះសម្ពុទ្ធ ដែលទ្រង់មានជាតិជាមនុស្ស ទ្រង់បានបង្ហឹកព្រះអង្គត្រឹមត្រូវឥតមានគ្គង មានព្រះទ័យខ្ជាប់ខ្ជួន ទ្រង់ ប្រព្រឹត្តក្នុងគន្លងដ៏ប្រសើរ ទ្រង់ពេញព្រះទ័យចំពោះឈាន ជាគ្រឿង ស្ងប់ចិត្ត ព្រះអង្គបានដល់នូវត្រើយនៃធម៌ទាំងពួង ទ្រង់ធ្វើងរំលងនូវ សំយោជនៈទាំងពួងហើយ ទ្រង់ ( ចេញផុត ) ចាកព្រៃ គឺកិលេស

ស្ដេចមកដល់ព្រះនិព្វានហើយ ទ្រង់ពេញព្រះទ័យក្នុងការចេញចាកកាមទាំងឡាយ ដូចមាសចេញផុតចាកជាតុថ្មហើយ ទោះបីពួកទេវតាក៏នមស្ការព្រះអង្គដែរ ពាក្យដូច្នេះនេះ ខ្ញុំព្រះអង្គបានស្ដាប់ ( ក្នុងសម្នាក់ ) នៃព្រះអរហន្ត ឯព្រះសមុទ្ទទ្រង់ព្រះនាមថា នាគនោះឯងព្រះអង្គរុងរឿងក្រៃពេក ដូចភ្នំហិមពាន្តដែលរុងរឿង កន្លងនូវពួកភ្នំឯទៀត ព្រះអង្គមានព្រះនាមពិតប្រាកដ ប្រសើរបំផុតជាងជនទាំងពួងដែលមាននាមថានាគដែរ ខ្ញុំនឹងថ្លែងនូវពុទ្ធនាគ ដល់អ្នកទាំងឡាយ ព្រះពុទ្ធនាគនោះ មិនធ្វើនូវអំពើអាក្រក់ទាំងឡាយ ។ សោរច្ចៈ និងអវិហិង្សាទាំងពីរនោះ ជាបាទា ( ខាងមុខ ) របស់ព្រះពុទ្ធនាគ ។ សតិនិងសម្បជញ្ញៈទាំងពីរនេះ ជាបាទាខាងក្រោយ របស់ព្រះពុទ្ធនាគ ។ ព្រះសមុទ្ទជាមហានាគ ទ្រង់មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុក ស ។ ព្រះពុទ្ធនាគនោះ មានសតិជា-ក បញ្ញាជាសិរ ប្រទេសគំនិតសម្រាប់គិតគូរធម៌ ជាចុងប្រមោយ ធម៌ជាផ្ទៃសម្រាប់ដាក់នូវគ្រឿងចម្អែត វិវេកជាកន្ទុយ ។ ព្រះពុទ្ធនាគនោះ មានឈាន ទ្រង់រីករាយចំពោះខ្យល់ដកដង្ហើម គឺព្រះនិព្វាន មានព្រះទ័យតាំងមាំខាងក្នុង ព្រះពុទ្ធនាគ កាលបើទ្រង់ស្ដេចយាត្រា ក៏មានព្រះទ័យខ្ជាប់ខ្ជួន ព្រះពុទ្ធនាគ

ទ្រង់ប្រថាប់ ក៏មានព្រះទ័យខ្វាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់ផ្ទំ ក៏មានព្រះទ័យខ្វាប់ខ្ជួន ទ្រង់គង់ ក៏មានព្រះទ័យខ្វាប់ខ្ជួន ព្រះពុទ្ធនាគ ទ្រង់សង្រួមរក្សាទ្វារទាំងអស់ នេះជាសម្បទា របស់ព្រះពុទ្ធនាគ ។ ព្រះពុទ្ធនាគ ទ្រង់សោយតែភោជន ដែលឥតមានទោស មិនសោយនូវភោជន ដែលប្រកបដោយទោស ( កាលបើ ) ទ្រង់បាននូវចង្ហាន់ និងគ្រឿងស្លៀកដណ្តប់ ទ្រង់វៀរនូវការសន្សំទុក ទ្រង់កាត់នូវសំយោជនៈដែលជាចំណងតូចធំទាំងអស់ហើយ ទ្រង់យាងទៅណាៗ ក៏ស្តេចទៅដោយឥតមានព្រះទ័យអាឡោះអាល័យ ។ ឈូកស ដុះចម្រើនឡើងក្នុងទឹក មិនជាប់ប្រឡាក់ដោយទឹក មានក្លិនក្រអូប ជាទីរីករាយចិត្តយ៉ាងណាមិញ ព្រះពុទ្ធ ទ្រង់កើតក្នុងលោក គង់នៅក្នុងលោក មិនប្រឡាក់ដោយលោក ដូចជាឈូក មិនជាប់ប្រឡាក់ដោយទឹកដូច្នោះឯង ។ គំនរភ្លើងធំ ដែលឆេះសន្ធោ មិនមានចំណី រមែងរលត់ បើទុកជារងើកភ្លើងទាំងឡាយមាននៅ ក៏គេនិយាយថា ភ្លើងរលត់ហើយ ។ ពាក្យឧបមានេះ ជាគ្រឿងបញ្ជាក់នូវសេចក្តី ដែលពួកវិញ្ញូជន បានសម្តែងហើយ មហានាគ គឺព្រះខីណាស្រពទាំងឡាយគង់ដឹងច្បាស់នូវព្រះពុទ្ធនាគ ដែលខ្ញុំជានាគសម្តែងរួចមកហើយនេះថា ព្រះពុទ្ធនាគ

ទ្រង់ប្រាសចាករាគៈ ទោសៈ មោហៈហើយ អស់អាសវៈហើយ លះបង់សរីរៈ មិនមានអាសវៈ នឹងបរិនិព្វាន ។

គាថាទាំង ១៦ គាថានេះ ដែលជាគាថា មានសម្តែងនៅក្នុង **ថេរគាថា សោឡសកនិបាតនោះ** ជាគាថាដែលព្រះឧទាយិបានពោលទុក ទាំងលោកក៏បានទទួលនូវការសរសើរថា ជាព្រះថេរៈដែលមានមហិទ្ធិឫទ្ធិ មាននូវចំណេះដឹងល្អ ក្លាហាននៅក្នុងការពោលកាសិតជាគាថាវែង ពោលបានយ៉ាងពីរោះ មានវគ្គ មានឃ្លា ល្អបទដើម បទកណ្តាល និងបទចុង ទាំងមានខ្លឹមសារយ៉ាងល្អទៀតផង ។ ព្រះឧទាយិត្ថេរ លោកជាអ្នកមានដំណើរជីវិត មកពីកន្លែងមនុស្សមិនចេះដឹង តែលោកបានតាំងចិត្តរៀនសូត្យ រហូតបានជាអ្នកចេះដឹង ដោយលោកមានដំណើរជីវិតយ៉ាងនេះ ក៏ជាគំរូដល់កុលបុត្រជំនាន់ក្រោយ ដោយលោកមិនបណ្តែតបណ្តោយជីវិតឲ្យប្រព្រឹត្តទៅ ដូចគ្នានឹងឈើដែលអណ្តែតលើទឹកនោះទេ ឬដូចគ្នានឹងត្រីស្លាប់ លោកក៏ប្រសព្វក្នុងការសម្រេចនៃគុណធម៌ថ្នាក់ខ្ពស់បំផុត គឺការអស់ទៅនៃទុក្ខ ដែលហៅថា បានសម្រេចលោកុត្តរធម៌ គឺធម៌ដែលកន្លងចាកលោក ឬដែលមានឈ្មោះថា អសេក្ខបុគ្គល គឺអ្នកមិនមានការសិក្សាជាបន្តទៅទៀត

ព្រោះលោកបានរៀនចប់វិជ្ជាជីវិតហើយ ដោយបរិបូណ៌ ក្នុងដំណើរជីវិតរបស់លោក ដោយលោកបានប្រសព្វនឹងសម្បត្តិជាលោកុត្តរធម៌ ដែលសម្រេចមកអំពីការសន្សំបុណ្យបារមី អស់កាលដ៏យូរអង្វែងមកហើយ ដោយសេចក្តីល្អនេះ ទើបធ្វើឲ្យលោកអស់ទៅនូវសេចក្តីទុក្ខ ។

ព្រះឧទាយិ លោកក៏ជាព្រះថេរៈមួយអង្គ ដែលជាអ្នកបានធ្វើឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន នាសម័យពុទ្ធកាលនោះ ដោយលោកជាអ្នកមានវត្តប្រតិបត្តិដ៏ល្អ ជាគតិដល់មហាជន ក្នុងការប្រព្រឹត្តប្រតិបត្តិតាម ជាពិសេសនោះ បានធ្វើឲ្យមហាជន ជួបប្រសព្វនូវសម្បត្តិទៅតាមឧបនិស្ស័យ ដែលខ្លួនសន្សំរួចមកហើយ ។ ទាំងនេះក៏ជាគុណសម្បត្តិរបស់លោកមួយផងដែរ នៅក្នុងការជួយផ្សព្វផ្សាយព្រះធម៌វិន័យ របស់ព្រះលោកនាថ ។៚

( ជីវប្រវត្តិរបស់ព្រះឧទាយិត្ថេរ ចប់ )

## ✍ ជីវប្រវត្តិរបស់ព្រះឧបវាណត្ថេរ ✍

**“ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”**

ព្រះឧបវាណៈ លោកជាព្រះមហាថេរៈមួយរូប ដែលទ្រទ្រង់នូវគុណធម៌ដ៏បវរ ថែមទាំងសង្គ្រោះចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប និងធ្លាប់បានធ្វើជាឧបដ្ឋាករបស់ព្រះសយម្ភូមកតាំងពីបឋមពោធិកាល តែមិនបានបដិបត្តិជាប្រចាំដូចជាព្រះអានន្ទត្ថេរទេ ចំណែកជីវប្រវត្តិរបស់លោកក៏មានសម្តែងទុកនៅក្នុងគម្ពីរផ្សេងៗ ជាច្រើនដែរ ទាំងក្នុងអតីតជាតិនិងបច្ចុប្បន្នជាតិ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះឧបវាណត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖-

ព្រះឧបវាណត្ថេរ លោកកើតនៅក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី លោកមានឈ្មោះថា **ឧបវាណៈ** កាលលោកចម្រើនវ័យធំដឹងក្តីឡើងហើយ បានទៅសិក្សាវិជ្ជាត្រៃវេទ តាមវង្សត្រកូលរបស់ខ្លួន ។ ហេតុដែលឧបវាណមាណព មានសទ្ធាជ្រះថ្លា របួតចូលមកបព្វជ្ជាឧបសម្បទា ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងព្រះសាសនានេះ ពីព្រោះមកពីលោកបានឃើញពុទ្ធានុភាព ក្នុងគ្រាដែលព្រះពុទ្ធអង្គទ្រង់

ទទួលការថ្វាយវត្តជេតពនមហាវិហារ របស់អនាថបិណ្ឌិកសេដ្ឋីសាង ថ្វាយ នៅក្នុងព្រះរាជឧទ្យានរបស់ស្តេចជេត ជិតក្រុងសាវត្ថី ហើយ ថ្វាយសង្ឃារាម គឺអារាមថ្វាយជាទីលំនៅរបស់ភិក្ខុសង្ឃ ដែលនិមន្ត មកអំពីទិសទាំង ៤ ។

ពុទ្ធានុភាពក្នុងគ្រានោះ ដែលមានប្រាកដការណ៍ ដែលគួរឲ្យ អស្ចារ្យដល់ទេវតា និងមនុស្សទាំងឡាយ ដូចមានរឿងតំណាលទុក ក្នុង **អដ្ឋកថា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីក្នុង **គម្ពីរ ខុទ្ទកនិកាយ សន្តិកេនិទានជាតក** ដូចមានសេចក្តីថា ៈ-

ការរៀបចំវិធីទទួលព្រះមានជោគ ព្រមដោយភិក្ខុសង្ឃរបស់ អនាថបិណ្ឌិកសេដ្ឋីនោះ ជាក្បួនយ៉ាងមហោឡារិកដ៏ក្រៃលែង ។ រីឯ ព្រះវិជិតមារ ក៏ស្តេចយាងចូលកាន់វត្តជេតពនមហាវិហារ ដោយមាន ឧបាសក និងភិក្ខុសង្ឃជាច្រើន ព្រះអង្គបានចាត់ចែងឲ្យពួកឧបាសក ដើរទៅខាងមុខ ចំណែកព្រះអង្គ និងភិក្ខុសង្ឃស្តេចនិមន្តតាមក្រោយ ចូលទៅកាន់វត្តជេតពនមហាវិហារ ។

ប៉ុន្តែការយាងចូលទៅកាន់វត្តជេតពននោះ ព្រះពុទ្ធអង្គទ្រង់ធ្វើ រាជដំណើរទៅដោយពុទ្ធលីលា ដែលរកប្រមាណមិនបាន ដោយព្រះ

អង្គទ្រង់បញ្ចេញឆព្វណ្ណរង្សី គឺរស្មី ៦ ពណ៌ តាមដែលមានសម្តែងប្រាជកនៅក្នុង **គម្ពីរបឋមពោធិកថា** និង **អដ្ឋកថាធម្មបទ** នៃ **ពុទ្ធវគ្គ ក្នុងរឿងយមកប្បាដិហារិយ៍** ដូចមានសេចក្តីថា ៖-

រស្មីទាំង ៦ ពណ៌នោះបានដល់ ១- **នីលៈ** ពណ៌ខៀវ ២- **បីតៈ** ពណ៌លឿង ៣- **លោហិតៈ** ពណ៌ក្រហម ៤- **ឱទាតៈ** ពណ៌ស ៥- **មញ្ជេដ្ឋៈ** ពណ៌ហង្សបាទ ៦- **បភស្សរៈ** ពណ៌ផ្លេក រស្មីទាំងអស់នេះបានផ្សាយចេញពីព្រះវរកាយ របស់ព្រះពុទ្ធអង្គទៅសព្វទិស ទើបជាហេតុ ធ្វើឲ្យចិត្តរបស់ឧបវាណមាណពកើតមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ។ កាលបើឧបវាណមាណពកើតមានសទ្ធាជឿយ៉ាងនេះហើយ ទើបចេញបព្វជ្ជាឧបសម្បទានៅក្នុងព្រះសាសនានេះ កាលបើបានបួសជាភិក្ខុហើយ ក៏ខំតាំងចិត្តព្យាយាមចម្រើនវិបស្សនាកម្មដ្ឋានមិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត និងបានសម្រេចអភិញ្ញា ៦ ទៀតផង ។

ចំណែកផលបុណ្យរបស់ព្រះឧបវាណត្ថេរ ដែលកើតមកអំពីការពោលធម៌នោះ មានសម្តែងប្រាកដនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** នៃ **បព្វតវគ្គទី ១** ក្នុង **ឧបវាណសូត្រ** មានន័យថា ៖-

សម័យមួយ ព្រះឧបវាណត្ថេរ និងព្រះសារីបុត្របានសម្រាក នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ លំដាប់នោះ ព្រះសារីបុត្រ បានចេញអំពីទីពួនសំងំនៅក្នុងវេលាល្ងាចហើយ បានចូលទៅរកព្រះ ឧបវាណត្ថេរដល់ទីលំនៅ និងបានប្រាស្រ័យនឹងព្រះឧបវាណៈ ល្មម សមគួរហើយ ទើបអង្គុយចុះ នៅលើអាសនៈដ៏សមគួរ ហើយបាន សួរព្រះឧបវាណត្ថេរឡើងថា នែឧបវាណៈដ៏មានអាយុ ភិក្ខុនឹងគប្បី ដឹងបានឬទេថា **ពោជ្ឈង្គ** ( អង្គនៃការត្រាស់ដឹង ) មាន ៧ ប្រការ នោះ គឺ ១- សតិសម្ពោជ្ឈង្គ ២- ធម្មវិចយសម្ពោជ្ឈង្គ ៣- វីរិយ- សម្ពោជ្ឈង្គ ៤- បីតិសម្ពោជ្ឈង្គ ៥- បស្សទ្ធិសម្ពោជ្ឈង្គ ៦- សមាធិ សម្ពោជ្ឈង្គ ៧- ឧបេក្ខាសម្ពោជ្ឈង្គ ។ ពោជ្ឈង្គ ៧ ប្រការនេះ ដែល យើងប្រារព្ធហើយ ដោយការធ្វើទុកនៅក្នុងចិត្ត ដោយឧបាយដ៏ប្រពៃ ហើយ សមនឹងហេតុផលចំពោះខ្លួន រមែងប្រព្រឹត្តទៅ ដើម្បីការរស់ នៅជាសុខ ។ ពេលនោះ ព្រះឧបវាណៈតបថា លោកម្ចាស់សារីបុត្រ ភិក្ខុគប្បីដឹងបានថា ពោជ្ឈង្គ ៧ ប្រការនោះ ដែលយើងប្រារព្ធល្អហើយ ដោយការធ្វើទុកនៅក្នុងចិត្ត ដោយឧបាយចំពោះខ្លួន រមែងប្រព្រឹត្តទៅ ដើម្បីការរស់នៅជាសុខ លោកម្ចាស់សារីបុត្រ ។ ព្រះសារីបុត្រសួរ

ទៀតថា លោកអ្នកដ៏មានអាយុឧបវាណៈ ភិក្ខុប្រារព្ធសតិសម្ពោជ្ឈង្គ រមែងដឹងបានឬទេថា ចិត្តរបស់យើងរួចផុតល្អហើយ ថីនមិទ្ធៈ យើងបានដកចេញហើយ ឧទ្ធច្ចកុក្កុច្ចៈ យើងបានកម្ចាត់ចោលហើយ ការព្យាយាមដែលយើងប្រារព្ធហើយ យើងធ្វើទុកក្នុងចិត្តយ៉ាងពិតប្រាកដ មិនបានថយចុះឡើយជាដើម ។ លោកដ៏មានអាយុឧបវាណៈ ភិក្ខុចម្រើនឧបេក្ខាសម្ពោជ្ឈង្គ រមែងដឹងបានឬទេថា ចិត្តរបស់យើងរួចផុតល្អហើយ ថីនមិទ្ធៈ យើងដកចេញហើយ ឧទ្ធច្ចកុក្កុច្ចៈ យើងបានកម្ចាត់ចោលហើយ ការព្យាយាម ដែលយើងប្រារព្ធហើយ យើងធ្វើទុកក្នុងចិត្តយ៉ាងពិតប្រាកដ មិនថយចុះនោះយ៉ាងណា ? ព្រះឧបវាណៈតបថា លោកម្ចាស់សារីបុត្រ ភិក្ខុគប្បីដឹងបានយ៉ាងនេះថា ពោជ្ឈង្គដែលយើងប្រារព្ធល្អហើយយ៉ាងនេះ ដោយការធ្វើទុកក្នុងចិត្ត ដោយឧបាយ ( សមនឹងហេតុផល ) ចំពោះខ្លួន រមែងប្រព្រឹត្តទៅបានជាសុខពិតប្រាកដ លោកម្ចាស់សារីបុត្រ ។

កាពអង់អាចក្នុងការតបបញ្ហាធម៌ របស់ព្រះឧបវាណៈ ដែលព្រះសយម្ភូទ្រង់ត្រាស់សួរ ដោយលោកក្រាបទូលតបបានយ៉ាងត្រឹមត្រូវត្រង់តាមព្រះពុទ្ធបំណង តាមដែលមានសម្ដែងទុកនៅក្នុង **គម្ពីរ**

**អង្គុត្តរនិកាយ បញ្ចកនិបាត** នៃ **និរោធសូត្រ** បានដល់ សូត្រដែលពោលដល់គុណធម៌របស់ព្រះថេរៈ ដែលគួរគោរពបូជា ថា ៖-

គ្រាមួយ ព្រះសារីបុត្រ ត្រូវព្រះឧទាយិត្ថេរពោលជំទាស់ក្នុងធម៌ដែលជាផ្លូវខុស ព្រះថេរៈទើបបានចូលទៅគាល់ព្រះលោកនាយក ដើម្បីក្រាបទូលដំណើររឿង របស់ព្រះឧទាយិត្ថេរឲ្យទ្រង់បានជ្រាប ។ គ្រានោះ ព្រះពុទ្ធអង្គត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ ហេតុដូចម្តេច ពួកអ្នកទើបមិនអើពើចំពោះសេចក្តីនេះ ព្រះអង្គក៏បានត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនៅក្នុងធម្មវិន័យនេះ ជាអ្នកដល់ព្រមដោយសីល ដល់ព្រមដោយសមាធិ ដល់ព្រមដោយបញ្ញា គប្បីចូលសញ្ញាវេទយិតនិរោធ ប្រសិនបើមិនទាន់បានសម្រេចព្រះអរហត្តផលក្នុងបច្ចុប្បន្ន អ្នកក៏ចូងរំលងភាពជាសម្លាញ់របស់ពួកទេព ដែលមានកវឡិង្ការាហារ បានដល់ អាហារដែលលេបចូលទៅ គឺដុំបាយ សូម្បីពួកទេវៈ ដែលមានឫទ្ធិផ្លូវចិត្តខ្លះ គប្បីចូលសញ្ញាវេទយិតនិរោធ ( គឺការរលត់សញ្ញា និងវេទនា ) ខ្លះ គប្បីចេញចាកសញ្ញាវេទយិតនិរោធខ្លះ សេចក្តីនោះជាឋានៈដែលនឹងមានបាន ។ កាលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់

ក៏ក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារវិញទៅ ។ កាលព្រះមុនី ស្ដេចចេញទៅមិនយូរប៉ុន្មាន ព្រះអានន្ទ បានចូលទៅរកព្រះឧបវាណៈ ហើយពោលថា ឧបវាណៈដ៏មានអាយុ ពួកភិក្ខុដទៃក្នុងសាសនានេះ ដែលបៀតបៀនភិក្ខុទាំងឡាយជាថេរៈ ពួកយើងមិនសួររកភិក្ខុទាំង នោះ ការដែលព្រះមានបុណ្យ ស្ដេចចេញចាកទីពួនសំងំនៅក្នុងវេលា ល្ងាច ទ្រង់ប្រារព្ធហេតុនេះហើយ ទ្រង់លើកឡើងត្រាស់ ដូចដែល ត្រាស់នឹងព្រះឧបវាណៈ ដោយចំពោះហេតុនោះ សេចក្ដីនោះមិនជា អស្ចារ្យ ឥឡូវនេះ ការអន់ចិត្តបានកើតឡើងដល់ពួកយើង ។

លំដាប់នោះ ព្រះមានព្រះភាគ ស្ដេចចេញចាកទីពួនសំងំក្នុង វេលាល្ងាច ហើយបានចូលទៅកាន់ឧបដ្ឋានសាលា ប្រថាប់គង់នៅ លើអាសនៈ ដែលបានរៀបចំទុក ហើយត្រាស់សួរព្រះឧបវាណត្ថេរ ថា ម្នាលឧបវាណៈ ភិក្ខុដែលជាថេរៈប្រកបដោយធម៌ប៉ុន្មាន ទើប ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព និងជាទីលើកតម្កើងរបស់ សព្រហ្មចារីទាំងឡាយ ។ ព្រះឧបវាណត្ថេរក្រាបទូលថា បពិត្រព្រះ អង្គដ៏ចម្រើន ភិក្ខុដែលជាថេរៈត្រូវប្រកបដោយធម៌ ៥ ប្រការ ទើប ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព និងជាទីលើកតម្កើងរបស់

សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ ប្រការរបស់ភិក្ខុក្នុងធម្មវិន័យនេះ គឺ ១- ជាអ្នកមានសីល គឺជាអ្នកសង្រួមក្នុងព្រះបាតិមោក្ខ បរិបូណ៌ ដោយអាចារៈ និងគោចរ ទោសត្រឹមតែបន្តិចបន្តួច ឃើញថាជាភ័យ សិក្សាមុតមាំក្នុងសិក្ខាបទទាំងឡាយ ។ ២- ជាពហូសូត គឺអ្នកស្តាប់ អ្នករៀនច្រើន ជាអ្នកចងចាំទុកច្រើន ជាអ្នករត់មាត់ និងចាំស្ទាត់ ជាអ្នកបែកធ្លាយក្នុងធម៌ ដែលល្អខាងដើម កណ្តាល និងទីបំផុត ដែលប្រកាសព្រហ្មចរិយធម៌បរិសុទ្ធបរិបូណ៌ទាំងអស់ ។ ៣- ជាអ្នក មានវាចាពីរោះ គឺមានពាក្យសម្តីផ្អែមល្ហែម និយាយបោរីកាសា ( សម្តី អ្នកទីក្រុង ) មានសណ្តាប់ធ្នាប់ល្អ មិនស្អកធ្វើឲ្យយល់ដឹងសេចក្តីបាន ងាយ ។ ៤- ជាអ្នកបានសម្រេចឈាន ៤ ដែលជាអភិចេតសិក គឺ មានចិត្តច្រើន ដែលជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន មានភាពស្ទាត់ ជំនាញក្នុងការចូលឈាន និងចេញចាកឈាន បានតាមសេចក្តីប្រាថ្នា ដោយមិនលំបាក ។ ៥- ជាអ្នកបានសម្រេចចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអាសវៈទាំងឡាយអស់ទៅ ដោយបញ្ញា ដ៏ក្រៃលែងក្នុងបច្ចុប្បន្ន ។ បពិត្រព្រះមានព្រះភាគ ភិក្ខុដែលជាថេរៈ ប្រកបដោយធម៌ ៥ ប្រការនេះឯង រមែងជាទីស្រឡាញ់ ជាទីពេញ

ចិត្ត ជាទីគោរព និងជាទីលើកតម្កើងរបស់សព្រហ្មចារីទាំងឡាយ ។ ព្រះមានព្រះភាគត្រាស់ទទួលថា ល្អហើយៗ ឧបវាណៈ ភិក្ខុដែលជាថេរៈប្រកបដោយធម៌ ៥ ប្រការនេះហើយ រមែងជាទីពេញចិត្ត ជាទីស្រឡាញ់ ជាទីគោរព និងជាទីលើកតម្កើងរបស់សព្រហ្មចារីទាំងឡាយ បើធម៌ ៥ ប្រការនេះ មិនមាននៅក្នុងភិក្ខុដែលជាថេរៈ សព្រហ្មចារីទាំងឡាយ នឹងធ្វើសក្ការៈ គោរពរាប់អានបូជា ភិក្ខុដែលជាថេរៈនោះ ដោយភាពជាអ្នកមាន ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ បានយ៉ាងណា តែធម៌ ៥ ប្រការនេះ មាននៅក្នុងភិក្ខុដែលជាថេរៈ ដូច្នោះ ទើបសព្រហ្មចារីទាំងឡាយ ធ្វើសក្ការៈ ធ្វើសេចក្ដីគោរពរាប់អានបូជា ចំពោះព្រះថេរៈនោះ ។

ព្រះឧបវាណត្ថេរ បានចូលទៅគាល់ព្រះមានព្រះភាគ ដើម្បីក្រាបទូលសួរដល់រឿងសុខ និងទុក្ខដែលកើតឡើង ព្រោះមានអ្វីជាហេតុ ដែលជាពាក្យរបស់សព្រហ្មចារីពួកខ្លះ ដែលមានការយល់ផ្សេងគ្នា ដូចមានរឿងដែលសម្ដែងទុកនៅក្នុង **គម្ពីរសំយុត្តនិកាយ និទានវគ្គ** នៃ **ឧបវាណសូត្រ** មានសេចក្ដីថា ៈ-

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងជេតពនមហាវិហារ ដែលសេដ្ឋីអនាថបិណ្ឌិកសាងថ្វាយ នៅជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះឧបវាណត្ថេរ បានចូលទៅគាល់ព្រះមានព្រះភាគដល់ទីគង់ប្រថាប់ ថ្វាយបង្គំរួចហើយ អង្គុយចុះក្នុងទីដ៏សមគួរ ក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន សមណព្រាហ្មណ៍មួយពួក បញ្ញត្តដាក់ជាច្បាប់ទុក ឬជាការតាំងឡើងថា ទុក្ខ គឺខ្លួនធ្វើឡើងដោយខ្លួនឯង សមណព្រាហ្មណ៍មួយពួកផ្សេងទៀត បញ្ញត្តថា ទុក្ខ អ្នកដទៃធ្វើឲ្យ ។ សមណព្រាហ្មណ៍មួយពួកផ្សេងទៀត បញ្ញត្តថា ទុក្ខ ខ្លួនធ្វើឡើងដោយខ្លួនឯងផង អ្នកដទៃធ្វើឲ្យផង ។ សមណព្រាហ្មណ៍មួយពួកផ្សេងទៀត បញ្ញត្តថា ទុក្ខ កើតឡើងដោយឯងៗ មិនមែនខ្លួនឯងធ្វើឲ្យ មិនមែនអ្នកដទៃធ្វើឲ្យ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវាទៈទាំង ៤ យ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងទុកយ៉ាងណា កាលបើខ្ញុំព្រះអង្គដោះស្រាយ តើត្រូវដោះស្រាយយ៉ាងណា ទើបត្រឹមត្រូវតាមព្រះវាចា ដែលព្រះមានជោគត្រាស់ហើយ និងជាការមិនពោលបន្ទំព្រះជិនស្រី ដោយពាក្យមិនពិត និងជាការពោលដោះស្រាយធម៌ តាមសមគួរដល់ធម៌ ទាំងជាការពោលស្របតាមពាក្យ

ដែលត្រឹមត្រូវ ដែលវិញ្ញូជនមិនតិះដៀលបាន ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ម្នាលឧបវាណៈ តថាគតពោលថា ទុក្ខ អាស្រ័យហេតុទើបកើតឡើង ។ ទុក្ខ អាស្រ័យអ្វីកើតឡើង ? ទុក្ខ អាស្រ័យផស្សៈកើតឡើង ។ បុគ្គលដែលពោលដូច្នេះ ឈ្មោះថា ជាអ្នកពោលតាមតថាគត និងមិនពោលបន្ទំតថាគត ដោយពាក្យមិនពិត និងជាការពោលដោះស្រាយធម៌ តាមសមគួរដល់ធម៌ ទាំងជាការពោលស្របតាមពាក្យដែលត្រឹមត្រូវ ដែលវិញ្ញូជនតិះដៀលមិនបាន ។

ម្នាលឧបវាណៈ វាទៈទាំង ៤ យ៉ាងនោះ គឺ ទោះបីពួកសមណព្រាហ្មណ៍មួយពួកបញ្ញត្តថា ទុក្ខ ខ្លួនធ្វើឡើងដោយខ្លួនឯង, ទុក្ខ ដែលពួកសមណព្រាហ្មណ៍មួយពួកទៀតបញ្ញត្តថា អ្នកដទៃធ្វើឲ្យ, ទុក្ខ ដែលពួកសមណព្រាហ្មណ៍មួយពួកទៀតបញ្ញត្តថា ខ្លួនធ្វើឲ្យផង អ្នកដទៃធ្វើឲ្យផង, សមណព្រាហ្មណ៍មួយពួកទៀតបញ្ញត្តថា ទុក្ខ កើតឡើងឯងៗ មិនមែនខ្លួនឯងធ្វើឲ្យ មិនមែនអ្នកដទៃធ្វើឲ្យក៏ដោយ តែរមែងកើតឡើងព្រោះអាស្រ័យផស្សៈ ។ ម្នាលឧបវាណៈ វាទៈទាំង ៤ យ៉ាងនោះ ដែលពួកសមណព្រាហ្មណ៍មួយពួកបញ្ញត្តថា ទុក្ខ ខ្លួនធ្វើឡើងដោយខ្លួនឯង បើវៀរផស្សៈហើយ គេរមែងបានទទួល

ទុក្ខ មិនមែនជាឋានៈដែលនឹងមាន ។ល។ ឬពួកសមណព្រាហ្មណ៍មួយពួកទៀតបញ្ញត្តថា ទុក្ខ កើតឡើងមិនមែនខ្លួនឯងធ្វើឲ្យ មិនមែនអ្នកដទៃធ្វើឲ្យ បើវៀរផស្សៈហើយ គេរមែងបានទទួលទុក្ខ មិនមែនជាឋានៈដែលនឹងមានឡើយ ។

ជីវប្រវត្តិក្នុងអតីតជាតិ របស់ព្រះឧបវាណត្ថេរ ទាក់ទងការកសាងបុណ្យបារមី ដែលកន្លងមកហើយ ក្នុងជាតិនោះ មានពោលទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** និង **គម្ពីរខុទ្ទកនិកាយ អបទាន** នៃ **សុភូតិវគ្គ ក្នុងរឿងព្រះឧបវាណត្ថេរាបទាន** ជារឿងដែលលោកពោលអំពីជីវប្រវត្តិរបស់លោក ក្រោយពេលដែលលោកបានជាព្រះអរហន្តហើយ ដូចមានសេចក្តីថា ៈ-

ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង រុងរឿងដូចជាគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។ មហាជនជួបជុំគ្នា បូជាព្រះតថាគត ធ្វើជើងថ្ករដ៏វិចិត្រ ហើយលើកតម្កល់ព្រះសរីរៈ ។ ពួកមហាជនទាំងនោះ ព្រមទាំងទេវតា និងមនុស្ស លុះធ្វើព្រះសរីរៈកិច្ចរួចហើយ ប្រមូលព្រះធាតុត្រង់កន្លែងជើងថ្ករនោះ មក

ធ្វើព្រះពុទ្ធស្តូប ។ ជាន់ទី ១ ធ្វើដោយមាស ជាន់ទី ២ ធ្វើដោយកែវមណី ជាន់ទី ៣ ធ្វើដោយប្រាក់ ជាន់ទី ៤ ធ្វើដោយកែវផលិក ។ ជាន់ទី ៥ នៃព្រះស្តូបនោះ ធ្វើដោយកែវទទឹម ជាន់ទី ៦ ធ្វើដោយកែវមរកត ខាងលើធ្វើដោយរតនៈគ្រប់យ៉ាង ។ ទ្រនាប់ខ្សាច់ ( នៃព្រះស្តូប ) ធ្វើដោយកែវមណី បង្កាន់ដៃធ្វើដោយកែវ តួព្រះស្តូបធ្វើមាសសុទ្ធទាំងអស់ កម្ពស់ឡើងទៅលើមួយយោជន៍ ។ កាលនោះទេវតាមកជួបជុំគ្នា ត្រង់កន្លែងនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ជាតាទិបុគ្គល ។ ព្រះធាតុឥតមានបែកខ្ញែកចេញពីគ្នា ព្រះសរីរធាតុនៅជាដុំមួយ ( បើដូច្នោះ ) ពួកយើងនឹងធ្វើព្រះស្តូប ស្រោបពីលើព្រះពុទ្ធស្តូបនេះ ។ ពួកទេវតាបានបង្កើនកម្ពស់មួយយោជន៍ដទៃទៀត ដោយកែវទាំង ៧ ប្រការ ព្រះស្តូបនោះទៅជាមានកម្ពស់ ២ យោជន៍ តែងកម្ចាត់បង់នូវងងឹតសព្វៗ កាល ។ គ្រានោះ ពួកនាគមកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាគ្នាថា ពួកមនុស្ស និងទេវតា បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ដូច្នេះ ពួកយើងចូរកុំប្រហែសឡើយ ព្រោះមនុស្ស និងទេវតាមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះមុនី

ព្រោះព្រះអង្គជាតាទិបុគ្គល ។ ពួកនាគទាំងនោះ ប្រមូលកែវឥន្ទនិល កែវមហានិល ទាំងកែវមណីមានរស្មីរុងរឿងក្នុងទីជាមួយគ្នា ហើយស្រោបព្រះពុទ្ធស្តូប ។ ព្រះពុទ្ធចេតិយទាំងមូល ប្រដាប់ដោយកែវមណីមានកម្ពស់ ៣ យោជន៍ តែងផ្សាយចេញនូវពន្លឺក្នុងកាលនោះ ។ កាលនោះ ពួកគ្រុឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្សទេវតា និងនាគទាំងឡាយ បានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ដូច្នេះ ពួកយើងចូរកុំប្រហែសឡើយ ព្រោះមានមនុស្ស និងទេវតាទាំងឡាយមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថព្រោះព្រះអង្គជាតាទិបុគ្គល ។ គ្រុឌទាំងនោះ បានធ្វើព្រះស្តូប ប្រដាប់ដោយកែវមណីសុទ្ធ ឲ្យជាគ្រឿងស្រោប មានទំហំប៉ុនគ្នា ពួកគ្រុឌទាំងនោះ បានធ្វើពុទ្ធចេតិយ ឲ្យមានកម្ពស់ កើនមួយយោជន៍ទៀត ។ ព្រះពុទ្ធស្តូប ទៅជាមានកម្ពស់ ៤ យោជន៍ រុងរឿងញ៉ាំងទិសទាំងអស់ឲ្យភ្លឺ ដូចព្រះអាទិត្យដែលរះឡើង ។ កាលនោះ ពួកកុម្ភណ្ឌមកជួបជុំគ្នា ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ និងគ្រុឌទាំងឡាយ បាននាំគ្នាធ្វើព្រះស្តូបដ៏ថ្លៃថ្លា ថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗគ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំង

ទ្បាយមិនប្រហែស បើដូច្នោះ ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះមុនី ព្រោះព្រះអង្គជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវទាំងឡាយតទៅទៀត ។ ពួកកុម្ភណ្ឌទាំងនោះ បានធ្វើពុទ្ធចេតិយឲ្យកើនកម្ពស់មួយយោជន៍តទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៥ យោជន៍ តែងរុងរឿងក្នុងកាលនោះ ។ លំដាប់នោះ ពួកយក្ខមកជួបជុំគ្នា ត្រង់កន្លែងព្រះស្តូបនោះ ហើយប្រឹក្សាជាមួយគ្នាថា ពួកមនុស្សទេវតា នាគ កុម្ភណ្ឌ និងគ្រុឌទាំងឡាយ បានធ្វើព្រះស្តូបដ៏ថ្លៃថ្លាថ្វាយព្រះពុទ្ធដ៏ប្រសើរផ្សេងៗ គ្នា ពួកយើងកុំធ្វេសប្រហែសឡើយ ព្រោះមនុស្ស និងទេវតាទាំងឡាយ មិនប្រហែស ពួកយើងនឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រោះព្រះអង្គ ជាតាទិបុគ្គល ពួកយើងនឹងស្រោបពុទ្ធចេតិយ ដោយកែវផលិកតទៅទៀត ។ ពួកយក្ខទាំងនោះ បានធ្វើពុទ្ធចេតិយឲ្យមានកម្ពស់មួយយោជន៍ទៅទៀត ព្រះស្តូបទៅជាមានកម្ពស់ ៦ យោជន៍ តែងរុងរឿងក្នុងកាលនោះ ។ គ្រានោះ ពួកគន្ធព្វប្រជុំប្រឹក្សាក្នុងទីជាមួយគ្នាថា ពួកមនុស្ស ទេវតា នាគ គ្រុឌ កុម្ភណ្ឌ និងយក្ខទាំងឡាយ ទាំងអស់គ្នាបានធ្វើព្រះស្តូបថ្វាយព្រះពុទ្ធ ឯពួកយើងមិនបានធ្វើព្រះស្តូបក្នុងទីនោះឡើយ បើដូច្នោះ ពួកយើង

នឹងធ្វើព្រះស្តូបថ្វាយព្រះលោកនាថ ព្រោះព្រះអង្គជាតាទិបុគ្គល ។ ពួកគន្ធព្វទាំងនោះ បានធ្វើថ្នាក់ទី ៧ ជាន់ ដរាបតាំងពីទ្រនាប់ខ្សាច់ឡើងទៅ បានធ្វើព្រះស្តូបសុទ្ធតែជាវិការនៃមាសទាំងអស់ ក្នុងកាលនោះព្រះស្តូបទៅជាមានកម្ពស់ ៧ យោជន៍ តែងរុងរឿង ក្នុងកាលនោះគេឥតដឹងថា យប់ ថ្ងៃ ព្រោះពន្លឺមាននៅសព្វៗ កាល ។ ព្រះច័ន្ទព្រះអាទិត្យព្រមទាំងពួកផ្កាយ គ្របសង្កត់ពន្លឺព្រះស្តូបនោះមិនបាន ឯប្រទីបរុងរឿង តែក្នុងទីចម្ងាយ ១០០ យោជន៍ជុំវិញ ។ ក្នុងកាលនោះ មនុស្សទាំងឡាយណាមួយ បូជាព្រះស្តូប មនុស្សទាំងនោះ មិនឡើងទៅកាន់ព្រះស្តូប មនុស្សទាំងនោះ តែងបោះទៅព្ធដ៏អាកាស ។ មានយក្ខមួយឈ្មោះថា អភិសម្មត: ដែលពួកទេវតាតាំងទុកហើយចាំទទួលទង់ ឬកម្រងផ្កាព្ធដ៏ខាងលើ ។ មនុស្សទាំងនោះ មិនឃើញយក្ខនោះទេ ឃើញតែកម្រងនៃផ្កាអណ្តែតទៅ លុះឃើញកម្រងផ្កាទាំងនោះហើយក៏ដើរទៅ ពួកមនុស្សទាំងអស់នោះឯង តែងទៅកាន់សុគតិ ។ ពួកមនុស្ស ទាំងអ្នកខុសសាសនា ទាំងអ្នកជ្រះថ្លា ក្នុងសាសនា ដែលចង់ឃើញបាដិហារិយ៍ តែងបូជាព្រះស្តូប ។ គ្រានោះខ្ញុំកើតជាអ្នកកម្សត់នៅក្នុងក្រុងហង្សវតី បានឃើញជនរីករាយហើយ

ក៏គិតយ៉ាងនេះ ក្នុងកាលនោះថា ព្រះស្តូបដែលបញ្ចុះព្រះសរីរធាតុប្រាកដដូចនេះ របស់ព្រះមានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះ មានបុណ្យដ៏លើសលប់ ពួកជននេះ មានចិត្តត្រេកអរហើយចំពោះជន អ្នកធ្វើនូវសក្ការៈ រមែងមិនក្តៅក្រហាយ ។ អាត្មាអញនឹងធ្វើសក្ការៈ ថ្វាយព្រះលោកនាថ ជាតាទិបុគ្គលដែរ នឹងបានជាព្រះទាយាទក្នុងធម៌ របស់ព្រះសម្ពុទ្ធអង្គនោះ ក្នុងកាលជាអនាគត ។ ខ្ញុំក៏លើកឡើងនូវសំពត់ របស់ជាងជ្រលក់ដែលបោកគក់យ៉ាងស្អាតព្យួរនឹងចុងឫស្សី ហើយលើកឡើងជាទង់ពួដ៏អាកាស ។ អភិសម្មតយក្ខ រីករាយកាន់ទង់របស់ខ្ញុំ ( ស្ថិតនៅ ) ពួដ៏អាកាស ខ្ញុំឃើញទង់ ដែលត្រូវខ្យល់បក់រវិចហើយ ក៏ញ៉ាំងសេចក្តីរីករាយ ឲ្យកើតឡើងដោយក្រៃលែង ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លា ចំពោះទង់នោះហើយ ក៏ចូលទៅរកព្រះសមណៈ ថ្វាយបង្គំទូលសួរនូវផលទង់នឹងភិក្ខុនោះ ។

ភិក្ខុនោះសម្តែងនូវកិរិយាកើតឡើង នៃសេចក្តីត្រេកអរ និងបីតិរបស់ខ្ញុំ ប្រាប់ខ្ញុំថា អ្នកនឹងបានទទួលផលរបស់ទង់នេះ សព្វៗកាល ។ សេនាមានអង្គ ៤ គឺដំរី សេះ រថ ពលថ្មើរជើង នឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ តូរ្យតន្ត្រី

៦០ ពាន់ និងស្គរដែលគេគាក់តែងយ៉ាងល្អ នឹងចោមរោមអ្នកអស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ ពួកនារី ៨៦ ពាន់ មានខ្លួនតាក់តែងបានយ៉ាងល្អ មានសំពត់ និងគ្រឿងអម្ពរដ៏វិចិត្រ ពាក់កែវមណី និងកុណ្ឌល ។ ពួកនារីទាំងនោះ មានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយ មានជង្ឃខ្លួនរៀវល្អ នឹងចោមរោមអ្នក អស់កាលជានិច្ច នេះជាផលនៃការថ្វាយទង់ ។ អ្នកនឹងរីករាយក្នុងទេវលោក អស់ ៣០ ពាន់កប្ប នឹងបានសោយទេវរាជ្យជាធំជាងទេវតា អស់ ៨០ ដង ។ នឹងបានជាស្តេចចក្រពត្តិ អស់ ១០០០ ដង នឹងសោយប្រទេសរាជ្យ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យជាតិ ។ កន្លងទៅមួយសែនកប្ប ព្រះសាស្តា ព្រះនាមគោតម ទ្រង់សម្ភពនៅក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ អ្នកនឹងច្យុតចាកទេវលោកមក ត្រូវកុសលមូលជាស់តឿន ប្រកបដោយបុញ្ញកម្ម នឹងកើតជាព្រាហ្មណ៍ អ្នកនឹងលះបង់ចោលនូវទ្រព្យ ៨០ កោដិ និងទាសកម្មករជាច្រើន ហើយបួសក្នុងសាសនា របស់ព្រះមានព្រះភាគព្រះនាមគោតម ។ អ្នកនឹងមានឈ្មោះថា ឧបវាណៈ

ញ៉ាំងព្រះសម្ពុទ្ធព្រះនាមគោតម ដ៏ប្រសើរជាងពួកសក្យៈ ឲ្យប្រោសប្រាណ ហើយនឹងបានជាសាវករបស់ព្រះសាស្តា ។

កុសលកម្មដែលខ្ញុំបានធ្វើហើយ ក្នុងរវាងមួយសែនកប្ប បានឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំផុតស្រឡះហើយ ( ចាកអាសវធម៌ ) ដូចសន្ទុះនៃព្រួញ ( ដែលផុតស្រឡះចាកធ្នូ ) ខ្ញុំដុតបំផ្លាញនូវកិលេសទាំងឡាយ របស់ខ្ញុំហើយ ។ កាលដែលខ្ញុំកើតជាស្តេចចក្រពត្តិ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ទង់ផុសឡើង ក្នុងរវាង ៣ យោជន៍ ដោយជុំវិញ សព្វៗ កាល ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការថ្វាយទង់ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ជីវប្រវត្តិបច្ចុប្បន្នជាតិរបស់ព្រះឧបវាណត្ថេរ ពោលក្នុងរឿងដែលលោកពាក់ព័ន្ធខ្លួន ធ្វើជាឧបដ្ឋាក ក្នុងរយៈពេលនៃបឋមពោធិកាលនៃការត្រាស់ដឹង ដូចមានរឿងតំណាលពោលទុក រួមជាមួយនឹងព្រះ-

ថេរៈអង្គដទៃៗ នោះ ដូចមានសម្ដែងនៅក្នុង **អដ្ឋកថាមនោរថបូរណី** ពោលក្នុងរឿងរបស់ព្រះអានន្ទត្ថេរ មានសេចក្ដីថា ៖-

ក្នុងបឋមពោធិកាល ព្រះភគវា ព្រះអង្គមិនទាន់មានភិក្ខុសង្ឃណាមួយ មករ៉ាប់ខ្លួនធ្វើជាឧបដ្ឋាក ជាប្រចាំរហូតអស់ ២០ វស្សា ។ ដោយពេលខ្លះ **ព្រះនាគសមាលៈ** កាន់បាត្រ និងចីវរឲ្យព្រះសម្ពុទ្ធ ។ ដោយគ្រាខ្លះក៏មាន **ព្រះនាគិតៈ** គ្រាខ្លះក៏មាន **ព្រះឧបវាណៈ** គ្រាខ្លះក៏មាន **ព្រះសុនក្ខត្តៈ** គ្រាខ្លះក៏មាន **ព្រះចុន្ទសមណុទ្ទេស** គ្រាខ្លះក៏មាន **ព្រះសាគតៈ** គ្រាខ្លះក៏មាន **ព្រះរាធៈ** និងនៅក្នុងគ្រាខ្លះក៏មាន **ព្រះមេឃិយៈ** ជាអ្នកកាន់បាត្រនិងចីវរឲ្យព្រះអង្គ ។ ដូច្នោះ រឿងនេះទើបជារឿងអះអាងបានថា **ព្រះឧបវាណៈ** បានរ៉ាប់ខ្លួនធ្វើជាឧបដ្ឋាកនៃព្រះទសពលមកពីកាលមុន មុនកាលដែលព្រះអានន្ទត្ថេរ មករ៉ាប់ខ្លួនធ្វើជាឧបដ្ឋាក នៃព្រះមហាមុនីជាប្រចាំ ។

ដូចមានរឿងដែលបង្ហាញឲ្យឃើញថា ព្រះឧបវាណៈ លោកក៏ធ្លាប់ធ្វើជាឧបដ្ឋាកនៃព្រះមហាវីរៈ មានរឿងសម្ដែងទុកនៅក្នុង **គម្ពីរសំយុត្តនិកាយ សគាថវគ្គ** នៃ **ទេវហិតសូត្រ** ក្នុង **ឧបសកវគ្គ** ថា ៖-

សម័យមួយ ព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន

ជិតក្រុងសាវត្ថី ។ ក្នុងកាលនោះ ព្រះលោកនាថ ទ្រង់ព្រះប្រឈួន ដោយរោគខ្យល់ ។ គ្រានោះ ព្រះឧបវាណត្ថេរ មាននាទីជាឧបដ្ឋាក នៃព្រះសក្យមុនី ដោយព្រះអង្គ បានត្រាស់ហៅព្រះឧបវាណត្ថេរមក ថា ម្នាលឧបវាណៈ អ្នកចូរទៅរកទឹកក្តៅមកថ្វាយដល់តថាគត ព្រះឧបវាណៈបានក្រាបទូលទទួលថា ព្រះករុណាព្រះអង្គ ហើយលោកបានកាន់យកបាត្រ និងគ្រងចីវរចូលទៅកាន់ផ្ទះរបស់ទេវហិតព្រាហ្មណ៍ ដោយទៅឈរស្ងៀមនៅក្នុងទីដ៏សមគួរ ។ ទេវហិតព្រាហ្មណ៍ បានក្រឡេកឃើញព្រះឧបវាណៈហើយ ទើបសួរឡើងថា លោកម្ចាស់ជាសមណៈក្បាលត្រងោល គ្រងនូវសំពត់សង្ឃដិ ឈរនៅស្ងៀម លោកម្ចាស់ត្រូវការអ្វី ? លោកម្ចាស់ស្វែងរកអ្វី លោកម្ចាស់មកដើម្បីសុំអ្វី ? ព្រះឧបវាណៈតបថា នែព្រាហ្មណ៍ ព្រះមុនី ទ្រង់ជាព្រះអរហន្ត ទ្រង់ជាព្រះសុគត ទ្រង់ជាអ្នកប្រាជ្ញ ឥឡូវនេះ ព្រះអង្គកំពុងតែប្រឈួនដោយរោគខ្យល់ ប្រសិនបើព្រាហ្មណ៍មានទឹកក្តៅ ក៏ចូរថ្វាយដល់ព្រះអង្គ ទ្រង់ជាអ្នកប្រាជ្ញចុះ ។ ព្រះសយម្ភូ ជាបុគ្គលគួរទទួលនូវការបូជាទាំងឡាយ ដែលបុគ្គលបានបូជាហើយ ជាអ្នកគួរទទួលសក្ការៈទាំងឡាយ ដែលបុគ្គលបានធ្វើសក្ការៈហើយ ជាអ្នក

គួរទទួលការនមស្ការទាំងឡាយ ដែលបុគ្គលបានធ្វើការនមស្ការហើយ អាត្មានិមន្តមកនេះ ដើម្បីត្រូវការទឹកក្តៅ នឹងយកទៅថ្វាយដល់ព្រះលោកនាថ ។ ទេវហិតព្រាហ្មណ៍ បានស្តាប់ព្រះកិត្តិគុណ របស់ព្រះជិនស្រីពីព្រះឧបវាណៈហើយ ទើបឲ្យបុរសរែកទឹកក្តៅ និងថូដាក់ទឹកអំពៅ តាមទៅប្រគេនព្រះឧបវាណៈនៅឯវត្តជេតពន ។

ព្រះឧបវាណត្ថេរ បាននាំទេវហិតព្រាហ្មណ៍មកដល់វត្តជេតពនហើយ ទើបចូលទៅក្រាបទូលព្រះលោកនាថ ឲ្យទ្រង់ស្រង់ទឹកក្តៅ និងនាំយកទឹកអំពៅទៅលាយនឹងទឹកផ្អិន ( ត្រជាក់ ) ហើយ ថ្វាយដល់ព្រះសក្យមុនី ។ ព្រះសាស្តា ក៏ទ្រង់បាត់ប្រឈួនរោគខ្យល់នោះទៅ ។ តមក ទេវហិតព្រាហ្មណ៍ បានចូលទៅក្រាបទូលសួរព្រះមុនីថា គួរឲ្យទេយ្យធម៌ក្នុងទីណា ទានដែលបុគ្គលឲ្យហើយ ក្នុងទីណាទើបមានផលច្រើន តើទក្ខិណាទានសម្រេចដល់បុគ្គល អ្នកបូជានោះយ៉ាងណា ។ ព្រះលោកនាយកត្រាស់តបថា ម្នាលព្រាហ្មណ៍ បុគ្គលណា ដែលដឹងនូវបុព្វេនិវាសានុស្សតិញ្ញាណ ឃើញស្ថានសួគ៌ និងអបាយ បានសម្រេចព្រះអរហត្ត ដែលអស់ការកើតទៀត បានសម្រេចអភិញ្ញា និងជាមុនី គួរឲ្យទេយ្យធម៌ក្នុងបុគ្គលនោះ ទានដែល

បុគ្គលឲ្យហើយ ចំពោះបុគ្គលនោះ ជាទានមានផលច្រើន ទក្ខិណារមែងសម្រេចដល់បុគ្គលដែលបូជាយ៉ាងនេះឯង ។ កាលព្រះពុទ្ធអង្គទ្រង់ត្រាស់ដូច្នេះហើយ ទេវហិតព្រាហ្មណ៍ ក៏បានក្រាបទូលពោលសរសើរព្រះធម៌ទេសនា និងបានប្រកាសខ្លួនជាឧបាសក អ្នកដល់នូវព្រះរតនត្រៃ ជាទីពឹង ទីរឭក ស្មើដោយជីវិតចាប់ពីថ្ងៃនេះតទៅ ។ រឿងនេះ ជាហេតុផលបញ្ជាក់ឲ្យឃើញថា ព្រះឧបវាណត្ថេរ លោកក៏ធ្លាប់បានធ្វើជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធដែរ និងជាហេតុផលបញ្ជាក់ដល់កាពអង់អាចរបស់លោកថា ដោយលោកបានដឹកនាំបុគ្គលដែលមិនមានសទ្ធាក្នុងព្រះសាសនានេះ ឲ្យមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនានេះបាន ។

ចំណែករឿងរបស់ព្រះឧបវាណៈ ដែលធ្វើជាឧបដ្ឋាកព្រះភគវាក្នុងបច្ឆិមពោធិកាល ក្រោយពេលនៃការត្រាស់ដឹង មានសម្តែងនៅក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** ក្នុង **មហាបរិនិព្វានសូត្រ** ថា ៖-

ក្នុងកាលព្រះទសពល ស្តេចចូលទៅគង់នៅសាលវនោទ្យានរបស់មល្លក្សត្រទាំងឡាយ នៅប្រាំងស្ទឹងហិរញ្ញវតី ជិតក្រុងកុសិនារាបានត្រាស់ប្រាប់ព្រះអានន្ទត្ថេរថា ឲ្យតម្កល់គ្រែបែរព្រះសិរសា ទៅ

ទិសឧត្តរ ក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ ទើបព្រះភគវាទ្រង់ផ្ទំ ដោយសីហសេយ្យាសន៍ គឺផ្ទំផ្អៀងខាងស្តាំ ទ្រង់មានសតិសម្បជញ្ញៈ នឹងទ្រង់តើនឡើង ។ ក្នុងគ្រានោះ ព្រះឧបវាណត្ថេរ បានឈរបក់ផ្លិត ថ្វាយចំពោះព្រះសម្ពុទ្ធ នៅចំព្រះភក្ត្ររបស់ព្រះអង្គ ។ ព្រះភគវាត្រាស់នឹងព្រះឧបវាណត្ថេរថា ម្នាលឧបវាណៈ អ្នកចូរចៀសចេញទៅ អ្នកកុំឈរនៅខាងមុខនៃតថាគតឡើយ ។ ព្រះអានន្ទបានស្តាប់ឮព្រះពុទ្ធដីកានោះហើយ ទើបគិតថា ព្រះឧបវាណៈនេះ លោកធ្លាប់ជាអ្នកបម្រើព្រះអង្គអស់កាលដ៏យូរដែរទេតើ លុះមកដល់ឥឡូវនេះត្រឡប់ជាព្រះមានព្រះភាគ ត្រាស់ឲ្យលោកចៀសចេញទៅ តើមានហេតុបច្ច័យអ្វីហ្ន៎ គិតដូច្នេះហើយ ទើបក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧបវាណៈ លោកធ្លាប់ជាអ្នកបដិបត្តិបម្រើជិតដិតនឹងព្រះលោកនាថអស់កាលដ៏យូរមកដែរទេតើ លុះមកដល់ឥឡូវនេះត្រឡប់ជាព្រះទសពលត្រាស់ឲ្យលោកចៀសចេញទៅ មិនឲ្យឈរចំព្រះភក្ត្រនៃព្រះអង្គដូច្នេះទៅវិញ តើមានហេតុបច្ច័យដូចម្តេចព្រះអង្គ? ព្រះសម្ពុទ្ធត្រាស់ថា ម្នាលអានន្ទ ទេវតាក្នុងម៉ឺនលោកធាតុ មានចំនួនច្រើនណាស់ បានមកប្រជុំគ្នា ដោយប្រាថ្នាចង់ឃើញតថាគត ក្នុង

ឧទ្យានសាលវ័ននេះ មានទំហំ ១២ យោជន៍ ទីប្រមាណប៉ុណ្ណេះ សូម្បី ប៉ុនចុងនៃរោមសត្វទ្រាយ ឬចាមរី ដែលទំនេរមិនមានទេ ទេវតា ដែលមានសក្តិធំមកនៅក្នុងទីនេះយ៉ាងណែនណាន់តាន់តាប់ តែមិនប៉ះ ពាល់កាយគ្នានិងគ្នា ទេវតាទាំងអស់តិះដៀលថា ពួកយើងមកអំពី ចម្ងាយ ប្រាថ្នាចង់ឃើញព្រះតថាគត ព្រះតថាគត ជាព្រះអរហន្ត សម្មាសម្ពុទ្ធជាម្ចាស់ ស្តេចតែងតែកើតឡើងក្នុងលោកម្តងម្កាល ប៉ុន្តែ នៅក្នុងបច្ឆិមយាមនៃរាត្រីនេះ ព្រះតថាគតនឹងស្តេចបរិនិព្វាន តែភិក្ខុ ដែលមានសក្តិធំរូបនេះ បានមកឈរបាំងនៅពីខាងមុខនៃព្រះទសពល ទៅវិញ ធ្វើឲ្យពួកយើងមិនបានឃើញព្រះតថាគតជាលើកចុងក្រោយ ដោយហេតុផលយ៉ាងនេះឯង អានន្ទ ទើបតថាគត មិនឲ្យឧបវាណៈ ឈរនៅខាងមុខតថាគត ។

រឿងរបស់ព្រះឧបវាណៈ នៅមានសម្តែងទុកនៅក្នុង **អដ្ឋកថា សុមង្គលវិលាសិនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរ ទីឃនិកាយ** នៃ **មហាបរិនិព្វានសូត្រ** ដូចមានសេចក្តីថា ៖-

ព្រះឧបវាណត្ថេរ បានស្តាប់ព្រះពុទ្ធតម្រាស់ត្រឹមតែមួយម៉ាត់ ប៉ុណ្ណោះ លោកក៏ដាក់ផ្ចិតចុះ ហើយចៀសចេញទៅឈរនៅក្នុងទីដ៏

សមគួរ ។ ចំណែកទេវតាទាំងឡាយ ដែលមានសក្តិធំ បាននិម្មិតខ្លួនឲ្យតូចៗ ឈរនៅក្នុងទីទំនេរប៉ុនចុងនៃរោមទ្រាយ ដោយត្រូវការឲ្យព្រះឧបវាណត្ថេរចៀសចេញទៅ ព្រោះទេវតាអាចមើលទម្លុះរាងកាយរបស់បុថុជ្ជនប៉ុណ្ណោះ តែមិនអាចមើលទម្លុះរាងកាយរបស់ព្រះអរហន្តបានទេ ទាំងមិនអាចចូលជិតព្រះឧបវាណត្ថេរបានផង ពីព្រោះព្រះថេរៈរូបនេះមានសក្តិធំជាង មានតេជះច្រើនជាង ។

មានសំណួរសួរថា តើហេតុអ្វីទើបមានតេជះច្រើន ចំពោះតែព្រះឧបវាណត្ថេរនេះឬ ចុះចំណែកព្រះអរហន្តដទៃ ? ឆ្លើយថា ហេតុដែលព្រះឧបវាណៈមានតេជះច្រើននោះ ពីព្រោះលោកធ្លាប់បានកើតជាអារក្ខទេវតាថែរក្សាព្រះចេតិយ របស់ព្រះកស្សបសម្មាសម្ពុទ្ធ ។

ដូចមានរឿងសម្តែងថា កាលព្រះវិបស្សីសម្ពុទ្ធស្តេចរំលត់ខន្ធបរិនិព្វានទៅហើយ មនុស្សទាំងឡាយ បាននាំគ្នាកសាងព្រះចេតិយសម្រាប់បញ្ចុះព្រះសារីរិកធាតុ ដែលមានសភាពដូចជាដុំមាសមួយដុំ គឺប្រសិនបើព្រះសម្ពុទ្ធមានព្រះជន្មវែង រមែងមានចេតិយតែមួយ ព្រះចេតិយនោះគេកសាងកម្ពស់មួយយោជន៍ ប្រើមាសប្រវែងមួយហត្ថកម្រាស់ ៨ ធ្នាប់ ធ្វើជាដុំឥដ្ឋ ប្រើហរតាល និងមនោសិលាជំនួស

ជីស្អិត ប្រើប្រេងល្វជំនួសទឹក ហើយពួកភុម្មទេវតា អាកាសទេវតា ឧណ្ហវលាហកទេវតា អព្ភវលាហកទេវតា ចាតុម្មហារាជិកទេវតា និងទេវតាជាន់តាវត្តិង្ស នាំគ្នាកសាងបំពេញបន្តឡើងទៅ មួយក្រុម មួយយោជន៍ទៀត សរុបកម្ពស់របស់ចេតិយ ៧ យោជន៍ ។ កាល បរិស័ទទាំងឡាយកាន់យកគ្រឿងសក្ការបូជា មានផ្កា និងគ្រឿងក្រអូប ក្រណាត់ស្បៃជាដើម មកបូជាព្រះចេតិយនោះ អារក្ខទេវតាបាននាំ យកឡើងទៅបូជាព្រះចេតិយ ឲ្យមនុស្សទាំងនោះមើលឃើញបាន ។ ក្នុងកាលនោះ ព្រះឧបវាណៈបានកើតជាព្រាហ្មណ៍មហាសាល ហើយ កាន់សំពត់ពណ៌លឿងមួយផ្ទាំងទៅបូជា ទេវតាទាំងឡាយបានទទួល សំពត់នោះពីដៃរបស់ព្រាហ្មណ៍ យកឡើងទៅបូជាព្រះចេតិយ លុះ ព្រាហ្មណ៍បានឃើញហើយក៏កើតសទ្ធាជ្រះថ្លា ទើបតាំងប្រាថ្នាថា សូម ឲ្យខ្ញុំបានជាអារក្ខទេវតា ក្នុងព្រះចេតិយរបស់ព្រះទសពលដូច្នេះ ក្នុង អនាគតកាលចុះ ។

លុះព្រាហ្មណ៍នោះអស់ជីវិតទៅ បានទៅកើតក្នុងទេវលោក កាលត្រាច់រង្គាត់នៅក្នុងទេវលោក និងមនុស្សលោកនោះ រហូតដល់ ព្រះសម្មាទកស្សបៈត្រាស់ដឹងឡើងនៅក្នុងលោក ហើយស្តេចរំលត់ខន្ធ

បរិនិព្វានទៅ បរិស័ទទាំងឡាយ ក៏បាននាំគ្នាកសាងព្រះចេតិយកម្ពស់មួយយោជន៍ សម្រាប់បញ្ចុះព្រះសារីរិកធាតុ ព្រះលោកនាថអង្គនោះ ហើយព្រាហ្មណ៍នោះ បានមកកើតជាអារក្ខទេវតា នៅព្រះចេតិយដែលតម្កល់ព្រះសារីរិកធាតុនោះ ។ កាលបើអស់ព្រះសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ហើយ អារក្ខទេវតា បានទៅកើតក្នុងទេវលោកទៀត ។

លុះមកដល់កាលនៃព្រះពុទ្ធ ជាបរមគ្រូនៃយើងនេះ ទេវបុត្រនោះ បានច្យុតចាកទេវលោក មកបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ហើយចេញបព្វជ្ជា បានជាព្រះអរហន្ត ដូចបានពោលរួចមកហើយ ។ ព្រះឧបវាណត្ថេរ ជាអ្នកមានតេជះច្រើន ពីព្រោះលោកធ្លាប់បានកើតជាអារក្ខទេវតាក្នុងព្រះចេតិយ ដូចបានរៀបរាប់មកនេះឯង ។

តាមរឿងរបស់ព្រះឧបវាណត្ថេរ ដែលបានចូលមកជាឧបដ្ឋាកព្រះមានព្រះភាគ ក្នុងពេលជិតនឹងបរិនិព្វាននោះ ល្មមជាសក្ខីភាពបញ្ជាក់ថា លោកមានជីវិតរស់នៅរហូតដល់ក្រោយពុទ្ធបរិនិព្វាន ។

ព្រះឧបវាណត្ថេរ លោកបានធ្វើសេចក្តីល្អជាច្រើន ទាំងក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិ ដោយហេតុនេះ ទើបធ្វើឲ្យលោកបាន

សម្រេចនូវសម្បត្តិលោកុត្តរធម៌ ដែលជាការអស់ទៅ នៃសេចក្តីទុក្ខ ដោយផលបុណ្យ និងសេចក្តីល្អនោះឯង ទើបជាហេតុ ធ្វើឲ្យលោកបានជួយប្រកាសព្រះធម៌វិន័យ ឲ្យដល់មហាជនបានយល់ដឹងទៀតផង ។

ព្រះឧបវាណត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ៕

( ជីវប្រវត្តិរបស់ព្រះឧបវាណត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះអង្គុលិមាលត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះអង្គុលិមាល លោកជាព្រះមហាថេរៈ ដែលយើងគ្រប់គ្នាតែងស្គាល់លោកហើយ ពីព្រោះលោក បានកសាងជីវប្រវត្តិដ៏គួរឲ្យអស្ចារ្យ និងសង្វេគ ទាំងផ្លូវលោក និងផ្លូវធម៌ ។ ជីវប្រវត្តិរបស់លោកមានទាំងផ្នែកអាក្រក់ និងផ្នែកល្អ រីឯផ្នែកល្អនោះ មិនមែនល្អថ្នាក់ធម្មតាទេ គឺល្អយ៉ាងខ្ពស់បំផុត ទាំងលោក ក៏បានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ពីព្រះលោកនាថ ដោយសង្គ្រោះលោកចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កមួយរូបផងដែរ រីឯចំណែកជីវប្រវត្តិរបស់លោកគួរឲ្យចាប់អារម្មណ៍ ឬជាតួយ៉ាង ។

ជីវប្រវត្តិរបស់ព្រះអង្គុលិមាលត្ថេរ តាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** ក្នុង **អង្គុលិមាលសូត្រ** ថា ៈ-

ព្រះអង្គុលិមាល មានព្រាហ្មណីដែលជាមាតាឈ្មោះថា **នាងមន្តានី** និងព្រាហ្មណ៍ដែលជាបិតាឈ្មោះថា **គគ្គៈ** លោកមានតំណែង

ជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលមហារាជ នៅក្នុងក្រុងសាវត្ថី ។ អង្គុលិមាលប្រសូតចាកគភ៌មាតា នៅពេលអធ្រាត្រការប្រសូតិនោះ បានកើតមាននិមិត្តប្រាកដឡើងដែលគួរឲ្យអស្ចារ្យ គឺសស្ត្រាវុធយុទ្ធកណ្ឌទាំងឡាយ ធ្លាក់ចុះមកពេញនគរ ភ្លឺសន្ធោសន្ធៅដូចអណ្តាតភ្លើង រហូតដល់ព្រះមង្គលាវុធដែលដាក់នៅជិតព្រះក្រឡាបន្ទំរបស់ព្រះបាទបសេនទិកោសលមហារាជ ក៏មានពន្លឺសន្ធោសន្ធៅឡើងប្រហែលគ្នានឹងអណ្តាតភ្លើង ។ កាលបើមានហេតុអស្ចារ្យដូច្នេះហើយ គគ្គព្រាហ្មណ៍ ដែលជាព្រះរាជបុរោហិតាចារ្យ មានចំណេះដឹងក្នុងការមើលផ្កាយ និងមើលឫក្សយាមយ៉ាងជំនាញ ទើបប្រញាប់ចេញចាកផ្ទះ ទៅពិនិត្យមើលផ្កាយលើផ្ទៃមេឃ បានឃើញថា កូនរបស់ខ្លួនកើតនៅក្នុងពេលចោរឫក្ស គឺឫក្សចោរ កាលបើពិនិត្យវិគ្រោះតាមតម្រាហើយយល់ថា កូនរបស់យើងនឹងជាចោរយ៉ាងពិតប្រាកដ ( ដែលដឹងតាមវិជ្ជាហោរាសាស្ត្រ គឺវិជ្ជាពោលដោយការព្យាករណ៍ ដោយអាស្រ័យតារាសាស្ត្រ គឺការដឹងរឿងផ្កាយផ្សេងៗ ជាគោល ) ។ កាលដឹងដូច្នេះហើយ លុះព្រឹកឡើង ក៏បានប្រញាប់ចេញទៅចូលទៅគាល់ព្រះបាទបសេនទិកោសល បានក្រាបទូលសួរដល់ការផ្ទំរបស់ព្រះរាជា

តាមទំនៀមដែលធ្លាប់បដិបត្តិមកថា សូមតេជះតម្កល់លើត្បូង សូមក្រាបថ្វាយបង្គំក្រោមល្អងធូលីព្រះបាទ ព្រះអង្គទ្រង់ផ្ទំជាសុខឬទេ ? ព្រះករុណាថ្លៃវិសេស ព្រះអង្គ ។ គ្រានោះ ព្រះបាទបសេនទិកោសល ត្រាស់តបថា នែលោកអាចារ្យ ការផ្ទំរបស់ខ្ញុំមិនជាសុខឡើយ ព្រោះអាវុធដែលជាមង្គលរបស់ខ្ញុំ បានមានពន្លឺសន្ធោសន្ធៅឡើង ដូចគ្នានឹងអណ្តាតភ្លើង ខ្ញុំយល់ថា នឹងមានអន្តរាយដល់រាជសម្បត្តិ ឬជីវិតរបស់ខ្ញុំ យ៉ាងណានីមួយយ៉ាងពិតប្រាកដ ។

គគ្គព្រាហ្មណ៍រាជបុរោហិត ក្រាបបង្គំទូលតបព្រះរាជតម្រាស់នោះថា បពិត្រមហារាជ ទ្រង់មានបុញ្ញាធិការ សូមឲ្យព្រះអង្គ ទ្រង់កុំមានភ័យឡើយ និមិត្តដ៏គួរឲ្យអស្ចារ្យ ដែលកើតឡើងហើយនោះ ដោយសារពីយប់មិញនេះ មានទារកកើតឡើងនៅក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ សស្ត្រាវុធទាំងឡាយ ដែលមានពន្លឺសន្ធោសន្ធៅឡើងហាក់បីដូចជាអណ្តាតភ្លើងនោះ ដោយអានុភាពរបស់ទារកនោះទេ ព្រះករុណាថ្លៃវិសេស ។ គ្រានោះ ព្រះរាជាត្រាស់សួរថា នែលោកអាចារ្យ ទារកនោះជាអ្វីតទៅក្នុងកាលជាអនាគត ? គគ្គព្រាហ្មណ៍បានក្រាបបង្គំទូលថា ទារកនេះក្នុងកាលជាអនាគត នឹងជាចោរ ព្រះករុណាជីវិតតម្កល់

លើត្បូង ៗ ព្រះរាជាត្រាស់សួរដោយការផ្តោតព្រះទ័យក្រៃលែងទៀតថា ទារកនេះជាឯកចោរ គឺចោរម្នាក់ដើរប្លន់សម្បត្តិឯកជន ឬជាចោរដែលជណ្តើមរាជសម្បត្តិមែនឬអត់ លោកអាចារ្យ ? រាជបុរោហិតអ្នកស្ទាត់ក្នុងការទាយ បានក្រាបទូលពាក្យទំនាយថា សូមតេជះ ទារកនោះ នឹងជាឯកចោរ គឺចោរម្នាក់ដើរធ្វើចោរកម្មឯកជនប៉ុណ្ណោះ ព្រះករុណាថ្លៃវិសេស ព្រះអង្គ ៗ កាលក្រាបបង្គំទូលដូច្នេះហើយ មានបំណង ធ្វើឲ្យព្រះរាជាសព្វព្រះហឫទ័យ ទើបក្រាបបង្គំទូលឡើងថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គមានព្រះរាជឱង្ការឲ្យសម្លាប់ទារកនោះចោល ដើម្បីកុំឲ្យភាពវឹកវរកើតឡើង ព្រោះតែទារកនេះ ព្រះករុណាថ្លៃវិសេស ព្រះអង្គ ៗ

ព្រះបាទបសេនទិកោសលទ្រង់ត្រាស់ហាមថា នែលោកអាចារ្យ ទារកនោះ ត្រឹមតែជាឯកចោរ នឹងធ្វើអ្វីយើងបាន ប្រៀបដូចកួរស្រូវសាលី ត្រឹមតែមួយកួរនៅក្នុងស្រែដ៏ធំទូលាយចំនួន ១០០០ ករីស ( ១ ករីស = ១២៥ ហត្ថ ) ព្រោះដូច្នោះ លោកអាចារ្យចូរចិញ្ចឹមទារកនោះទុកឲ្យល្អចុះ ៗ កាលបានទទួលព្រះមហាករុណាពីព្រះរាជា គគ្គព្រាហ្មណ៍ ទើបបានចិញ្ចឹមកូនប្រុសរបស់ខ្លួនដោយល្អ ៗ លុះដល់

ពេលដែលនឹងដាក់ឈ្មោះឲ្យទារកនោះ មាតាបិតា ព្រមដោយពពួកញាតិ សម្រេចគ្នានឹងដាក់ឈ្មោះឲ្យផ្ទុយគ្នា នឹងនិមិត្តនៃហេតុ ដែលប្លែក ដោយឡែកនោះថា **អហិង្សកកុមារ** ប្រែថា អ្នកមិនបៀតបៀន ដើម្បីកែនិមិត្តនៃសស្ត្រាវុធ ដែលមានពន្លឺសន្ធោសន្ធៅ ហាក់បីដូចជាអណ្តាតភ្លើងនោះ មិនឲ្យកើតហេតុអាក្រក់ឡើង ។

ប៉ុន្តែ រឿងឈ្មោះអហិង្សកៈនេះ មានហេតុផលផ្សេងគ្នា ដូចដែលមានសម្តែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា ៖-

ការដាក់ឈ្មោះឲ្យកុមារនោះ ព្រោះព្រះបាទបសេនទិកោសល បានព្រះរាជទាននាមឲ្យ និងបានពោលដល់ភាវៈ ជាអ្នកមានកម្លាំងខ្លាំង និងការធ្វើបុណ្យកុសលទុកក្នុងអតីតជាតិរបស់អហិង្សកកុមារ ។ អហិង្សកកុមារ ជាអ្នកមានកម្លាំងខ្លាំងក្លាស្មើនឹងដំរី ៧ ទាំងនេះ កើតឡើងដោយបុណ្យកុសល របស់អហិង្សកកុមារ ដែលបានធ្វើទុកមកហើយក្នុងអតីតជាតិ គឺក្នុងជាតិមួយ អហិង្សកកុមារនេះ បានកើតជាកសិករ បានជួបព្រះបច្ចេកពុទ្ធមួយអង្គ ដែលមានចីវរសើម ពីព្រោះត្រូវភ្លៀងទទឹក គេក៏កើតសទ្ធាជ្រះថ្លាឡើងក្នុងចិត្តថា ពេលនេះយើង

បានជួបស្រែបុណ្យហើយ ទើបបន្តាត់ភ្លើង ថ្វាយដល់ព្រះបច្ចេកពុទ្ធនោះ ដោយកុសលកម្មនេះ ធ្វើឲ្យលោកកើតជាតិណាៗ តែងជាអ្នកមានកម្លាំងខ្លាំងស្មើនឹងដំរី ៧ គ្រប់ៗ ជាតិ ។

ការសិក្សាវិជ្ជាការរបស់អហិង្សកកុមារ ដែលជាការចាប់ផ្តើមមុនដំបូងនោះ ដូចមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបបញ្ចសូទនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **អង្គុលិមាលសូត្រ** ថា ៖-

កាលអហិង្សកកុមារចម្រើនវ័យធំដឹងក្តីឡើង សមគួរនឹងអាចសិក្សាសិល្បវិជ្ជាហើយ គគ្គព្រាហ្មណ៍ និងនាងព្រាហ្មណី ទើបបានបញ្ជូនអហិង្សកកុមារកូនប្រុសរបស់ខ្លួនទៅស្វែងរកចំណេះដឹង នៅឯនគរតក្កសិលា ។ អហិង្សកៈ លុះធ្វើដំណើរទៅដល់នគរតក្កសិលាហើយ បានចូលទៅប្រគល់ខ្លួន ជាសិស្សក្នុងសម្នាក់របស់លោកអាចារ្យទិសាបាមោក្ខមួយកន្លែង ដើម្បីសុំការសិក្សាសិល្បវិជ្ជា និងប្រាកដថា គេជាអ្នកមានបញ្ញាល្អ រៀនចេះគ្រប់វិជ្ជា ដែលលោកអាចារ្យបានបង្រៀន ទាំងជាអ្នករៀនពូកែជំនាញជាងសិស្សដទៃទៀតក្នុងសម្នាក់ជាមួយគ្នា ។ ការប្រឹងប្រែងព្យាយាមរៀនសូត្រ និងធ្វើវត្តប្រតិបត្តិចំពោះលោកអាចារ្យ និងភរិយារបស់លោកអាចារ្យ ដោយ

គោរព ទើបធ្វើឲ្យលោកអាចារ្យ និងភរិយាសង្គ្រោះអហិង្សកកុមារ ដោយបាយ និងទឹកជាដើម និងជាមនុស្សជឿស្តាប់ពាក្យរបស់លោកអាចារ្យ ប្រតិបត្តិល្អស្មើចុងស្មើដើម ។ អហិង្សកៈ ទើបបានជាទីស្រឡាញ់ពេញចិត្ត និងប្រោសប្រាណពីលោកអាចារ្យទិសាបាមោក្ខណាស់ ។ កាលតមក មិនយូរប៉ុន្មាន អហិង្សកៈ ដោយការស្រឡាញ់ និងយកចិត្តទុកដាក់ពីលោកអាចារ្យ និងភរិយា ទើបធ្វើឲ្យសិស្សដទៃមានការប្រណែន ចំពោះអហិង្សកៈ ។

ពួកសិស្សដែលមានការប្រណែនទាំងនោះ កាលបើបានឃើញអហិង្សកៈ ទទួលបាននូវការយកចិត្តទុកដាក់អំពីលោកអាចារ្យ ដូច្នេះហើយ ដោយសេចក្តីប្រណែនកើតឡើងនោះ ទើបនាំគ្នាប្រឹក្សាថា តាំងពីអហិង្សកៈ ចូលមកនៅក្នុងសម្នាក់នេះកាលណាហើយ ពួកយើងក៏ចាប់ផ្តើមអាប់ឱន ថែមទាំងមិនបានទទួលការយកចិត្តទុកដាក់ពីលោកអាចារ្យដូចកាលមុនឡើយ ដូច្នេះ ពួកយើងគួរធ្វើយ៉ាងណា ញុះញង់ឲ្យអហិង្សកៈ បែកចេញអំពីលោកអាចារ្យបាន ឧបាយដែលយើងញុះញង់លោកអាចារ្យថា អហិង្សកៈ ជាមនុស្សល្ងង់ខ្លៅ ដូចជាមិនកើត ព្រោះថា អហិង្សកៈ ជាអ្នកមានបញ្ញាពូកែជាងពួកយើង ឬនឹង

ញុះញង់លោកអាចារ្យថា អហិង្សកៈជាអ្នកមិនបដិបត្តិខ. វត្តដែលល្អ ក៏និយាយមិនបាន ពីព្រោះខ.បដិបត្តិរបស់គេល្អសែនល្អ ឬទឹងញុះញង់លោកអាចារ្យថា អហិង្សកៈ ជាអ្នកមានជាតិត្រកូលមិនល្អ ក៏លោកអាចារ្យ មិនជឿ ព្រោះថា គេជាអ្នកបរិបូណ៌ដោយជាតិត្រកូល ពួកយើងនឹងធ្វើយ៉ាងណាទើបល្អហ្ន៎ ។ នៅក្នុងចំនួនសិស្សទាំងនោះ មានមាណពម្នាក់ដែលជាអ្នកមានបញ្ញាគ្រាន់បើ ដោយការគិតឃើញឧបាយរបស់ខ្លួន ទើបបានពោលឡើងថា ណ្ហើយចុះ ពួកយើងនឹងញុះញង់លោកអាចារ្យ ឲ្យស្អប់អហិង្សកៈទាល់តែបាន ថាហើយ ទើបបែងចែកសិស្សទាំងនោះ ជាបីពួក ដើម្បីចូលទៅនិយាយញុះញង់លោកអាចារ្យ ម្តងមួយពួកៗ ។ គ្រាដំបូងចាត់បញ្ជូនសិស្សពួកទី ១ ឲ្យចូលទៅរកលោកអាចារ្យ ដោយចូលទៅនៅឈរស្ងៀម មិនពោលពាក្យណាៗ ទាំងអស់ ។ កាលបើលោកអាចារ្យបានឃើញអាការប្លែករបស់សិស្ស ដែលខុសពីកាលមុន ទើបសួរឡើងថា ពួកអ្នកមានធុរៈអ្វីឬ ? ពួកសិស្ស ពួកដំបូងតបថា ពួកខ្ញុំបានឮរឿងមួយកើតឡើងនៅក្នុងផ្ទះនេះ ។ លោកអាចារ្យសួរថា មានរឿងអ្វី ? ពួកសិស្សតបថា ពួកខ្ញុំបានជ្រាបថា អហិង្សកៈគិតអាក្រក់ចំពោះលោកអាចារ្យ ។ លោកអាចារ្យ

ស្តីបន្ទោសឡើងថា យើពួកមនុស្សអាក្រក់ ពួកអ្នកចូរនាំគ្នាចេញទៅឥឡូវនេះចុះ កុំមកនិយាយបន្ថុចកូនរបស់យើង ។ កាលពួកសិស្សពួកទី ១ ចេញទៅមួយភ្លែត សិស្សពួកទី ២ បាននាំគ្នាចូលមកនិយាយទំនងដូចគ្នា តែលោកអាចារ្យមិនព្រមជឿ កាលពួកសិស្សទី ២ ចេញទៅ ពួកសិស្សទី ៣ ទើបចូលមកដល់ ហើយនាំគ្នានិយាយដូចគ្នានឹងពួកសិស្សមុនៗ តែត្រូវលោកអាចារ្យបណ្តេញចេញទៅទៀតដូចមុនដែរ ។ ចំណែកពួកសិស្សទី ៣ នេះ កាលបើឃើញលោកអាចារ្យមិនព្រមជឿការនិយាយញុះញង់បំបែកបំបាក់របស់ខ្លួន ទើបនាំគ្នានិយាយបោលចុងក្រោយ ឲ្យលោកអាចារ្យគិតមុននឹងខ្លួនចេញទៅថា លោកអាចារ្យ សូម្បីលោកអាចារ្យ ក៏មិនជឿតាមពាក្យរបស់ពួកខ្ញុំ តែមិនជាអ្វីទេ សូមឲ្យលោកអាចារ្យសង្កេតពិនិត្យពិចារណាមើល ដោយខ្លួនឯង ។

អាចារ្យទិសាបាមោក្ខ កាលបើបានស្តាប់ ពួកសិស្សចូលមកនិយាយប្រាប់ក្នុងរឿងដូចគ្នា រហូតដល់ ៣ ពួក ដូច្នោះហើយ ទើបនាំឲ្យមានការយល់ខុសស្រេបតាមថា ជារឿងពិត ហើយទើបគិតនឹងសម្លាប់អហិង្សកៈចោល តែត្រឡប់ភ្ញាក់គំនិតថា ប្រសិនបើយើង

សម្លាប់អហិង្សកៈចោលក្នុងទីនេះ នឹងធ្វើឲ្យកើតការរិះគន់ជាច្រើនថា លោកអាចារ្យទិសាបាមោក្ខ បានសម្លាប់កូនសិស្សដែលបានមកសិក្សាវិជ្ជាសិល្បៈក្នុងសម្នាក់របស់ខ្លួន បើជាយ៉ាងនេះ ក្នុងកាលជាអនាគតប្រាកដជាមិនមានមាណពណាហ៊ានមកសិក្សាសិល្បវិជ្ជា ក្នុងសម្នាក់របស់យើងទៀតទេ ដូច្នេះ លាភសក្ការៈរបស់យើងត្រូវវិនាសអន់ថយទៅ គិតដូច្នេះហើយ ទើបគិតរកឧបាយដែលធ្វើឲ្យអហិង្សកៈទៅត្រូវសម្លាប់ខាងក្រៅសម្នាក់ ដែលជាឧបាយធ្វើឲ្យខ្លួនរួចផុតអំពីការរិះគន់អំពីបុគ្គលដទៃ ដោយមិនមាននរណាដឹង ។ កាលលោកអាចារ្យគិតរកឧបាយកលបានហើយ ទើបប្រាប់ដល់អហិង្សកៈថា នែអហិង្សកៈសិល្បវិជ្ជា ការដែលអ្នកត្រូវរៀនជិតនឹងបានសម្រេចហើយ តែអ្នកចូរទៅសម្លាប់មនុស្សឲ្យបាន ១០០០ នាក់ យើងនឹងប្រកបសិល្បសាស្ត្រដែលមានឈ្មោះថា **វិស្ណុមន្ត** ឲ្យដល់អ្នក និងការសិក្សារបស់អ្នក ក៏នឹងបានសម្រេចដោយបរិបូណ៌ ។ ក្នុងពេលជាដំបូង អហិង្សកៈមានការរង្កៀសក្នុងការសម្លាប់មនុស្ស ទើបមកប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំបាទកើតនៅក្នុងត្រកូលព្រាហ្មណ៍អហិង្សកៈ គឺត្រកូលដែលមិនមានការបៀតបៀនអ្នកដទៃ ព្រោះដូច្នោះ ខ្ញុំបាទមិនអាចសម្លាប់

មនុស្សបានទេ ។ គ្រានោះ លោកអាចារ្យទើបនិយាយជំទាស់ថា នែ អហិង្សកៈ បើអ្នកមិនអាចសម្លាប់មនុស្សបានទេ ការសិក្សាសិល្បសាស្ត្ររបស់អ្នក ក៏នឹងមិនបានសម្រេចបរិបូណ៌ពិតប្រាកដឡើយ ។

អហិង្សកៈ បានជឿក្នុងពាក្យនិយាយរបស់លោកអាចារ្យថាជាការពិត ហើយប្រកបនឹងការចង់សម្រេចវិជ្ជាមន្ត ទើបបានត្រៀមចងអាវុធ ៥ ប្រការទុកនឹងខ្លួន ហើយក្រាបបង្គំលាលោកអាចារ្យ ទៅដោយការបន្ទំចិត្ត ទៅសម្លាប់មនុស្ស ដោយចូលទៅក្នុងព្រៃក្រាស់ជាសិទី ដោយចាំស្កាត់សម្លាប់មនុស្ស ដែលចូលទៅក្នុងព្រៃក្រាស់នោះ អ្នកនៅក្នុងកណ្តាលព្រៃខ្លះ អ្នកដែលចេញចាកព្រៃខ្លះ តែកាលអហិង្សកៈសម្លាប់មនុស្សហើយ មិនបានកាត់យកវត្ថុណាទីមួយទុកជាគ្រឿងកំណត់សម្គាល់ គ្រាន់តែបានកំណត់ទុកក្នុងចិត្តថា យើងសម្លាប់បានម្នាក់ហើយ ពីរនាក់ហើយ ដូច្នេះ តែកន្លងទៅយូរថ្ងៃ ក៏ចាំមិនបានថា តើយើងសម្លាប់មនុស្សបានប៉ុន្មាននាក់ហើយ ពីព្រោះហេតុថា ចិត្តរបស់អ្នកធ្វើបាណាតិបាត តែងមិនតាំងមាំ ។ តពីនោះមក កាលអហិង្សកៈ សម្លាប់មនុស្សហើយ បានកាត់យកម្រាមដៃទុកម្នាក់មួយម្រាម តែម្រាមដៃទាំងនោះ កើតការរលួយ ក៏រហូតបាត់

ទៅម្តងបន្តិចៗ គេទើបដោតម្រាមដៃឲ្យជាប់ជាកម្រងដូចផ្កា ហើយពាក់ជាប់នឹង-ក ។ កាលតមក មនុស្សទាំងឡាយ បានហៅអហិង្សកៈថា **ចោរអង្គុលិមាល** ប្រែថា ចោរអ្នកមានម្រាមដៃជាកម្រងផ្កា ហើយឈ្មោះអហិង្សកៈក៏បាត់ទៅ ប្រាកដឈ្មោះមកវិញថា ចោរអង្គុលិមាល ទើបមានអ្នកហៅរហូតជាប់មាត់ និងល្បីល្បាញទូទៅទៀតផង ។ ក្នុងគ្រានោះ ចោរអង្គុលិមាល បានធ្វើព្រៃក្រាស់ទាំងអស់ មិនឲ្យមានអ្នកដំណើរទៅមក មនុស្សជាច្រើនមិនហ៊ានទៅកាន់ព្រៃបេះបន្លែ ឬកាប់ឧសជាដើម ដោយភ័យខ្លាចចោរអង្គុលិមាលសម្លាប់ ។ វិធីតទៅរបស់អង្គុលិមាល គឺគេចូលទៅកាន់ស្រុកក្នុងពេលពាក់កណ្តាលយប់ ប្រើជើងធាក់ទ្វារទម្លាយ ហើយចូលទៅសម្លាប់មនុស្សដែលកំពុងតែដេកលក់ សម្លាប់ហើយ កាត់យកម្រាមដៃម្នាក់មួយៗ គេចចេញទៅ ។ ពួកអ្នកស្រុកបានទទួលភាពក្តៅក្រហាយ ពីព្រោះញាតិ ឪពុកម្តាយ បងប្អូន ត្រូវចោរអង្គុលិមាលសម្លាប់ ហើយទើបនាំគ្នាផ្លាស់ទីលំនៅបែកខ្ញាត់ខ្ញាយ រត់ចូលទៅរស់នៅក្នុងនិគម ចំណែកអ្នកនិគមបាននាំគ្នារត់ចូលទៅរស់នៅក្នុងក្រុង ដោយភ័យខ្លាចចោរអង្គុលិមាលសម្លាប់ ។

មនុស្សទាំងឡាយ ដោយច្រើនដែលតាំងលំនៅ នៅឆ្ងាយពី

ព្រៃក្រាស់នោះ ៣ យោជន៍ ហើយក៏ដោយ ប៉ុន្តែដោយការខ្លាចចោរអង្គុលិមាល តែងតែបាននាំគ្នារត់ចោលផ្ទះសម្បែង ប្តីកូន ជញ្ជូនចៅរត់ទៅខ្ចាត់ខ្ចាយ ដោយទៅកាន់ក្រុងសាវត្ថី កាលបើបានកន្លែងស្នាក់អាស្រ័យសមគួរហើយ បាននាំគ្នាចូលទៅក្រាបបង្គំទូលរឿងទាំងអស់នោះ ដល់ព្រះបាទបសេនទិកោសលថា សូមតេជះ ចោរអង្គុលិមាលបានកើតឡើងក្នុងដែនរបស់ព្រះអង្គហើយ ព្រះករុណាវិសេស ។ ព្រះបាទបសេនទិកោសលត្រាស់ជាមួយនឹងប្រជាជនទាំងនោះថា ថ្ងៃស្អែកនេះ ខ្ញុំនឹងលើកពលយោធាចេញទៅចាប់ចោរអង្គុលិមាល ។ រយៈពេលនៃការទៅរកសម្លាប់មនុស្សរបស់ចោរអង្គុលិមាល កន្លងមកដល់រយៈពេលនេះ ប្រាកដថា ចោរអង្គុលិមាលទៅសម្លាប់មនុស្ស និងកាត់យកម្រាមដៃដោតជាកម្រងពាក់-ក បាន ៩៩៩ ម្រាម នៅសល់តែមួយម្រាមទៀតប៉ុណ្ណោះ ឬក៏ម្នាក់ទៀត នឹងគ្រប់ ១០០០ នាក់ ដូចដែលលោកអាចារ្យបានកំណត់ឲ្យ ព្រោះដូច្នោះ ចោរអង្គុលិមាល ទើបចេញទៅស្វែងរកសម្លាប់មនុស្សដោយសង្ឃឹមថា ខ្លួននឹងសម្លាប់មនុស្សឲ្យបានគ្រប់ ១០០០ នាក់ ។ ដំណឹងចចាមអារ៉ាមក្នុងរឿងចោរអង្គុលិមាលបានជ្រាបទៅដល់គគ្គព្រាហ្មណ៍ដែលជាបិតា ។ គគ្គព្រាហ្មណ៍បានយល់

ថា ចោរអង្គុលិមាលនោះ គង់នឹងជាបុត្ររបស់យើងយ៉ាងពិតប្រាកដ ទើបប្រាប់ដល់នាងមន្តានីជាភរិយាថា ចោរដែលឈ្មោះថា អង្គុលិមាល នោះ មិនមែននរណាដទៃក្រៅអំពីអហិង្សកៈកូនប្រុសរបស់យើងនោះទេ ឥឡូវនេះ ព្រះរាជាទ្រង់ស្តេចយាងទៅចាប់ដោយព្រះអង្គឯង ចំពោះចោរអង្គុលិមាល តើយើងគួរធ្វើយ៉ាងណាទើបល្អ ?

នាងមន្តានីព្រាហ្មណីទើបប្រាប់ស្វាមីថា បើយ៉ាងនោះ លោកគួរនឹងទៅប្រាប់ឲ្យកូនរបស់យើង រត់គេចទៅកាន់ទីដទៃទៅ ឬនាំកូនរបស់យើងមកវិញ កុំឲ្យព្រះរាជាទ្រង់ចាប់បានឡើយ ។ គគ្គព្រាហ្មណ៍ពោលថា យើងមិនត្រូវការកូនដូច្នេះទេ ព្រះរាជាទ្រង់ធ្វើយ៉ាងណា ក៏ធ្វើទៅ ទាំងយើងក៏មិនអាចនឹងទៅរកកូនបែបនេះ ព្រោះថា មិនគួរនឹងទុកចិត្តក្នុងបុគ្គល ៤ ចំពូក គឺ ១. មិនគួរនឹងទុកចិត្តថា ចោរម្នាក់នេះជាសម្លាញ់ចាស់របស់យើង ២. មិនគួរនឹងទុកចិត្តសម្លាញ់ថា សម្លាញ់នេះធ្លាប់បានស្និទ្ធស្នាលជាមួយនឹងយើងជាយូរមកហើយ ៣. មិនគួរទុកចិត្តព្រះរាជាថា ព្រះរាជារាប់អានបូជាយើង ៤. មិនគួរទុកចិត្តស្ត្រីថា ស្ត្រីនេះធ្លាក់នៅក្នុងអំណាចរបស់យើង ។ ធម្មតាចិត្តរបស់មាតាតែងតែទន់ទោរ មានការអាណិតអាសូរចំពោះបុត្រធីតារបស់ខ្លួន ដោយ

ហេតុនេះ ទើបធ្វើឲ្យនាងមន្តានីព្រាហ្មណីប្រាប់ដល់ស្វាមីថា បើយ៉ាងនោះ ខ្ញុំនឹងទៅរកកូនប្រុសរបស់ខ្ញុំដោយខ្លួនឯងក៏បាន ពោលដូច្នោះហើយ ក៏បានប្រញាប់ប្រញាល់ចេញពីក្រុងសាវត្ថីទៅ ។

រឿងពុទ្ធវិធីប្រោសដល់ចោរអង្គុលិមាលនោះ ដូចមានសម្តែងនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** នៃ **អង្គុលិមាលសូត្រ** មានសេចក្តីថា ៈ-

សម័យមួយ ព្រះសយម្ភូ ទ្រង់គង់ប្រថាប់ក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ក្នុងពេលទៀបភ្លឺនៃរាត្រីថ្ងៃមួយ ព្រះអង្គក៏បានប្រមើលមើលឧបនិស្ស័យរបស់សត្វលោក ទ្រង់ក៏បានឃើញឧបនិស្ស័យ នៃចោរអង្គុលិមាល មកប្រាកដនៅក្នុងសំណាញ់ញាណ របស់ព្រះអង្គ ទើបទ្រង់អាវជ្ជនាការ គឺការរព្ញកថា កាលបើតថាគត ទៅប្រោសប្រយោជន៍ នៃការសម្រេចជាព្រះសោតាបត្តិផល នឹងកើតមានឡើងដល់ចោរអង្គុលិមាល បើតថាគតមិនទៅប្រោសទេ ចោរអង្គុលិមាលដែលជាមនុស្សសាហាវយង់ឃ្នង នឹងសម្លាប់មាតារបស់ខ្លួន ហើយនឹងទៅសោយទុក្ខក្នុងអវិចីនរក ដូច្នេះ គួរតែតថាគតទៅប្រោសដល់ចោរអង្គុលិមាល ទើបជាការល្អ លុះពេលអរុណោទ័យ ( ពេល

ព្រឹកព្រលឹម ឬពេលនៃអរុណរះឡើង ) ព្រះវិជិតមារ ស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់ពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តកិច្ច ទ្រង់រៀបចំសេនាសនៈ រួចប្រដាប់ដោយបាត្រនិងចីវរ ស្តេចយាងសំដៅទៅត្រង់កន្លែងដែលចោរអង្គុលិមាលនៅ ។ ដោយព្រះអង្គស្តេចយាងទៅមុននាងមន្តានីព្រាហ្មណីទៅដល់ ។ រីឯពួកអ្នកកង្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកធ្វើដំណើរបានឃើញព្រះមានជោគ ស្តេចកំពុងតែយាងទៅត្រង់កន្លែងដែលចោរអង្គុលិមាលនៅ ដោយរង់ចាំស្ទាក់សម្លាប់មនុស្ស ដឹងដូច្នេះហើយ ទើបព្រមគ្នាក្រាបទូលហាមថា បពិត្រព្រះសមណៈ សូមកុំនិមន្តទៅព្រៃនោះអី ត្បិតព្រៃនោះ មានចោរអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ដោយឈាម ប្រក្រតីតែងតែបៀតបៀន និងសម្លាប់មនុស្សជាច្រើន ដោយឥតមានការអាណិតអាសូរពពួកសត្វមានជីវិតឡើយ និងបានធ្វើស្រុកឲ្យទៅមិនមែនជាស្រុកក៏មាន ធ្វើនិគមឲ្យទៅមិនមែនជានិគមក៏មាន ធ្វើជនបទឲ្យទៅមិនមែនជាជនបទក៏មាន ចោរនោះតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ទោះបីបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០

នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ព្រៃនោះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសនៅក្នុងកណ្តាប់ដៃចោរអង្គុលិមាល សម្លាប់ទាំងអស់ ព្រះករុណា ព្រះអង្គ ។

បុរសទាំងនោះបានក្រាបទូលហាមយ៉ាងនេះហើយ ព្រះភគវា ក៏ទ្រង់ស្ងៀម ទ្រង់ក៏នៅតែយាងទៅទៀត ។ ជនទាំងនោះឃើញព្រះអង្គទ្រង់មិនជឿ ទើបក្រាបទូលជាលើកទីពីរ និងលើកទីបីទៀត ព្រះសក្យមុនីក៏ទ្រង់មិនជឿស្តាប់ ទ្រង់នៅតែយាងទៅមុខទៀត ។ លុះចោរអង្គុលិមាល បានឃើញនាងមន្តានីព្រាហ្មណី ដែលជាមាតាមកពីចម្ងាយហើយ ទើបគិតថា ថ្ងៃនេះឯង យើងនឹងសម្លាប់ម្តាយរបស់យើង កាត់យកម្រាមដៃជាគម្រប់ ១០០០ គិតរួចស្រេចហើយ បានដកដាវចេញពីស្រោម ទាំងត្រៀមកាន់ខែល និងសៀតធ្នូទៅក្នុងបំពង់ព្រួញ ដោយរត់សំដៅទៅរកមាតាមួយរំពេច ។ ខណៈនោះ ព្រះមុនីស្តេចបានមកដល់ចន្លោះផ្លូវពាក់កណ្តាល នៃបុគ្គលទាំងពីរនាក់នោះ ព្រះអង្គក៏បង្ហាញព្រះកាយ ឲ្យចោរអង្គុលិមាលបានឃើញ កាលបើចោរអង្គុលិមាល បានក្រឡេកឃើញព្រះសម្ពុទ្ធ ស្តេចយាងមកអំពីចម្ងាយ ដូច្នេះហើយ ទើបគិតសាឡើងវិញថា រាប់ថាជាការអស្ចារ្យ

ពិតៗ ព្រោះព្រៃនេះ ទោះបុរស ១០-២០-៣០-៤០ នាក់ក្តី នាំគ្នាដើរជាពួកៗ នៅតែត្រូវយើងសម្លាប់គ្មានសល់ម្នាក់ តែដូចម្តេចព្រះសមណៈរូបនេះ ទើបមកតែម្នាក់ឯង មិនមានអ្នកណាមកជាមួយ សូម្បីតែម្នាក់ មើលអាការហាក់បីដូចថា នឹងមកកំហែងយើង យើងនឹងសម្លាប់សមណៈនេះឲ្យបាន ។ គិតរួចស្រេចដូច្នេះហើយ ទើបចាប់ដាវយ៉ាងមាំ សៀតធ្នូ និងបំពង់ព្រួញ រត់ដេញតាមព្រះលោកទាថពីក្រោយឈប់ដេញតាមសម្លាប់មាតារបស់ខ្លួន ។ គ្រានោះ ព្រះទសពល ទ្រង់សម្តែងឫទ្ធិធ្វើឲ្យចោរអង្គុលិមាល រត់ដេញតាមពេញទំហឹងហើយ នៅតែរត់មិនទាន់ព្រះអង្គ ដោយទ្រង់សម្តែងឫទ្ធិ ឲ្យផែនដីដូចជារលកនៃទឹកមហាសមុទ្ទ ដែលមានផ្ទៃទឹកធំទូលាយ ជាទឹក ជាកក់ល្បាប់ ពាំងនៅខាងមុខ ។ ចំណែកចោរអង្គុលិមាលបានគិតថា យីអើអស្ចារ្យពេកណាស់ ពេលមុនៗ សូម្បីដំរីកំពុងបោល សេះដែលកំពុងផាយ រថដែលកំពុងលឿន ឬម្រឹគដែលកំពុងតែបោល យើងនៅតែស្ទុះដេញចាប់បាន គេគិតដូច្នេះហើយ ទើបឈប់ឈរនៅស្ងៀម ហើយស្រែកយាត់ថា សមណៈឈប់សិន សមណៈឈប់សិន ។

គ្រានោះ ព្រះមានព្រះភាគត្រាស់តបថា តថាគតឈប់ហើយ

នៅតែអ្នកឯងទេតើ មិនទាន់ឈប់ ព្រោះដូច្នេះ អ្នកឯងចូរឈប់ដែរ ទៅ ។ ពេលនោះ ចោរអង្គុលិមាល បានស្ដាប់ព្រះពុទ្ធតម្រាស់នោះ ហើយ ចោរអង្គុលិមាល ទើបគិតថា សមណៈទាំងឡាយ ជាអ្នក ពោលពាក្យពិត ជាអ្នកមានសច្ចបដិញ្ញា តែសមណៈនេះកំពុងតែ ដើរទេតើ ម្ដេចឡើយ ទើបពោលប្រាប់យើងថា តថាគតឈប់ហើយ ទាំងប្រាប់ឲ្យយើងឈប់ផងដែរ ដូច្នេះ អញត្រូវសួរសមណៈនេះ ឲ្យ ដឹងរឿងសិនមើល លុះគិតដូច្នេះហើយ ទើបក្រាបទូលសួរឡើងថា នែសមណៈ លោកកំពុងតែដើរទេតើ ចុះហេតុអ្វី ក៏បានជាលោក ត្រឡប់ជានិយាយថា តថាគតឈប់ហើយ និងប្រាប់ឲ្យខ្ញុំឈប់ផង ដែរ ខ្ញុំសូមសួរលោកថា ដែលលោកនិយាយថា តថាគតឈប់ហើយ នៅតែអ្នកឯងមិនទាន់ឈប់នោះ តើមានសេចក្ដីយ៉ាងណាដែរ ? ព្រះ លោកនាថត្រាស់តបថា នែអង្គុលិមាល ដែលតថាគតពោលថាឈប់ ហើយនោះ មានសេចក្ដីថា តថាគតឈប់បៀតបៀនសត្វទាំងឡាយ ហើយ នៅតែអ្នកឯងទេតើ ដែលមិនទាន់ឈប់នោះ ។ លំដាប់នោះ ចោរអង្គុលិមាលក្រាបទូលឡើងថា បពិត្រព្រះសមណៈ លោកជាអ្នក ស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតា និងមនុស្សទាំងឡាយ តែង

បូជា លោកមកកាន់ទីនេះ ដើម្បីប្រយោជន៍សង្គ្រោះដល់ខ្ញុំព្រះអង្គ ដោយពិតប្រាកដមែន ខ្ញុំព្រះអង្គបានស្តាប់នូវព្រះវាចា ដែលប្រកបដោយធម៌របស់ព្រះអង្គហើយ ខ្ញុំព្រះអង្គនឹងលះបង់នូវបាបទាំងនោះចេញ កាលក្រាបទូលដូច្នេះហើយ ក៏គ្រវែងដាវ និងអាវុធចោលទៅក្នុងត្រពាំងក្នុងជ្រោះ ក្នុងរណ្តៅ ដោយកាត់ចិត្តមិននឹកនាដល់អំពើទាំងអស់នោះឡើយ ហើយបានបង្អោនខ្លួន ក្រាបចុះទៀបព្រះយុគលបាទ របស់ព្រះមានជោគ និងក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងពេលនោះឯង ។ ព្រះមានបុណ្យ ទ្រង់មានព្រះមហាករុណា ដែលទ្រង់ជាព្រះបរមគ្រូនៃទេវតា និងមនុស្សទាំងឡាយ ទើបទ្រង់បានប្រោសប្រទានការបព្វជ្ជាឧបសម្បទាឲ្យដល់ចោរអង្គុលិមាល ដោយទ្រង់ត្រាស់ថា អ្នកចូរមកជាភិក្ខុចុះ ធម៌ណា ដែលតថាគតសម្តែងទុកហើយដោយល្អ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីធ្វើឲ្យអស់ទៅនូវទុក្ខដោយប្រពៃចុះ លុះចប់ព្រះពុទ្ធតម្រាស់នោះ ចោរអង្គុលិមាលបានភាវៈជាភិក្ខុទៅ ។

ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយនៅក្នុង **អដ្ឋកថាថា** ព្រះលោកនាយក ទ្រង់ជ្រាបហើយថា អង្គុលិមាល ជាអ្នកធ្លាប់បានថ្វាយគ្រឿងបរិក្ខារទាំង ៨ ដល់អ្នកមានសីលរួចមកហើយ ក្នុងអតីតជាតិ

មុនៗ ដោយហេតុដូច្នេះ ទើបព្រះសក្យមុនី ទ្រង់ត្រាស់ប្រទានឯហិភិក្ខុឧបសម្បទា ហើយព្រះអង្គុលិមាល ក៏មាននូវបរិក្ខារទាំង ៨ ដែលសម្រេចដោយបុញ្ញឫទ្ធិភ្លាមៗ ពេលនោះឯង ព្រមគ្នានឹងព្រះទសពលតម្រាស់ត្រាស់ចប់ ។ ព្រះអង្គុលិមាលត្ថេរ មានឈ្មោះមួយទៀតថា **ព្រះគគ្គមន្តានីបុត្ត** ដោយនាំយកឈ្មោះមាតាបិតា របស់លោកមកហៅរួមជាមួយគ្នា ។ ចំណែកមាតារបស់ព្រះអង្គុលិមាល កាលបើរកកូនមិនជួប ទើបត្រឡប់ទៅផ្ទះរបស់ខ្លួនវិញ ក្នុងថ្ងៃនោះឯង ។ ក្នុងសម័យមួយ ព្រះលោកនាថ ទ្រង់ទូន្មានព្រះអង្គុលិមាលត្ថេរ ឲ្យអស់ចបេសអាក្រក់ឈប់ធ្វើជាចោរ ចូលមកបួសក្នុងព្រះពុទ្ធសាសនានេះហើយ មានមហាជនពួកខ្លះ នៅមិនទាន់បានជ្រាបក្នុងរឿងនេះ ដោយការភ្ញាក់ផ្អើលស្រឡាំងកាំងខ្លាចចោរអង្គុលិមាល បាននាំគ្នាទៅជំនុំក្រាបបង្គំទូលតវ៉ានៅត្រង់ទ្វារព្រះរាជវាំង របស់ព្រះបាទបសេនទិកោសលថា សូមតេជះ បពិត្រព្រះសម្មតិទេព ចោរអង្គុលិមាលមកដល់ដែនរបស់ព្រះអង្គហើយ ជាចោរដែលកាច មានដៃប្រឡាក់ទៅដោយឈាមបានដើរសម្លាប់មនុស្សជាច្រើន ជាអ្នកមានចិត្តមិនមានមេត្តា ករុណាដល់មនុស្សទាំងឡាយទេ រហូតធ្វើស្រុក និគម និងជនបទ ឲ្យក្លាយ

ទៅជាកន្ទែងស្ងាត់ទំនេរ មិនមានមនុស្សនៅ ចោរអង្គុលិមាលនោះ ពេលសម្លាប់មនុស្សរួចហើយ តែងតែកាត់យកម្រាមដៃមកដោតជាកម្រងដូចជាកម្រងផ្កាពាក់-ក ហេតុដូច្នេះ សូមព្រះអង្គ ទ្រង់កម្ចាត់ចោរអង្គុលិមាលនោះចោល ព្រះករុណាវិសេស ព្រះអង្គ ។

លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ព្រះសណ្តាប់នូវពាក្យក្រាបទូលរបស់មហាជន ដូច្នេះហើយ ទើបស្តេចចេញចាកក្រុងសាវត្ថី ព្រមដោយទាហានសេះ ៥០០ តែព្រះអង្គមិនបានតម្រង់ទៅបង្ក្រាបចោរអង្គុលិមាលតែម្តងទេ ទ្រង់បានស្តេចយាងចៀងចូលទៅកាន់វត្តជេតពន ក្នុងពេលថ្ងៃត្រង់នោះឯង ដោយស្តេចចុះចាកពីយានហើយ ស្តេចបានចូលទៅគាល់ព្រះជិនស្រី ទ្រង់ថ្វាយបង្គំហើយ ទ្រង់គង់ប្រថាប់នៅក្នុងទីដ៏សមគួរ ។ **មានសំណួរក្នុងអដ្ឋកថាបបញ្ចសូទនីដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃអង្គុលិមាលសូត្រថា ហេតុអ្វី បានជាព្រះបាទបសេនទិកោសល ទើបស្តេចយាងចៀងចូលទៅកាន់វត្តជេតពននោះសិន ។ មានចម្លើយថា** ព្រោះព្រះបាទបសេនទិកោសលទ្រង់ខ្លាចចោរអង្គុលិមាល ទាំងមិនមានព្រះបំណងនឹងទៅបង្ក្រាបដែរ តែចាំបាច់ស្តេចត្រូវតែចេញទៅ ព្រោះទ្រង់ខ្លាចពាក្យនិន្ទា ទើបទ្រង់

ត្រិះរិះថា យើងទៅគាល់ព្រះលោកនាថជាមុនសិន ។ ប្រសិនបើព្រះអង្គទ្រង់ត្រាស់សួរយើងថា ព្រោះហេតុអ្វីទើបទ្រង់លើកពលយោធាចេញមកក្នុងពេលនេះ យើងនឹងក្រាបទូលឲ្យព្រះអង្គទ្រង់ជ្រាប ។ ព្រះអង្គក៏ប្រាកដជាទ្រង់សង្គ្រោះប្រយោជន៍ដល់យើង ទាំងបច្ចុប្បន្ន និងទាំងអនាគតមិនខានទេ ប្រសិនបើយើងមានជ័យជម្នះក្នុងគ្រានេះ ព្រះមុនីទ្រង់នឹងអនុញ្ញាតឲ្យយើងទៅ តែបើយើងជាអ្នកចាញ់វិញ ព្រះអង្គនឹងត្រាស់ហាមឃាត់យើងថា តើប្រយោជន៍ឯណា ដែលមហាបពិត្រនឹងត្រូវស្តេចចេញទៅព្រោះចោរម្នាក់ មហាជនទាំងឡាយ នឹងបានដឹងទូទៅថា ព្រះរាជាស្តេចបានយាងចេញទៅ ដើម្បីនឹងទៅចាប់ចោរអង្គុលិមាលហើយ ដោយថាព្រះមហាវីរៈត្រាស់ហាមឃាត់ កាលបើដូចនេះ យើងនឹងផុតចាកពាក្យនិន្ទា កាលព្រះរាជា ទ្រង់ពិចារណាឃើញដូច្នេះហើយ ទើបបានជាស្តេចយាងចៀងចូលទៅវត្តជេតពនជាមុនសិន មុននឹងស្តេចយាងចេញទៅបង្ក្រាបចោរអង្គុលិមាល ។

ការយាងចូលគាល់ព្រះភគវា របស់ព្រះបាទបសេនទិកោសល ជាហេតុឲ្យព្រះអង្គ បានជួបនឹងព្រះអង្គុលិមាលត្ថេរ ដូចមានសេចក្តីអធិប្បាយនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ** ថា ៖-

ព្រះលោកនាយក បានត្រាស់សួរព្រះបាទបសេនទិកោសល ដែលស្ដេចយាងចូលមកគាល់ថា បពិត្រមហារាជ ព្រះអង្គមានរឿង នឹងព្រះបាទពិម្ពិសារ ឬទ្រង់មានរឿងនឹងស្ដេចលិច្ឆវី ឬទ្រង់មានរឿង ជាមួយនឹងក្សត្រអង្គដទៃៗ ទៀត ប្រការណាមួយឬ ? គ្រានោះ ព្រះ បាទបសេនទិកោសល ទ្រង់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ ព្រះអង្គគ្មានរឿងអ្វីនឹងព្រះបាទពិម្ពិសារ បណ្ដាស្ដេចលិច្ឆវី ឬនឹងក្សត្រ អង្គដទៃៗ នោះទេ តែថាមានចោរម្នាក់ ឈ្មោះអង្គុលិមាលកើតឡើង ក្នុងដែនរបស់ខ្ញុំព្រះអង្គ ជាចោរដែលកាចណាស់ សម្លាប់មនុស្សអស់ ជាច្រើន ជាចោរឥតមានចិត្តមេត្តាករុណា ដល់អ្នកណាមួយឡើយ បានធ្វើឲ្យស្រុក និងទីក្រុងកើតការជ្រួលច្របល់ឡើង គ្មានសេចក្ដី សុខស្ងប់ ពេលដែលចោរអង្គុលិមាលសម្លាប់មនុស្សហើយ តែងតែ បានកាត់យកម្រាមដៃ ទៅដោតជាកម្រងពាក់-ក របស់គេ ខ្ញុំព្រះអង្គ នឹងទៅបង្ក្រាប ក្នុងពេលឥឡូវនេះ ព្រះអង្គ ។ គ្រានោះ ព្រះជិនស្រី ត្រាស់ថា នៃមហាបពិត្រ ប្រសិនបើព្រះអង្គទ្រង់បានទតឃើញចោរ អង្គុលិមាលកោរសក់ ពុកមាត់ ពុកចង្កាចេញហើយ បួសក្នុងព្រះ សាសនានេះ ឬធម្មវិន័យនេះ ហើយជាអ្នកវៀរចាកបាណាតិបាត គឺ

មិនសម្លាប់សត្វ គឺមិនលួចទ្រព្យគេ និងវៀរចាកមុសាវាទ គឺមិននិយាយកុហក ជាអ្នកឆាន់ចង្ហាន់តែមួយពេល ប្រព្រឹត្តខ្លួនឲ្យដូចជាព្រហ្ម គឺជាអ្នកមានសីលដ៏ល្អស្អាត ព្រះអង្គនឹងទ្រង់ធ្វើយ៉ាងណា ? ព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលថា ខ្ញុំព្រះអង្គនឹងថ្វាយបង្គំ ក្រោកទទួលនិមន្តឲ្យគង់ដោយគោរព នឹងតាំងចិត្តបដិបត្តិទំនុកបម្រុង ដោយបច្ច័យទាំងឡាយ ៤ ដល់លោក ប៉ុន្តែបុគ្គលដែលមានការកាចសាហាវ ដូចជាចោរអង្គុលិមាលនេះ នឹងសង្រួមនៅក្នុងសីលដូចម្តេចកើតទៅ បើជាអ្នកមានចិត្តមិនមានមេត្តាដូច្នេះនោះ ព្រះអង្គ ?

ក្នុងគ្រានោះ ព្រះអង្គុលិមាលត្ថេរ ក៏បានគង់នៅជិតព្រះភគវានោះដែរ ប៉ុន្តែព្រះបាទបសេនទិកោសលទ្រង់មិនស្គាល់លោក ។ ព្រះសម្ពុទ្ធ ទ្រង់បានលាតព្រះហស្តខាងស្តាំចង្អុលប្រាប់ថា នេះឯង ចោរអង្គុលិមាល មហាបពិត្រ ។ លុះព្រះបាទបសេនទិកោសល ទ្រង់បានក្រឡេកឃើញ ព្រះអង្គុលិមាលត្ថេរហើយ ទ្រង់កើតការភ័យខ្លាចតក់ស្លុត ព្រឺរោម ព្រឺស្បែក កើតឡើងមួយរំពេចក្នុងពេលនោះឯង ។ ក្នុងសេចក្តីនោះ មានពាក្យអធិប្បាយនៅក្នុង **អដ្ឋកថា** ថា មិនមែនត្រឹមតែព្រះបាទបសេនទិកោសលភ័យខ្លាចប៉ុណ្ណឹងទេ សូម្បីយោធាទាំង

៥០០ នាក់ ដែលមកតាមព្រះបាទបសេនទិកោសល ម្នាក់ៗ ក៏ភ័យខ្លាចដូចគ្នា និងខ្លាចរហូតដល់បោះបោលខែល និងអាវុធប្រញាប់រត់ចូលទៅព្រះនគរបិទទ្វារព្រះនគរហើយ រត់ឡើងទៅលើបន្ទាយរង់ចាំមើល ហើយនិយាយជាមួយគ្នានិងគ្នាថា ចោរអង្គុលិមាលគង់នឹងជ្រាបថា ព្រះរាជានឹងមកចាប់យើង ទើបបានមកកាន់វត្តជេតពនមុន ដូច្នេះចោរអង្គុលិមាលប្រាកដជាចាប់ព្រះរាជាទុកហើយ ចំណែកពួកយើងបានរត់មកផុតហើយ ។ ព្រះសយម្ភូ ទ្រង់ត្រាស់លួងលោមព្រះទ័យព្រះបាទបសេនទិកោសលថា មហាបពិត្រទ្រង់កុំភ័យខ្លាចអី អន្តរាយកើតពីអង្គុលិមាលមិនមានទៀតទេ ។ កាលព្រះបាទបសេនទិកោសលទ្រង់ព្រះសណ្តាប់ហើយ ការភ័យខ្លាចតក់ស្លុតក៏ស្ងប់រំងាប់បាត់អស់ទៅការព្រឺរោមក៏ស្ងប់ចុះភ្លាមដែរ ព្រះរាជាទើបទ្រង់យាងចូលទៅជិតព្រះអង្គុលិមាលត្ថេរ ( មានព្រះរាជឱង្ការសួរ ) បពិត្រលោកម្ចាស់ដ៏ចម្រើនលោកម្ចាស់ឈ្មោះអង្គុលិមាលឬ ? ព្រះអង្គុលិមាលត្ថេរ ទើបថ្វាយព្រះពរតបថា សូមថ្វាយព្រះពរ មហាបពិត្រ អាត្មាភាពនេះឯង ជាអង្គុលិមាល ។

គ្រានោះ ព្រះរាជាមានព្រះរាជឱង្ការបន្តទៅទៀតថា មាតាបិតា

របស់លោកម្ចាស់ មានជាតិត្រកូលយ៉ាងណា មានឈ្មោះថាអ្វី ? ព្រះអង្គុលិមាលត្ថេរថ្វាយព្រះពរតបថា ញោមប្រុសរបស់អាត្មាភាព ឈ្មោះថា **គគ្គព្រាហ្មណ៍** ចំណែកញោមស្រីរបស់អាត្មាភាពឈ្មោះថា **នាងមន្តានីព្រាហ្មណី** សូមថ្វាយព្រះពរ ។ ព្រះរាជាបានបវារណាព្រះអង្គុលិមាលថា សូមលោកម្ចាស់សប្បាយចិត្តចុះ ញោមនឹងបដិបត្តិទំនុកបម្រុងលោកម្ចាស់ ដោយចតុប្បច្ច័យទាំងឡាយ ដែលសមគួរដល់សមណបរិភោគ តាមសេចក្តីប្រាថ្នារបស់លោកម្ចាស់ ដែលត្រូវការ ។ ក្នុងគ្រានោះ ព្រះអង្គុលិមាល បានសមាទានធុតង្គ ៤ ប្រការ គឺ **១. អារញ្ញិកង្គ** អង្គនៃភិក្ខុអ្នកនៅក្នុងព្រៃជាវត្ត **២. បិណ្ឌបាតិកង្គ** អង្គនៃភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្ត **៣. សង្សុកូលិកង្គ** អង្គនៃភិក្ខុអ្នកប្រើប្រាស់សំពត់សង្សុកូលជាវត្ត **៤. តិចីវរិកង្គ** អង្គនៃភិក្ខុអ្នកប្រើប្រាស់ត្រៃចីវរជាវត្ត ។ ព្រោះដូច្នោះ ព្រះអង្គុលិមាលត្ថេរ ទើបថ្វាយព្រះពរតបបដិសេធនឹងព្រះបាទបសេនទិកោសលមហារាជថា ពុំបាច់ទេ មហារាជ អាត្មាភាពមានត្រៃចីវរគ្រប់គ្រាន់ហើយ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះបរមគ្រូ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានជោគ ហើយគង់ក្នុងទីដ៏សម

គួរ និងក្រាបទូលថា គួរឲ្យអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន នៅក្នុងកាលដែលព្រះលោកនាថទ្រង់បានទូន្មាន បុគ្គលដែលគេទូន្មានមិនបាន ទ្រង់អាចរំងាប់បុគ្គលដែលគេរំងាប់មិនបាន បុគ្គលដែលមិនទាន់រំលត់កិលេស ក៏ឲ្យរំលត់កិលេសបាន បុគ្គលដែលពួកខ្ញុំព្រះអង្គមិនអាចទូន្មានដោយអាជ្ញាក្តី ឬដោយអាវុធក្តី តែព្រះមានបុណ្យទ្រង់អាចទូន្មានបុគ្គលនោះបាន ដោយមិនប្រើអាជ្ញា ឬក៏ប្រើអាវុធណាៗឡើយ ។ **សេចក្តីក្នុងវគ្គនេះ ក្នុងអដ្ឋកថាបបញ្ចសូទនីបានអធិប្បាយទុកថា** កាលដែលព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលនឹងព្រះពុទ្ធអង្គថា ព្រះសក្យមុនី ទ្រង់បានទូន្មានបុគ្គលដែលខ្ញុំព្រះអង្គ មិនអាចទូន្មានបាន ដោយប្រើអាជ្ញាក្តី ឬសស្ត្រាក្តី ព្រោះថា ព្រះបាទបសេនទិកោសលទ្រង់ធ្លាប់បានបញ្ជូនចតុរង្គយោធា បានដល់ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង ចេញទៅដើម្បីឲ្យបង្ក្រាបចោរអង្គុលិមាលនោះ ប៉ុន្តែត្រឡប់ត្រូវចោរអង្គុលិមាលសម្លាប់ទាំងអស់ និងព្រះរាជាទ្រង់បានបញ្ជូនពលយោធា គឺពលដំរី ពលសេះ សូម្បីរហូតដល់ពលរថចេញទៅចាប់ចោរអង្គុលិមាល ច្រើនលើក ច្រើនសារហើយក៏ដោយ តែកាលពួកយោធាទាំងនោះ បានឮសំឡេងថា

អើអញនេះឯង ឈ្មោះចោរអង្គុលិមាល គ្រាន់តែឮសំឡេងប៉ុណ្ណោះ មិនមានអ្នកណាអាចតស៊ូ ហើយត្រូវចោរអង្គុលិមាលសម្លាប់ពពួកយោធាទាំងនោះទាល់តែអស់ ឯដំរី សេះ ដែលទ្រង់បញ្ជូនទៅ បានក្លាយជាដំរីព្រៃ សេះព្រៃ និងរថទាំងឡាយ ត្រូវបានចោលនៅជេរជាសពេញព្រៃនោះ ។ **តាមសេចក្តីព្រះបាលីមានតទៅទៀតថា** កាលព្រះបាទបសេនទិកោសល ទ្រង់ក្រាបទូលនឹងព្រះទសពល ដល់រឿងការទូន្មានចោរអង្គុលិមាល ឲ្យក្លាយមកជាព្រះថេរៈហើយ ព្រះរាជាទើបទ្រង់ក្រាបទូលថា បពិត្រព្រះមានជោគ ខ្ញុំព្រះអង្គទាំងឡាយសូមក្រាបទូលលាទៅសិន ព្រោះខ្ញុំព្រះអង្គទាំងឡាយ មានកិច្ចការងារដែលនឹងត្រូវធ្វើនៅមានច្រើនណាស់ ព្រះករុណាម្ចាស់ ។ គ្រានោះព្រះមហាវីរៈត្រាស់អនុញ្ញាតថា យាងទៅចុះមហាបពិត្រ ។ ព្រះបាទបសេនទិកោសលក៏ក្រោកចាកអាសនៈហើយ ថ្វាយបង្គំលាព្រះមុនីហើយធ្វើប្រទក្សិណស្តេចចៀសចេញទៅ ។

ការចេញបិណ្ឌបាតថ្ងៃដំបូង របស់ព្រះអង្គុលិមាលត្រេរក្រោយពីតាមព្រះលោកវិទូមកនៅវត្តជេតពននោះ មានសេចក្តីក្នុង **អដ្ឋកថាបបញ្ចសូទនី** បានពោលទុកថា ៖-

ក្នុងបុព្វណ្ហសម័យ ព្រះអង្គុលិមាល បានចេញទៅបិណ្ឌបាត មនុស្សទាំងឡាយ បានឃើញលោកនិមន្តចូលទៅបិណ្ឌបាត ក៏កើតការភ័យខ្លាចតក់ស្លុត រត់ឡើងលើផ្ទះ ដោយពួកខ្លះ នៅមិនទាន់បានឃើញលោកនៅឡើយ គ្រាន់តែឮសំឡេងថា ព្រះអង្គុលិមាលប៉ុណ្ណោះ រត់យកតែប្រាសអាយុស ដោយពួកខ្លះរត់ចូលទៅព្រៃ ដោយពួកខ្លះរត់ចូលទៅក្នុងរាជវាំង និងបិទទ្វារផ្ទះសម្ងៀង ឯពួកអ្នកដែលមិនអាចរត់ទៅណាទាន់ បានប្រើវិធីឈរបែរខ្នងឲ្យហើយ ម្នាក់ៗ បានពោលពាក្យចចាមអារ៉ាមទ្រហឹងអឺងកង ដោយអ្នកខ្លះបាននិយាយថា ព្រះអង្គុលិមាលបន្ទំជាព្រះសង្ឃ ដើម្បីគេចពីរាជភ័យ អ្នកខ្លះនិយាយថា លោកប្រាថ្នានឹងសម្លាប់មនុស្សនៅខាងក្នុងព្រះនគរ ពេលដែលលោកនិមន្តទៅបិណ្ឌបាតដល់ទីណា ពាក្យចចាមអារ៉ាមនោះ បានផ្សាយខ្ចរ-ខ្ចាយទៅដល់ទីនោះ រហូតជាហេតុធ្វើឲ្យលោកមិនបានចង្ហាន់អ្វីឡើយ សូម្បីត្រឹមតែមួយវែក និងអាក្រក់ក្រៃលែងជាងនោះ ភិក្ខុសង្ឃដែលនិមន្តទៅបិណ្ឌបាតរួមផ្លូវជាមួយនឹងលោក ក៏មិនបានចង្ហាន់ដូចលោកដែរ ។ ជាច្រើនថ្ងៃដែលព្រះអង្គុលិមាលត្រូវ បានចេញទៅបិណ្ឌបាតទៅតាមបរិវេណខាងក្រៅព្រះនគរ មិនដែលបានទទួលចង្ហាន់ឆាន់ទេ ។

**ចំណែកនៅក្នុងសេចក្តីព្រះបាលីមានសម្តែងទុកថា** ព្រឹកថ្ងៃមួយ ព្រះអង្គុលិមាល បាននិមន្តទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ថ្ងៃនោះ ចៃដន្យលោកបានជួបនឹងស្ត្រីម្នាក់មានគភ៌កំពុងតែប្រសូតកូន ដោយមិនទាន់នឹងប្រសូតរួច លោកទើបគិតថា ឱហ្ន៎ ! សត្វលោកទាំងឡាយលំបាកពិតៗ ពេលដែលលោកត្រឡប់ពីបិណ្ឌបាតហើយ ព្រះអង្គុលិមាលបានចូលទៅក្រាបបង្គំទូលព្រះទសពលឲ្យទ្រង់ជ្រាប ។ គ្រានោះ ព្រះពុទ្ធអង្គទ្រង់បានត្រាស់ណែនាំ ម្នាលអង្គុលិមាល បើដូច្នោះ អ្នកចូរទៅហើយចូលទៅជិតស្ត្រីនោះ ហើយអ្នកពោលឡើងថា ម្នាលប្អូនស្រីតាំងអំពីអាត្មាកើតហើយដោយអរិយជាតិ មិនចេះក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់អ្នក សូមសិរីសួស្តី កើតមានដល់គភ៌របស់នាង ។

ព្រះអង្គុលិមាលត្ថេរ ឱនទទួលបញ្ជាព្រះសម្ពុទ្ធថា ព្រះករុណាព្រះអង្គ ។ ហើយក៏បានចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ជិតស្ត្រីនោះហើយ បានពោលព្រះគាថា តាមដែលព្រះលោកនាថទ្រង់ត្រាស់បង្រៀនមក ផលប្រាកដថា ស្ត្រីនោះ បានប្រសូតបុត្រមក ដោយសុវត្ថិភាព ឬបានយ៉ាងងាយ ។ ក្នុង **អដ្ឋកថា** បានអធិប្បាយ ក្នុង

**ព្រះពុទ្ធមន្ត** និងភាពសក្តិសិទ្ធិរបស់ព្រះអង្គុលិមាលត្ថេរទុកថា កាលដែលលោកទៅសម្តែងពុទ្ធមន្ត ដើម្បីសង្គ្រោះដល់ស្ត្រីនោះ បានពោលនៅខាងក្រៅសំពត់វាំងនន គឺមនុស្សទាំងឡាយ ក៏បានជ្រាបថា ព្រះអង្គុលិមាលត្ថេរមកប្រោស ទើបនាំគ្នាបាំងវាំងននឡើង ក្នុងបរិវេណដែលស្ត្រីនោះនឹងប្រសូតបុត្រ ហើយនិមន្តព្រះអង្គុលិមាលឲ្យគង់នៅលើតាំង ឬគ្រែនៅខាងក្រៅវាំងនន ។ កាលលោកគង់នៅលើតាំងហើយ ក៏បានពោលនូវមន្តនោះឡើង ជាសច្ចកិរិយា គឺប្រកាសភាពពិតឲ្យប្រាកដដល់មនុស្សទាំងឡាយ កាលចប់សច្ចកិរិយានោះហើយទារកនោះក៏ប្រសូតមក ដូចគ្នានឹងទឹកដែលបាកចេញអំពីបំពង់តម្រងទឹក ដូច្នោះ ទាំងមាតា និងទារក ម្នាក់ៗ មាននូវសេចក្តីសុខ ឬសុវត្ថិភាព ព្រះពុទ្ធមន្តនោះ ទើបមានឈ្មោះថា **ព្រះមហាបរិត្ត** ។ កាលតមក តាំង ឬគ្រែ ដែលព្រះអង្គុលិមាលគង់ ពោលព្រះមហាបរិត្តនោះ ក៏បានជាស្ថានទីធ្វើសក្ការគោរពបូជា របស់មនុស្សទាំងឡាយពោលគឺមិនថាមនុស្ស ឬសត្វ ពេលប្រសូតបុត្រលំបាក គេតែងនាំយកមកដាក់លើតាំង ឬគ្រែនោះ ហើយក៏ប្រសូតបានដោយងាយ តែបើបុគ្គលណាមានកម្លាំងទន់ខ្សោយ មិនអាចនឹងនាំមកកាន់កន្លែងតាំង

ឬគ្រែនោះបានទេ មនុស្សទាំងឡាយ នឹងនាំយកទឹកទៅលាងតាំង ឬគ្រែនោះហើយ ត្រូវយកទឹកដែលលាងតាំង ឬគ្រែនោះ ទៅស្រោចស្រពលើក្បាលរបស់ស្ត្រីនោះ ។ ហើយស្ត្រីនោះ អាចប្រសូតបុត្របានមួយរំពេចពេលនោះឯង ទាំងមិនមានរោគភ័យអ្វីមកបៀតបៀនឡើយ ។ មានសំណួរសួរថា ដូចម្តេច ព្រះលោកនាយក ទើបឲ្យព្រះអង្គុលិមាលត្ថេរធ្វើវេជ្ជកម្មដូច្នេះ ? មានចម្លើយឆ្លើយថា ព្រះមុនីបានឲ្យព្រះអង្គុលិមាលធ្វើវេជ្ជកម្ម តែឲ្យធ្វើសច្ចកិរិយាទាំងនេះ ដោយទ្រង់អនុគ្រោះដល់ព្រះអង្គុលិមាល ដោយមិនឲ្យលោកលំបាក ក្នុងរឿងចង្ហាន់តែប៉ុណ្ណោះ ។ ដោយហេតុថា នៅក្នុងគ្រានោះ មនុស្សទាំងឡាយ បានឃើញព្រះអង្គុលិមាលចូលទៅដល់ ម្នាក់ៗ នាំគ្នារត់ចេញទៅ ដោយម្នាក់ៗ មិនហ៊ានដាក់បាត្រលោក ដូច្នេះ ទើបធ្វើឲ្យលោកមិនមានចង្ហាន់ឆាន់ ការស្រេកឃ្លានកើតឡើង ក៏ជាហេតុ មិនអាចធ្វើសមណធម៌បានដែរ ព្រះពុទ្ធអង្គទ្រង់យល់ថា ប្រសិនបើព្រះអង្គុលិមាលត្ថេរ បានធ្វើសច្ចកិរិយានេះហើយ មនុស្សទាំងឡាយនឹងហ៊ានចូលទៅជិត ដោយយល់ថា លោកជាអ្នកមានចិត្តមេត្តា ដល់មនុស្សទាំងឡាយ ហើយការធ្វើសច្ចកិរិយា មិនមែនជាវេជ្ជកម្មទេ ។

មួយប្រការទៀត នៅក្នុងពេលដែលព្រះអង្គុលិមាលត្ថេរ ចូលទៅធ្វើសមណធម៌ នៅត្រង់ទីសម្រាកពេលថ្ងៃ និងពេលយប់ ចិត្តរបស់លោកក៏មិនធ្លាក់ចុះកាន់កម្មដ្ឋាន ត្រឡប់ទៅនៅកណ្តាលព្រៃ កន្លែងដែលលោកធ្លាប់បានសម្លាប់មនុស្សក្នុងកាលមុននោះ និមិត្តក្លាមៗ ដ៏សាហាវ ដែលកើតពីការធ្វើសមណធម៌ បានប្រាកដឡើងជារូបភាពអាក្រក់ច្រើនប្រការ ដូចជាខ្មោចអត់ក្បាលខ្លះ ខ្មោចអត់ដៃខ្លះ ខ្មោចមានរាងកាយវិកលវិការខ្លះ និងជាខ្មោចមានដំបៅធំៗ រឡេះរលួយទូទាំងរាងកាយ ហើយខ្មោចទាំងនោះ ម្នាក់ៗ នាំគ្នាមកចោមរោមលោក និងម្នាក់ៗ សម្តែងការឈឺចាប់ស្រែកថ្ងូរ រហូតដល់មានអាការញ័រដៃ-ជើង ដៃប្រណម្យខ្លាចស្លាប់ ពោលស្រែកសូមជីវិតជាមួយនឹងលោកថា សូមករុណាទុកជីវិតដល់ខ្ញុំផង សូមលោកកុំសម្លាប់ខ្ញុំ ។

ព្រះអង្គុលិមាលត្ថេរ សូម្បីនឹងធ្លាប់ជាចោរ ដែលមានចិត្តកាចឃោរឃៅ កាលបានមកឃើញពួកខ្មោចបិសាច សុទ្ធតែជាខ្មោចដែលលោកធ្លាប់សម្លាប់មកប្រាកដកាយឲ្យឃើញ ខណៈដែលលោកអង្គុយបិទភ្នែកធ្វើសមណធម៌ទៅ លោកក៏មានចិត្តរាយមាយ មិនអាចធ្វើសមណធម៌ឲ្យកើតចិត្តស្ងប់បាន ព្រះមានព្រះភាគ ទើបទ្រង់បង្រៀន

ឲ្យធ្វើសច្ចកិរិយា និងក្រៅពីនោះ ទ្រង់បានណែនាំប្រៀនប្រដៅ មិនឲ្យរឭកដល់អតីត គឺកិច្ចដែលកន្លងរួចមកហើយ និងអនាគត គឺកិច្ចដែលនៅមិនទាន់មកដល់ ឲ្យពិចារណាធម៌ដែលជាបច្ចុប្បន្ន គឺកំពុងប្រាកដមកតែប៉ុណ្ណោះ ( អនាគតមិនគិត អតីតមិនចាំ ធ្វើតែបច្ចុប្បន្ន ) ។

ក្នុងសេចក្តីនេះ មានសេចក្តីក្នុងព្រះបាលីអង្គុលិមាលសូត្រពោលតទៅទៀតថា ព្រះអង្គុលិមាលត្ថេរ កាលត្រឡប់ពីការធ្វើសច្ចកិរិយាដល់ស្ត្រីនោះហើយ រហូតដល់ជាទីប្រត្យក្សនៃមហាជនទាំងពួងហើយ តមកលោកក៏មានចង្ក្រាន់ឆាន់បរិបូណ៌ លោកទើបគេចចេញចាកពួកគណៈទៅនៅតែម្នាក់ឯង ដោយតាំងចិត្តធ្វើសមណធម៌ ជាអ្នកមិនមានសេចក្តីប្រមាទ ជាអ្នកមានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស ដើម្បីឲ្យរួចផុតអំពីសេចក្តីទុក្ខ មានការតាំងចិត្តចំពោះមគ្គផល និងនិព្វានមិនយូរប៉ុន្មាន ក៏បានសម្រេចដល់ទីបំផុត នៃព្រហ្មចរិយធម៌ដ៏ប្រសើរដែលជាទីត្រូវការរបស់កុលបុត្រទាំងឡាយ ដែលជាអ្នកចេញចាកផ្ទះបួសដោយសទ្ធា ហើយដឹងច្បាស់ថា អស់ការកើតហើយ ព្រហ្មចរិយធម៌ចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចស្រេចហើយ មិនមានកិច្ចដទៃដែលនឹងត្រូវធ្វើទៀតឡើយ មានសេចក្តីថា លោកបានសម្រេចជាព្រះ

អរហន្តហើយ ។ កាលដែលលោកបានសម្រេចជាព្រះអរហន្តនោះ ក្នុងជាតិមុន លោកធ្លាប់បានធ្វើកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធទាំងឡាយដែលបានត្រាស់ដឹងរួចមកហើយ ដោយបានកសាងសន្សំបុណ្យកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពផ្សេងៗ នោះ ។

កាលព្រះអង្គុលិមាល បានសម្រេចជាព្រះអរហន្តហើយនោះ ក្នុងបុព្វណ្ហសម័យ លោកបានចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានមានហេតុអាក្រក់កើតឡើងដល់លោកទៀត គឺមានដុំដី ដែលមនុស្សបានគ្រវែងឡើងទៅលើអាកាស បានធ្លាក់ចុះមកចំរាងកាយរបស់លោក នៅមានដំបង និងដុំក្រួសជាដើម ដែលមនុស្សបានគ្រវែងឡើង ទៅលើអាកាស ដោយបំណងយ៉ាងដទៃ ( គឺដើម្បីដេញសត្វផ្សេងៗ ដូចជាក្អែក ក្តែ ជ្រូក ជាដើម ) តែបែរត្រឡប់មកធ្លាក់ចំលើកលោកទៅវិញ ។ ព្រះអង្គុលិមាល បានត្រូវបែកសិរសាចេញឈាមហូរ បាត្របែក ចីវររហែកដាច់ បានចូលទៅគាល់ព្រះសយម្ភូ ។ ព្រះលោកនាថទ្រង់ក្រឡេកឃើញព្រះអង្គុលិមាលត្ថេរ មកអំពីចម្ងាយ ទើបត្រាស់ដាស់តឿនសតិថា

ម្នាលព្រាហ្មណ៍ ( ព្រះខីណាស្រព ) អ្នកចូរអត់ទ្រាំៗ អ្នកនឹង

ត្រូវទៅឆេះក្នុងនរកច្រើនម៉ឺនសែនឆ្នាំ ដោយផលនៃកម្ម ( អាក្រក់ ) ឯណា អ្នកក៏បានសោយផលកម្មទាំងនោះ ក្នុងបច្ចុប្បន្នជាតិនេះប៉ុណ្ណោះឯង មិនមែនជាការអស្ចារ្យទេ ។

ព្រះអង្គុលិមាលត្ថេរ បានទទួលការសង្គ្រោះឲ្យឈប់ធ្វើអំពើបាបពីព្រះសម្ពុទ្ធជាម្ចាស់ ធ្លាប់បានមានរួចមកហើយ ក្នុងអតីតជាតិដូចមានរឿងសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាជាតក** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៃ **គម្ពីរខុទ្ទកនិកាយ មហានិបាតជាតក** មានសេចក្ដីថា ៈ-

កាលព្រះភគវា ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់បានត្រាស់ប្រារព្ធព្រះអង្គុលិមាលត្ថេរ ឲ្យជាដើមហេតុ នៃមាតិកាព្រះធម៌ទេសនាថា ថ្ងៃមួយ ភិក្ខុទាំងឡាយបានសន្ទនាគ្នាក្នុងសាលាធម្មសភាថា គួរឲ្យអស្ចារ្យពេកណាស់ ព្រះសាស្ដាទ្រង់ទូន្មានចោរអង្គុលិមាលឲ្យលះបង់នូវអំពើអាក្រក់ចេញ ក្លាយជាមនុស្សល្អវិញបាន នៅក្នុងព្រះសាសនានេះ ។ ព្រះសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅក្នុងព្រះគន្ធកុដិ ទ្រង់បានព្រះសណ្ដាប់ពាក្យសន្ទនារបស់ភិក្ខុទាំងនោះហើយ ទើបស្ដេចចេញពីព្រះគន្ធកុដិទៅកាន់សាលាធម្មសភា លុះព្រះអង្គទ្រង់គង់ប្រថាប់លើ

អាសនៈ ដែលគេក្រាលទុកហើយ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ បានសន្ទនាគ្នាអំពីរឿងអ្វី ? ភិក្ខុទាំងនោះ បានក្រាបទូលឲ្យទ្រង់បានជ្រាបក្នុងរឿងនោះហើយ ទើបព្រះទសពលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានទូន្មានអង្គុលិមាលត្ថេរ ឲ្យលះបង់នូវអំពើអាក្រក់ ឬកាពកាចសាហាវ ឲ្យក្លាយមកជាមនុស្សល្អ មិនមែនមានតែក្នុងជាតិនេះប៉ុណ្ណោះទេ ដែលតថាគតទូន្មានឲ្យអស់កាពកាចសាហាវ ក្នុងពេលឥឡូវនេះ ជាការណ៍មិនសូវនឹងអស្ចារ្យពេកទេ ព្រោះហេតុថា តថាគតបានសម្រេចព្រះបរមាភិសេកសម្ពោធិញ្ញាណហើយ ក្នុងកាលដែលតថាគតទូន្មាន ឲ្យអង្គុលិមាលអស់នូវកាពកាចសាហាវក្នុងអតីតជាតិនោះ រាប់ថាជាការអស្ចារ្យក្រៃលែង កាលត្រាស់ដូច្នេះហើយ ទ្រង់គង់នៅស្ងៀម ។ ភិក្ខុទាំងឡាយ ចង់ដឹងរឿងក្នុងអតីតជាតិ របស់ព្រះអង្គុលិមាលត្ថេរនោះ ទើបនាំគ្នាក្រាបទូលឲ្យព្រះមហាមុនី ទ្រង់នាំរឿងអតីតជាតិមកត្រាស់សម្តែង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងដល់រឿងរបស់ព្រះអង្គ ដែលធ្លាប់កើតជាព្រះបាទមហាសុតសោម ទ្រង់បានទូន្មានស្តេចបោរិសាទ ដែលជាអតីតរបស់ព្រះអង្គុលិមាលត្ថេរ ដោយ

ពិស្តារ តែក្នុងទីនេះ នឹងសូមលើកយកមកសម្តែងដោយសេចក្តីសង្ខេប ប៉ុណ្ណោះ មិនបានពោលដោយសេចក្តីពិស្តារទេ ។

នៅក្នុងអតីតកាល ព្រះបាទមហាសុតសោម ដែលទ្រង់ជាព្រះរាជឱរសរបស់ព្រះបាទកោរព្យ ទ្រង់ជាក្សត្រនៅក្នុងនគរឥន្ទបត្ត កាលទ្រង់ចម្រើនវ័យធំដឹងក្តីហើយ ទ្រង់បានទៅសិក្សានៅក្នុងនគរតក្កសិលា ព្រមជាមួយនឹងព្រះបាទព្រហ្មទត្ត ព្រះរាជឱរសរបស់ព្រះបាទកាសិកៈ នៅក្នុងនគរពារាណសី ព្រះរាជាទាំងពីរព្រះអង្គនេះ ទ្រង់បានប្តេជ្ញាជាសម្លាញ់នឹងគ្នា ។ ព្រះបាទមហាសុតសោម ទ្រង់បានជាប្រធាននៃសិស្សទាំងឡាយ ដែលមានព្រះរាជកុមារទាំងអស់ ១០១ អង្គ ។ កាលទ្រង់សិក្សាចប់ហើយ ស្តេចមួយអង្គៗ បានបែកគ្នាត្រឡប់ទៅសោយរាជ្យបន្តវង្សក្នុងប្រទេសរៀងៗ ព្រះអង្គ និងទ្រង់បានបញ្ជូនព្រះរាជសារឲ្យដល់ព្រះបាទមហាសុតសោមជានិច្ច ឬជារឿយៗ ។ បណ្តាក្សត្រទាំងអស់នោះ ព្រះបាទព្រហ្មទត្ត ទ្រង់មានការសោយប្លែកពីក្សត្រទាំងនោះ គឺដោយទ្រង់សោយសាច់អាំងជាប្រចាំរៀងរាល់ថ្ងៃ ។ ចៃដន្យថ្ងៃមួយ អ្នកធ្វើព្រះក្រយាហារ រកទិញសាច់មិនបាន ទើបទៅពន្លះយកសាច់មនុស្សថ្មីៗ ពីព្រៃខ្មោចយកមកអាំងរួចហើយនាំយកទៅថ្វាយ ។ ព្រះ

បាទព្រហ្មទត្ត កាលបើបានសោយទៅហើយ ទ្រង់ដឹងជ្រួតជ្រាបសព្វសារសៃ ព្រោះព្រះបាទព្រហ្មទត្តធ្លាប់បានកើតជាយក្ខ ច្រើនជាតិមកហើយ ទើបត្រាស់សួរអ្នកធ្វើព្រះក្រយាហារ រហូតដឹងការពិតថា ជាសាច់មនុស្ស ទើបត្រាស់ឲ្យអ្នកធ្វើព្រះក្រយាហារ រកសាច់មនុស្សមកអាំងថ្វាយជារៀងរាល់ថ្ងៃ ដោយត្រាស់ឲ្យសម្លាប់អ្នកទោសក្នុងគុកមិនយូរប៉ុន្មាន អ្នកទោសក្នុងគុកទាំងនោះ បានសម្លាប់អស់ ហើយត្រាស់ឲ្យនាំយកបង្វិចទ្រព្យ ទៅដាក់បញ្ឆោត អ្នកណាមកយកទ្រព្យនោះ ក៏សម្លាប់ដែរ អំណើះកាលតមក មិនមានអ្នកណាហ៊ានទៅយកទ្រព្យ ដូច្នេះវិធីនេះក៏អស់ប្រសិទ្ធិភាព ទើបត្រាស់ឲ្យចាំស្កាត់ សម្លាប់មនុស្ស ដែលធ្វើដំណើរពេលអធ្រាត្រវិញម្តង ។

កាលបើមានមនុស្ស ត្រូវគេសម្លាប់បាត់ទៅអស់ច្រើន ពួកឪពុកម្តាយ បងប្អូន កូនចៅ បាននាំគ្នាយករឿងនោះ ទៅក្រាបទូលចំពោះព្រះបាទព្រហ្មទត្ត ដែលទ្រង់ជាដើមហេតុក្នុងរឿងនេះ ដូច្នេះហើយ ទើបទ្រង់មិនយកចិត្តទុកដាក់ក្នុងរឿងនោះ ប្រជាជនទាំងនោះទើបបាននាំគ្នាចូលទៅរកកាឡហត្ថីសេនាបតីៗ ទទួលនឹងជួយចាត់ចែងក្នុងរឿងនេះឲ្យ ។ កាលតមក កាឡហត្ថីសេនាបតី ទើបបានបញ្ជា

ឲ្យតាមស៊ើបមើល ឲ្យចាប់អ្នកដែលសម្លាប់មនុស្សទាំងនោះឲ្យបាន ហើយក្នុងកាលមិនយូរប៉ុន្មាន អ្នកស៊ើបការនោះក៏បានចាប់ស្ត្រីមេផ្ទះម្នាក់ ដែលកំពុងពន្លះសាច់មនុស្សស្លាប់ ដាក់ទៅក្នុងកន្ត្រក ទើបនាំខ្លួន ទៅប្រគល់ឲ្យដល់កាឡហត្ថីសេនាបតីៗ បានសួរចម្លើយ រហូតដល់ស្ត្រីនោះប្រាប់ថា នឹងនាំយកទៅថ្វាយដល់ព្រះរាជា ទើបបញ្ជាឲ្យស្ត្រីនោះចូលទៅថ្លែងរឿងនេះក្នុងទីគាល់ព្រះរាជា ក្នុងថ្ងៃស្អែកនេះ ។ លុះព្រឹកឡើងកាឡហត្ថីសេនាបតី ទើបបានណាត់ប្រជុំគណៈអមាត្យនិងអ្នកនគរ ហើយនាំយកកន្ត្រកដែលដាក់សាច់ចងជាប់នឹង-ករបស់ស្ត្រីនោះ រួចក៏នាំចូលទៅកាន់ព្រះរាជវាំង ។ ព្រះបាទព្រហ្មទត្ត ទ្រង់ទតឃើញតាមចន្លោះសីហបញ្ជរ ទ្រង់បានឃើញមេគ្រួ ដែលត្រូវគេចាប់ខ្លួនយកមក ក៏ទ្រង់គិតក្នុងព្រះទ័យថា រឿងរបស់យើង ប្រាកដជាបែកការណ៍ហើយ តែទ្រង់ប្រមូលអារម្មណ៍ មិនឲ្យភ័យខ្លាចញាប់ញ័រ កាលបើសេនាបតីក្រាបបង្គំទូលសួរ ក៏ត្រាស់សារភាព ហើយកាឡហត្ថីសេនាបតី ទើបក្រាបបង្គំទូលហាមនៅក្នុងអំពើទាំងនោះ តែទ្រង់បដិសេធ មិនអាចបដិបត្តិតាមបាន រីឯសេនាបតី និងព្រះរាជាក៏បានលើកយករឿងអតីតមកជាការអះអាង តែទោះយ៉ាងណាក៏ដោយ

ក្នុងកាលជាទីបំផុត ព្រះបាទព្រហ្មទត្ត ត្រាស់បដិសេធថា យើងអត់មិនបាន សូម្បីថា យើងនឹងត្រូវទទួលការនិរទេសក៏ព្រម តែត្រាស់សូមដាវមួយ ភាជនៈមួយ កន្ទ្រកមួយ និងអ្នកធ្វើព្រះក្រយាហារម្នាក់ ។ កាឡហត្ថីសេនាបតី និងពួកអ្នកនគរគ្រេកអរណាស់ បានប្រគល់ឲ្យតាមដែលត្រាស់សូម ហើយទើបនិរទេសចេញទៅខាងក្រៅក្រុង ។ ព្រះបាទព្រហ្មទត្ត និងមេគ្រួចេញអំពីក្រុង បានទៅសម្រាកនៅត្រង់ដើមជ្រៃមួយដើម ចាំស្កាត់សម្លាប់អ្នកដើរធ្លងកាត់ទៅមក ហើយនាំយកមកឲ្យមេគ្រួ ធ្វើព្រះក្រយាហារបរិភោគ ។ តែថា មានប្រក្រតីនៅតែម្នាក់ឯង ពេលដែលព្រះបាទព្រហ្មទត្ត ទ្រង់ចាប់មនុស្សបាន និងទ្រង់បញ្ចេញព្រះសូរសៀងឡើងថា យើងជាមនុស្សស៊ីមនុស្ស ទើបមានឈ្មោះថា បោរិសាទ ។ នៅថ្ងៃមួយ ស្តេចបោរិសាទសម្លាប់មនុស្សធ្វើអាហារមិនបាន ទើបសម្លាប់មេគ្រួនោះធ្វើអាហារ និងជាខាងក្រោយមក ក៏លេចឮដំណឹងថា ស្តេចបោរិសាទ ជាអ្នកស៊ីមនុស្ស បានឮខ្ចរខ្ចាយទៅពេញជម្ពូទ្វីប ។

គ្រានោះ មានអ្នកឈ្នួញរទេះ ៥០០ រទេះ ដោយដឹកទំនិញយកទៅលក់ដូរ តែកាលនឹងចូលទៅដល់មាត់ព្រៃក្រាស់នោះ នឹកភ័យខ្លាច

ចំពោះស្តេចបោរិសាទ ក៏បាននិយាយឡើងថា ពួកយើងនឹងជួលពួកអ្នកដែលនៅមាត់ព្រៃក្រាស់នេះដោយប្រាក់ ១០០០ កហាបណៈ ដើម្បីជួយជូនដំណើរពួកយើង ឲ្យឆ្លងផុតអំពីព្រៃក្រាស់នេះ ។ ពួកអ្នកដែលនៅមាត់ព្រៃក្រាស់នោះ ក៏បានយល់ព្រម ដោយបានបបួលគ្នាជាច្រើននាក់ ថែមទាំងត្រៀមអាវុធគ្រប់ដៃ ដោយឲ្យពួករទេះទៅនៅខាងមុខ ពួកខ្លួនដើរតាមក្រោយ ចំណែកប្រធានពាណិជអង្គុយនៅលើយានតូច ទឹមដោយគោសម្បុរ-ស មានពួកការពារនៅខាងមុខ និងនៅខាងក្រោយ ។ គ្រានោះ ស្តេចបោរិសាទឡើងលើដើមឈើចាំពិនិត្យមើល លុះឃើញប្រធានពាណិជ ធ្វើឲ្យទឹកចង់ស៊ីសាច់ រហូតដល់ស្រក់ទឹកមាត់ កាលប្រធានពាណិជចូលមកដល់ជិត ទើបចុះចាកពីដើមឈើស្រែកឡើងថា យើង គឺស្តេចបោរិសាទៗ ហើយគ្រវីដាវរត់ចូលទៅចាប់ប្រធានពាណិជនោះលីរត់ទៅ ដោយមិនមាននរណាតស៊ូជាមួយបានឡើយ ។ ពួកអ្នកជួយជូនដំណើរបានដេញទៅតាម ពេលនោះ មានបុរសខ្លាំងក្លាម្នាក់រត់ទៅទាន់ ស្តេចបោរិសាទឃើញរត់តាមមកជិតនឹងខ្លួន ទើបលោតឆ្លងរំលងរបងមួយកន្លែង ដល់គ្រាគ្រោះអាក្រក់របស់ស្តេចបោរិសាទ ជើងក៏ជាន់ជន្លត់ឈើគគីរច្មុះដល់ខ្នងជើង មានឈាម

ហូរយ៉ាងខ្លាំង កាលបើឃើញថា ខ្លួនរត់លែងរួចហើយ ទើបដោះលែងប្រធានពាណិជ ដើម្បីរត់យកតែរួចខ្លួនសិន ពួកអ្នកជូនដំណើរ ទើបបាននាំប្រធានពាណិជត្រឡប់មក ឯកន្លែងពួករទេះវិញ ។

ចំណែកឯស្តេចបោរិសាទ លុះត្រឡប់ទៅដល់ទីសម្រាករបស់ខ្លួនហើយ បានបន់ដល់ទេវតាថា ប្រសិនបើជួយធ្វើឲ្យរបួសត្រង់ជើងរបស់យើងបានជាសះស្បើយបានក្នុងរវាង ៧ ថ្ងៃ យើងនឹងយកឈាមស្តេច ១០១ អង្គ មកលាងដើមជ្រៃរបស់លោក យកពោះវៀនក្សត្រទាំងនោះវង់ជាខ្សែ និងយកសាច់ក្សត្រទាំងនោះបូជាលោក ក្រោយពីបន់រួចហើយ ៧ ថ្ងៃ របួសនោះក៏ជាសះស្បើយ គេទើបយល់ថានេះគឺដោយអំណាចអានុភាពរបស់ទេវតា ហើយគេទើបចេញទៅរកស៊ីមនុស្ស រហូតមានកម្លាំងគ្រប់គ្រាន់ រួចបានកាន់យកដាវចេញអំពីដើមជ្រៃប្រាថ្នានឹងទៅចាប់ស្តេចទាំង ១០១ អង្គ មកលាបំណន់ទេវតា ចៃដន្យទៅជួបយក្ខសម្លាញ់ចាស់ គេបានសូមរៀនមន្តដើម្បីជួយឲ្យរត់លឿន និងមានកម្លាំងច្រើន ទើបអាចធ្វើឲ្យចាប់ក្សត្រក្នុងជម្ពូទ្វីបបានមក ១០០ អង្គ ក្នុងរយៈពេលត្រឹម ៧ ថ្ងៃប៉ុណ្ណោះ ដោយនៅសល់តែព្រះបាទមហាសុតសោម ដែលនៅលើកលែងទុក ព្រោះនៅទឹកដល់

គុណបុណ្យ ដែលលោកធ្លាប់ណែនាំ នៅក្នុងសម័យដែលនៅរៀនជាមួយគ្នា នៅនគរតក្កសិលាម្យ៉ាងទៀត ទ្រង់យល់ថា គួរបន្សល់ទុកជាពូជពង្សក្សត្រតទៅ ហើយចាត់ការបោះបាតដៃក្សត្រទាំងអស់ដោយខ្សែចងព្យួរទុកនូវត្រង់មែក ល្មមឲ្យចុងជើងមក ប៉ះដល់ផ្ទៃដីប៉ុណ្ណោះ ហើយបង្កាត់ភ្លើង ត្រៀមដាវដើម្បីចាក់ក្សត្រទាំងនោះ យកឈាមលាបំណន់រុក្ខទេវតា ។ រុក្ខទេវតាបានឃើញហេតុការណ៍ទាំងនោះ ក៏កើតការតក់ស្លុតចិត្ត តែមិនអាចហាមឃាត់បាន ទើបបានឡើងទៅប្រាប់ដល់ស្ដេចចាតុម្មហារាជិកាៗ ក៏មិនអាចហាមឃាត់បាន ទើបបានឡើងទៅរកសក្កទេវរាជៗ ត្រាស់ថា សូម្បីយើងក៏មិនអាចហាមឃាត់បាន តែបានប្រាប់ឧបាយថា លោកក្លែងភេទជាសមណៈរួចហើយ ដើរកាត់មុខស្ដេចបោរិសាទទៅ កាលបើស្ដេចបោរិសាទសួរលោកៗ ចូរក្រឡាខ្លួនធ្វើជាទេវតា ហើយប្រាប់ឲ្យជ្រាបថា យើងជាទេវតាអាស្រ័យនៅត្រង់ដើមជ្រៃដែលបួងសួងនេះ ប៉ុន្ដែយើងមិនពេញចិត្តចំពោះការសែនព្រេនរបស់លោក ដែលនិយាយកុហក ព្រោះលោកបានបន់ថា នឹងនាំក្សត្រ ១០១ អង្គមកលាបំណន់ តែលោកនាំបានមកតែ ១០០ អង្គប៉ុណ្ណោះ ប្រសិនបើលោកមិនទៅនាំយកព្រះបាទមហាសុតសោមមក

ការបន់ស្រន់នេះរាប់ថាមិនបានការ ។ កាលបើគេទទួលយល់ព្រមថា នឹងទៅនាំយកព្រះបាទមហាសុតសោមមក លោកចូលទៅដើមជ្រៃដូច កាលមុនទៀត ហើយព្រះបាទមហាសុតសោមមក នឹងទូន្មានស្ដេច បោរិសាទ ឲ្យលះបង់នូវអំពើទាំងនោះចោល និងជួយជីវិតក្សត្រទាំង ១០០ អង្គផង រហូតដល់មនុស្សដទៃៗ ទៀត ។

កាលបើរុក្ខទេវតាទទួលទេវរាជឱង្ការហើយ ទើបប្រញាប់ចុះ មកបដិបត្តិ តាមមួយរំពេចពេលនោះឯង ចំណែកឯស្ដេចបោរិសាទ ទទួលយល់ព្រមថា នឹងទៅនាំព្រះបាទមហាសុតសោម ហើយនៅ ចាំស្កាត់ចាប់នៅក្នុងស្រះបោក្ខរណី កន្លែងចុះស្រង់ទឹក របស់ព្រះបាទ មហាសុតសោម ក្នុងពេលពាក់កណ្ដាលយប់ ។ ព្រះមហាសុតសោម ព្រមដោយចតុរង្គសេនា ស្ដេចយាត្រាចេញចាកព្រះនគរ ហើយបាន ជួបនឹងអានន្ទព្រាហ្មណ៍ ដែលនាំគាថា ដែលមានតម្លៃ ១០០ កហាបណៈ មកពីនគរតក្កសិលា ដើម្បីនឹងសម្ដែងថ្វាយព្រះអង្គៗ ត្រាស់ថា ចាំ យើងត្រឡប់មកវិញសិន ទើបបានស្ដាប់ ហើយស្ដេចយាងទៅកាន់ ព្រះរាជឧទ្យាន ដោយមានពួកពលយោធាហែហមយ៉ាងតឹងរ៉ឹង កាល មានឱកាសល្អ ព្រះបាទមហាសុតសោម ស្ដេចចុះស្រង់ទឹកនៅក្នុង

ស្រះបោក្ខរណី ហើយស្ដេចឡើងមកគង់ប្រថាប់លើមង្គលសិលា ។ ខណៈនោះ នាយភ្នាក់ងារគ្រឿងទ្រទ្រង់ព្រះរាជា នឹងបង្អោនគ្រឿងទ្រទ្រង់ទាំងនោះចូលទៅថ្វាយព្រះអង្គ គ្រានោះ ស្ដេចបោរិសាទ បានបញ្ចេញសំឡេងឡើងថា យើង គឺស្ដេចបោរិសាទៗ ហើយឡើងចេញពីស្រះ រត់តម្រង់ចូលទៅចាប់ត្រង់ជើងរបស់ព្រះបាទមហាសុតសោម លើកឡើងដាក់លើស្មា លីរត់ទៅយ៉ាងរហ័ស ដោយមិនមាននរណាអាចដេញទាន់បាន ។ លុះរត់ទៅឆ្ងាយប្រមាណបាន ៣ យោជន៍ ស្ដេចបោរិសាទក៏ដើរតិចៗ ទៅ តែបានសង្កេតឃើញថា មានទឹកភ្នែករបស់ព្រះបាទមហាសុតសោមស្រក់ចុះមកត្រូវ នឹងទ្រូងរបស់ខ្លួន ដោយយល់ឃើញព្រះបាទមហាសុតសោម ទ្រង់ព្រះកន្សែង ទើបទូលសួរហេតុដែលទ្រង់ព្រះកន្សែងនោះ ។

ព្រះបាទមហាសុតសោមត្រាស់តបថា ហេតុដែលយើងយំមិនមែនខ្លាចស្លាប់នោះទេ មកពីយើងស្ដាយ ដែលយើងមិនទាន់បានស្ដាប់គាថា ដែលមានតម្លៃមួយរយកហាបណៈនោះ ដែលយើងបានសន្យាជាមួយនឹងអានន្ទព្រាហ្មណ៍ តែយើងសូមអង្វរអ្នកត្រឡប់ទៅស្ដាប់គាថានោះសិន ហើយយើងត្រឡប់មកឲ្យអ្នកស៊ីវិញ តែស្ដេចបោរិសាទមិន

